ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា



# កម្មវិធីជាតិ
# សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# នៅថ្នាក់ក្រោមជាតិ
# ២០១០-២០១៩

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..១១..សរណន....**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

គោលនយោបាយ យុទ្ធសាស្ត្រ និងការខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលជាង១០ឆ្នាំកន្លងមក បានធ្វើឱ្យមានភាពប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចនៅកម្ពុជា និងបង្កើតបាននូវវប្បធម៌បង្រួបបង្រួមជាតិ សន្តិភាព និងស្ថិរភាពនយោបាយដែលប្រទេសជាតិរបស់យើងមានសព្វថ្ងៃនេះ។ ស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចបើកចំហដែលបានចាក់ឫសយ៉ាងជ្រៅនៅកម្ពុជា បង្កើតឱកាសក្នុងការទាក់ទាញនូវការវិនិយោគ និងរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាកត្តាដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនឹងជោគជ័យទាំងនេះ យើងចាំបាច់ត្រូវខិតខំប្រឹងប្រែងឱ្យបានច្រើនថែមទៀត ដើម្បីធានាឱ្យការរីកចម្រើនផ្នែកសេដ្ឋកិច្ច ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋដែលមានឱកាសតិចតួច។

ផ្អែកតាមបទពិសោធន៍នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍក្នុងល្បឿនលឿនមួយចំនួន ការរីកចម្រើនផ្នែកសេដ្ឋកិច្ចមិនបានផ្តល់ផលប្រយោជន៍ស្មើគ្នាដល់ប្រជាពលរដ្ឋគ្រប់រូប និងតំបន់ផ្សេងៗក្នុងប្រទេសទាំងនោះទេ។ ក្នុងពេលដែលសេដ្ឋកិច្ចនៃប្រទេសទាំងនោះបន្តរីកចម្រើន ការអភិវឌ្ឍនៅកម្រិតតំបន់ មូលដ្ឋាន និងគ្រួសារនៅមានវិសមភាពនៅឡើយ។ ដោយឡែក នៅកម្ពុជា យើងក៏ជួបនូវការលំបាកក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋានដែលធ្វើឡើងពីថ្នាក់ជាតិដោយផ្ទាល់ផងដែរ។ ដូចនេះយើងចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរវិធីសាស្ត្រក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានទាំងនេះ។

វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រជាគន្លឹះៗរបស់យើង ក្នុងការដោះស្រាយនូវវិសមភាពនៃការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ គឺគោលការណ៍ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានាខែមិថុនា ឆ្នាំ២០០៥កន្លងមក។ រហូតមកដល់ពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានអនុវត្តច្បាប់រៀបចំអង្គការ និងបង្កើតឱ្យមានក្រុមប្រឹក្សានានានៃ រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ។

រាជរដ្ឋាភិបាលបានសម្រេចជ្រើសរើសយកមាគ៌ានេះ  ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងការខិតខំប្រឹងប្រែងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅធានាឱ្យមានការអភិវឌ្ឍដ៏ទូលំទូលាយនិងប្រកបដោយនិរន្តរភាព និងដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចមូលដ្ឋានដ៏សំខាន់នេះ។  រាជរដ្ឋាភិបាលចង់ឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថារដ្ឋបាលឯកភាពដែលបង្កើតឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើឱ្យសម្រេចបាននូវបំណងប្រាថ្នាខាងលើនេះ។ ក្នុងន័យនេះ  រាជរដ្ឋាភិបាលនឹងផ្ទេរជាបណ្តើរៗនូវមុខងារសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិ  ដោយភ្ជាប់ទៅជាមួយនូវធនធានហិរញ្ញវត្ថុ  ធនធានមនុស្សនិងធនធានចាំបាច់ដទៃទៀតសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនេះ  និងជួយគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកសាងនិងពង្រឹងសមត្ថភាព ដើម្បីឱ្យមានលទ្ធភាពក្នុងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាពទៅដល់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទទឹមនេះ  រាជរដ្ឋាភិបាលក៏បាននិងកំពុងអនុវត្តកំណែទម្រង់ពាក់ព័ន្ធនឹងអភិបាលកិច្ចសំខាន់ៗមួយចំនួនទៀត ដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលការអនុវត្តកំណែទម្រង់ទាំងនេះ  ត្រូវមានការសម្របសម្រួលយ៉ាងជិតស្និទ្ធ  និងមានសុខដុមនីយកម្មជាមួយគ្នា  ដើម្បីផ្តល់ផលប្រយោជន៍ជាអតិបរមាដល់ប្រជាពលរដ្ឋទូទៅ។  ខ្ញុំមានមោទនភាព  និងបីតិសោមនស្សយ៉ាងខ្លាំងដែលបានឃើញថា  យន្តការដោះស្រាយនូវបញ្ហាទាំងនេះ ត្រូវបានកំណត់នៅក្នុងកម្មវិធីជាតិនេះ។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ត្រូវបានបង្កើតឡើងដើម្បីជួយរាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់រៀបចំអង្គការ និងការរៀបចំ ការសម្របសម្រួល ការអនុវត្ត និងត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គ.ជ.អ.ប បាន និងកំពុងដំណើរការ និងធ្វើការជាមួយគ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្រេចឱ្យបាននូវគោលបំណងរួមរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយ និងរក្សាបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះ  ត្រូវបានរៀបចំតាក់តែងឡើងដោយមានការចូលរួមយ៉ាងពេញលេញពីក្រសួង ស្ថាប័ននៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល  និងអ្នកពាក់ព័ន្ធនានា  និងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួង ស្ថាប័នដែលជាសមាជិក គ.ជ.អ.ប ទាំងអស់ ចាំបាច់ត្រូវតែឈានមុខគេក្នុងការរៀបចំយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ ផែនការ និងធនធានមនុស្ស ព្រមទាំងប្រព័ន្ធសម្រាប់ផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រសួង ស្ថាប័នទាំងនេះត្រូវធ្វើការងារយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីធានាដល់ការអនុវត្តកម្មវិធីជាតិនេះប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ក្រសួង ស្ថាប័នទាំងអស់ ត្រូវពិនិត្យមើលភារកិច្ច ការទទួលខុសត្រូវ និងមុខងារបច្ចុប្បន្នរបស់ខ្លួន ដើម្បីកែសម្រួលនូវភារកិច្ច ការទទួលខុសត្រូវ និងមុខងារទាំងនោះ ឱ្យមានភាពសមស្របទៅនឹងគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ រាជរដ្ឋាភិបាល រំពឹងថា ក្រសួង ស្ថាប័ននីមួយៗ នឹងសិក្សាស្វែងយល់ឱ្យបាន

ស៊ីជម្រៅអំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ និងទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្ត គោលនយោបាយ និងច្បាប់ទាំងនេះ ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាយន្តការក្នុងការផ្តល់នូវធនធានហិរញ្ញវត្ថុ និងបច្ចេកទេស ដើម្បីអនុវត្តគោលនយោបាយ និងច្បាប់ខាងលើនេះ ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវស្វែងយល់អំពីគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ និងត្រូវយកចិត្តទុកដាក់ទៅលើតួនាទី និងការទទួលខុសត្រូវថ្មីៗរបស់ខ្លួន ដើម្បីអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយធានាឱ្យមានការពិភាក្សា និងការចូលរួមពីប្រជាពលរដ្ឋគ្រប់ៗរូប ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់នៅមូលដ្ឋាន រួមទាំងវិស័យឯកជន និងសង្គមស៊ីវិលផងដែរ ។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវត្រៀមខ្លួនទទួលយកនូវការទទួលខុសត្រូវ និងមុខងារ ដែលនឹងត្រូវផ្ទេរដោយថ្នាក់ជាតិ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។ វិធីសាស្ត្រដែលរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងារ នឹងជះឥទ្ធិពលទៅលើការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាននៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាលនឹងផ្តល់នូវការគាំទ្រ ការណែនាំ និងជំនួយដទៃទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកិច្ចការទាំងនេះ តាមរយៈកម្មវិធីជាតិនេះ ។

តាមរយៈមេរៀនបទពិសោធន៍ផ្ទាល់របស់យើង និងបណ្តាប្រទេសមួយចំនួន យើងចាំបាច់ត្រូវត្រៀមខ្លួនទុកជាមុនថា ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងជួបប្រទះនូវបញ្ហាប្រឈម ភាពស្មុគស្មាញ និងការលំបាកមួយចំនួន ។ ដូចនេះ យើងចាំបាច់ត្រូវមានការប្តេជ្ញាចិត្តខាងនយោបាយរួមគ្នាក្នុងរយៈពេលវែង ដោយត្រូវធ្វើការត្រួតពិនិត្យនូវភាពរីកចម្រើននៃការអនុវត្ត និងកែសម្រួលកម្មវិធីនានា តាមដំណាក់កាលនីមួយៗ ដើម្បីដោះស្រាយនូវបញ្ហាប្រឈម ភាពស្មុគស្មាញ និងការលំបាកទាំងនេះ តាមរយៈការរៀនសូត្របណ្តើរ និងធ្វើបណ្តើររបស់យើង ។

កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺជាឱកាសមួយដើម្បីបង្កើតប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលឆ្លុះបញ្ចាំងនូវគោលការណ៍ជាគន្លឹះនានានៃអភិបាលកិច្ចល្អ រួមមាន គណនេយ្យភាព នីតិរដ្ឋ តម្លាភាព ការចូលរួម ការលើកស្ទួយសមធម៌ ការឆ្លើយតប ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាល ដូចនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ននីមួយៗ នឹងរៀបចំកម្មវិធីរបស់ខ្លួនដើម្បីរួមចំណែកធ្វើឱ្យគោលបំណងរបស់យើងក្នុងការបង្វិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ ទទួលបានជោគជ័យ ហើយក៏សង្ឃឹមផងដែរថា រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងប្រជាពលរដ្ឋ នឹងរៀបចំ និងអនុវត្តកម្មវិធីនេះក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងផ្តល់នូវឱកាសដ៏ធំធេងដើម្បីសម្រេចបានការរីកចម្រើនប្រកបដោយសមធម៌ លើកស្ទួយនិងសម្រេចបាននូវការអភិវឌ្ឍមូលដ្ឋានប្រកបដោយនិរន្តរភាព និងចូលរួមដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងមួយទសវត្សរ៍ខាងមុខ ។ នេះគឺជាបំណងប្រាថ្នារបស់យើង ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានា ដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ផ្តល់នូវការគាំទ្រ ទាំងផ្នែកហិរញ្ញប្បទានសហប្រតិបត្តិការ និងជំនួយបច្ចេកទេសក្នុងការអនុវត្តកម្មវិធីជាតិនេះ។ ទន្ទឹមនេះ ខ្ញុំសូមឱ្យក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ផ្តល់ការគាំទ្រ និងចូលរួមអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីសម្រេចឱ្យបានជោគជ័យត្រចះត្រចង់ តាមការរំពឹងទុក។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...... ខែ............ ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា

សារលិខិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា...... i

មាតិកា.......... v

អារម្ភកថា.......... ix

## ជំពូកទី១

## សេចក្ដីផ្ដើម

១.១. សាវតារ.......... ១

១.១.១. រដ្ឋបាលដែនដី និងសេដ្ឋកិច្ចនៅកម្ពុជា.......... ១

១.១.២. សនិទានភាព និងបញ្ហាប្រឈមនានាដែលជំរុញឱ្យមានការបន្តធ្វើកំណែទម្រង់.......... ២

១.២. គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា.......... ៤

១.៣. សមិទ្ធផលនៃកំណែទម្រង់ដែលសម្រេចបានកន្លងមក.......... ៧

១.៤. បរិយាកាសដែលនាំឱ្យមានការផ្លាស់ប្ដូរ.......... ៩

១.៥. វិធីសាស្ត្រនៃកិច្ចដំណើរការតាក់តែងកម្មវិធីជាតិ.......... ១២

១.៥.១. គោលការណ៍តម្រង់ទិស.......... ១៣

១.៥.២. ធាតុសំខាន់ៗនៃតារាងក្របខ័ណ្ឌតក្កភាព.......... ១៣

១.៦. ទម្រង់ និងភាពលំដាប់លំដោយនៃឯកសារកម្មវិធីជាតិ.......... ១៤

## ជំពូកទី២

## ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

២.១. ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ...... ១៦

២.២. ការប្ដេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល.......... ១៨

២.៣. ក្របខ័ណ្ឌសម្រាប់ការអនុវត្តកម្មវិធីជាតិ.......... ១៩

២.៣.១. គោលដៅ និងគោលបំណង.......... ១៩

២.៣.២. វិសាលភាពនៃក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិ.......... ២១

២.៤. សនិទានភាពនៃការរៀបចំកម្មវិធីជាតិ.......... ២៦

២.៥. ការអភិវឌ្ឍសមត្ថភាព.......... ២៦

២.៦. ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន.......... ២៨

២.៧. រយៈពេល និងលទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ.......... ២៨

២.៨. ការសម្របសម្រួលជាមួយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសារណៈ និងកំណែទម្រង់តាមវិស័យនានា.......... ៣១

២.៩. ក្របខ័ណ្ឌតក្កភាពគោលរបស់កម្មវិធីជាតិ ....................................................................................៣២

## ជំពូកទី៣

## សមាសធាតុនានារបស់កម្មវិធីជាតិ

**៣.១. សមាសធាតុកម្មវិធីទី១ : ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ** .......................................... ៤៥
៣.១.១. សនិទានភាព............................................................................................................៤៥
៣.១.២. គោលបំណងសមាសធាតុកម្មវិធី ......................................................................................... ៤៧
៣.១.៣. ការងារជាអាទិភាពនានា........................................................................................... ៤៧
៣.១.៤. ក្របខ័ណ្ឌតក្កភាព .................................................................................................. ៤៩
**៣.២. សមាសធាតុកម្មវិធីទី២ : ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស**......................................៥៦
៣.២.១. សនិទានភាព............................................................................................................៥៦
៣.២.២. គោលបំណងសមាសធាតុកម្មវិធី .........................................................................................៥៦
៣.២.៣. ការងារជាអាទិភាពនានា........................................................................................... ៥៧
៣.២.៤. ក្របខ័ណ្ឌតក្កភាព .................................................................................................. ៥៧
**៣.៣. សមាសធាតុកម្មវិធីទី៣ : ការផ្ទេរមុខងារ** ................................................................... ៦៣
៣.៣.១. សនិទានភាព............................................................................................................៦៣
៣.៣.២. គោលបំណងសមាសធាតុកម្មវិធី .........................................................................................៦៥
៣.៣.៣. ការងារជាអាទិភាពនានា...........................................................................................៦៦
៣.៣.៤. ក្របខ័ណ្ឌតក្កភាព ..................................................................................................៦៨
**៣.៤. សមាសធាតុកម្មវិធីទី៤ : ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**.....៧៦
៣.៤.១. សនិទានភាព............................................................................................................ ៧៦
៣.៤.២. គោលបំណងសមាសធាតុកម្មវិធី ......................................................................................... ៧៨
៣.៤.៣. ការងារជាអាទិភាពនានា........................................................................................... ៧៨
៣.៤.៤. ក្របខ័ណ្ឌតក្កភាព .................................................................................................. ៨១
**៣.៥. សមាសធាតុកម្មវិធីទី៥ : ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**...................... ៩៣
៣.៥.១. សនិទានភាព............................................................................................................ ៩៣
៣.៥.២. គោលបំណងសមាសធាតុកម្មវិធី .........................................................................................៩៦
៣.៥.៣. ការងារជាអាទិភាពនានា...........................................................................................៩៦
៣.៥.៤. ក្របខ័ណ្ឌតក្កភាព ..................................................................................................៩៨

## ជំពូកទី៤
## ការគ្រប់គ្រងកម្មវិធីជាតិ


**៤.១. ការរៀបចំចាត់ចែងសម្រាប់ការគ្រប់គ្រងកម្មវិធីជាតិ ..... ១០៥**

៤.១.១. ការណែនាំខាងគោលនយោបាយស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ..... ១០៥

៤.១.២. ការសម្របសម្រួលកម្មវិធីជាតិ ..... ១០៦

៤.១.៣. ការសម្របសម្រួលកម្មវិធីជាតិជាមួយដៃគូអភិវឌ្ឍន៍ ..... ១០៨

៤.១.៤. រចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីជាតិ ..... ១០៩

៤.១.៥. តម្រូវការព័ត៌មាន ការតាមដាន និងការរៀបចំរបាយការណ៍សម្រាប់កម្មវិធីជាតិ ..... ១០៩

៤.១.៦. សវនកម្មកម្មវិធីជាតិ ..... ១១០

**៤.២. ការតាមដាន និងវាយតម្លៃ ..... ១១១**

៤.២.១. ទំនាក់ទំនងរវាងក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃជាមួយនឹងសមាសធាតុកម្មវិធីនានា និងគោលបំណងនានានៃវិមជ្ឈការ និងវិសហមជ្ឈការ ..... ១១១

៤.២.២. ការរៀបចំរបៀបរបបគ្រប់គ្រងសម្រាប់ការតាមដាន និងវាយតម្លៃ ..... ១១២

៤.២.៣. សំណើនានាសម្រាប់ការតាមដាន និងវាយតម្លៃចំពោះថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ..... ១១៣

៤.២.៤. ការតម្រឹមដៃគូអភិវឌ្ឍន៍ជាមួយក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃនៃកម្មវិធីជាតិ ..... ១១៤

**៤.៣. ហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យនៃកម្មវិធីជាតិ ..... ១១៤**


## ជំពូកទី៥
## ហិរញ្ញវត្ថុ និងថវិកានៃកម្មវិធីជាតិ


**៥.១. ការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីជាតិ ..... ១១៩**

៥.១.១. ការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីជាតិត្រូវផ្អែកលើកម្មវិធី និងត្រូវឆ្លុះបញ្ចាំងនៅក្នុងថវិកា ..... ១១៩

៥.១.២. លំហូរមូលនិធិ និងយន្តការផ្តល់មូលនិធិ ..... ១២០

៥.១.៣. ការផ្តល់ហិរញ្ញប្បទានទៅតាមសមាសធាតុកម្មវិធីទាំងប្រាំ ..... ១២៤

៥.១.៤. អនុស្សរណៈនៃការយោគយល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ..... ១២៥

**៥.២. យុទ្ធសាស្ត្រអន្តរកាល ..... ១២៥**

៥.២.១. ការតម្រឹម និងការធ្វើសុខដុមនីយកម្មរវាងកម្មវិធីកំណែទម្រង់ទាំងបី ..... ១២៥

៥.២.២. ការតម្រឹម និងការធ្វើសុខដុមនីយកម្មនៃកម្មវិធី និងគម្រោងនានាដែលកំពុងដំណើរការ ..... ១២៦

**៥.៣. កម្មវិធីបាន់ស្មានរយៈពេល៣ឆ្នាំនៃកម្មវិធីជាតិ ..... ១២៩**

៥.៣.១. វិធីសាស្ត្រអនុវត្តន៍ ..... ១២៩

៥.៣.២. កម្មវិធីបាន់ស្មានសម្រាប់រយៈពេល៣ឆ្នាំ ..... ១៣១

៥.៤. ការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់កម្មវិធីជាតិ ........ ១៣១
៥.៤.១. វិសាលភាព ........ ១៣១
៥.៤.២. ការណែនាំសំខាន់ៗក្នុងការវិភាជន៍ធនធាន ........ ១៣២
៥.៤.៣. ការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់កម្មវិធីជាតិ ........ ១៣៣

## តារាង

តារាង ២.១ : រយៈពេល និងលទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ ........ ២៩
តារាង ២.២ : ក្របខ័ណ្ឌតក្កភាពគោលសម្រាប់កម្មវិធីជាតិរយៈពេល១០ឆ្នាំ ........ ៣៣
តារាង ៣.១ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី១ ........ ៥០
តារាង ៣.២ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី២ ........ ៥៨
តារាង ៣.៣ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៣ ........ ៦៩
តារាង ៣.៤ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៤ ........ ៨២
តារាង ៣.៥ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៥ ........ ៩៩
តារាង ៤.១ : ហានិភ័យ និងសកម្មភាពកាត់បន្ថយហានិភ័យ ........ ១១៥
តារាង ៥.១_ក : ការប្រែប្រួលនៃការផ្តល់ការគាំទ្រពីដៃគូអភិវឌ្ឍន៍នៅក្នុងដំណើរការអនុវត្តកម្មវិធីជាតិ...... ១២២
តារាង ៥.១_ខ : ជម្រើសនានានៃលំហូរមូលនិធិតាមប្រភេទចំណាយ ........ ១២៣
តារាង ៥.១_គ : ប្រភេទចំណាយតាមសមាសធាតុកម្មវិធី ........ ១២៤
តារាង ៥.២ : កម្មវិធី និងគម្រោងដែលបានទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ........ ១២៧

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ : របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំង៥លើក ........ ១៣៤
ឧបសម្ព័ន្ធទី២ : ការបញ្ច្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ១៤០
ឧបសម្ព័ន្ធទី៣ : គណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ១៤៩

## សទ្ទានុក្រម

សទ្ទានុក្រម ........ ១៦០

កំណត់សម្គាល់ : អត្រាប្តូរប្រាក់ : ៤.១៥០រៀលក្នុងមួយដុល្លារសហរដ្ឋអាមេរិក។

# អារម្ភកថា

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានតាក់តែងឡើងនេះ គឺជារបៀបវារៈការងាររបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់រយៈពេល១០ឆ្នាំ ក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដ៏ទូលំទូលាយ និងស៊ីជម្រៅនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយកំណែទម្រង់នេះក៏មានផលប៉ះពាល់មកលើស្ថាប័ននានានៅថ្នាក់ជាតិផងដែរ។ ម្យ៉ាងទៀត ការរៀបចំឱ្យមានកម្មវិធីជាតិនេះ ក៏ជាការបញ្ជាក់អះអាងឡើងវិញនូវការប្តេជ្ញាចិត្តខាងនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះចក្ខុវិស័យ នយោបាយ និងយុទ្ធសាស្ត្រដែលបានកំណត់រួចមកហើយក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តច្បាប់រៀបចំអង្គការសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

ទន្ទឹមនេះ កម្មវិធីជាតិនេះ ក៏ត្រូវបានរៀបចំឡើងក្នុងបរិបទដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋបាលគ្រប់លំដាប់ថ្នាក់ សំដៅលើកកម្ពស់អភិបាលកិច្ចល្អ ការលើកស្ទួយការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្របន្ថែមទៀត។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវរៀបចំឱ្យមានការសហការដ៏មានប្រសិទ្ធភាពរវាងកិច្ចខិតខំប្រឹងប្រែង ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការនេះ ទាមទារឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នា ដើម្បីចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន និងទាមទារឱ្យមានការផ្តល់សេវាសាធារណៈដែលមានគុណភាព និងទូលំទូលាយជាងមុន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើក្រុមជនងាយរងគ្រោះ ជាពិសេសជនជាតិដើមភាគតិច ស្ត្រី និងកុមារ។

ដូច្នេះ គោលបំណងដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺដើម្បី ៖

- បង្កើតវប្បធម៌ប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាពលរដ្ឋ និងប្រកបដោយការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ
- កែលម្អការផ្តល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ
- នាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច
- ចូលរួមកាត់បន្ថយភាពក្រីក្រ។

ឯកសារកម្មវិធីជាតិនេះ បានកំណត់នូវគោលដៅ គោលបំណង វិសាលភាពនៃក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិដោយបែងចែកជាដំណាក់កាលអនុវត្ត និងសកម្មភាពសំខាន់ៗសម្រាប់អនុវត្តតាមសមាសធាតុនីមួយៗដូចដែលបានកំណត់ក្នុងឯកសារកម្មវិធី ដើម្បីឆ្ពោះទៅកាន់គោលដៅនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ឯកសារកម្មវិធីជាតិបានកំណត់នូវសមាសធាតុកម្មវិធីចំនួន៥ រួមមាន ៖

### មួយ ៖ ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ

ក្រុមប្រឹក្សាដែលជាប់ឆ្នោតតាមរយៈការបោះឆ្នោតសកល និងអសកលនៅតាមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាមធ្យោបាយសម្រាប់អនុវត្តការងារ។ ការបង្កើតឡើងនូវក្រុមប្រឹក្សាទាំងនេះ មិនមែនសម្រាប់ធ្វើជាវេទិកាដើម្បីពិភាក្សានោះទេ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ មានបំណងឱ្យក្រុមប្រឹក្សាទាំងនោះសម្រេចបាននូវលទ្ធផលជាក់លាក់ ក្នុងការលើកស្ទួយគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដោយត្រូវចាប់ផ្តើមពីជនក្រីក្រ និងក្រុមជនងាយរងគ្រោះ។ គោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តម្រូវឱ្យក្រុមប្រឹក្សាដែលជាប់ឆ្នោតនៅតាមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិតំណាងឱ្យសហគមន៍នៅមូលដ្ឋានរបស់ខ្លួន មានការឆ្លើយតប និងមានគណនេយ្យភាពចំពោះសហគមន៍នៅមូលដ្ឋានលើការងារដែលក្រុមប្រឹក្សាទាំងនោះអនុវត្តមុខងាររបស់ខ្លួន។ ដើម្បីសម្រេចបាននូវបេសកកម្មទាំងនេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបានអំណាច និងធនធានចាំបាច់ រួមមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ សមត្ថភាពរូបវន្ត និងសមត្ថភាពតាមផ្លូវច្បាប់ ដើម្បីក្រុមប្រឹក្សាទាំងនោះ ធ្វើសេចក្តីសម្រេចក្នុងការអនុវត្តការងារនានាសម្រាប់បម្រើផលប្រយោជន៍របស់សហគមន៍នៅមូលដ្ឋាន។

ដូចនេះ ការបង្កើតឡើងនូវក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ បានធ្វើឱ្យមានការផ្លាស់ប្តូរដ៏ជ្រាលជ្រៅនូវខ្សែគណនេយ្យភាពរបស់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ច្បាប់រៀបចំអង្គការមានបំណងធ្វើឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិរីកចម្រើន ក្លាយទៅជារដ្ឋបាលមូលដ្ឋានដែលរឹងមាំ និងមានស្វ័យភាពប៉ុន្តែមិនមានអធិបតេយ្យភាពនោះទេ។

ដើម្បីឆ្លើយតបជាមួយតម្រូវការនៃការផ្លាស់ប្តូរថ្មីទាំងនេះ ក្រុមប្រឹក្សានៅតាមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីប្រតិបត្តិការច្បាស់លាស់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋានយ៉ាងរឹងមាំ សំដៅចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រទេសជាតិប្រកបដោយនិរន្តរភាព។

### ពីរ ៖ ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏រឹងមាំ

ក្រុមប្រឹក្សាដែលជាប់ឆ្នោតតាមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានសមាសភាពសមាជិកមកពីគណបក្សនយោបាយនានា។ ដូច្នេះសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោតទាំងនោះមិនអាចមានវិជ្ជាជីវៈ ជំនាញគ្រប់បែបយ៉ាង ដើម្បីអនុវត្តមុខងារទាំងអស់បានឡើយ។ លើសពីនេះទៅទៀត នៅពេលដែលមុខងារ និងធនធានត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើង សមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោតពិតជាមិនអាចរ៉ាប់រងបំពេញមុខងារ និងចាត់ចែងធនធានទាំងនោះដោយខ្លួនឯងបានឡើយ។ ដូច្នេះ ក្រុមប្រឹក្សាត្រូវតែមានបុគ្គលិកប្រកបដោយគុណភាព មានសមត្ថភាព និងមានបទពិសោធន៍ ដើម្បីបំពេញការងារនានាក្នុងនាមក្រុមប្រឹក្សា និងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ តម្រូវឱ្យក្រុមប្រឹក្សាមានបុគ្គលិករបស់ខ្លួនជាអចិន្ត្រៃយ៍ ដើម្បីបំពេញការងារនានារបស់ក្រុមប្រឹក្សា និងត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។ ច្បាប់រៀបចំអង្គការ បានតម្រូវឱ្យរៀបចំក្របខ័ណ្ឌបុគ្គលិកមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ

តាមរយៈការបង្កើតឱ្យមានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំឱ្យមានក្របខ័ណ្ឌបុគ្គលិករបស់ក្រុមប្រឹក្សា គឺជាដំណើរការមួយដែលផ្សារភ្ជាប់ជាមួយការផ្ទេរមុខងារ និងធនធាន។ ជាការពិត ដំណើរការផ្ទេរបុគ្គលិកទៅឱ្យក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈស្មុគស្មាញ នឹងត្រូវអនុវត្តដោយប្រុងប្រយ័ត្ន។

ឯកសារកម្មវិធីជាតិ បានកំណត់អំពីជំហាន ដំណាក់កាល និងសកម្មភាពសំខាន់ៗក្នុងការផ្ទេរបុគ្គលិក ការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដ៏សមស្របមួយ ដែលមិនបង្កើននូវទំហំនៃមន្ត្រីសាធារណៈក្នុងទូទាំងប្រទេស ដែលនឹងនាំឱ្យមានផលប៉ះពាល់ដល់ការបង្កើនការចំណាយទៅលើបុគ្គលិក។

## បី : ការផ្ទេរមុខងារ និងធនធាន

ការផ្តល់សេវាសាធារណៈ មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន គឺជាសមាសភាគដ៏សំខាន់មួយនៃកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបាននូវការផ្ទេរមុខងារ និងធនធានដ៏សមស្រប ដើម្បីឱ្យក្រុមប្រឹក្សាទាំងនោះអាចផ្តល់សេវាសាធារណៈ មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដល់សហគមន៍មូលដ្ឋានរបស់ខ្លួន។ ការផ្ទេរមុខងារ និងធនធាននានា ត្រូវធ្វើឡើងក្នុងលក្ខណៈមួយដែលមានផែនការ មានការបែងចែកជាដំណាក់កាល មានភាពសមហេតុផល មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានការរំខានជាអប្បបរមាដល់កិច្ចប្រតិបត្តិការនានា ដែលកំពុងប្រព្រឹត្តទៅរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព គឺពាក់ព័ន្ធទៅនឹងការផ្ទេរអំណាចក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗជាមូលដ្ឋាននានាឱ្យកាន់តែខិតជិតប្រជាពលរដ្ឋ។ ទន្ទឹមនេះ ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យក្រុមប្រឹក្សាដែលជាប់ឆ្នោត និងមន្ត្រីសាធារណៈដែលតែងតាំងឱ្យទៅបំពេញការងាររបស់ក្រុមប្រឹក្សា និងបុគ្គលិកទាំងអស់របស់ក្រុមប្រឹក្សា ត្រូវមានសមត្ថភាព មានឆន្ទៈបំពេញការងារ និងមានភាពប៉ិនប្រសព្វ។ ព្រមជាមួយនោះការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ត្រូវធានាថា ប្រជាពលរដ្ឋនៅមូលដ្ឋានត្រូវបានទទួលនូវការផ្តល់សិទ្ធិដើម្បីចូលរួមនៅក្នុងការធ្វើការសម្រេចពាក់ព័ន្ធនឹងសេវាសាធារណៈដែលប៉ះពាល់ជីវភាពប្រចាំថ្ងៃរបស់ខ្លួន ដើម្បីប្រជាពលរដ្ឋធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាជាប់ឆ្នោត និងមន្ត្រីរបស់ក្រុមប្រឹក្សា ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើគុណភាពនៃសេវាសាធារណៈដែលក្រុមប្រឹក្សា និងមន្ត្រីរបស់ក្រុមប្រឹក្សាត្រូវផ្តល់ឱ្យប្រជាពលរដ្ឋ។

ដូច្នេះការផ្ទេរការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗ និងជាមូលដ្ឋានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសាធារណៈ និងសមត្ថភាពរបស់ក្រុមប្រឹក្សានៅមូលដ្ឋាន ដើម្បីរៀបចំការសម្រេច និងជម្រើសនានាចំពោះតម្រូវការនៅមូលដ្ឋាន ដោយផ្តោតជាសំខាន់ទៅលើការកាត់បន្ថយភាពក្រីក្រ គឺជាដំណើរការស្នូលក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## បួន ៖ អំពីប្រព័ន្ធថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ បានតម្រូវឱ្យក្រុមប្រឹក្សាតាមប្រភេទនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិសមស្រប ដើម្បីក្រុមប្រឹក្សាអនុវត្តមុខងារ និងការទទួលខុសត្រូវនានា សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដើម្បីធានាឱ្យក្រុមប្រឹក្សាគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិដែលបានប្រគល់ឱ្យ មានលក្ខណៈតម្លាភាព មានសុចរិតភាពខ្ពស់បំផុត និងមានគណនេយ្យភាពចំពោះមូលដ្ឋាន និងចំពោះរាជរដ្ឋាភិបាលអំពីវិធានការខាងផ្លូវច្បាប់ ច្បាប់រៀបចំអង្គការបានតម្រូវឱ្យមានច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្រុមប្រឹក្សាត្រូវធានាអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីដែលទាក់ទងដល់ការរៀបចំ ការអនុម័ត និងការអនុវត្តថវិកា គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ទ្រព្យសម្បត្តិ ព្រមទាំងការធ្វើសវនកម្មផ្ទៃក្នុង និងសវនកម្មផ្ទៃក្រៅទៅលើហិរញ្ញវត្ថុ និងថវិការបស់ក្រុមប្រឹក្សា។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវទទួលខុសត្រូវក្នុងការរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដើម្បីកំណត់អំពីចក្ខុវិស័យរបស់ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍក្នុងតំបន់របស់ខ្លួន។

## ប្រាំ ៖ អំពីស្ថាប័នគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

កិច្ចដំណើរការនៃការកែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ មានផលប៉ះពាល់មកលើស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដូច្នេះ ដើម្បីឱ្យដំណើរការកំណែទម្រង់នេះប្រព្រឹត្តទៅដោយរលូន ទាមទារត្រូវមានយន្តការដ៏រឹងមាំមួយ ដើម្បីសម្របសម្រួលស្ថាប័ននានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធីជាតិនេះ។

ការសម្របសម្រួលក្នុងចំណោមក្រសួង ស្ថាប័ននៅថ្នាក់ជាតិ នឹងស្តែងឡើងក្នុងដំណើរការនៃការពិនិត្យមើលមុខងារ ធនធាន និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ក្នុងគោលបំណងធ្វើការផ្ទេរមុខងារ ធនធាន ការទទួលខុសត្រូវដែលពាក់ព័ន្ធដល់សេវាសាធារណៈសំខាន់ៗ និងជាមូលដ្ឋាន ដែលប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់សហគមន៍នៅមូលដ្ឋាន ទៅឱ្យក្រុមប្រឹក្សាសមស្របណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដំណើរការនេះនឹងធ្វើឱ្យមានការផ្លាស់ប្តូរតួនាទី និងការទទួលខុសត្រូវបច្ចុប្បន្នរបស់ក្រសួង ស្ថាប័ននានា ដែលមានតួនាទីជាអ្នកកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រផង និងជាប្រតិបត្តិករលើកិច្ចការគ្រប់វិស័យផង មកកាន់តួនាទីថ្មី គឺការកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានជាតិទៅលើមុខងារទាំងឡាយណាដែលបានផ្ទេរទៅឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីសម្របសម្រួលដំណើរការកំណែទម្រង់ដ៏ស៊ីជម្រៅ និងសាំញ៉ាំនេះ ច្បាប់រៀបចំអង្គការបានតម្រូវឱ្យបង្កើតឡើងនូវយន្តការអន្តរក្រសួងជាអចិន្ត្រៃយ៍មួយ ដើម្បីធ្វើជាសេនាធិការដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់រៀបចំអង្គការ គឺគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)។

កម្មវិធីជាតិបានកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ គ.ជ.អ.ប ដើម្បីសម្របសម្រួលការអនុវត្តការពិនិត្យមើលការអនុវត្តកម្មវិធីជាតិនេះ ដោយមានការសហការសម្របសម្រួលជាមួយយន្តការកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់តាមវិស័យនានា តាមដំណាក់កាលនីមួយៗ

រួមទាំងការកំណត់អំពីតម្រូវការបុគ្គលិក សមត្ថភាព ធនធានហិរញ្ញវត្ថុ និងធនធានសមស្របដទៃទៀត ដើម្បីធានាឱ្យ គ.ជ.អ.ប សម្របសម្រួលការអនុវត្តកម្មវិធីជាតិនេះ។

សរុបមក ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យគ្មានទីបញ្ចប់ឡើយ ហើយដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យមានការវិវឌ្ឍជាប្រចាំ តាមរយៈការគិត ការអនុវត្ត ការរៀនសូត្រ ការវាយតម្លៃ ការកែសម្រួល និងការធ្វើឱ្យកាន់តែប្រសើរឡើងជាលំដាប់។

ជាក្រឹត្យក្រម ដំណើរការកំណែទម្រង់គឺជាការប្រកាន់យកវិធានការដ៏ហ្មត់ចត់ និងប្រុងប្រយ័ត្ន ដើម្បីដោះស្រាយបញ្ហាប្រឈម។ បញ្ហាប្រឈមមួយត្រូវបានដោះស្រាយ បញ្ហាប្រឈមថ្មីនឹងអាចលេចឡើង ដែលទាមទារត្រូវមានដំណោះស្រាយសមស្រប។ ក្នុងការអនុវត្តកម្មវិធីជាតិនេះ នឹងអាចលេចឡើងនូវបញ្ហាប្រឈមនានាដែលមិនអាចមើលឃើញជាមុនបានឡើយ។ ដូច្នេះចាំបាច់ត្រូវមានភាពបត់បែនថែមទៀតក្នុងចិត្តគំនិត និងការគ្រប់គ្រងដែលត្រៀមខ្លួនឱ្យហើយស្រេច ដើម្បីធ្វើការសម្របខ្លួន និងធ្វើការកែប្រែបង្ការកុំឱ្យមានការខុសឆ្គង និងកុំឱ្យមានការបាត់បង់គោលនយោបាយ និងការប្តេជ្ញាចិត្ត។

ជោគជ័យនៃការអនុវត្តកម្មវិធីជាតិ សំដៅជំរុញ និងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ អាស្រ័យទៅលើការប្តេជ្ញាចិត្តរួមគ្នាដោយឥតងាករេ ក្នុងការពុះពារឆ្លងកាត់បញ្ហាប្រឈមនានាចំពោះលទ្ធិប្រជាធិបតេយ្យ ដែលគាំទ្រដោយការយល់ដឹង និងការគិតពិចារណាទុកជាមុនយ៉ាងប្រុងប្រយ័ត្ន។ ក្នុងទស្សនទាននេះ ទើបកម្មវិធីជាតិនេះ ត្រូវបានតាក់តែងឡើងដោយប្រមូលផ្តុំបញ្ញាញាណក្នុងរាជរដ្ឋាភិបាលទាំងមូល និងការចូលរួមពីភាគីដែលពាក់ព័ន្ធនានា នៅក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា សង្ឃឹមថា កម្មវិធីជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩) សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនេះ នឹងទទួលបានការគាំទ្រ និងអនុវត្តដោយឥតសំចៃពីគ្រប់ក្រសួង ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល ពីមន្ត្រីរាជការសាធារណៈគ្រប់ថ្នាក់ ពីគណបក្សនយោបាយ ពីដៃគូអភិវឌ្ឍន៍ ពីសង្គមស៊ីវិល ពីផ្នែកឯកជន និងពីសំណាក់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ឯកសារកម្មវិធីជាតិនេះ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

### ១.១.១. រដ្ឋបាលដែនដី និងសេដ្ឋកិច្ចនៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីសរុប១៨១.០៣៥គីឡូម៉ែត្រការ៉េ មានប្រជាជនសរុបចំនួន១៣.៣៩៥.៦៨២នាក់(ស្រី៦.៨៧៩.៦២៨នាក់ ស្មើនឹង៥១,៣៦%) និងមានដង់ស៊ីតេប្រជាជន៧៥នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ[១]។ ប្រជាជនប្រមាណ៨៥%ជាកសិករ រស់នៅពឹងផ្អែកលើវិស័យកសិកម្ម ដែលជាវិស័យមួយមានចំណែកប្រមាណ៣២.៤% នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០០៨ និងជាមូលដ្ឋានបង្កើតការងារសម្រាប់ប្រជាជនជាង៧០%។ ក្រៅពីវិស័យកសិកម្ម វិស័យផ្សេងៗទៀតជាពិសេសវិស័យកាត់ដេរ វិស័យទេសចរណ៍ និងសំណង់ បានជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានការកើនឡើងក្នុងកម្រិតខ្ពស់ ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ៩.៥%នៅក្នុងអំឡុងឆ្នាំ១៩៩៩-២០០៨ និងបានជួយលើកកម្ពស់ចំណូលប្រជាជនក្នុងម្នាក់ៗបានកើនឡើងពី២៨១ដុល្លារអាមេរិកក្នុងឆ្នាំ១៩៩៩ ទៅ៧៣៩ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៨ ព្រមទាំងបានកាត់បន្ថយភាពក្រីក្រពី ៣៤.៨%ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ៣០.១%ក្នុងឆ្នាំ២០០៧[២]។

នាពេលថ្មីៗនេះ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក បានបង្កជាសម្ពាធមកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេសបានជះឥទ្ធិពលផ្ទាល់មកលើវិស័យកាត់ដេរ និងទេសចរណ៍នៅកម្ពុជា។ វិបត្តិនេះបានបង្កនូវការប្រឈមមួយដល់ការថែរក្សាសមិទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ ដោយសារភាពគ្មានការងារធ្វើមានការកើនឡើង ជាពិសេសក្នុងចំណោមយុវជន។ លើសពីនេះទៀត លទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដោះស្រាយនូវបញ្ហាសង្គម សេដ្ឋកិច្ចទាំងនេះ នឹងជួបប្រទះការលំបាក ដោយសារការប្រមូលពន្ធ និងចំណូលអាចនឹងមានការធ្លាក់ចុះ ហើយហិរញ្ញប្បទានសហប្រតិបត្តិការក៏អាចនឹងមានការថយចុះផងដែរ ដោយសារប្រទេសអ្នកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការទាំងនោះជួបប្រទះនូវការធ្លាក់ចុះនៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងប្រទេសរបស់ខ្លួន។

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កម្ពុជាជារដ្ឋទោលដែលមិនអាចបំបែកបាន។ មាត្រា១៤៥ថ្មី(មួយ) និងមាត្រា១៤៦ថ្មី(មួយ)នៃរដ្ឋធម្មនុញ្ញ បានកំណត់ពីការគ្រប់គ្រងរដ្ឋបាលដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយចែកទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ ហើយរដ្ឋបាលដែនដីទាំងនេះត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ មកដល់ចុងឆ្នាំ២០០៩ ព្រះរាជាណាចក្រកម្ពុជារួមមានរាជធានីភ្នំពេញ និងខេត្តចំនួន២៣ ស្រុកចំនួន១៥៩ ក្រុងចំនួន២៦ ខណ្ឌចំនួន៨ និងឃុំ សង្កាត់ចំនួន១.៦២១។

មុនខែកុម្ភៈ ឆ្នាំ២០០២ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអាជ្ញាធរដែលត្រូវបានតែងតាំងឡើង។ រដ្ឋបាលទាំងនេះបំពេញការងារក្នុងនាមរាជរដ្ឋាភិបាល ក្នុងឋានៈជាទីភ្នាក់ងារដែលរាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្មឱ្យ

---

[១] ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨។

[២] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។

អនុវត្តសេចក្តីសម្រេច សេចក្តីណែនាំ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។ មន្ទីរខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា ត្រូវបានដាក់ពង្រាយចាប់ពីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តសេចក្តីសម្រេច សេចក្តីណែនាំ និងគោលនយោបាយរបស់ក្រសួង ស្ថាប័នសាមី។ ក្នុងប្រព័ន្ធនេះ រាជរដ្ឋាភិបាលបានរក្សាទុកភាពជាម្ចាស់ និងការទទួលខុសត្រូវចំពោះមុខងារដែលបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ឬមន្ទីរខ្សែបណ្តោយ។ ប្រតិភូកម្មនេះអមជាមួយទៅដោយសេចក្តីណែនាំ និងការត្រួតពិនិត្យយ៉ាងល្អិតល្អន់។ ប្រព័ន្ធនេះ រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានការឆ្លើយតប និងគណនេយ្យភាពពីក្រោមឡើងលើមករាជរដ្ឋាភិបាលចំពោះអ្វីដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តអំណាចដែលបានធ្វើប្រតិភូកម្ម។

ដូច្នេះ រហូតមកដល់មុនឆ្នាំ២០០២ រដ្ឋបាលថ្នាក់ក្រោមជាតិមានតែមួយប្រភេទនេះប៉ុណ្ណោះ។ កម្ពុជាចាត់ទុកអភិបាលកិច្ចនេះថាជា វិសហមជ្ឈការ។ វិសហមជ្ឈការនៅកម្ពុជាបានចាក់ឬសយ៉ាងជ្រៅ ព្រោះអភិបាលកិច្ចនេះបានអនុវត្តនៅពេលមិនទាន់មានអាជ្ញាធរ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងនៅថ្នាក់ក្រោមជាតិ។

ខែមីនា ឆ្នាំ២០០១ ច្បាប់រៀបចំអង្គការ មានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអនុម័ត។ តាមរយៈច្បាប់នេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើឡើងដោយជោគជ័យនាខែកុម្ភៈ ឆ្នាំ២០០២ ហើយបានបង្កើតជាអាជ្ញាធរមូលដ្ឋានយ៉ាងសំខាន់។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលនយោបាយថ្មីនេះថាជា វិមជ្ឈការ និងវិសហមជ្ឈការ ដូចដែលបានកំណត់នៅក្នុងច្បាប់រៀបចំអង្គការសម្រាប់រដ្ឋបាលឃុំ សង្កាត់។

ដូច្នេះចាប់ពីខែកុម្ភៈ ឆ្នាំ២០០២មក អភិបាលកិច្ចនៅថ្នាក់ឃុំ សង្កាត់ មានការកែសម្រួលជាច្រើន។ រដ្ឋបាលដែលបានជ្រើសរើសឡើងតាមការបោះឆ្នោតនេះ គឺជាមធ្យោបាយសម្រាប់អនុវត្តការងារតាមរយៈការផ្ទេរភាពជាម្ចាស់ពីរាជរដ្ឋាភិបាល ដើម្បីធានាឱ្យឃុំ សង្កាត់តំណាងឱ្យផលប្រយោជន៍សហគមន៍នៅមូលដ្ឋានរបស់ខ្លួន មានការឆ្លើយតប និងគណនេយ្យភាពចំពោះសហគមន៍នៅមូលដ្ឋាន។

## ១.១.២. សនិទានភាព និងបញ្ហាប្រឈមនានាដែលជំរុញឱ្យមានការបន្តធ្វើកំណែទម្រង់

កំណើនសេដ្ឋកិច្ចដ៏គួរឱ្យកត់សម្គាល់ នាំឱ្យចំណាយលើការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកើនឡើង ជាពិសេសលើវិស័យអប់រំ សុខាភិបាល កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា សំដៅកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ។ ថ្វីបើកម្ពុជាមានដីធ្លីប្រកបដោយសក្តានុពល ព្រមទាំងធនធានធម្មជាតិ និងធនធានមនុស្សក៏ដោយ ក៏ប្រជាពលរដ្ឋនៅជនបទ និងនៅតំបន់ក្រីក្រនៃទីប្រជុំជន មានជីវភាពមិនទាន់ស័ក្តិសមនឹងសក្តានុពលនេះនៅឡើយ ហើយជីវភាពរបស់ប្រជាពលរដ្ឋទាំងនោះនៅមានកម្រិតទាប បើប្រៀបធៀបនឹងប្រទេសផ្សេងទៀតនៅក្នុងតំបន់។ ស្ថិតក្នុងបរិបទនេះ គោលដៅរបស់រាជរដ្ឋាភិបាលក្នុងការធានាឱ្យបាននូវការទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ និងការកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យពិតជាមានអត្ថន័យដ៏ជ្រាលជ្រៅ។

បញ្ហាប្រឈមមួយចំនួនក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា គឺគុណភាព ប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈនៅមានកម្រិតទាប មិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការចាំបាច់ជាក់ស្តែងនៅឡើយ ដូចជា (១) គុណភាពអប់រំនៅមានកម្រិតទាប ទាំងនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា (២) ការផ្តល់សេវាសុខាភិបាលសាធារណៈប្រកបដោយគុណភាពនៅមានកម្រិត ទោះបីជាវិស័យនេះសម្រេចបានលទ្ធផលជាវិជ្ជមានជាច្រើនក៏ពិតមែន ប៉ុន្តែអត្រាមរណៈមាតានៅមានកម្រិតខ្ពស់ (៣) សេវាថែទាំសុខភាព និងអនាម័យជនបទ រួមទាំងការផ្គត់ផ្គង់ទឹកស្អាតជនបទ សម្រេចបានក្នុងកម្រិតទាបនៅឡើយបើធៀបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (៤) លទ្ធភាពទទួលបានការអប់រំនៅមានកម្រិត អំពើហិង្សានិងការជួញដូរមនុស្សបានធ្វើឱ្យប៉ះពាល់ដល់ស្ត្រីក្នុងការស្វែងរកការងារ និងឱកាសរបស់ស្ត្រីក្នុងការចូលរួមកិច្ចអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច (៥) វិសាលភាពនៃការប្រើប្រាស់អគ្គិសនីនៅជនបទនៅមានកម្រិតទាប (៦) បណ្តាញផ្លូវថ្នល់មិនទាន់គ្រប់គ្រាន់តាមតម្រូវការ (៧) ប្រព័ន្ធធារាសាស្ត្រមិនទាន់មានលទ្ធភាពស្រោចស្រពតាមតម្រូវការនៅឡើយ[៣] ។ល។ កន្លងមក រាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលត្រូវខ្ទេចខ្ទីដោយសង្គ្រាមស៊ីវិល ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនោះ រួមនឹងកង្វះខាតប្រព័ន្ធគ្រប់គ្រង និងការថែទាំផង បានធ្វើឱ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍវិស័យទាំងនោះប្រកបដោយនិរន្តរភាព។

ទន្ទឹមនេះ អភិបាលកិច្ចមូលដ្ឋានក៏កំពុងជួបប្រទះនូវបញ្ហាប្រឈមចម្បងៗចំនួនបួន :

**ទីមួយ** ការបំពេញការងាររដ្ឋបាលប្រកបដោយគណនេយ្យភាព និងការឆ្លើយតបរបស់ថ្នាក់ក្រោមជាតិចំពោះតម្រូវការនៅមូលដ្ឋានមានភាពទន់ខ្សោយនៅឡើយ។ ទោះបីជាក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានបង្កើតឡើងដោយការបោះឆ្នោត ហើយច្បាប់បានផ្តល់សិទ្ធិឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តមុខងារ និងចាត់ចែងធនធានរបស់ខ្លួន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋានក៏ដោយ ក៏ការអនុវត្តមុខងារ និងការចាត់ចែងធនធាននៅមានកម្រិត ដោយសារមុខងារ និងធនធានហិរញ្ញវត្ថុសមស្របនានា នៅមិនទាន់បានប្រគល់ច្បាស់លាស់ឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់។ លើសពីនេះទៀត ប្រព័ន្ធគ្រប់គ្រង និងខ្សែគណនេយ្យភាពនៅរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ មិនទាន់បានរៀបចំ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន។

**ទីពីរ** ការផ្តល់សេវាសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងទីផ្សារ និងទ្រព្យសម្បត្តិសាធារណៈនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមានភាពមិនច្បាស់លាស់អំពីប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងការបែងចែកសមត្ថកិច្ចគ្រប់គ្រង ប្រើប្រាស់ និងការទាញយកផលប្រយោជន៍ពីទ្រព្យសម្បត្តិទាំងនោះក៏មិនបានច្បាស់លាស់ក្នុងចំណោមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ ទោះបីសមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការត្រូវបានបង្កើនជាបន្តបន្ទាប់ក៏ពិតមែន ប៉ុន្តែការ

---

[៣] សន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី១នៃរដ្ឋសភាជាតិនីតិកាលទី៤ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨។

ពង្រាយមន្ត្រីដែលមានសមត្ថភាពក្នុងចំណោមក្រសួង ស្ថាប័ន និងថ្នាក់រដ្ឋបាលនានាមិនស្របនឹងទំហំការងារ និងសេចក្តីត្រូវការជាអាទិភាពនៅឡើយ។ ព្រមជាមួយនោះ ក្រសួង ស្ថាប័នមានការប្រទាញប្រទង់គ្នាទៅលើមុខងារដែលត្រួតជាន់គ្នា ហើយនីតិវិធីអនុវត្តភាគច្រើនតម្រូវឱ្យមានការសម្រេចពីថ្នាក់លើ។ ស្ថានភាពនេះ ទាមទារឱ្យបង្កើតឡើងនូវកម្មវិធី និងគម្រោងនានាជាច្រើនដើម្បីដោះស្រាយបញ្ហាជាអាទិភាពនានាផង និងការសម្របសម្រួលអន្តរវិស័យផង ដែលកម្មវិធី និងគម្រោងទាំងនោះតែងតែមានការប្រកួតប្រជែងគ្នា មានការគ្រប់គ្រងត្រួតគ្នារវាងកម្មវិធី គម្រោង និងតួនាទីរបស់ស្ថាប័ន។ បញ្ហានេះបានបង្កឱ្យមានភាពស្មុគស្មាញក្នុងការឆ្លើយតបចំពោះតម្រូវការនានារបស់មូលដ្ឋាន។

**ទីបី** ភាពមិនចុះសម្រុងគ្នានៃកម្មវិធីនានាដែលទទួលហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ក៏បានបង្កជាបញ្ហាចោទផងដែរ។ ការផ្តោតការយកចិត្តទុកដាក់ទៅលើគម្រោងវិនិយោគរយៈពេលខ្លី វិសហមជ្ឈការ និងការផ្តល់បៀវត្សរ៍បន្ថែមចំពោះតែមន្ត្រីអនុវត្តគម្រោង បានគំរាមកំហែងដល់កំណែទម្រង់ស្ថាប័ន និងការកសាងសមត្ថភាពរយៈពេលវែង ដូចដែលមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

**ទីបួន** ក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ យន្តការគណនេយ្យភាពមួយចំនួនសម្រាប់ការជជែកពិភាក្សា ការតស៊ូមតិ និងការទិតៀនទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាល ដំណើរការតែនៅក្នុងប្រព័ន្ធបោះឆ្នោត និងប្រព័ន្ធនយោបាយប៉ុណ្ណោះ។

## ១.២. គោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

ឯកសារគោលនយោបាយមួយចំនួនរបស់រាជរដ្ឋាភិបាល បានផ្តល់ជាមូលដ្ឋានដ៏សំខាន់ក្នុងការកំណត់នូវចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តអនុវត្តគោលនយោបាយអភិបាលកិច្ចល្អ ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១កាលពីឆ្នាំ២០០៤ ក្នុងនោះរួមមានកម្មវិធីកំណែទម្រង់សំខាន់ៗចំនួន៤ គឺ (១)ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២)កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (៣)កំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ និង (៤)កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេសកម្មវិធីកាត់រំសាយទ័ព។

នៅខែមិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅបង្កើតឡើងនូវប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។ គោលដៅអភិវឌ្ឍន៍រយៈពេលវែងនៃយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល គឺការអភិវឌ្ឍដ៏ទូលំទូលាយ និងប្រកបដោយនិរន្តរភាព ការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចប្រកបដោយភាពស្វាហាប់នៅមូលដ្ឋាន ដែលផ្តល់កាលានុវត្តភាពប្រកបដោយសមធម៌ចំពោះប្រជាពលរដ្ឋគ្រប់រូបក្នុងការចូលរួមកិច្ចអភិវឌ្ឍមូលដ្ឋាន ការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដើម្បី

ឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ និងការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដោយផ្តោតជាសំខាន់ទៅលើក្រុមជនងាយរងគ្រោះ ជាពិសេសជនជាតិដើមភាគតិច ស្ត្រី និងកុមារ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ បានដាក់ចេញនូវយុទ្ធសាស្ត្ររួមនានាក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា។ ជាមួយគ្នានេះដែរ អភិបាលកិច្ចល្អត្រូវបានកំណត់ថា ជាស្នូលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលមិនត្រឹមតែដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នានា និងការកាត់បន្ថយភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជាទូទៅផងដែរ ។

កិច្ចប្រជុំពេញអង្គលើកទី១របស់គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ បានប្រកាសឱ្យប្រើប្រាស់នូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ហើយដែលយុទ្ធសាស្ត្រនេះមានចែងយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលលើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលមានខ្លឹមសារថា :

*"រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំបទដ្ឋានគតិយុត្ត និងការដាក់ចេញនូវវិធានការថ្មីថែមទៀត ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាពិសេសការរៀបចំ និងអនុវត្តលិខិតបទដ្ឋានដែលពាក់ព័ន្ធនឹងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិមកឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី សិទ្ធិអំណាច និងការធានាគណនេយ្យភាពក្នុងការបំពេញការងារ"* ។

សមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងការបង្កើនល្បឿននៃកំណែទម្រង់រដ្ឋបាលសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

រាជរដ្ឋាភិបាលនឹងរក្សាទុកនូវមុខងារនានាពាក់ព័ន្ធនឹងកិច្ចការវិនិយោគ កិច្ចការរដ្ឋបាល កិច្ចការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការផ្តល់សេវាសាធារណៈទាំងឡាយដែលសាធារណជនសមនឹងទទួលបាន។ ការទទួលខុសត្រូវលើការងារទាំងនេះ ពិសេសការវិនិយោគ និងការផ្តល់សេវាសាធារណៈ រាជរដ្ឋាភិបាលអាចអនុវត្តដោយផ្ទាល់(នៅថ្នាក់រដ្ឋបាលនានា) ឬដោយប្រយោលតាមរយៈការចុះកិច្ចសន្យាជាមួយផ្នែកឯកជន ឬអង្គការមិនស្វែងរកប្រាក់កម្រៃនានា។ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានប្រមើលមើលឃើញថា ប្រភេទនីមួយៗនៃរដ្ឋបាលគ្រប់ថ្នាក់ ត្រូវមានតួនាទីដ៏សំខាន់ក្នុងការអនុវត្តការងារទាំងនេះ និងធ្វើឱ្យសម្រេចនូវគោលបំណងនានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

ការរៀបចំគោលនយោបាយស្តីពីការរៀបចំមុខងារ ចាំបាច់ត្រូវដំណើរការតាមវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ ដូចខាងក្រោម :

- ថ្នាក់ជាតិត្រូវមានតួនាទីចម្បងក្នុងការបង្កើត និងរក្សាឱ្យបាននូវបរិយាកាស ដែលបង្កលក្ខណៈឱ្យរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តបាននូវយុទ្ធសាស្ត្រតាមវិស័យ ជំរុញកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើត និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដឹកនាំអនុវត្ត ដោយឈរលើមូលដ្ឋាននៃការការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ដើម្បីធានានូវគុណភាពនៃសេវាសាធារណៈនានា ថ្នាក់ជាតិត្រូវបង្កើតស្តង់ដារជាតិ គោលនយោបាយជាតិ និងកំណត់អាទិភាពនានាសម្រាប់ការអភិវឌ្ឍប្រទេស។
- រាជធានី ខេត្តត្រូវបំពេញតួនាទីក្នុងការសម្របសម្រួល និងរៀបចំផែនការ និងត្រូវធានាថា ការសម្រេចបែងចែកធនធាននានារបស់ខ្លួន អាចដោះស្រាយបាននូវវិសមភាពនៅតាមតំបន់នានាក្នុងរាជធានី ខេត្ត ដោយយកចិត្តទុកដាក់ទៅលើភាពខុសគ្នារវាងសមត្ថភាពគ្រប់គ្រង និងហិរញ្ញវត្ថុរបស់តំបន់ជនបទ និងតំបន់ទីប្រជុំជន។ រាជធានី ខេត្តត្រូវបំពេញការងារដោយផ្ទាល់ជាមួយថ្នាក់ជាតិ និងត្រូវទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយជាតិ ដែលនឹងត្រូវបានអនុវត្តដោយរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្ទេរមុខងារ និងធនធាននានា។
- ក្រុង ស្រុក ត្រូវមានតួនាទីចម្បងក្នុងការឆ្លើយតបចំពោះតម្រូវការជាអាទិភាពនានារបស់ឃុំ និងសង្កាត់។ ផ្អែកលើសេដ្ឋកិច្ចវិមាត្រ មុខងារនានាត្រូវបានផ្ទេរទៅឱ្យក្រុងឬស្រុក ហើយដែលមុខងារទាំងនោះមានការពាក់ព័ន្ធផ្ទាល់ដល់ក្រុងឬស្រុក ឬមុខងារនោះជះឥទ្ធិពលដល់ឃុំឬសង្កាត់ច្រើនជាងមួយ។ លើមូលដ្ឋាននេះ ក្រុងឬស្រុកត្រូវរៀបចំកម្មវិធីអនុវត្ត និងត្រូវផ្តល់សេវាសាធារណៈ ដោយផ្ទាល់ដល់ឃុំ សង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ចំពោះខណ្ឌនានានៅក្នុងរាជធានីភ្នំពេញ នឹងត្រូវដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងឯកភាពតែមួយរបស់រដ្ឋបាលរាជធានីភ្នំពេញក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃរដ្ឋបាលរាជធានីភ្នំពេញ។
- ឃុំ សង្កាត់ជារដ្ឋបាលដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋ គឺជាតំណាងឱ្យសំឡេងរបស់ប្រជាពលរដ្ឋ។ ហេតុនេះ ឃុំ សង្កាត់ត្រូវធានាថា តម្រូវការអភិវឌ្ឍន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវបានធ្វើឱ្យសម្រេចដោយខ្លួនឯងផ្ទាល់ ឬដោយរដ្ឋបាលប្រភេទផ្សេងទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកលើមុខងារនានាដែលត្រូវបានផ្ទេរឱ្យថ្នាក់រដ្ឋបាលនោះ។ លើសពីនេះទៀត ឃុំ សង្កាត់ត្រូវជំរុញឱ្យក្រុង ស្រុក ខណ្ឌមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ តាមរយៈការចូលរួមនៅក្នុងយន្តការនៃការធ្វើសេចក្ដីសម្រេចនានា ដូចជាភាពជាតំណាងនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស និងតាមរយៈសិទ្ធិទទួលបានព័ត៌មាន សិទ្ធិតាមដាន និងសិទ្ធិទទួលបានរបាយការណ៍ស្ដីពីសកម្មភាពនានារបស់រដ្ឋបាលប្រភេទផ្សេងទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមរយៈយន្តការគណនេយ្យភាពនានា ដែលរួមមានការរៀបចំនូវវិធានការចាំបាច់សម្រាប់ដាក់វិន័យដល់រដ្ឋបាលនានា ដែលបំពេញមុខងារមិនបានសមស្រប។

## ១.៣. សមិទ្ធផលនៃកំណែទម្រង់ដែលសម្រេចបានកន្លងមក

ក្នុងអំឡុងពេល១៥ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលបានសម្រេចនូវសមិទ្ធផលជាច្រើននៅក្នុងកិច្ចការកំណែទម្រង់រដ្ឋ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមិនមែនជាបញ្ហាថ្មីថ្មោងនៅកម្ពុជានោះទេ យើងបានអនុវត្តកំណែទម្រង់នេះតាំងពីឆ្នាំ២០០២មក។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលបានអនុម័តនៅឆ្នាំ២០០១ បានត្រួសត្រាយផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់។ រហូតមកដល់បច្ចុប្បន្ន កម្ពុជាបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពីរដងរួចមកហើយ គឺលើកទី១ នៅខែកុម្ភៈ ឆ្នាំ២០០២ និងលើកទី២ នៅខែមេសា ឆ្នាំ២០០៧។

ការបង្កើតឱ្យមានក្រុមប្រឹក្សាឃុំ សង្កាត់បានផ្តល់នូវលទ្ធផលជាវិជ្ជមានគួរឱ្យកត់សម្គាល់ : **ទីមួយ** ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបាននូវភាពជាតំណាងស្របច្បាប់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននីមួយៗ ដែលនាំឱ្យមានការផ្លាស់ប្តូរខ្សែគណនេយ្យភាព ដែលទាមទារឱ្យមានការរៀបចំឡើងវិញនូវជំនួយផ្នែកធនធានអភិវឌ្ឍន៍ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបតម្រូវការនៅមូលដ្ឋាន។ **ទីពីរ** នីតិវិធីរៀបចំផែនការ និងថវិកាឃុំ សង្កាត់ បានអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួម និងលើកឡើងពីតម្រូវការរបស់សហគមន៍។ **ទីបី** កម្មវិធីវិមជ្ឈការបានរួមចំណែកក្នុងការកសាងសន្តិភាព សន្តិសុខ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាការជួយជំរុញដល់កំណើនសេដ្ឋកិច្ច។ **ទីបួន** កំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់បានជួយពង្រឹងរាជរដ្ឋាភិបាលឱ្យកាន់តែរឹងមាំ មានស្ថិរភាព និងទទួលបាននូវការគាំទ្រកាន់តែច្រើនឡើង។ បច្ចុប្បន្ននេះ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមានបេក្ខភាពមកពីគណបក្សនយោបាយនានា និងធ្លាប់ជាគូបដិបក្ខនឹងគ្នា បានចូលមកធ្វើការរួមគ្នាដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។

លទ្ធផលទាំងនេះ មួយផ្នែកធំសម្រេចបានតាមរយៈការបង្កើតមូលនិធិឃុំ សង្កាត់ ដែលនាំឱ្យមានលំហូរថវិកាកើនឡើងជានិច្ចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយរាជរដ្ឋាភិបាលបានប្រើប្រាស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តធ្វើជាយន្តការសម្របសម្រួលអន្តរវិស័យនៅថ្នាក់ក្រោមជាតិដើម្បីគាំទ្រដល់ការងារកសាងផែនការ ការអនុវត្តគម្រោង និងថវិការបស់ឃុំ សង្កាត់។ ថវិកាជាតិដែលវិភាជន៍ទៅឱ្យមូលនិធិឃុំ សង្កាត់បានបង្កើនពី១,៥%នៃចំណូលចរន្តក្នុងស្រុកនៅឆ្នាំ២០០២ ដល់២,៧៥%ក្នុងឆ្នាំ២០០៩[៤]។ មូលនិធិនេះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន តាមរយៈដំណើរការនៃការកសាងផែនការ និងការគ្រប់គ្រងគម្រោងដែលមានការចូលរួម។ យោងតាមប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោងឃុំ សង្កាត់ឆ្នាំ២០០២-២០០៦ បានបង្ហាញឱ្យឃើញថា មានគម្រោងទឹកស្អាតប្រមាណជិត៥.០០០គម្រោង(រួមទាំងអណ្តូងស្នប់ និងស្រះទឹកសហគមន៍) ផ្លូវលំដី និងផ្លូវលំក្រាលក្រួសក្រហមប្រវែងជាង៧.០០០គីឡូម៉ែត្រ(រួមទាំងស្ពាននិងលូ) សាលាបឋមសិក្សាចំនួន៧៣០បន្ទប់ និងគម្រោងជាច្រើនទៀត ដូចជាគម្រោងប្រព័ន្ធធារាសាស្ត្រខ្នាតតូច កសិកម្ម បរិស្ថាន និងសេវាសង្គម ត្រូវបានគាំទ្រដោយមូលនិធិឃុំ សង្កាត់។ ក្នុងការអនុវត្តគម្រោងទាំងនេះ គណៈកម្មាធិការ

---

[៤] អនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់។

ប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត បានជួយគាំទ្រឃុំ សង្កាត់ក្នុងការងារគ្រប់គ្រងគម្រោង និងការអនុវត្ត កិច្ចសន្យា និងកិច្ចព្រមព្រៀងនានា ផ្អែកតាមគោលការណ៍នៃអភិបាលកិច្ចល្អ។

ទន្ទឹមនឹងការផ្តល់ធនធានហិរញ្ញវត្ថុ ក៏មានការគាំទ្រ និងការកសាងសមត្ថភាពជាច្រើនសម្រាប់ថ្នាក់ក្រោមជាតិ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ មន្ត្រីនៅថ្នាក់រាជធានី ខេត្ត និងគ្រូបង្គោលរាប់ពាន់នាក់ បានចូលរួម ក្នុងវគ្គបណ្តុះបណ្តាលអំពីគោលការណ៍នានានៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការកសាងផែនការ និងថវិកា ដែលមានការចូលរួម។ ឧទាហរណ៍ ឆ្នាំ២០០៨ វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងសម្រាប់មន្ត្រី និងគ្រូបង្គោល ថ្នាក់ជាតិចំនួន២.៤៥៤នាក់(ស្រីចំនួន៤៩៣នាក់) មន្ត្រីថ្នាក់រាជធានី ខេត្តចំនួន៨.៣៧៣នាក់(ស្រីចំនួន១.០៥៩នាក់) សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៧.៦១២នាក់(ស្រីចំនួន១.២២៩នាក់) និងស្មៀនឃុំ សង្កាត់ចំនួន២.៨៨៥នាក់ (ស្រីចំនួន២១២នាក់)[៥]។

នៅថ្នាក់ក្រុង ស្រុក ខណ្ឌ គម្រោង និងយន្តការគាំទ្រមួយចំនួនដែលបានរៀបចំឡើង បង្កើតបានជាមូលដ្ឋាន សម្រាប់ចូលរួមក្នុងដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនាជំហានបន្ទាប់។ រចនាសម្ព័ន្ធរដ្ឋបាល និង ថវិកាត្រូវបានបង្កើត និងពង្រឹងនៅក្រុង ស្រុក ខណ្ឌគោលដៅសាកល្បងមួយចំនួន ដែលបង្កលទ្ធភាពឱ្យក្រុង ស្រុក ខណ្ឌ គោលដៅសាកល្បងទាំងនោះអាចផ្តល់សេវាសាធារណៈនានា និងសហការកាន់តែជិតស្និទ្ធជាមួយរាជធានី ខេត្ត និងឃុំ សង្កាត់ ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។ ការិយាល័យច្រកចេញចូលតែមួយត្រូវបានសាកល្បងបង្កើតឡើង នៅស្រុកបាត់ដំបង និងស្រុកសៀមរាប(បច្ចុប្បន្នបានប្តូរជាក្រុង)។ សមិទ្ធផលនៃគម្រោងសាកល្បងនេះ បានលើកទឹក ចិត្តដល់រាជរដ្ឋាភិបាលដើម្បីពង្រីកការបង្កើតការិយាល័យនេះនៅថ្នាក់ក្រុង ស្រុកគោលដៅមួយចំនួនបន្ថែមទៀត ក្នុង គោលដៅពង្រឹងបន្ថែមនូវតួនាទីរបស់ក្រុង ស្រុក ក្នុងការផ្តល់សេវាសាធារណៈនានា ការប្រាស្រ័យទាក់ទងជាមួយ ប្រជាពលរដ្ឋ និងបង្ហាញឱ្យឃើញថា រដ្ឋបាលក្រុង ស្រុកកាន់តែមានគណនេយ្យភាពខ្លាំងឡើង។

ការចូលរួមចំណែក និងការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ននានា មានការវិវឌ្ឍគួរឱ្យកត់សម្គាល់។ តំណាងរបស់ក្រសួង ស្ថាប័ននានា ដែលជាសមាជិកគណៈកម្មាធិការអន្តរក្រសួង និង ក្រុមការងារនានាដែលគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានចូលរួមយ៉ាងសកម្មក្នុងការ រៀបចំផែនការ និងអនុវត្តគម្រោងនានា សំដៅជំរុញកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រសួង ស្ថាប័ននានាបានបង្កើតនូវក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ខ្លួន ដើម្បីសិក្សាវាយតម្លៃអំពីមុខងាររបស់ ក្រសួង ស្ថាប័នខ្លួន ដែលចាំបាច់ត្រូវធ្វើការប្រគល់ និងគិតគូរអំពីវិធីសាស្ត្រ ព្រមទាំងកិច្ចដំណើរការនៃការផ្ទេរមុខងារ ដោយភ្ជាប់ជាមួយធនធាន និងសមត្ថភាពទៅឱ្យរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមតាមច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

[៥] របាយការណ៍ស្តីពីការកសាងសមត្ថភាពរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០០៨។

ការសិក្សាមួយចំនួនបានបង្ហាញថា តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងធំធេងនូវការយល់ឃើញរបស់ប្រជាពលរដ្ឋ ដែលពីមុនប្រជាពលរដ្ឋយល់ថា រដ្ឋាភិបាលធ្វើអ្វីៗដោយមិនមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប៉ុន្តែបច្ចុប្បន្ននេះប្រជាពលរដ្ឋយល់ថា ជារដ្ឋាភិបាលមួយដែលមានការចូលរួម មានការគាំទ្រ និងមានការឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ។

ផ្អែកលើជោគជ័យ និងការទទួលស្គាល់ពីភាពចាំបាច់នៃការកែលម្អបន្ថែមទៀត បានផ្តល់នូវជំនឿទុកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីបោះជំហានទៅមុខក្នុងការកែទម្រង់រដ្ឋបាលគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ជាក់ស្តែង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុម័តនៅឆ្នាំ ២០០១ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុម័តនៅឆ្នាំ២០០៨។

## ១.៤. បរិយាកាសដែលនាំឱ្យមានការផ្លាស់ប្តូរ

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានអនុម័តនៅខែមិថុនា ឆ្នាំ២០០៥ បានដាក់ចេញនូវចក្ខុវិស័យ សម្រាប់ចង្អុលទិសដល់ការរៀបចំកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបន្តពង្រីកកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់បន្ថែមទៀត។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវតែស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងមានការគាំទ្រគ្នាទៅវិញទៅមកជាមួយកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើឱ្យការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលដ៏មានប្រសិទ្ធភាព។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុវត្តតាមគោលការណ៍នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ចំណែកយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ត្រូវបានអនុវត្តតាមរយៈការកែលម្អកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលបានប្រកាសឱ្យប្រើនៅក្នុងកម្មវិធីជាតិស្តីពីកំណែទម្រង់រដ្ឋបាល។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទំនាក់ទំនងដោយផ្ទាល់ សំដៅលើកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីតាក់តែងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបន្ទាប់មកត្រូវអនុវត្តនូវរាល់បញ្ញត្តិរបស់ច្បាប់នេះ សំដៅបង្កើតនូវប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទំនាក់ទំនងដោយប្រយោលកើតឡើងតាមរយៈក្រសួង ស្ថាប័ននានាដែលត្រូវផ្សារភ្ជាប់កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងវិស័យរបស់ខ្លួន ជាមួយការផ្ទេរមុខងារ និងធនធាននានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវផ្សារភ្ជាប់ជាមួយកម្មវិធីជាតិស្តីពីកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីសម្រេចបាននូវគោលបំណងសំខាន់នៃការប្រគល់សិទ្ធិអំណាច និងគណនេយ្យភាពក្នុងការគ្រប់គ្រងធនធានមនុស្ស ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តមុខងាររបស់ខ្លួនបាន។ នៅទីបញ្ចប់

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងនាំយកកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យជាអាទិភាពទាំងឡាយឱ្យខិតកាន់តែជិតនឹងប្រជាពលរដ្ឋ ដើម្បីធានាថាការបន្តធ្វើកំណែទម្រង់អភិបាលកិច្ចបានឆ្លើយតបតាមតម្រូវការនានារបស់ប្រជាពលរដ្ឋ ។

កំណែទម្រង់ដែលមានលក្ខណៈអន្តរវិស័យទាំងបីនេះ គឺជាមូលដ្ឋានគ្រឹះក្នុងការសម្រេចគោលដៅ និងគោលបំណងរបស់យុទ្ធសាស្ត្រជាតិ និងជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ ។

កំណែទម្រង់នានានៅក្នុងដំណាក់កាលនេះ នឹងមានលក្ខណៈស្មុគស្មាញ ពាក់ព័ន្ធរដ្ឋបាលគ្រប់ថ្នាក់ និងមានបញ្ហាប្រឈមជាច្រើន ដោយសារការអនុវត្តកំណែទម្រង់នេះ :

- ប៉ះពាល់ដល់ស្ថាប័នរាជរដ្ឋាភិបាលទាំងមូល ដោយព្យាយាមប្តូរពីការគ្រប់គ្រងតាមបែបមជ្ឈការ និងតាមខ្សែបណ្តោយ ឱ្យទៅជាប្រព័ន្ធមួយដែលមានការសម្របសម្រួលជាអន្តរវិស័យ សម្រាប់លើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- តម្រូវឱ្យបង្កើតនូវរដ្ឋបាលឯកភាពមួយក្រោមការដឹកនាំរបស់ក្រុមប្រឹក្សា និងមានបណ្តាញអាជ្ញាធររដ្ឋបាលថ្មី សម្រាប់ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ។
- ផ្តល់ឱ្យប្រជាពលរដ្ឋនូវសិទ្ធិអំណាចច្រើនជាងមុនក្នុងការកំណត់ពីអាទិភាពនានា ដែលជះឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សានៅក្នុងការប្រើប្រាស់ធនធាននានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- តម្រូវឱ្យមានការកែសម្រួលនូវខ្សែគណនេយ្យភាពរវាងថ្នាក់រដ្ឋបាលនានា និងនៅក្នុងក្របខ័ណ្ឌផ្ទៃក្នុងនៃប្រភេទរដ្ឋបាលនីមួយៗ ។
- ផ្លាស់ប្តូរ និងពង្រឹងបរិយាកាសនៃការគ្រប់គ្រងរបស់ថ្នាក់ឃុំ សង្កាត់ ជាពិសេសទំនាក់ទំនងរវាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ។
- តម្រូវឱ្យមានការផ្ទេរសិទ្ធិអំណាច ហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិពីប្រភេទរដ្ឋបាលមួយទៅឱ្យប្រភេទរដ្ឋបាលមួយទៀត ។
- បង្កើតនូវប្រព័ន្ធគ្រប់គ្រងអន្តររដ្ឋបាលមួយ ដើម្បីជៀសវាងភាពត្រួតគ្នានៃការផ្តល់សេវាសាធារណៈ និងការរៀបចំកម្មវិធីនានា ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ដែលមានមហិច្ឆតា និងការផ្លាស់ប្តូរដ៏ស៊ីជម្រៅបំផុតនៅក្នុងអភិបាលកិច្ចនៅកម្ពុជា ចាប់ពីការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣មក ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានគូស បញ្ជាក់ពីគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចខាងក្រោម :

*"កម្ពុជាគ្មានជម្រើសណាល្អប្រសើរ ក្រៅតែពីការធ្វើកំណែទម្រង់ទេ នៅក្នុងឱកាសដែលប្រទេសជាតិយើង កំពុងតែទទួលផលចំណេញពីសន្តិភាព និងស្ថិរភាពដែលយើងខិតខំកសាង និងការពារបាន។ រដ្ឋបាល សាធារណៈសព្វថ្ងៃត្រូវធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅថែមទៀត ដើម្បីប្រែក្លាយខ្លួនឱ្យទៅជា**អ្នកផ្តល់សេវាសាធារណៈ**ដ៏មានប្រសិទ្ធភាព និងជា**ដៃគូអភិវឌ្ឍន៍**ដែលអាចទុកចិត្តបាន សំដៅបម្រើប្រជាពលរដ្ឋឱ្យ បានកាន់តែល្អប្រសើរឡើង"*[៦] ។

*"រាជរដ្ឋាភិបាលបានដាក់ចេញនូវចក្ខុវិស័យជាយុទ្ធសាស្ត្ររបស់ខ្លួនស្តីពីវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុង ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានអនុម័តនៅឆ្នាំ២០០៥។ បច្ចុប្បន្ន នេះ យើងបានអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំណត់កាលបរិច្ឆេទនៃ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានានា ហើយនិងបានបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ។ ទាំងអស់នេះ គឺជាគ្រឹះដ៏សំខាន់ សម្រាប់កិច្ចដំណើរការ ដែលកិច្ចការជាក់ស្តែងបានចាប់ផ្តើមពីឥឡូវនេះទៅហើយ។ យើងបានជ្រើសរើសយកមាគ៌ានេះក្នុងគោលបំណង ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅលើមូលដ្ឋានទូលំទូលាយជាងមុន និងមានសមត្ថភាព ប្រកួតប្រជែងជាងមុន ព្រមទាំងការពង្រឹងការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ដើម្បីឆ្លើយតបតម្រូវការនានារបស់មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។ ជាការពិត យើងទទួលស្គាល់ថា រាជរដ្ឋាភិបាល ពិតជាមិនអាចមានលទ្ធភាពផ្តល់នូវតម្រូវការដ៏ទូលំទូលាយនៃសេវាសាធារណៈនៅទូទាំងប្រទេស ចាប់តាំងពីរាជធានីភ្នំពេញរហូតដល់តំបន់ជនបទឆ្ងាយដាច់ស្រយាល ប្រកបដោយប្រសិទ្ធភាពនោះទេ។ ដូច្នេះ ជាមួយនឹងការអនុម័តនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ យើងបានសម្រេចឱ្យមានការផ្លាស់ប្តូរ ជាសារវន្តនូវរបៀបរបបធ្វើការងាររបស់យើង។ បច្ចុប្បន្ននេះ យើងកំពុងរៀបចំបង្កើតនូវប្រព័ន្ធរដ្ឋបាលថ្នាក់ ក្រោមជាតិមួយ ជាមួយនឹងការប្រគល់មុខងារនានា ដែលរួមមានមុខងារផ្តល់សេវាសាធារណៈនានា រួមជា មួយធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានដទៃៗទៀត ពីថ្នាក់ជាតិឱ្យទៅថ្នាក់ក្រោមជាតិ"*[៧] ។

[៦] គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ដែលអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦។

[៧] សន្ទរកថាគន្លឹះរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ថ្លែងក្នុងពិធីផ្សព្វផ្សាយស្តីពីដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩។

## ១.៥. វិធីសាស្ត្រនៃកិច្ចដំណើរការតាក់តែងកម្មវិធីជាតិ

រាជរដ្ឋាភិបាលបានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់រយៈពេល១០ឆ្នាំនេះ ដោយផ្អែកលើសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល១៥ឆ្នាំកន្លងមក។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍បោះជំហានទៅមុខជានិច្ច និងមានការគិតគូរច្បាស់លាស់ និងទទួលស្គាល់ថា ការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំអាចអនុវត្តជាក់ស្តែងបាន លុះត្រាតែមានការប្តេជ្ញាចិត្ត និងការគាំទ្រដ៏ទូលំទូលាយពីគ្រប់មជ្ឈដ្ឋាន និងពីគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល អាស្រ័យហេតុនេះ ការតាក់តែងកម្មវិធីជាតិនេះ បានជ្រើសរើសយកវិធីសាស្ត្រមួយដែលលើកទឹកចិត្តឱ្យមានការចូលរួមដ៏សកម្មពីតំណាងក្រសួង ស្ថាប័ន មន្ត្រីនៅថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា។ ដំណើរការនៃការតាក់តែងកម្មវិធីជាតិ ក៏បានយកចិត្តទុកដាក់ផងដែរទៅលើបទពិសោធន៍កន្លងមក ដើម្បីជាមូលដ្ឋានសម្រាប់ការកែទម្រង់នៅជំហានបន្ទាប់។

ដោយប្រកាន់ខ្ជាប់នូវគោលគំនិតខាងលើ ការតាក់តែងកម្មវិធីជាតិបានរៀបចំឱ្យមានកិច្ចពិភាក្សាជាបន្តបន្ទាប់សំដៅទទួលនូវគំនិត និងការឯកភាពជារួមលើបញ្ហាជាគន្លឹះនានា ដើម្បីកំណត់ជាគោលការណ៍ និងវង្វង់សមត្ថកិច្ចសម្រាប់កំណែទម្រង់ទាំងមូល[៨]។ ប្រធានបទកិច្ចពិភាក្សានីមួយៗ ផ្តោតលើទិដ្ឋភាពសំខាន់ៗសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ប្រធានបទទាំងនោះរួមមាន :

- គោលដៅ និងយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ
- ការផ្ទេរមុខងារ និងការទទួលខុសត្រូវឱ្យទៅថ្នាក់ក្រោមជាតិ
- ហិរញ្ញវត្ថុ និងថវិកាថ្នាក់ក្រោមជាតិ
- គណនេយ្យភាព ការពិនិត្យមើល និងការឆ្លើយតបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

លើសពីនេះទៀត ក្នុងកិច្ចដំណើរការតាក់តែងកម្មវិធីជាតិក៏បានរៀបចំឱ្យមានកិច្ចពិភាក្សាដោយឡែកៗ ជាមួយក្រសួង ស្ថាប័នមួយចំនួនអំពីការផ្ទេរមុខងារ ធនធាន និងបុគ្គលិក។ កិច្ចប្រជុំជាមួយក្រសួង ស្ថាប័នសំខាន់ៗ ត្រូវបានធ្វើឡើងទាំងមុន និងក្រោយកិច្ចពិភាក្សា ក្នុងគោលបំណងកសាងនូវយុទ្ធសាស្ត្រដ៏លម្អិតសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យជាអាទិភាពបន្ថែមទៀត។

លទ្ធផលដែលទទួលបានពីការពិភាក្សាទាំងនេះ បានបង្កើតជាមូលដ្ឋានគ្រឹះមួយដ៏រឹងមាំសម្រាប់ការចាប់ផ្តើមអនុវត្តសកម្មភាពរៀបចំតាក់តែងកម្មវិធីជាតិនេះ។ ទិន្នន័យជាច្រើនទៀតត្រូវបានប្រមូលពីប្រភពនានា ដើម្បីពង្រីកបន្ថែមលើព័ត៌មានដែលទទួលបានពីកិច្ចពិភាក្សា។

---

[៨] របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំងប្រាំលើកនៅក្នុងដំណើរការតាក់តែងកម្មវិធីជាតិ មាននៅឧបសម្ព័ន្ធទី១។

### ១.៥.១. គោលការណ៍តម្រង់ទិស

កម្មវិធីជាតិនេះ ឆ្លុះបញ្ចាំងពីគោលការណ៍តម្រង់ទិសសំខាន់ៗមួយចំនួន ដែលដកស្រង់ចេញពីឯកសារគោលនយោបាយ ច្បាប់ និងយុទ្ធសាស្ត្រជាតិទាក់ទងនឹងការអភិវឌ្ឍជាទូទៅរបស់ជាតិ និងជាពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ គោលការណ៍តម្រង់ទិសទាំងនោះរួមមាន :

- ធានាសម្រេចឱ្យបាននូវគុណតម្លៃស្នូល និងគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដូចមានអធិប្បាយនៅក្នុងជំពូកទី២នៃកម្មវិធីជាតិនេះ
- ប្រុងប្រយ័ត្ននៅក្នុងដំណើរការនៃការរៀបចំតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការផ្ទេរមុខងារ និងធនធាន ដើម្បីធានាថាកំណែទម្រង់នេះ នឹងមិនបង្អាក់ដល់កិច្ចការរបស់ឃុំ សង្កាត់ ឬធ្វើសេចក្តីសម្រេចដែលប៉ះពាល់ដល់សិទ្ធិរបស់ឃុំ សង្កាត់
- ជំនះលើការលំបាកនាពេលបច្ចុប្បន្ន ដែលបង្កឡើងដោយសារការគ្រប់គ្រងដែលមានលក្ខណៈមជ្ឈការកន្លងមក
- ជំរុញឱ្យមានការកសាងសមត្ថភាពស្ថាប័ន និងធានាឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថនៃការបំពេញការងារ ដើម្បីឱ្យរចនាសម្ព័ន្ធរដ្ឋបាលថ្មី ប្រតិបត្តិ និងសម្រេចបាននូវលទ្ធផលតាមការរំពឹងទុក
- ធានាថា រាល់តម្រូវការជាបន្ទាន់របស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយ
- ធានាថា ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះ ដូចជាស្ត្រី កុមារ និងជនជាតិដើមភាគតិចជាដើម មានសិទ្ធិចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ជំរុញឱ្យមានភាពបត់បែន ដើម្បីសម្របសម្រួលតាមការវិវឌ្ឍនៃសង្គម សេដ្ឋកិច្ច និងនយោបាយ
- យកចិត្តទុកដាក់ឱ្យបានសមស្របក្នុងការបញ្ចូលនូវបញ្ហាបរិស្ថាននានា ជាពិសេសពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុទៅក្នុងសកម្មភាពទាំងឡាយរបស់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រូវផ្អែកលើក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- ជំរុញឱ្យមានកិច្ចសហការជិតស្និទ្ធរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

### ១.៥.២. ធាតុសំខាន់ៗនៃតារាងក្របខ័ណ្ឌតក្កភាព

កម្មវិធីជាតិប្រើប្រាស់នូវតារាងក្របខ័ណ្ឌតក្កភាព ដើម្បីជាមធ្យោបាយក្នុងការរៀបចំទិន្នន័យ ព្រមទាំងបង្ហាញពីលទ្ធផលរំពឹងទុក និងសកម្មភាពសំខាន់ៗ ។ តារាងក្របខ័ណ្ឌតក្កភាពនេះ មានធាតុសំខាន់ៗដូចខាងក្រោម :

- **គោលដៅ :** លទ្ធផលរួមនៃកម្មវិធីដែលរាជរដ្ឋាភិបាលរំពឹងថា នឹងសម្រេចបានពីការអនុវត្តកម្មវិធីជាតិ ។
- **គោលបំណង :** លទ្ធផលនៃកម្មវិធីដែលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅ ។
- **លទ្ធផលរំពឹងទុក :** លទ្ធផលនៃសមាសធាតុកម្មវិធីដែលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលបំណង ។

- **សកម្មភាពសំខាន់ៗ :** សកម្មភាពនានានៃសមាសធាតុកម្មវិធី ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុក។
- **សូចនាករ :**
  - **សូចនាករនៃផលប៉ះពាល់ :** ជាមធ្យោបាយសម្រាប់វាស់វែងពីផលប៉ះពាល់ជារួមនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទៅលើគោលដៅជាតិនានា។
  - **សូចនាករកម្មវិធី :** ជាមធ្យោបាយសម្រាប់វាស់វែងវឌ្ឍនភាពនៃការសម្រេចបាននូវចក្ខុវិស័យរបស់កម្មវិធីជាតិ។
- **ដំណាក់កាល :** ជារយៈពេលកំណត់ជាក់លាក់មួយ ដើម្បីសម្រេចឱ្យបាននូវចំណុចគោលដៅរំពឹងទុកនានា សំដៅសម្រេចបាននូវលទ្ធផលរួមរបស់កម្មវិធីជាតិ។

## ១.៦. ទម្រង់ និងភាពលំដាប់លំដោយនៃឯកសារកម្មវិធីជាតិ

កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានកំណត់អំពីគោលនយោបាយ និងកម្មវិធីចាំបាច់នានាដើម្បីអនុវត្តចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា កំណត់អំពីជំហាននានានៃការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងកំណត់អំពីការទទួលខុសត្រូវរបស់ គ.ជ.អ.ប ក្នុងការគ្រប់គ្រងកម្មវិធីជាតិ។

ជំពូកទី១ អធិប្បាយអំពីសាវតារដែលទាក់ទងនឹងរដ្ឋបាលដែនដី សេដ្ឋកិច្ចនៅកម្ពុជា សនិទានភាព និងបញ្ហាប្រឈមនានាដែលជំរុញឱ្យបន្តធ្វើកំណែទម្រង់។ ជំពូកនេះក៏អធិប្បាយផងដែរអំពីគោលនយោបាយនិងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ សមិទ្ធផលនៃកំណែទម្រង់ដែលសម្រេចបានកន្លងមក ព្រមទាំងបរិយាកាសដែលនាំឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រនៃកិច្ចដំណើរការតាក់តែងកម្មវិធីជាតិ និងគោលការណ៍តម្រង់ទិស។

ជំពូកទី២ អធិប្បាយអំពីចក្ខុវិស័យ និងការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជំពូកនេះក៏មានអធិប្បាយផងដែរអំពីវិធីសាស្ត្រជាទូទៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងទំនាក់ទំនងដ៏សមស្របរវាងការបង្កើតស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិដ៏រឹងមាំ និងគោលបំណងនានារបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ។

ជំពូកទី៣ អធិប្បាយលម្អិតអំពីសកម្មភាពចាំបាច់នានា ដើម្បីធ្វើស្ថាប័នភាវូបនីយកម្មនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបែងចែកជាសមាសធាតុកម្មវិធីចំនួន៥។ **សមាសធាតុកម្មវិធីទី១** បង្ហាញអំពីសកម្មភាពចាំបាច់នានាក្នុងការរៀបចំស្ថាប័ននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រងចាត់ចែងការងារប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈប្រជាធិបតេយ្យ។ **សមាសធាតុកម្មវិធីទី២** បង្ហាញអំពីបញ្ហាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ **សមាសធាតុកម្មវិធីទី៣** បង្ហាញអំពីជំហានចាំបាច់នានាក្នុងការផ្ទេរមុខងារ និងធនធាន ព្រមទាំងការលើកកម្ពស់ការផ្តល់សេវាសាធារណៈតាម

រយៈរដ្ឋបាលថ្នាក់ក្រោមជាតិ។ **សមាសធាតុកម្មវិធីទី៤** បង្ហាញអំពីប្រព័ន្ធហិរញ្ញវត្ថុ និងថវិកាដ៏ច្បាស់លាស់មួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ **សមាសធាតុកម្មវិធីទី៥** បង្ហាញអំពីការបង្កើតស្ថាប័នដែលចាំបាច់ សម្រាប់សម្របសម្រួលការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកែសម្រួលនូវស្ថាប័នដែលកំពុងមាននាពេលបច្ចុប្បន្ន ដើម្បីធានាថាស្ថាប័នទាំងនោះត្រូវមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយរចនាសម្ព័ន្ធរដ្ឋបាល ដែលត្រូវបានរៀបចំឡើងវិញតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ជំពូកទី៤ អធិប្បាយអំពីសកម្មភាពគ្រប់គ្រងចាំបាច់នានា ដើម្បីអនុវត្តកម្មវិធីជាតិដែលរួមមានរចនាសម្ព័ន្ធ និងវិធីសាស្ត្រគ្រប់គ្រងរបស់ គ.ជ.អ.ប ក្នុងការអនុវត្តនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ ព្រមទាំងទំនាក់ទំនងរវាងក្របខ័ណ្ឌតាមដាន និងវាយតម្លៃជាមួយនឹងសមាសធាតុកម្មវិធីទាំង៥ និងការវាយតម្លៃអំពីហានិភ័យ ដែលគូសបញ្ជាក់ពីផលប៉ះពាល់នានាបណ្ដាលមកពីការខកខានមិនបានដោះស្រាយនូវសកម្មភាព ឬជំហានសំខាន់ៗទាំងឡាយដែលបានចែងក្នុងកម្មវិធីជាតិរយៈពេល១០ឆ្នាំ។

ជំពូកទី៥ បង្ហាញពីបញ្ហាហិរញ្ញវត្ថុ រួមទាំងគោលការណ៍និងយន្តការនៃការផ្ដល់ហិរញ្ញប្បទាន កម្មវិធីប៉ាន់ស្មានរយៈពេល៣ឆ្នាំ និងការប៉ាន់ស្មានអំពីតម្រូវការធនធាន ដោយបង្ហាញអំពីតម្រូវការធនធានសម្រាប់ឆ្នាំ២០១០ និងតម្រូវការធនធានសម្រាប់រយៈពេល៣ឆ្នាំជាបន្តបន្ទាប់។

ឯកសារកម្មវិធីជាតិនេះ នឹងភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធរួមមាន :

- ឧបសម្ព័ន្ធទី១ : របាយការណ៍សង្ខេបស្ដីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំង៥លើក
- ឧបសម្ព័ន្ធទី២ : ការបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឧបសម្ព័ន្ធទី៣ : គណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ជំពូកទី២

# ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការអភិវឌ្ឍតាមបែប
# ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ជំពូកទី២
# ក្របខ័ណ្ឌយុទ្ធសាស្ត្រ
# នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលសម្រាប់នីតិកាលទីបួននៃរដ្ឋសភា(២០០៨-២០១៣) បាននិងកំពុងបន្តកំណែទម្រង់របស់ខ្លួនដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ក្នុងការផ្តល់និងការគ្រប់គ្រងសេវាសាធារណៈ ជាពិសេសការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ សំដៅឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងរួមចំណែកដល់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ដើម្បីការពារទ្រព្យសម្បត្តិសហគមន៍ គ្រប់គ្រងធនធានធម្មជាតិ ទប់ទល់ការប្រែប្រួលអាកាសធាតុ លើកកម្ពស់ការប្រើប្រាស់ជាតិកាបូនដែលមានកម្រិតទាប និងឆ្លើយតបតម្រូវការផ្នែកសង្គម និងសេដ្ឋកិច្ចរបស់បុគ្គល និងគ្រួសារនានាឱ្យបានកាន់តែប្រសើរឡើងថែមទៀត។ តាមរយៈមធ្យោបាយនេះ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងផ្តល់ឱកាសឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួមចំណែកកាន់តែច្រើនឡើង ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងការកាត់បន្ថយភាពក្រីក្រ។

## ២.១. ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ដើម្បីបន្តធ្វើឱ្យមានវឌ្ឍនភាពក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ចក្ខុវិស័យក្នុងការបង្កើត *"ប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដោយឈរលើគោលការណ៍នៃការចូលរួមតាមលក្ខណៈប្រជាធិបតេយ្យ ហើយត្រូវដំណើរការប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងដែនដីរបស់ខ្លួននីមួយៗ"*[៥] ។

ចក្ខុវិស័យ និងគោលបំណងទាំងឡាយនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ គឺដើម្បីបង្កើត លើកស្ទួយ និងទ្រទ្រង់ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយនិរន្តរភាព។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដែលមានចែងនៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់យ៉ាងច្បាស់អំពីការតម្រូវឱ្យរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈ (១)ភាពជាតំណាងសាធារណៈ (២)ស្វ័យភាពរបស់មូលដ្ឋាន (៣)ការពិគ្រោះយោបល់និងការចូលរួម (៤)ការឆ្លើយតបនិងគណនេយ្យភាព (៥)ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ

[៥] ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។

ក្នុងមូលដ្ឋាន (៦) ការលើកស្ទួយសមធម៌ (៧) តម្លាភាពនិងសុចរិតភាព និង (៨) វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានតួនាទី អំណាច និងធនធានសមស្រប។

ជោគជ័យនៃកំណែទម្រង់នេះអាស្រ័យជាសំខាន់ទៅលើគោលគំនិតដែលថា ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានរដ្ឋបាលឯកភាពមួយ។

ការរៀបចំឱ្យមានរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សបញ្ជាក់ឱ្យឃើញកាន់តែច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈក្នុងការប្រគល់តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ទៅឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់នៅក្នុងដែនសមត្ថកិច្ចនីមួយៗ (សកម្មភាពរដ្ឋបាលសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន) ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន។ ការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពគឺពាក់ព័ន្ធទៅនឹងការផ្ទេរនូវអំណាចក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗ ទៅឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ គោលការណ៍នេះតម្រូវឱ្យក្រសួង ស្ថាប័ននានាត្រូវពិនិត្យមើលឡើងវិញនូវមុខងារក្នុងការផ្តល់សេវាសាធារណៈ ដើម្បីផ្ទេរមុខងារដែលចាំបាច់ទៅឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ហើយត្រូវរៀបចំ និងកែសម្រួលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធក្រសួង ស្ថាប័ន និងវិស័យរបស់ខ្លួនឱ្យមានភាពស្របគ្នា ស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាឱ្យក្រុមប្រឹក្សានីមួយៗអាចទទួលខុសត្រូវពេញលេញក្នុងការផ្តល់សេវាសាធារណៈ និងការសម្របសម្រួលសកម្មភាពនានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ប្រព័ន្ធរបាយការណ៍ និងការតាមដាននូវខ្សែគណនេយ្យភាពរវាងក្រុមប្រឹក្សាជាមួយគណៈអភិបាល និងជាមួយក្រសួង ស្ថាប័ន និងមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នទាំងនោះគឺជាតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាក្នុងការធ្វើសេចក្តីសម្រេចនានា។

ចក្ខុវិស័យនេះជំរុញឱ្យការអនុវត្តសកម្មភាពនានានៅក្នុងដែនសមត្ថកិច្ចរបស់ថ្នាក់រដ្ឋបាលនីមួយៗ ធ្វើការឆ្លុះបញ្ចាំងអំពីល័ក្ខខ័ណ្ឌប្រជាសាស្ត្រ ភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ចរបស់មូលដ្ឋាននោះ។ ក្រុមប្រឹក្សានានាមានសិទ្ធិបញ្ចេញយោបល់តំណាងឱ្យប្រជាពលរដ្ឋរបស់ខ្លួន ក្នុងការកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។ ដំណើរការនេះ ទាមទារឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធសេវាសាធារណៈនានា ដោយប្រជាពលរដ្ឋមានសិទ្ធិតាមដានសកម្មភាពការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអាចទាមទារឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះរាល់ទង្វើរបស់ខ្លួនថែមទៀត។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាត្រូវទទួលបានធនធាននានា និងសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការបែងចែកធនធានទាំងនោះដល់បណ្តាវិស័យនានា។ ចក្ខុវិស័យនេះបង្កើតឡើងនូវរដ្ឋបាលដែលមានការឆ្លើយតប និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ។

## ២.២. ការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នឹងបង្ហាញឱ្យឃើញតាមរយៈគោលនយោបាយដូចខាងក្រោម :

១. ផ្តល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិអំណាចកាន់តែច្រើនឡើងតាមរយៈការប្រគល់មុខងារ ។

២. ធានាឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចលើការបែងចែកធនធាន ដែលមានលក្ខណៈអន្តរវិស័យ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ។

៣. ធានាឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការតាមដាន និងវាយតម្លៃទៅលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាជាប់ឆ្នោត និងមន្ត្រីរបស់ក្រុមប្រឹក្សា ព្រមទាំងគណៈអភិបាល ដើម្បីធានាថាក្រុមប្រឹក្សា និងមន្ត្រីទាំងនោះ មានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។ កំណត់ពីប្រភេទនានានៃគណនេយ្យភាព ដែលមានលក្ខណៈសមស្របសម្រាប់រចនាសម្ព័ន្ធរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កើតនូវយន្តការនានា ដើម្បីអនុវត្តប្រភេទនានានៃគណនេយ្យភាពទាំងនេះ ។

៤. ផ្ទេរមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ចឱ្យទៅក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមគោលការណ៍ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានចែងថា មុខងារត្រូវផ្ទេរដោយផ្អែកតាមគោលការណ៍ ដូចខាងក្រោម :

- ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- អាចគ្រប់គ្រង និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- បម្រើ ឬផ្តល់ផលប្រយោជន៍ជាចម្បងដល់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ
- មានផលប៉ះពាល់ជាចម្បងនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ ។

៥. បង្កើតយន្តការផ្តល់មូលនិធិមួយ ដែលផ្តល់ឱ្យក្រុមប្រឹក្សានូវសិទ្ធិអំណាចក្នុងការប្រើប្រាស់ប្រភពចំណូលមានភ្ជាប់ល័ក្ខខ័ណ្ឌ និងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌដែលពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចចាំបាច់ ហើយដែលធនធានផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌនឹងកើនឡើងជាបណ្តើរៗធៀបជាមួយនឹងធនធានផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ ។

៦. ពង្រឹងសិទ្ធិអំណាចក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន លើការកំណត់ប្រភេទចំណូលផ្ទាល់នានារបស់ខ្លួន និងឬអត្រាប្រមូលចំណូលផ្ទាល់ទាំងនោះនៅក្នុងចន្លោះអត្រាដែលកំណត់ដោយថ្នាក់ជាតិ ។

៧. ផ្ទេរការងារគ្រប់គ្រងបុគ្គលិកនៅថ្នាក់ក្រោមជាតិឱ្យទៅក្រុមប្រឹក្សា រួមទាំងសិទ្ធិអំណាចក្នុងការជ្រើសរើស ការដំឡើងថ្នាក់ ឋានន្តរសក្តិ ការតែងតាំង និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

៨. ជំរុញ និងលើកកម្ពស់តួនាទីស្ត្រីក្នុងដំណើរការអភិបាលកិច្ច និងធានាថា តម្រូវការជាអាទិភាពរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះនានានឹងទទួលបានធនធានសមស្របសម្រាប់គាំទ្រដល់តម្រូវការជាអាទិភាពទាំងនោះ ។

ដើម្បីអនុវត្តនូវគោលនយោបាយខាងលើ ចាំបាច់ត្រូវមានលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការសមស្រប នានារបស់ក្រសួង ស្ថាប័នក្នុងការគ្រប់គ្រង និងបែងចែកការទទួលខុសត្រូវ និងធនធាននានាដល់ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់។ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការទាំងនោះ ត្រូវតែស្របទៅតាមគោលបំណង និងគោលការណ៍នានានៃក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

## ២.៣. ក្របខ័ណ្ឌសម្រាប់ការអនុវត្តកម្មវិធីជាតិ

### ២.៣.១. គោលដៅ និងគោលបំណង

**គោលដៅកម្មវិធីជាតិ** គឺដើម្បីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួមនិងមានសមធម៌ លើកកម្ពស់បរិមាណ គុណភាព និងការទទួលបានសេវាសាធារណៈឱ្យមានភាពប្រសើរឡើង និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។

**គោលបំណងកម្មវិធីជាតិ** គឺដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យដែលធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាព សំដៅលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាននីមួយៗ។

អភិបាលកិច្ចល្អ ត្រូវបានកំណត់ជាស្នូលនៃការអភិវឌ្ឍ ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ព្រមទាំងការកាត់បន្ថយភាពក្រីក្រ ដោយផ្អែកតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តចំពោះការអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន ដើម្បីនាំប្រទេសជាតិទៅរកវិបុលភាព ដូចខាងក្រោម :

*"ការប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យនៅក្នុងអភិបាលកិច្ច ដែលប្រជាពលរដ្ឋកម្ពុជាគ្រប់រូប អាចធ្វើការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ដោយសេរី ដើម្បីដឹកនាំសង្គមជាតិនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រដ្ឋបាលគ្រប់លំដាប់ថ្នាក់ត្រូវមានការឆ្លើយតប ការទទួលខុសត្រូវ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងមានសមត្ថភាពអាចដឹងជាមុនបានយ៉ាងពេញលេញ។ រាជរដ្ឋាភិបាលត្រូវផ្តល់សេវាសង្គមសំខាន់ៗ សម្រាប់ការបង្កើត និងការលើកកម្ពស់មូលធនមនុស្ស (វិស័យសុខាភិបាល អប់រំ ការអភិវឌ្ឍវប្បធម៌ជាតិ) ហើយក្នុងន័យនេះ ត្រូវបង្កើតបរិស្ថានមួយដែលអាចឱ្យបុគ្គលគ្រប់រូប ធ្វើការស្វែងរកនិងធ្វើឱ្យសម្រេចនូវសក្តានុពលពេញលេញរបស់ពួកគេ និងធ្វើការរួមចំណែកលើកកម្ពស់សុខុមាលភាពផ្ទាល់ខ្លួនរបស់ពួកគេ និងការរីកចម្រើនរបស់ប្រទេសជាតិ"*[១០] ។

[១០] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។

រាជរដ្ឋាភិបាលទទួលស្គាល់ថា រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាថ្នាក់រដ្ឋបាលដ៏មានសារៈសំខាន់ដែលមានលទ្ធភាពចូលរួមជាមួយរាជរដ្ឋាភិបាលផ្តល់ការដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច និងបញ្ហាបរិស្ថាននានា ហេតុនេះ រាជរដ្ឋាភិបាលនឹងរៀបចំផ្ទេរការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាននានាឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលទាំងនោះអាចដោះស្រាយនូវបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ និងសហគមន៍មូលដ្ឋាននានានៅកម្ពុជា បាននិងកំពុងដោះស្រាយបញ្ហាប្រឈមនានាដែលកំពុងជួបប្រទះ។ ការបង្កើតឱ្យមានក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាការពង្រីកថ្នាក់រដ្ឋបាលដែលប្រជាពលរដ្ឋអាចចូលរួមដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាននានាជាមួយថ្នាក់រដ្ឋបាលទាំងនេះ។

ទោះជាយ៉ាងនេះក្តី ក៏បច្ចុប្បន្ននេះ និរន្តរភាពនៃការឆ្លើយតបក្នុងការដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែជាបញ្ហានៅឡើយ។ ការរៀបចំបង្កើតឱ្យមានតែគោលនយោបាយ និងការផ្ទេរធនធាន គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់សម្រាប់ការផ្តល់សេវាមូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាពនោះឡើយ។ បញ្ហានេះទាមទារឱ្យមានការរៀបចំជាបន្ថែមទៀតនូវប្រព័ន្ធ និងនីតិវិធីសម្រាប់ផ្តល់សេវាសាធារណៈដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដូច្នេះ ថ្នាក់ជាតិត្រូវរៀបចំឱ្យមានប្រព័ន្ធ និងនីតិវិធីនានាសម្រាប់ឱ្យមន្ត្រីប្រើប្រាស់សិទ្ធិអំណាច និងធនធាននានាដែលបានផ្ទេរឱ្យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងឆ្លើយតបទៅនឹងសេចក្តីរំពឹងទុករបស់រាជរដ្ឋាភិបាលកម្ពុជា។

ដើម្បីសម្រេចបានគោលដៅខាងលើ ចាំបាច់ត្រូវមានស្ថាប័នថ្នាក់ក្រោមជាតិដ៏រឹងមាំ ប្រកបដោយយុត្តិធម៌ និងបម្រើដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ដែលធានាថា :

- រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័ននានាយល់ដឹងពីសំណូមពររបស់ប្រជាពលរដ្ឋ
- ការធ្វើស្ថាប័នភាវូបនីយកម្មនៃកំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ដើម្បីដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋប្រកបដោយនិរន្តរភាព
- ប្រជាពលរដ្ឋមានតួនាទីសំខាន់ក្នុងការទាមទារឱ្យមន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពចំពោះខ្លួន
- ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពពេញលេញ ក្នុងការសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ តាមរយៈកិច្ចដំណើរការនេះ ក្រុមប្រឹក្សានឹងទទួលបាននូវការផ្តល់សិទ្ធិអំណាចជាបន្តបន្ទាប់ ក្នុងការសម្រេចលើការបែងចែកមូលនិធិសម្រាប់សកម្មភាពនៃវិស័យនីមួយៗ ព្រមទាំងសកម្មភាពអន្តរវិស័យនានា។

ក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិបានកំណត់ពីវិសាលភាព និងវិធីសាស្ត្រនៃកម្មវិធីនានា ដែលធានាសម្រេចឱ្យបាននូវការរំពឹងទុកទាំងនេះ។ ក្របខ័ណ្ឌនេះត្រូវបានរៀបចំតាក់តែងឡើងដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដូចមានអធិប្បាយក្នុងផ្នែក១.៤ ជំពូកទី១ ដែលបញ្ហាប្រឈមទាំងនេះអាចនឹងក្លាយទៅជាឧបសគ្គដល់កំណែទម្រង់ ប្រសិនបើពុំបានដោះស្រាយឱ្យបានសមស្រប។ ក្របខ័ណ្ឌនេះ ក៏ជាមូលដ្ឋានដើម្បីឱ្យដៃគូអភិវឌ្ឍន៍ប្រើប្រាស់កាន់តែច្រើននូវប្រព័ន្ធរបស់រាជរដ្ឋាភិបាល ដែលជាសារធាតុមួយដ៏សំខាន់នៃការបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រជាធិបតេយ្យ។

### ២.៣.២. វិសាលភាពនៃក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិ

ក្របខ័ណ្ឌអនុវត្តកម្មវិធីជាតិបានផ្តោតទៅលើគ្រប់ទិដ្ឋភាពនៃរចនាសម្ព័ន្ធ ប្រព័ន្ធ និងកិច្ចប្រតិបត្តិការនានារបស់រាជរដ្ឋាភិបាល ដែលនឹងរួមចំណែកដល់ការបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងប្រជាធិបតេយ្យ។ កម្មវិធីជាតិរយៈពេល១០ឆ្នាំបានកំណត់នូវសកម្មភាពសំខាន់ៗដែលត្រូវអនុវត្ត ដូចជាការរៀបចំសេចក្តីព្រាង និងការអនុម័តលិខិតបទដ្ឋានគតិយុត្តនានា ត្រូវស្របនឹងការប្តេជ្ញាចិត្តខាងគោលនយោបាយក្នុងការអនុវត្តកម្មវិធី ដើម្បីធានាថា ការប្តេជ្ញាចិត្តខាងគោលនយោបាយទទួលបានលទ្ធផលជោគជ័យតាមការរំពឹងទុក។

#### ក). ទំនាក់ទំនងទៅវិញទៅមកក្នុងកម្មវិធី

កម្មវិធីជាតិបានរៀបចំឱ្យមានសមាសធាតុកម្មវិធីចំនួន៥ ដែលមានទំនាក់ទំនងទៅវិញទៅមក ក្នុងការកសាងសមត្ថភាពស្ថាប័នដែលគាំទ្រ និងបង្កលក្ខណៈឱ្យសម្រេចបាននូវគោលដៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំនេះ គឺគូសបញ្ជាក់ពីលក្ខណៈដែលត្រូវអនុវត្តព្រមៗគ្នា និងមានភាពប្រទាក់ក្រឡាគ្នានៃប្រព័ន្ធ និងកិច្ចប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ពោលគឺមិនមែនមានគោលបំណងបញ្ជាក់អំពីភាពជាលំដាប់លំដោយនៃសកម្មភាពនានាក្នុងការគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនោះទេ។ សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ មានដូចខាងក្រោម :

- **សមាសធាតុកម្មវិធីទី១ : ការរៀបចំស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ដើម្បីធានាថា ហេដ្ឋារចនាសម្ព័ន្ធស្ថាប័នជាមូលដ្ឋានត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលដល់ការធ្វើសេចក្តីសម្រេច និងការបែងចែកសិទ្ធិអំណាចនៅក្នុងចំណោមថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដើម្បីសម្របសម្រួលការធ្វើស្ថាប័នភាវូបនីយកម្មយន្តការនានា សំដៅធានាឱ្យដំណើរការអនុវត្តស្របតាមគោលការណ៍ប្រជាធិបតេយ្យ នីតិរដ្ឋ និងធានាការពារបាននូវសិទ្ធិរបស់ប្រជាពលរដ្ឋ។
- **សមាសធាតុកម្មវិធីទី២ : ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស** នឹងធ្វើឱ្យមានការកែសម្រួលការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងបុគ្គលិកនៅថ្នាក់ក្រោមជាតិ។ ការសម្រេចបាននូវលទ្ធផលនានាដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីនេះ ធ្វើឱ្យមានការផ្លាស់ប្តូរប្រព័ន្ធលើកទឹកចិត្តក្នុងការបំពេញការងាររបស់មន្ត្រីរាជការស៊ីវិល ពីអ្នកដែលបំពេញការងារឱ្យគ្រាន់តែបានចប់តាមការកំណត់ ទៅជាអ្នកដែលបម្រើសេវាជូនប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ ការគ្រប់គ្រងបុគ្គលិកតាមទស្សនទាននេះ នឹងជួយដល់ការលើកកម្ពស់គណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈនានា។
- **សមាសធាតុកម្មវិធីទី៣ : ការផ្ទេរមុខងារ** គឺជាស្នូលនៃកំណែទម្រង់ទាំងមូល ពីព្រោះសមាសធាតុកម្មវិធីនេះបានកំណត់អំពី (ក) ការទទួលខុសត្រូវ និងសិទ្ធិអំណាចដែលត្រូវអនុវត្តតាមរយៈរចនាសម្ព័ន្ធស្ថាប័នដែលបានបង្កើតឡើងក្នុងសមាសធាតុកម្មវិធីទី១ និង (ខ) ធនធាននានាដែលត្រូវគ្រប់គ្រង ចាត់ចែង ផ្អែកតាមប្រព័ន្ធ និងនីតិវិធីប្រតិបត្តិការនានាដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទី១ ទី២ និងទី៤។

- **សមាសធាតុកម្មវិធីទី៤ : ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនានា** នឹងចូលរួមចំណែកក្នុងការរៀបចំកម្មវិធីជាតិលើទិដ្ឋភាពពីរ : ទីមួយ គឺការបង្កើតប្រព័ន្ធហិរញ្ញវត្ថុ និងក្របខ័ណ្ឌប្រតិបត្តិការដែលចាំបាច់សម្រាប់ការគ្រប់គ្រងធនធានហិរញ្ញវត្ថុទាំងឡាយ (ឧទាហរណ៍ : ចំណូល និងទ្រព្យសម្បត្តិ) និងទីពីរ គឺការកំណត់យន្តការនានាក្នុងការផ្តល់ហិរញ្ញប្បទាន សម្រាប់សកម្មភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- **សមាសធាតុកម្មវិធីទី៥ : ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** គឺដើម្បីធានាឱ្យមានការរៀបចំស្ថាប័នដែលចាំបាច់ និងបេសកកម្មនានារបស់ស្ថាប័ន ដើម្បីជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងបង្កលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង និងចាត់ចែងការងារប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។

## ខ). កម្មវិធីអន្តរវិស័យ

ប្រធានបទចំនួនបីដែលមានលក្ខណៈអន្តរវិស័យ គឺ**ការបញ្ជ្រាបយេនឌ័រ ការប្រែប្រួលអាកាសធាតុ** និង**គណនេយ្យភាព** ត្រូវបានដាក់បញ្ចូលទៅក្នុងសមាសធាតុកម្មវិធីទាំង៥។

### ខ.១). ការបញ្ជ្រាបយេនឌ័រ

ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីជាតិ គឺជាការខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាពិសេសតួនាទីក្នុងការធ្វើសេចក្តីសម្រេច នៅក្នុងគ្រប់ផ្នែកនៃអភិបាលកិច្ច និងការធ្វើឱ្យស្ត្រីទទួលបានសេវាសាធារណៈផ្សេងៗកាន់តែប្រសើរឡើង។ កម្មវិធីជាតិបានផ្តល់នូវចំណុចចាប់ផ្តើម និងកាលានុវត្តភាពដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំ សំដៅបង្កើនកាលានុវត្តភាព និងភាពអង់អាចដល់ស្ត្រី និងធានាថាសេវាសាធារណៈទាំងអស់ដែលជាតម្រូវការរបស់ស្ត្រីត្រូវបានឆ្លើយតប។ សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីនៃកម្មវិធីជាតិ នឹងបង្កើនលទ្ធភាពដល់ស្ត្រី និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត ក្នុងការទទួលបាននូវសេវាសាធារណៈ ព្រមទាំងបង្កើនការគ្រប់គ្រង ធនធានអភិវឌ្ឍន៍សម្រាប់លើកកម្ពស់ជីវភាពរស់នៅ។ សកម្មភាពជាក់លាក់ពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ មានអធិប្បាយនៅឧបសម្ព័ន្ធទី២។

### ខ.២). ការប្រែប្រួលអាកាសធាតុ

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា មិនអាចប៉ាន់ស្មានបាននោះឡើយ ហេតុនេះទាមទារឱ្យរដ្ឋបាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ត្រូវយកចិត្តទុកដាក់ក្នុងការឆ្លើយតបចំពោះការគំរាមកំហែងដែលមានលក្ខណៈជាសាកលនេះចំពោះអាយុជីវិត ជីវភាពរស់នៅ និងប្រព័ន្ធគាំទ្រជីវិតនានា។ ដូច្នេះ ទាមទារឱ្យមានការអនុម័តជាបន្ទាន់នូវវិធានការនានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ជាតិកាបូនកម្រិតទាប ហើយក្នុងពេលជាមួយគ្នានេះដែរ ត្រូវរៀបចំដើម្បីការពារចំពោះហានិភ័យថ្មីៗផ្នែកអាកាសធាតុដែលគំរាមកំហែងដល់ប្រទេសកម្ពុជា។ កម្មវិធីជាតិ

ផ្តល់នូវចំណុចចាប់ផ្តើមមួយដ៏សំខាន់ក្នុងការបង្កើត "ប្រព័ន្ធសម្របសម្រួល"ថ្នាក់ជាតិមួយ ដែលគាំទ្រដល់សង្គមក្នុងរយៈពេលវែង និងដំណើរការសម្របសម្រួលជាមួយនឹងការប្រែប្រួលអាកាសធាតុ ។

## ខ.៣). គណនេយ្យភាព និងការការពារក្រុមជនក្រីក្រ និងក្រុមជនងាយរងគ្រោះ

កម្មវិធីជាតិនឹងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានតម្លាភាព ដែលអាចឱ្យសាធារណជនអាចសង្កេត និងចូលរួមក្នុងសកម្មភាពនានា។ ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងកម្មវិធីជាតិទាមទារឱ្យមានការបង្កើតនូវខ្សែគណនេយ្យភាពថ្មីនានា ការលើកកម្ពស់ការយល់ដឹង និងការបង្កើតប្រព័ន្ធ នីតិវិធី និងយន្តការទាំងឡាយ ដើម្បីធានាថា សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារ សំឡេងរបស់ប្រជាពលរដ្ឋត្រូវបានដឹងឮ និងធនធាននានាត្រូវបានប្រើប្រាស់ស្របតាមច្បាប់ ។

ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ក្នុងការទទួលបាននូវព័ត៌មានអំពីការធ្វើសេចក្តីសម្រេច និងការចាត់វិធានការនានារបស់ក្រុមប្រឹក្សា។ ជាមួយគ្នានេះដែរ ត្រូវរៀបចំនូវយន្តការនានាដើម្បីផ្តល់នូវមធ្យោបាយសមស្របដល់ប្រជាពលរដ្ឋក្នុងការវាយតម្លៃសកម្មភាពនានារបស់ក្រុមប្រឹក្សា និងដើម្បីឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះទង្វើរបស់ខ្លួនដែលអនុវត្តមិនបានសមស្រប ។ ដូច្នេះ វិធីសាស្រ្តដែលធ្វើឱ្យសម្រេចនូវគណនេយ្យភាពត្រូវតែដាក់បញ្ចូលទៅក្នុងគ្រប់ផ្នែកទាំងអស់នៃកំណែទម្រង់របស់រាជរដ្ឋាភិបាល ព្រមទាំងទៅក្នុងដំណើរការខាងបញ្ញត្តិ និងក្នុងដំណើរការរដ្ឋបាល ។

ដើម្បីធានាសម្រេចឱ្យបាននូវគណនេយ្យភាពដោយរដ្ឋបាលថ្នាក់ក្រោមជាតិ គឺត្រូវអនុវត្តតាមវិធានការមួយចំនួន នៅតាមសមាសធាតុកម្មវិធីនីមួយៗនៃកម្មវិធីជាតិ ដូចខាងក្រោម :

- បញ្ជាក់ឱ្យបានច្បាស់ពីគោលដៅ និងគោលបំណងនានានៃគណនេយ្យភាព
- ពិនិត្យឡើងវិញនូវយន្តការគណនេយ្យភាពដែលមានស្រាប់ និងអនុវត្តសាកល្បងនូវយន្តការថ្មីនានា ដើម្បីពិនិត្យមើលលទ្ធភាពក្នុងការសម្រេចនូវគោលដៅ និងគោលបំណងនានានៃគណនេយ្យភាពរបស់រដ្ឋបាលនានា ដើម្បីជាមូលដ្ឋានសម្រាប់បង្កើតនូវសេចក្តីណែនាំ និងនីតិវិធីប្រតិបត្តិការនានា
- ត្រូវរៀបចំឱ្យមានលិខិតបទដ្ឋានគតិយុត្តនានាស្តីពីការដាក់ពិន័យ ដូចមានចែងក្នុងមាត្រានានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលពាក់ព័ន្ធនឹងការពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើឱ្យប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ពិតប្រាកដក្នុងការទទួលបានព័ត៌មាន
- ចាត់វិធានការសមស្របនានា ក្នុងការលើកកម្ពស់ការយល់ដឹងរបស់សង្គមស៊ីវិលអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ពង្រឹងយន្តការនានាសម្រាប់ការតវ៉ារបស់ប្រជាពលរដ្ឋ នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានរំលោភសិទ្ធិរបស់ពួកគាត់ ។

យន្តការគណនេយ្យភាពទាំងឡាយដែលធ្វើស្ថាប័នភាវូបនីយកម្មគណនេយ្យភាពផ្នែកច្បាប់ ហិរញ្ញវត្ថុ និងរដ្ឋបាល និងដែលធានាដល់ការការពារសិទ្ធិ និងសំឡេងរបស់ប្រជាពលរដ្ឋ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ត្រូវអនុវត្តតាមខ្សែគណនេយ្យភាពជាក់លាក់[១១] ។

កម្មវិធីជាតិបានកំណត់ឱ្យមានខ្សែគណនេយ្យភាពចំនួនបួន ដូចខាងក្រោម :

១. **គណនេយ្យភាពផ្ទៃក្នុង** សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

២. **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។

៣. **គណនេយ្យភាពអន្តររដ្ឋបាល** សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ** សំដៅទៅលើខ្សែគណនេយ្យភាពផ្នែកនយោបាយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

សមាសធាតុកម្មវិធីនីមួយៗអាចមានការពាក់ព័ន្ធនឹងខ្សែគណនេយ្យភាពមួយ ឬច្រើន។

**សមាសធាតុកម្មវិធីទី១** គឺជាសមាសធាតុសំខាន់ដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តខ្សែគណនេយ្យភាពទាំងបួន ដូចខាងក្រោម :

- **គណនេយ្យភាពផ្ទៃក្នុង** នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតនូវប្រព័ន្ធរដ្ឋបាលដោយផ្អែកលើវិធាននៃច្បាប់ និងតម្រូវការរបាយការណ៍
- **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតអង្គភាពគាំទ្រឃុំ សង្កាត់របស់ថ្នាក់ស្រុក និងប្រព័ន្ធរបាយការណ៍រវាងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- **គណនេយ្យភាពអន្តររដ្ឋបាល** នឹងបង្ហាញឱ្យឃើញតាមរយៈការសម្របសម្រួលខ្សែទទឹងរវាងមន្ទីរការិយាល័យ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌនៃរដ្ឋបាលឯកភាព
- **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ** នឹងបង្ហាញឱ្យឃើញតាមរយៈ (១) ការអង្កេតពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈនានា (២) ការប្រើប្រាស់ព័ត៌មានវិទ្យាដើម្បីជួយឱ្យប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មាន និងសេវាសាធារណៈនានា (៣) គោលការណ៍ណែនាំ សេចក្តីណែនាំ និងឧបករណ៍នានាសម្រាប់ការចូលរួម ការទទួលបាននូវព័ត៌មាន និងការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ (៤) ការបង្កើតនូវកម្មវិធី និងយន្តការនានាសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។

**សមាសធាតុកម្មវិធីទី២** គណនេយ្យភាពផ្ទៃក្នុងនឹងត្រូវអនុវត្តតាមរយៈតួនាទីជាក់លាក់ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងទំនាក់ទំនងរបស់មន្ត្រីជាមួយ

[១១] ការវិភាគអំពីក្របខ័ណ្ឌគតិយុត្ត និងយន្តការគណនេយ្យភាព មាននៅក្នុងឧបសម្ព័ន្ធទី៣។

សហគមន៍ប្រជាពលរដ្ឋ។ គណនេយ្យភាពអន្តររដ្ឋបាលនឹងត្រូវស្តែងឡើងតាមរយៈការរៀបចំបុគ្គលិកឡើងវិញរបស់ក្រសួង ស្ថាប័នជាមួយនឹងការផ្ទេរមុខងារ និងធនធាន។

**សមាសធាតុកម្មវិធីទី៣** គណនេយ្យភាពអន្តររដ្ឋបាលនឹងត្រូវស្តែងឡើងតាមរយៈបែបផែននៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (រួមមានធនធាន និងបុគ្គលិកដើម្បីធានាថាពុំមានការរំខានដល់ការផ្តល់សេវាសាធារណៈ) និងតាមរយៈយន្តការនៃការតាមដាន និងពិនិត្យមើលឡើងវិញនូវការអនុវត្តមុខងារដែលបានផ្ទេរឱ្យ។ គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ នឹងត្រូវស្តែងឡើងតាមរយៈការលើកកម្ពស់ទាំងបរិមាណ និងគុណភាពសេវាសាធារណៈដែលបានផ្តល់ទៅដល់ប្រជាពលរដ្ឋ ប៉ុន្តែនៅក្នុងពេលបណ្តោះអាសន្ន ត្រូវរៀបចំនូវវិធានការជាក់លាក់នានា ដើម្បីលើកកម្ពស់គណនេយ្យភាពស្របតាមប្រភេទសេវាសាធារណៈផ្សេងៗ និងមុខងារផ្សេងទៀតដែលចាំបាច់ដើម្បីអនុវត្តសាកល្បង និងវាយតម្លៃអំពីប្រសិទ្ធភាពនៃមុខងារទាំងនោះធៀបនឹងគោលដៅ និងគោលបំណងនានារបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទី៣នេះ។ ជាងនេះទៀត គណនេយ្យភាពចំពោះប្រជាពលរដ្ឋអាចលើកកម្ពស់តាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ និងការទទួលបានជាសាធារណៈនូវព័ត៌មានអំពីការបំពេញមុខងារ និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមរយៈការសាកល្បងអំពីវិធីសាស្ត្រផ្សេងៗក្នុងការលើកកម្ពស់គណនេយ្យភាព និងការតាមដានទៅលើប្រសិទ្ធភាពនៃការអនុវត្តនៃវិធីសាស្ត្រទាំងនេះ។

**សមាសធាតុកម្មវិធីទី៤** គឺជាសមាសធាតុសំខាន់មួយទៀតដែលមានការពាក់ព័ន្ធទៅនឹងការអនុវត្តខ្សែគណនេយ្យភាពទាំងបួន ដូចខាងក្រោម :

- **គណនេយ្យភាពផ្ទៃក្នុង** នឹងស្តែងឡើងតាមរយៈការធ្វើសវនកម្មផ្ទៃក្នុង ទំនាក់ទំនង និងរបៀបរបបធ្វើការងាររវាងក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពនានារបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការអនុវត្តថវិកា។
- **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** នឹងស្តែងឡើងតាមរយៈការចែករំលែកចំណូលរវាងស្រុក និងឃុំ សង្កាត់នៅក្នុងស្រុក។
- **គណនេយ្យភាពអន្តររដ្ឋបាល** នឹងស្តែងឡើងតាមរយៈការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ទៅលើការអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ** នឹងស្តែងឡើងតាមរយៈការរៀបចំការសម្រេច និងការអនុវត្តថវិកា និងតាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងកិច្ចការថវិកា ការវិនិយោគ និងការអភិវឌ្ឍនានា ព្រមទាំងតាមរយៈការអនុវត្តសាកល្បងនូវយន្តការនានាដែលពាក់ព័ន្ធនឹងសវនកម្មផ្នែកសង្គមកិច្ច និងការផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋ ឬក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចូលរួមផ្តល់យោបល់លើគម្រោងថវិកានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទផ្សេងទៀត។

**សមាសធាតុកម្មវិធីទី៥** គឺជាការបង្កើតនូវយន្តការមួយសម្រាប់ធ្វើការសម្របសម្រួលកិច្ចការរដ្ឋបាល និងដោះស្រាយវិវាទ ដើម្បីធានាឱ្យមានមធ្យោបាយសម្រាប់ពង្រឹងដំណើរការនានានៃគណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ពាក់ព័ន្ធនឹងបញ្ហានេះ រួមមានយន្តការជាក់លាក់នានាសម្រាប់ឱ្យក្រុមប្រឹក្សាមានគណនេយ្យភាព ដើម្បីធានាថាស្ត្រី ក្រុមជនងាយរងគ្រោះ និងក្រុមជនក្រីក្រមានលទ្ធភាពទទួលបាននូវសេវាសាធារណៈនានាប្រកបដោយសមធម៌។

## ២.៤. សន្និទានភាពនៃការរៀបចំកម្មវិធីជាតិ

ក្រោមក្របខ័ណ្ឌនៃកំណែទម្រង់ទាំងនេះ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលខុសត្រូវក្នុងការអភិវឌ្ឍ ការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈប្រកបដោយនិរន្តរភាពនៅក្នុងមូលដ្ឋានរបស់ខ្លួនកាន់តែច្រើនឡើង។

ក្នុងពេលដែលមុខងារត្រូវបានផ្ទេរ ក្រុមប្រឹក្សាត្រូវបញ្ចូលអាទិភាពអភិវឌ្ឍន៍នានា ដែលបានលើកឡើងដោយប្រជាពលរដ្ឋ និងដែលជាតម្រូវការរបស់ថ្នាក់ជាតិ ទៅជាកិច្ចប្រតិបត្តិការជាប្រចាំ ហើយត្រូវប្រើប្រាស់សិទ្ធិអំណាច និងធនធានរបស់ខ្លួន ដើម្បីធានាដល់ការវិនិយោគ និងនិរន្តរភាពដល់ការលើកកម្ពស់គុណភាពនិងបរិមាណនៃការផ្តល់សេវាសាធារណៈ។ កិច្ចការនេះតម្រូវឱ្យមានការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធស្ថាប័នចាំបាច់នានា ដូចមានអធិប្បាយនៅក្នុងសមាសធាតុកម្មវិធីទាំង៥។

ប្រសិនបើគ្មានហេដ្ឋារចនាសម្ព័ន្ធស្ថាប័នចាំបាច់នានាទេនោះ ក្រុមប្រឹក្សានឹងមិនអាចមានលទ្ធភាពបំពេញការងារដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពបានឡើយ ហើយប្រជាពលរដ្ឋក៏មិនអាចមានលទ្ធភាពទាមទារឱ្យក្រុមប្រឹក្សាមានគណនេយ្យភាពចំពោះខ្លួនបានដែរ។

លើសពីនេះទៀត ប្រសិនបើគ្មានហេដ្ឋារចនាសម្ព័ន្ធស្ថាប័ននានាទេនោះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនឹងមិនអាចចូលរួមចំណែកសម្រេចបាននូវគោលដៅរបស់ជាតិក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការកាត់បន្ថយភាពក្រីក្របានឡើយ។

## ២.៥. ការអភិវឌ្ឍសមត្ថភាព

ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងស្ថាប័នដែលចាំបាច់សម្រាប់ធានាដល់ការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ គឺជាសមាសធាតុស្នូលដ៏សំខាន់មួយនៃកម្មវិធីជាតិ។ វិសាលភាពការងារនេះ ទាមទារឱ្យមានការប្រើប្រាស់វិធីសាស្ត្រជាច្រើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការដ៏ធំធេងសម្រាប់ការអភិវឌ្ឍសមត្ថភាព។

ដើម្បីសម្រេចបាននូវគោលបំណងនៃកម្មវិធីជាតិ ការអភិវឌ្ឍសមត្ថភាព គឺសំដៅទៅលើការគាំទ្របច្ចេកទេសកាលានុវត្តភាពនៃការសិក្សារៀនសូត្រ និងតម្រូវការព័ត៌មាន ទិន្នន័យ សម្ភារៈបរិក្ខារ ប្រព័ន្ធ និងនីតិវិធីនានា ដែលបង្ក

លក្ខណៈឱ្យបុគ្គលិក និងស្ថាប័ននានាអាចសម្រេចបាននូវលទ្ធផលទាំងឡាយនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ ការអភិវឌ្ឍសមត្ថភាព គឺជាបុរេល័ក្ខខ័ណ្ឌក្នុងការផ្តល់លទ្ធភាពឱ្យបុគ្គលិក និងស្ថាប័ននានាអាចមានសមត្ថភាពបំពេញការងារបច្ចេកទេស ការងារគ្រប់គ្រង ឬការងាររដ្ឋបាលដោយខ្លួនឯងផ្ទាល់។

ផែនការអភិវឌ្ឍន៍សមត្ថភាព ត្រូវរៀបចំឡើងដើម្បីដោះស្រាយតម្រូវការចាំបាច់ និងបន្ទាន់របស់បុគ្គលិក និងស្ថាប័ននានាក្នុងការអនុវត្តនូវការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ខ្លួននៅតាមថ្នាក់រដ្ឋបាលនីមួយៗ។ ផែនការអភិវឌ្ឍន៍សមត្ថភាពត្រូវរៀបចំឡើងដើម្បីឱ្យស្ថាប័ននានា មានលទ្ធភាពអភិវឌ្ឍស្ថាប័ន និងកសាងសមត្ថភាពបុគ្គលិករបស់ខ្លួន។ ដូចនេះ ផែនការអភិវឌ្ឍន៍សមត្ថភាពមានការពាក់ព័ន្ធទៅនឹងលទ្ធផលទាំងឡាយនៃសមាសធាតុកម្មវិធីទាំងអស់របស់កម្មវិធីជាតិ។ ផែនការអភិវឌ្ឍន៍សមត្ថភាពនេះនឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងឆមាសទី១ឆ្នាំ២០១០។

កម្មវិធីជាតិបរិយាយអំពីការរៀបចំនានាពាក់ព័ន្ធនឹងការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពដូចខាងក្រោម :

១. លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវពិនិត្យមើល និងតាមដានការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពដែលបានកំណត់នៅក្នុងឯកសារផែនការ។ ឯកសារផែនការនេះអធិប្បាយពីវិធីសាស្ត្រដែលត្រូវអនុវត្តសម្រាប់ការផ្តល់ជំនួយបច្ចេកទេស ការបណ្តុះបណ្តាល ការបង្កើតកម្មវិធីសាកល្បង ការគ្រប់គ្រង ការអភិវឌ្ឍសមត្ថភាព និងបញ្ជីបរិយាយលម្អិតអំពីសមត្ថភាពចាំបាច់នានា ដែលជាតម្រូវការរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងលទ្ធផលរំពឹងទុកនានានៃកម្មវិធីជាតិដែលបានកំណត់នៅក្នុងជំពូកទី៣។

២. ជំនួយបច្ចេកទេសត្រូវបានផ្តល់ដល់ស្ថាប័ន ដែលមានភារកិច្ចក្នុងការកសាងសមត្ថភាពរបស់បុគ្គល និងស្ថាប័នដូចជាសាលាភូមិន្ទរដ្ឋបាល សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងមហាផ្ទៃជាដើម។ លទ្ធផលរំពឹងទុកនានានៃការកសាងសមត្ថភាពស្ថាប័នមានអធិប្បាយនៅក្នុងសមាសធាតុកម្មវិធីទី៥។ នៅក្នុងដំណាក់កាលទី២ ស្ថាប័នទាំងនេះនឹងមានការទទួលខុសត្រូវកាន់តែច្រើនឡើងក្នុងការកំណត់ និងកសាងសមត្ថភាពបុគ្គលិក និងស្ថាប័ននានា។

៣. ក្នុងពេលវេលាមួយសមស្រប រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលខុសត្រូវក្នុងការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័នរបស់ខ្លួន។ ការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័ន គឺជាតួនាទីចម្បងរបស់ស្ថាប័ននានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សមាសធាតុកម្មវិធីទី២ មានគូសបញ្ជាក់ពីលទ្ធផលរំពឹងទុកនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវនេះ។ នៅក្នុងដំណាក់កាលទី២ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ពីតម្រូវការ និងធានាឱ្យមានធនធាននានាសម្រាប់ការកសាងសមត្ថភាព។

៤. មូលនិធិចាំបាច់សម្រាប់តម្រូវការផ្នែកមូលធន និងសម្ភារៈបរិក្ខារ ត្រូវបានផ្តល់ដើម្បីធានាដល់កិច្ចប្រតិបត្តិការនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើបញ្ជីសារពើភ័ណ្ឌអំពីមូលធន និងសម្ភារៈបរិក្ខាររបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងកំណត់បានពីតម្រូវការរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២.៦. ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន

ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន ការផ្តល់សេវាសាធារណៈនានាត្រូវតែមានលក្ខណៈជឿទុកចិត្តបាន ងាយស្រួលទទួលយក និងព្យាករណ៍បាន ហើយដែលប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពទទួលបាននូវសេវាសាធារណៈទាំងនោះស័ក្តិសមនឹងសមត្ថភាពរបស់ខ្លួនដើម្បីបង្កើនលទ្ធភាពអនុវត្តសកម្មភាពរកប្រាក់ចំណូល។ ការគិតគូរអំពីផលប្រយោជន៍នៃការអភិវឌ្ឍរបស់បុគ្គល និងអ្នកវិនិយោគឯកជនតែងតែមានគោលបំណងផ្សេងៗគ្នា ដែលទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគិតគូរដោះស្រាយ តាមរយៈដំណើរការរៀបចំផែនការ រៀបចំវិភាជន៍ថវិកា និងកំណត់វិធានដើម្បីកែលម្អលទ្ធភាពទទួលបានសេវាសាធារណៈ។

កម្មវិធីជាតិបង្ហាញអំពីមធ្យោបាយនានាដើម្បីសម្រេចបាននូវកិច្ចការខាងលើនេះ ហេតុនេះរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតែទទួលបាននូវសិទ្ធិអំណាចក្នុងការជ្រើសរើសជម្រើស ដែលមានលក្ខណៈល្អបំផុតសម្រាប់ខ្លួន។ ជាមួយគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែយកចិត្តទុកដាក់ពិចារណាទៅលើភាពជឿទុកចិត្តបាន ភាពងាយស្រួលទទួលយក និងភាពអាចព្យាករណ៍បាននៃការផ្តល់សេវាសាធារណៈទាំងនេះ ព្រមទាំងត្រូវមានជំនាញ មានប្រព័ន្ធ និងមានចំណេះដឹង ដើម្បីគ្រប់គ្រងលើធនធាន ដែលខ្លួនមានសិទ្ធិប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។

កម្មវិធីជាតិ ក៏គួសបញ្ជាក់អំពីវិធីសាស្រ្តនានាសម្រាប់លើកកម្ពស់ភាពជឿទុកចិត្តបាន ភាពងាយស្រួលទទួលយក និងភាពអាចព្យាករណ៍បាននៃការផ្តល់សេវាសាធារណៈ តាមរយៈការផ្ទេរមុខងារ និងតាមរយៈការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើការងារជាមួយសហគមន៍ និងមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នដើម្បីកំណត់គោលដៅសំខាន់ៗ និងផែនការសកម្មភាពក្នុងការលើកកម្ពស់ការផ្តល់ សេវាសាធារណៈ។ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់ទៅលើមុខងារទាំងឡាយណាដែលរដ្ឋបាលថ្នាក់ក្រោមជាតិ មានលទ្ធភាពអនុវត្តបានប្រកបដោយប្រសិទ្ធភាព នៅក្នុងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចក្នុងការរៀបចំ គ្រប់គ្រង ចាត់ចែងសេវា សាធារណៈនិងធនធានទាំងឡាយពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនានា។

## ២.៧. រយៈពេល និងលទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ

កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងក្នុងទម្រង់ជាតារាងក្របខ័ណ្ឌតក្កភាពមួយ និងកំណត់អំពីលទ្ធផលរំពឹងទុកនានាតាមដំណាក់កាលនីមួយៗដែលត្រូវអនុវត្តពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩។

រយៈពេលនៃដំណាក់កាលនីមួយៗ ត្រូវបានកំណត់ និងមានលក្ខណៈសមស្របទៅនឹងការអនុម័ត និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹង :

- ការផ្ទេរមុខងារ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិមូលដ្ឋាន ព្រមទាំងបុគ្គលិកចាំបាច់សម្រាប់បង្កើតរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការផ្តល់សេវាសាធារណៈសម្រាប់ប្រជាពលរដ្ឋក្រីក្រ ព្រមទាំងមានធនធាន និងសិទ្ធិអំណាចនានាពាក់ព័ន្ធនឹងការទទួលខុសត្រូវនោះ។

- ការសម្រេចឱ្យបាននូវគណនេយ្យភាពប្រកបដោយប្រសិទ្ធភាព និងពេញលេញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសពាក់ព័ន្ធនឹងគណនេយ្យភាពរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

ដំណាក់កាលនីមួយៗនឹងកំណត់នូវមូលដ្ឋានគ្រឹះសម្រាប់ការអនុវត្តសកម្មភាពនានា ដើម្បីរួមចំណែកសម្រេចបាននូវលទ្ធផលរំពឹងទុក។ រយៈពេលនៃដំណាក់កាលនីមួយៗ ឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃការអនុវត្តជាក់ស្តែងនូវកម្មវិធីកំណែទម្រង់ដ៏ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយពិចារណាលើរយៈពេលដែលត្រូវប្រើប្រាស់សម្រាប់ការកែតម្រូវ និងការសម្របសម្រួលនានាពាក់ព័ន្ធនឹងការផ្លាស់ប្តូរបុគ្គលិក និងស្ថាប័ន។ កម្មវិធីជាតិរយៈពេល១០ឆ្នាំចែកចេញជាបីដំណាក់កាល គឺដំណាក់កាលទីមួយមានរយៈពេល៣ឆ្នាំ ដំណាក់កាលទីពីរមានរយៈពេល៣ឆ្នាំ និងដំណាក់កាលទីបីមានរយៈពេល៤ឆ្នាំ(៣-៣-៤)។ ការកំណត់រយៈពេលតាមដំណាក់កាលនីមួយៗបែបនេះ នឹងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់អនុញ្ញាតឱ្យមានការសិក្សាវាយតម្លៃច្បាស់លាស់ទៅលើកិច្ចខិតខំប្រឹងប្រែងនៃកំណែទម្រង់ និងការកែតម្រូវតាមការចាំបាច់នានា។ ម្យ៉ាងទៀត វដ្តនៃផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបានបញ្ចូលទៅក្នុងដំណាក់កាលនីមួយៗ ហើយដំណាក់កាលទី១ និងទី២ ក៏មានរយៈពេលសមស្របជាមួយនឹងអាណត្តិទី១នៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផងដែរ។ ការតាមដាន និងវាយតម្លៃទៅលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិមានអធិប្បាយនៅក្នុងផ្នែកទី៤.២ ជំពូកទី៤។ របាយការណ៍តាមដាន និងវាយតម្លៃនឹងផ្តល់ព័ត៌មានចាំបាច់នានាសម្រាប់អនុវត្ត និងឬកែតម្រូវនូវសកម្មភាពនានាជាបន្តបន្ទាប់ទៀត។

ការផ្លាស់ប្តូរស្ថាប័ននឹងកើតមានឡើងនៅពេលដែលគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តនានាត្រូវបានអនុម័ត និងកម្មវិធីនានានៃកម្មវិធីជាតិដែលពាក់ព័ន្ធនឹងគោលនយោបាយទាំងនេះ ត្រូវបានអនុវត្ត។ តារាង២.១ បង្ហាញពីគោលដៅ ការផ្លាស់ប្តូរផ្នែកស្ថាប័ន និងលទ្ធផលផ្នែកស្ថាប័នដែលរំពឹងទុកតាមដំណាក់កាលនីមួយៗ។

### តារាង២.១ : រយៈពេល និងលទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១០-២០១២) | ដំណាក់កាលទី២ (២០១៣-២០១៥) | ដំណាក់កាលទី៣ (២០១៦-២០១៩) |
| គោលដៅ | បង្កើតរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ច ទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដើម្បីធានាដល់ការអនុវត្តគោលនយោបាយ និងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | ពង្រឹង និងពង្រីករចនាសម្ព័ន្ធ និងប្រព័ន្ធដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពដាក់ចេញ និងអនុវត្តនូវគោលនយោបាយសម្រាប់មូលដ្ឋានខ្លួនសំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងបង្កើនលទ្ធភាពទទួលយកសេវា | កែតម្រូវកម្មវិធីនានា និងធ្វើឱ្យមានឥទ្ធិពលកាន់តែស៊ីជម្រៅតាមរយៈការអនុវត្តមេរៀន និងបទពិសោធន៍ដែលទទួលបាន និងធានាថា កម្មវិធីនានាស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១០-២០១២) | ដំណាក់កាលទី២ (២០១៣-២០១៥) | ដំណាក់កាលទី៣ (២០១៦-២០១៩) |
| | | សាធារណៈរបស់ស្ត្រី និងអ្នកដែលបានទទួលសេវាសាធារណៈជាមូលដ្ឋានតិចតួច | ឆ្លើយតប និងឆ្លុះបញ្ចាំងពីគោលនយោបាយ និងយុទ្ធសាស្ត្រថ្មីៗរបស់រាជរដ្ឋាភិបាល |
| ការផ្លាស់ប្តូរផ្នែកស្ថាប័ន | ក្រុមប្រឹក្សាទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងក្លាយជាអ្នកធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | នៅពេលមុខងារត្រូវបានផ្ទេរកាន់តែច្រើនឡើង ខ្សែគណនេយ្យភាពរវាងក្រសួង ស្ថាប័នជាមួយរដ្ឋបាលនានាថ្នាក់ក្រោមជាតិ នឹងត្រូវបានបង្កើនឡើងចំពោះក្រុមប្រឹក្សា | ក្រសួង ស្ថាប័ននានា ទទួលខុសត្រូវកាន់តែច្រើនឡើង ក្នុងការបង្កលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកអនុវត្តយុទ្ធសាស្ត្រនានារបស់វិស័យ |
| លទ្ធផលរំពឹងទុកផ្នែកស្ថាប័ន | • មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាពចាំបាច់ជាមូលដ្ឋានដើម្បីអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• លិខិតបទដ្ឋានគតិយុត្តចាំបាច់នានាសម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់<br>• កិច្ចដំណើរការដែលមានលក្ខណៈជាប្រព័ន្ធមួយអំពីការពិនិត្យមុខងារឡើងវិញ ដោយរួមទាំងការពិនិត្យមើលមុខងារជាជម្រើសជាដំបូងដែលនឹងត្រូវផ្ទេរជាបន្តបន្ទាប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុម័តដោយ គ.ជ.អ.ប<br>• ប្រព័ន្ធដែលចាំបាច់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទទួល | • មុខងារដែលបានផ្ទេរក្នុងដំណាក់កាលទី១ ត្រូវពិនិត្យឡើងវិញដើម្បីបន្តពង្រីកការផ្ទេរមុខងារជាបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពផ្នែករដ្ឋបាលច្រើនជាងមុននៅពេលដែលសមត្ថភាពរបស់ខ្លួនមានការកើនឡើង<br>• គណនេយ្យភាពខ្សែទទឹង និងខ្សែបណ្តោយមានតុល្យភាព ដើម្បីធានាឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបតម្រូវការ និងគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ | • រដ្ឋបាលថ្នាក់ក្រោមជាតិមានការទទួលខុសត្រូវកាន់តែច្រើនចំពោះគុណភាព និងការទទួលបាននូវសេវាសាធារណៈនានារបស់ប្រជាពលរដ្ឋ<br>• ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការរួមគ្នាជាមួយប្រជាពលរដ្ឋ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចបែងចែកធនធានសម្រាប់កិច្ចការតាមវិស័យ |

| ការពិពណ៌នា | លទ្ធផលរំពឹងទុកតាមដំណាក់កាលនីមួយៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ (២០១០-២០១២) | ដំណាក់កាលទី២ (២០១៣-២០១៥) | ដំណាក់កាលទី៣ (២០១៦-២០១៨) |
| | យកមុខងារ និងធនធានដែលនឹងត្រូវផ្ទេរជាបន្តបន្ទាប់ ត្រូវបានបង្កើតឡើង<br>• មុខងារជាបឋមនានាដែលបានផ្ទេរដោយថ្នាក់ជាតិត្រូវបានអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ | | |

នៅចុងបញ្ចប់នៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ ចរិតលក្ខណៈ និងវិសាលភាពនៃសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានការផ្លាស់ប្តូរយ៉ាងច្រើន ហើយទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នក៏នឹងមានការផ្លាស់ប្តូរផងដែរ។ ក្រុមប្រឹក្សានានានឹងទទួលបាននូវការទទួលខុសត្រូវកាន់តែច្រើនឡើងក្នុងការផ្តល់សេវាសាធារណៈដោយផ្ទាល់ ដែលនឹងផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាក្នុងការឆ្លើយតបតម្រូវការ និងអាទិភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងពេលដែលមុខងារនានាត្រូវបានប្រគល់ឱ្យទៅក្រុមប្រឹក្សា ខ្សែគណនេយ្យភាពនឹងមានការផ្លាស់ប្តូរផងដែរ ដោយពេលនោះនឹងមានការកើនឡើងនូវការប្រាស្រ័យទាក់ទងរវាងក្រុមប្រឹក្សានានាជាមួយក្រសួង ស្ថាប័ន ជាងទំនាក់ទំនងរវាងក្រសួង ស្ថាប័ន ជាមួយមន្ទីរ អង្គភាពរបស់ខ្លួន។

នៅពេលដែលមុខងារនានាត្រូវបានផ្ទេរ តួនាទីរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ត្រូវបង្កលទ្ធភាពសមស្របសម្រាប់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងសម្រេចបាននូវគោលបំណង និងគោលដៅនានានៃគោលនយោបាយជាតិ។

## ២.៨. ការសម្របសម្រួលជាមួយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យនានា

ដើម្បីធានាដល់ដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គ.ជ.អ.ប ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយកំណែទម្រង់នានា ជាពិសេសកំណែទម្រង់រដ្ឋបាល និងកំណែទម្រង់ហិរញ្ញវត្ថុ។ ការសម្របសម្រួលនេះ ត្រូវអនុវត្តដូចខាងក្រោម :

- លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការជាប្រចាំជាមួយនឹងក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាននៃគណៈកម្មាធិការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ

- ក្នុងការរៀបចំមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចដែលបានកំណត់ក្នុងសមាសធាតុកម្មវិធីទី២ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ តាមរយៈអនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិរបស់ គ.ជ.អ.ប ត្រូវអនុវត្តដោយមានការសម្របសម្រួលជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ ។
- សមាសធាតុកម្មវិធីទី៤ ត្រូវអនុវត្តជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ហើយពាក់ព័ន្ធនឹងសមាសធាតុកម្មវិធីនេះ គ.ជ.អ.ប ត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទន្ទឹមនេះ ការអនុវត្តកម្មវិធីជាតិក៏នឹងប៉ះពាល់ដល់កំណែទម្រង់អន្តរវិស័យនានាក្នុងដំណាក់កាលនៃការផ្ទេរមុខងារ និងធនធាន ដូចដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទី៣ ។ អាស្រ័យហេតុនេះ គ.ជ.អ.ប ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានាត្រូវកែសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ដើម្បីធានាឱ្យមានសង្គតិភាពរវាងកំណែទម្រង់តាមវិស័យជាមួយនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ការងារនេះត្រូវអនុវត្តដូចខាងក្រោម :

- បន្ទាប់ពីកម្មវិធីជាតិត្រូវបានអនុម័ត ក្រសួង ស្ថាប័ននានាត្រូវមានយុទ្ធសាស្ត្រកំណែទម្រង់វិស័យរបស់ខ្លួន ដើម្បីរៀបចំផែនការសកម្មភាពក្នុងការប្រគល់ ឬធ្វើប្រតិភូកម្មមុខងារដោយអនុលោមទៅតាមកម្មវិធីជាតិ ។
- គ.ជ.អ.ប តាមរយៈអនុគណៈកម្មាធិការរបស់ខ្លួន ត្រូវធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកំណត់គោលការណ៍ណែនាំ សម្រាប់ធ្វើសមាហរណកម្មកម្មវិធីនានានៃកំណែទម្រង់តាមវិស័យជាមួយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។
- ដៃគូអភិវឌ្ឍន៍ត្រូវពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួន និងកំណត់អំពីកម្មវិធីតាមវិស័យសំខាន់ៗឱ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ។

## ២.៩. ក្របខ័ណ្ឌតក្កភាពគោលរបស់កម្មវិធីជាតិ

ក្របខ័ណ្ឌតក្កភាពគោលសម្រាប់កម្មវិធីជាតិ បង្ហាញពីទំនាក់ទំនងរវាងលទ្ធផលនានានៃសមាសធាតុកម្មវិធីនីមួយៗ ។ ក្របខ័ណ្ឌតក្កភាពគោលរួមមានគោលដៅ គោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងការសន្មតសំខាន់ៗ ។ ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីនីមួយៗ ដែលមានរៀបរាប់ក្នុងជំពូកទី៣ ឆ្លុះបញ្ចាំងពីលទ្ធផលរំពឹងទុក និងសកម្មភាពនានា ដែលរួមចំណែកក្នុងការសម្រេចនូវលទ្ធផលដែលរំពឹងទុកចុងក្រោយរបស់កម្មវិធីជាតិ ។

## តារាង២.២ : ក្របខ័ណ្ឌគុណភាពគោលសម្រាប់កម្មវិធីជាតិរយៈពេល១០ឆ្នាំ

| គោលដៅ និងគោលបំណងកម្មវិធីជាតិ | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|
| **គោលដៅកម្មវិធីជាតិ :**<br>• អភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួម និងមានសមធម៌<br>• លើកកម្ពស់បរិមាណ គុណភាព និងការទទួលបានសេវាសាធារណៈឱ្យមានភាពប្រសើរឡើង<br>• រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។ | • ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ ដែលពេញចិត្តលើលទ្ធផលការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលឆ្លើយថា ខ្លួនទទួលបានសេវាសាធារណៈច្រើនជាងមុន<br>• ភាគរយប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះមានលទ្ធភាពទទួលបានសេវាសាធារណៈនានា ដូចជា :<br>– អត្រាចូលរៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ<br>– ការប្រើប្រាស់សេវាសុខភាព ដូចជាការពិគ្រោះជំងឺ<br>– ភាគរយកុមារអាយុក្រោមមួយឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រិល<br>– ភាគរយកំណើតដែលផ្តល់សេវាដោយបុគ្គលិកសុខាភិបាល<br>– ភាគរយប្រជាពលរដ្ឋទទួលបាននូវទឹកស្អាតប្រើប្រាស់<br>– ភាគរយប្រជាពលរដ្ឋដែលទទួលបាននូវសេវាអនាម័យ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលមានចំណូលក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ ។ | • រាជរដ្ឋាភិបាលអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវលិខិតបទដ្ឋានគតិយុត្តនានា ដែលមានលក្ខណៈស្របនឹងការប្តេជ្ញាចិត្តខាងគោលនយោបាយ ។ |

| គោលដៅ និងគោលបំណងកម្មវិធីជាតិ | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|
| **គោលបំណងកម្មវិធីជាតិ :**<br>បង្កើតប្រព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ ដែលធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាព សំដៅលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាននីមួយៗ។ | • ភាគរយប្រជាពលរដ្ឋទាំងពីរភេទទទួលស្គាល់ថា ក្រុមប្រឹក្សាជាអង្គធ្វើសេចក្តីសម្រេចសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ចំនួនមុខងារដែលបានប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកើនឡើងច្រើនជាងចំនួនមុខងារដែលបានធ្វើប្រតិភូកម្ម<br>• ចំនួនក្រសួង ស្ថាប័នដែលបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• កម្រិតដែលក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិតាមដាន និងត្រួតពិនិត្យសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងទៀត | • រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានជំនួយបច្ចេកទេសចាំបាច់សម្រាប់កសាងប្រព័ន្ធ នីតិវិធីប្រតិបត្តិការ និងសមត្ថភាពបុគ្គលិក<br>• ផ្ទេរមូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ចាប់ពីដំណាក់កាលទី១នៃកម្មវិធីជាតិ<br>• កាលវិភាគជាក់លាក់នៃការផ្ទេរមុខងារត្រូវបានរៀបចំ និងអនុវត្តដោយ គ.ជ.អ.ប<br>• យុទ្ធនាការលើកកម្ពស់ការយល់ដឹងត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យប្រជាពលរដ្ឋបានយល់ពីការបង្កើត និងពីតួនាទីរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ជាគោលនយោបាយជាតិ<br>• រៀបចំវិធីសាស្ត្រសម្រាប់ការចូលរួម និងការវាយតម្លៃដែលសមស្របនឹងបរិបទកម្ពុជា។ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| ១. បង្កើតស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងមួយផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ ។ | ១.១. បង្កើតរចនាសម្ព័ន្ធជាមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យបានសមស្របតាមកម្រិតថ្នាក់រដ្ឋបាលនីមួយៗ<br>១.២. រៀបចំប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិស្តង់ដារដើម្បីគាំទ្រខ្សែគណនេយ្យភាពថ្មី និងការទទួលខុសត្រូវផ្អែកគ្រប់គ្រង<br>១.៣. រៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីនានាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ<br>១.៤. រៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធទំនាក់ទំនងអន្តររដ្ឋបាល<br>១.៥. ដាក់បញ្ចូលស្តង់ដារសមភាព និងសមធម៌យេនឌ័រទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>១.៦. ដាក់ឱ្យអនុវត្តនូវកម្មវិធីព័ត៌មានវិទ្យា និងទំនាក់ទំនងតាមប្រព័ន្ធព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • ភាគរយនៃក្រុមប្រឹក្សាដែលឆ្លើយថា ខ្លួនពេញចិត្តដោយបានធ្វើសេចក្តីសម្រេចដោយខ្លួនឯង ដោយមិនចាំបាច់ស្នើសុំការយល់ព្រមពីថ្នាក់លើ<br>• ភាគរយនៃផែនការអភិវឌ្ឍន៍ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានដាក់បញ្ចូលនូវផែនការ និងថវិការបស់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន<br>• ភាពច្បាស់លាស់នៃគោលដៅ និងគោលបំណងនានាដែលពាក់ព័ន្ធនឹងគណនេយ្យភាព និងកម្មវិធីសាកល្បងនូវយន្តការគណនេយ្យភាពនានា<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលពេញចិត្តចំពោះការបំពេញការងារនៃរដ្ឋបាលរបស់ខ្លួន<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលបានកំណត់ថាក្រុមប្រឹក្សា គឺជាអង្គដែលមានសិទ្ធិដាក់ចេញនូវបេសកកម្ម និងគោលដៅនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • ដាក់ឱ្យអនុវត្តនូវព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងឡាយដែលចែងពីតួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងរវាងបណ្តាថ្នាក់រដ្ឋបាលនានានៅឆ្នាំ២០១០<br>• កំណត់នូវតួនាទី និងសិទ្ធិដែលមានលក្ខណៈសមស្របសម្រាប់ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រុមប្រឹក្សាទទួលបានសិទ្ធិអំណាចផ្អែករដ្ឋបាល ក្នុងការរៀបចំនីតិវិធីធ្វើការងាររបស់ខ្លួន ដោយអនុលោមតាមច្បាប់របស់ជាតិជាធរមាន<br>• មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសចាំបាច់ ដើម្បីកំណត់ និងរៀបចំរចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួន<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំ និងយន្តការនានាទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មាន សិទ្ធិចូលរួម និងពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ នៅក្នុងការកសាងផែនការនិងថវិកា និងអភិបាលកិច្ចរបស់ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | ១.៧. រៀបចំ និងអនុវត្តនូវកម្មវិធីដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការកសាងផែនការ ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងបញ្ហានានា<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលបានចូលរួមក្នុងការវាយតម្លៃការបំពេញការងាររបស់ក្រុមប្រឹក្សា និងសកម្មភាពផ្សេងៗទៀតដូចមានកំណត់នៅផ្នែកគណនេយ្យភាព<br>• ភាគរយនៃក្រុមប្រឹក្សាដែលយកចិត្តទុកដាក់ និងគាំទ្រលើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។ | រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ការងារគណនេយ្យភាពមានកំណត់ច្បាស់លាស់នៅក្នុងគោលដៅនិងគោលបំណងនានារបស់រាជរដ្ឋាភិបាល<br>• រាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការងារគណនេយ្យភាពក្នុងការអនុវត្តគោលដៅនិងគោលបំណងនានាតាមរយៈការពិនិត្យឡើងវិញនូវយន្តការនានាដែលមានស្រាប់ពាក់ព័ន្ធនឹងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ហើយប្រើប្រាស់នូវបទពិសោធន៍ទាំងនេះ ដើម្បីជាមូលដ្ឋានរៀបចំ និងសាកល្បងយន្តការគណនេយ្យភាពថ្មីៗ<br>• រាជរដ្ឋាភិបាលអនុវត្តសាកល្បងនូវយន្តការគណនេយ្យភាពអន្តររដ្ឋបាលនានា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំ និងនីតិវិធីប្រតិបត្តិការនានា។ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| ២. រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។ | ២.១. រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ ដើម្បីផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង និងចាត់ចែងមន្ត្រីបុគ្គលិករបស់ខ្លួន តាមរយៈការបង្កើតនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស<br>២.២. បុគ្គលិករបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំឡើងវិញ ដោយផ្អែកលើមុខងារដែលបានផ្ទេរ តាមរយៈដំណើរការមួយប្រកបដោយតម្លាភាព<br>២.៣. បង្កើតឱ្យមានកម្មវិធីសម្រាប់ការអភិវឌ្ឍធនធានមនុស្ស<br>២.៤. បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីគ្រប់គ្រងធនធានមនុស្ស និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព<br>២.៥. បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបាននូវការលើកកម្ពស់ឱ្យក្លាយជាបុគ្គលិកប្រកបដោយវិជ្ជាជីវៈ | • ភាគរយនៃអ្នកធ្វើការទាំងពីរភេទនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវតែងតាំងជាបុគ្គលិករបស់ក្រុមប្រឹក្សា<br>• ភាគរយនៃមន្ត្រីរាជការស៊ីវិលទាំងពីរភេទបានទទួលការបណ្តុះបណ្តាល<br>• ភាគរយនៃស្ត្រីដែលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃស្ត្រីដែលត្រូវបានដំឡើងថ្នាក់ ឋានន្តរសក្តិ និងការតែងតាំងក្នុងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលរាយការណ៍ថា បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់ក្នុងការបម្រើ និងគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ<br>• ភាគរយនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានចំណាយសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ។ | • ធ្វើសមាហរណកម្មបុគ្គលិកក្រសួងមហាផ្ទៃ ដែលសព្វថ្ងៃកំពុងបំពេញការងារនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិសមស្របណាមួយ ដោយភ្ជាប់ជាមួយនូវការធ្វើប្រតិភូកម្មក្នុងការគ្រប់គ្រងមន្ត្រីទាំងនោះ នៅឆ្នាំ២០១០<br>• ដាក់ចេញនូវព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងដំណាក់កាលទី១នៃកម្មវិធីជាតិ<br>• គ.ជ.អ.ប ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវសហការសម្របសម្រួលរៀបចំយុទ្ធសាស្ត្រសម្រាប់កែសម្រួលប្រព័ន្ធលើកទឹកចិត្តជាបណ្តើរៗ ដើម្បីឈានទៅប្រើប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍បុគ្គលិកដែលផ្អែកតាមសមត្ថភាព និងស្នាដៃរបស់មន្ត្រីម្នាក់ៗ<br>• គ.ជ.អ.ប សម្របសម្រួលឱ្យមានការរៀបចំ និងការដាក់ចេញនូវព្រះរាជក្រឹត្យ និងអនុក្រឹត្យទាំងឡាយដែលផ្តល់អំណាចឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | | | ក្រោមជាតិមានសិទ្ធិកាន់តែច្រើនឡើងលើការគ្រប់គ្រងបុគ្គលិក (ដូចជាការជ្រើសរើស ការដំឡើងថ្នាក់ឋានន្តរសក្តិ ការតែងតាំង ការលើកសរសើរ ការដាក់ពិន័យ និងការបញ្ឈប់ពីការងារ)<br>• ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |
| ៣. លើកកម្ពស់បរិមាណ និងគុណភាពសេវាសាធារណៈ តាមរយៈការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារទាំងនោះ ។ | ៣.១. ពិនិត្យមើលមុខងារឡើងវិញ និងផ្ទេរមុខងារស្របតាមវិធីសាស្ត្រ និងដំណើរការដែលមានការពិគ្រោះយោបល់ មានការគ្រោងទុក មានសនិទានភាព និងមានលក្ខណៈជាប្រព័ន្ធ<br>៣.២. ការទទួលខុសត្រូវ និងសិទ្ធិអំណាចសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ត្រូវបានអនុវត្តដោយពុំមានការរំខានដល់ការផ្តល់សេវាសាធារណៈនានា<br>៣.៣. រៀបចំ និងអនុវត្តផែនការស្តីពីការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន ឱ្យបានច្បាស់លាស់<br>៣.៤. យកចិត្តទុកដាក់ដល់ការលើកកម្ពស់សមភាព | • ភាគរយនៃមុខងារដែលបានផ្ទេរ (រួមទាំងការប្រគល់ឬធ្វើប្រតិភូកម្ម) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃមុខងារដែលបានផ្ទេរ ធៀបនឹងមុខងារដែលកំណត់នៅក្នុងផែនការផ្ទេរមុខងាររបស់ក្រសួងស្ថាប័ន<br>• ភាគរយនៃមុខងារដែលបានផ្ទេរមានភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាននានា<br>• ភាគរយប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះមានលទ្ធភាពទទួលបានសេវាសាធារណៈនានា ដូចជា ៖ | • អនុម័តនូវនីតិវិធីក្នុងការពិនិត្យមើលឡើងវិញ និងការផ្ទេរមុខងារ នៅឆ្នាំ២០១០<br>• សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនូវការផ្ទេរមុខងារ ហើយអនុវត្តការផ្ទេរនេះក្នុងលក្ខណៈជាប្រព័ន្ធ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានសមស្រប<br>• រៀបចំ និងផ្ទេរមុខងារបឋមទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១០<br>• គ.ជ.អ.ប អនុម័តនូវដំណើរការដែលមានលក្ខណៈជាប្រព័ន្ធមួយអំពីការពិនិត្យឡើងវិញនូវមុខងារ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | យេនឌ័រ និងបង្កើនការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះនានានៅក្នុងការផ្ទេរមុខងារ<br>៣.៥. លើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ | – អាត្រាចូលរៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ<br>– ការប្រើប្រាស់សេវាសុខភាព ដូចជាការពិគ្រោះជំងឺ<br>– ភាគរយកុមារអាយុក្រោមមួយឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រិល<br>– ភាគរយកំណើតដែលផ្តល់សេវាដោយបុគ្គលិកសុខាភិបាល<br>– ភាគរយប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់<br>– ភាគរយប្រជាពលរដ្ឋដែលទទួលបានសេវាអនាម័យ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលឆ្លើយថាខ្លួននឹងទៅរកក្រុមប្រឹក្សា ឬបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីដោះស្រាយបញ្ហាសេវាសាធារណៈ<br>• ភាគរយនៃថវិកាជាតិដែលបានចំណាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងសមាជិកក្រុមប្រឹក្សាទាំងពីរភេទដែលដឹងពីសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ | នៅឆ្នាំ២០១០<br>• មុខងារភាគច្រើនដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិគឺជាមុខងារដែលផ្ទេរតាមការប្រគល់<br>• រាល់ការផ្ទេរមុខងារពីក្រសួង ស្ថាប័ននានាត្រូវអនុវត្តដោយមានលក្ខណៈជាប្រព័ន្ធ ដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>• រាជរដ្ឋាភិបាលកំណត់ច្បាស់លាស់ពីសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| ៤. បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពកៀរគរ និងទទួលបានធនធានគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងបែងចែកធនធានទាំងនោះប្រកបដោយតម្លាភាព និងគណនេយ្យភាព។ | ៤.១. បង្កើតប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍និងថវិកា និងប្រព័ន្ធគណនេយ្យសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលលើកកម្ពស់គណនេយ្យភាព តម្លាភាព និងដែលមានសង្គតិភាពជាមួយនឹងគោលការណ៍នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>៤.២. ប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍ និងថវិកាបានលើកកម្ពស់សមភាពយេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ<br>៤.៣. ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដែលមានលក្ខណៈឆ្លើយតប និងមានប្រសិទ្ធភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៤. ផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានទាន់ពេលវេលា ដោយមានការផ្តល់នូវសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការប្រើប្រាស់ និងការបែងចែកដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានតម្លាភាព | • ភាគរយនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុវត្តផែនការពិនិត្យមើលឡើងវិញលើយន្តការគណនេយ្យភាពនានាដែលមានស្រាប់ និងដែលបានធ្វើការសាកល្បងយន្តការទាំងនោះ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំនានាស្តីពីការចូលរួមផ្តល់យោបល់របស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ទៅលើគម្រោងថវិការបស់ក្រុមប្រឹក្សាប្រភេទផ្សេងៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានផែនការអភិវឌ្ឍន៍ និងថវិកាដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រួតពិនិត្យអនុម័ត ដោយក្រុមប្រឹក្សា<br>• ភាគរយនៃមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានផ្ទេរទាន់ពេលវេលា<br>• ភាគរយជាមធ្យមនៃភាពមិនប្រក្រតី ទាក់ទងនឹងការងារលទ្ធកម្ម ដែលបានរកឃើញដោយការធ្វើសវនកម្មនៅឆ្នាំកន្លងមក | • រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានសិទ្ធិអំណាចទៅលើថវិកា និងធនធានច្រើនជាងមុន<br>• អនុម័តនូវច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅឆ្នាំ២០១០<br>• អនុម័តនូវបទប្បញ្ញត្តិស្តីពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ នៅឆ្នាំ២០១០<br>• រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានមូលនិធិផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ និងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់អនុវត្តមុខងារ ដែលផ្ទេរតាមការប្រគល់ និងការធ្វើប្រតិភូកម្ម បន្ថែមលើប្រភពចំណូលមូលដ្ឋានរបស់ខ្លួន<br>• ផ្តល់ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសគ្រប់គ្រាន់ដល់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាដែលឆ្លើយតបនឹងការបញ្ជ្រាបយេនឌ័រ<br>• កំណត់នីតិវិធីធ្វើការងារ និងតួនាទីរបស់គណៈកម្មា |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | ៤.៥. ប្រគល់ប្រភេទចំណូលពន្ធមូលដ្ឋានដ៏ច្បាស់លាស់ (១០០% ឬចែករំលែកជាមួយថ្នាក់រដ្ឋបាលផ្សេងទៀត) ទៅឱ្យប្រភេទរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៦. ប្រគល់ប្រភេទចំណូលមិនមែនសារពើពន្ធមួយចំនួន និងសិទ្ធិចាត់ចែងចំណូលមិនមែនសារពើពន្ធទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៧. ឃុំ សង្កាត់ក្នុងស្រុកទទួលបានចំណូលចែករំលែកដែលត្រូវបានផ្តល់ឱ្យតាមមធ្យោបាយមួយប្រកបដោយតម្លាភាព និងសមធម៌<br>៤.៨. ផ្ទេរ និងផ្តល់ទ្រព្យសម្បត្តិចាំបាច់ឱ្យបានទាន់ពេលវេលាសម្រាប់អនុវត្តមុខងារនានា និងបង្កើតប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.៩. រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធ និងនីតិវិធីលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍តម្លាភាព និងប្រសិទ្ធភាព | • ភាគរយនៃក្រុមប្រឹក្សាដែលឆ្លើយថា រដ្ឋបាលរបស់ខ្លួនបានធ្វើសវនកម្មផ្ទៃក្នុង និងរាយការណ៍ពីលទ្ធផលជាទៀងទាត់<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលដឹងថា អ្នកណាដែលខ្លួនអាចសួរដឹងបានអំពីចំនួន និងការបែងចែកថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលគាំទ្រដល់ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី<br>• ភាគរយនៃការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹង :<br>– ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ<br>– ការលើកកម្ពស់សេវាអប់រំ<br>– ការលើកកម្ពស់សេវាសុខភាព<br>– ការលើកកម្ពស់អនាម័យ និងទឹកស្អាត<br>• ភាគរយប្រជាពលរដ្ឋដែលចូលរួមក្នុងការពិនិត្យមើលឡើងវិញនូវការអនុវត្តថវិកា និងកិច្ចលទ្ធកម្ម ។ | ធិការលទ្ធកម្ម និងប្រធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កើតយន្តការនានាដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិសាកសួរ និងទទួលបានព័ត៌មានស្តីពីហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>• កំណត់គោលដៅ និងគោលបំណងនានាសម្រាប់គណនេយ្យភាពចំពោះប្រជាពលរដ្ឋពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | ៤.១០. រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.១១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើអធិការកិច្ចហិរញ្ញវត្ថុទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តតាមច្បាប់ និងនីតិវិធីនានា<br>៤.១២. គាំទ្រផ្នែកស្ថាប័ន និងការកសាងសមត្ថភាពដល់អាជ្ញាធរសវនកម្មជាតិក្នុងការធ្វើសវនកម្មទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៤.១៣. រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពរៀបចំផែនការប្រកបដោយតម្លាភាព ដោយយកចិត្តទុកដាក់លើការចំណាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ | | |
| ៥. ពង្រឹងស្ថាប័នថ្នាក់ជាតិនានាសម្រាប់ដឹកនាំការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ | ៥.១. គ.ជ.អ.ប ត្រូវរៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការសមស្របសម្រាប់ការអនុវត្តកម្មវិធីជាតិ<br>៥.២. ជួយគាំទ្រក្រសួង ស្ថាប័នក្នុងការពិនិត្យមើល និងរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងដំណើរការដែល | • ចំនួននិស្សិតទាំងពីរភេទដែលទទួលបានសញ្ញាប័ត្ររដ្ឋបាល និងគោលនយោបាយសាធារណៈ និងភាគរយនៃនិស្សិតទាំងនេះបានចូលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃសម្ព័ន្ធភាព និងសមាគមរដ្ឋបាលថ្នាក់ | • ស្ថាប័ននៅថ្នាក់ជាតិទទួលបានជំនួយបច្ចេកទេសដែលចាំបាច់ក្នុងការកែតម្រូវ និងផ្តល់ការណែនាំដល់អង្គភាពរបស់ខ្លួនស្របតាមគោលការណ៍នានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | ឆ្លុះបញ្ចាំងពីតួនាទី និងការទទួលខុសត្រូវថ្មីរបស់ខ្លួនចំពោះរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៥.៣. បង្កើតឱ្យមានយន្តការសម្របសម្រួលកិច្ចការរដ្ឋបាល និងសម្រុះសម្រួលវិវាទរដ្ឋបាល<br>៥.៤. គ.ជ.អ.ប ត្រូវរៀបចំឡើងវិញនូវអង្គភាពតាមដាន និងវាយតម្លៃរបស់ខ្លួនដើម្បីអនុវត្តកម្មវិធីតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ<br>៥.៥. បង្កើត និងដាក់ឱ្យអនុវត្តនូវយន្តការនានាសម្រាប់ការត្រួតពិនិត្យនីត្យានុកូលភាពលើលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>៥.៦. រៀបចំបង្កើតស្ថាប័នបណ្តុះបណ្តាលដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក និងស្ថាប័នដែលទទួលខុសត្រូវចំពោះការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ<br>៥.៧. ស្ថាប័ននានាសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបង្កើន និងជំរុញការយកចិត្ត | ក្រោមជាតិ មានផែនការ និងថវិកាសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលបង្ហាញថាខ្លួនយល់ដឹងពីសមភាព និងសមធម៌យេនឌ័រនៅក្នុងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ | និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• វិធីសាស្ត្រនៃការកសាងសមត្ថភាពមានលក្ខណៈសមស្របតាមស្ថានភាពដោយឡែកៗរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រសួង ស្ថាប័នកសាងសមត្ថភាពផ្ទៃក្នុងស្ថាប័នដើម្បីចូលរួមចំណែកក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យត្រូវចូលរួមគាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ |

| គោលបំណងសមាសធាតុកម្មវិធី | លទ្ធផលរំពឹងទុក | សូចនាករ | ការសន្មតសំខាន់ៗ |
|---|---|---|---|
| | ទុកដាក់ក្នុងការលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ<br>៥.៨. សម្ព័ន្ធភាពជាតិ និងសមាគមនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព និងថវិកាសមស្របសម្រាប់រៀបចំកម្មវិធី ដើម្បីឆ្លើយតបនឹងតម្រូវការនានា | | |

# ជំពូកទី៣
# សមាសធាតុនានារបស់កម្មវិធីជាតិ

# ជំពូកទី៣
# សមាសធាតុនានារបស់កម្មវិធីជាតិ

## ៣.១. សមាសធាតុកម្មវិធីទី១ : ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ

### ៣.១.១. សនិទានភាព

ដើម្បីធានាដល់ការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តប្រគល់តួនាទី និងការទទួលខុសត្រូវទៅឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់លទ្ធភាពឱ្យរដ្ឋបាលទាំងនោះ សម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន(សកម្មភាពរដ្ឋបាលសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន)។ ក្នុងដំណើរការនេះ ទាមទារឱ្យមានការរៀបចំឡើងវិញនូវស្ថាប័នថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃរដ្ឋបាលឯកភាព ដោយមានក្រុមប្រឹក្សាជាអ្នកដឹកនាំធានាឱ្យមានការសម្របសម្រួលការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់គណនេយ្យភាព និងការឆ្លើយតបចំពោះប្រជាពលរដ្ឋ។ ដើម្បីគាំទ្រដល់កិច្ចដំណើរការនេះ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់រៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងលើមូលដ្ឋាននៃខ្សែគណនេយ្យភាពថ្មីរបស់រដ្ឋបាលទាំងនោះ ហើយការផ្ទេរមុខងារត្រូវកំណត់ឱ្យច្បាស់អំពីតួនាទី មុខងារ សិទ្ធិអំណាច និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារដែលបានផ្ទេរឱ្យនោះ រួមនឹងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការផ្ទេរមុខងារដោយការប្រគល់ច្រើនជាងការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នាំឱ្យក្រុមប្រឹក្សាមានសិទ្ធិអំណាចកាន់តែច្រើនឡើង។

ការបង្កើតក្រុមប្រឹក្សានៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាំឱ្យមានការផ្លាស់ប្តូរនូវខ្សែគណនេយ្យភាពនៃរដ្ឋបាលបច្ចុប្បន្ន និងបរិយាកាសការងារនៅថ្នាក់ឃុំ សង្កាត់។ ការបង្កើតក្រុមប្រឹក្សាទាំងនេះ ក៏ទាមទារឱ្យមានការកែសម្រួលតួនាទី និងទំនាក់ទំនងរវាងបណ្តាក្រសួង ស្ថាប័ននានាជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ នៅពេលដែលមុខងារត្រូវបានផ្ទេរ តួនាទី និងទំនាក់ទំនងនេះនឹងត្រូវមានការផ្លាស់ប្តូរផងដែរ ពោលគឺក្រសួង ស្ថាប័នពាក់ព័ន្ធនឹងធ្វើការកាន់តែជិតស្និទ្ធថែមទៀតជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនឹងដើរតួនាទីជាយន្តការមួយក្នុងចំណោមយន្តការនានារបស់ក្រុមប្រឹក្សា ក្នុងការសម្របសម្រួលការងាររវាងស្ថាប័នទាំងនេះនៅតាមថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

តួនាទី និងលក្ខណសម្បត្តិរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានកំណត់តាមរយៈ (១)ខ្សែគណនេយ្យភាព (២)ប្រភពចំណូលនិងយន្តការគាំទ្រហិរញ្ញប្បទាន (៣)ដំណើរការកសាងផែនការ ការចូលរួមនិងសិទ្ធិរបស់ប្រជាពលរដ្ឋ (៤)របៀបផ្ទេរមុខងារនិងការចាត់ចែងមុខងារដែលបានផ្ទេរ និង(៥)កម្រិតនៃការទទួលខុសត្រូវក្នុងការសម្របសម្រួលសកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ថ្នាក់រដ្ឋបាលនីមួយៗ។

ទំនាក់ទំនងរវាងចំណុចទាំង៥ខាងលើនេះ នឹងកំណត់បាននូវកម្រិតនៃស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ទៅលើធនធានដែលក្រុមប្រឹក្សាត្រូវធ្វើការវិភាជន៍ និងទៅលើសមត្ថភាពរបស់ក្រុមប្រឹក្សាក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ទោះបីក្រសួង ស្ថាប័ន ពុំមានអង្គភាពខ្សែបណ្តោយរបស់ខ្លួននៅថ្នាក់ឃុំ សង្កាត់ក៏ដោយ ក៏ឃុំ សង្កាត់នឹងទទួលខុសត្រូវក្នុងការសម្របសម្រួល សកម្មភាពរដ្ឋបាលសាធារណៈនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈមធ្យោបាយផ្សេងៗ ដូចជាការចូលរួមនៅក្នុងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសនៅរដ្ឋបាលថ្នាក់ខ្ពស់ជាង និងការបញ្ចូលតម្រូវការនានារបស់ឃុំ សង្កាត់ ទៅក្នុងផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សានៅថ្នាក់ខ្ពស់ជាងនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍។

ទំនាក់ទំនងរវាងចំណុចទាំង៥ខាងលើនេះ គឺជាលក្ខណៈវិនិច្ឆ័យដែលត្រូវប្រើប្រាស់នៅពេលរៀបចំប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឱ្យមានដំណើរការល្អ គឺជាកត្តាដ៏សំខាន់ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចដោះស្រាយភាពស្មុគស្មាញនៃទំនាក់ទំនងផ្នែកនយោបាយ និងផ្នែករដ្ឋបាល ជាពិសេសដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដោយផ្តោតលើលទ្ធផលការងារ ការធ្វើគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ការឆ្លើយតបចំពោះប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

សកម្មភាពនៅក្នុងសមាសធាតុកម្មវិធីទី១ គឺរៀបចំឡើងដើម្បីកសាងសមត្ថភាពដល់ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាច :

- ធ្វើការពិសោធន៍ សាកល្បង និងពិនិត្យឡើងវិញនូវការទទួលយកនូវខ្សែគណនេយ្យភាពថ្មី
- មានសមត្ថភាពរ៉ាប់រងការទទួលខុសត្រូវដែលកាន់តែច្រើននិងមានកម្រិតខ្ពស់ជាងមុន ជាពិសេសទាក់ទងនឹងការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងបុគ្គលិក និងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការបែងចែកធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
- សម្របសម្រួលជាមួយថ្នាក់រដ្ឋបាលប្រភេទផ្សេងទៀត ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន សង្គមស៊ីវិល និងផ្នែកឯកជន
- កំណត់នូវបេសកកម្ម ចក្ខុវិស័យ និងគោលដៅរបស់អង្គភាពនីមួយៗ ជាពិសេសការគិតគូរអំពីស្ត្រី និងតម្រូវការរបស់ស្ត្រី និងបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីរដ្ឋបាល និងសកម្មភាពផ្តល់សេវាសាធារណៈនានា។

សកម្មភាពនាឆ្នាំដំបូងៗ នឹងផ្តោតលើការរៀបចំអន្តរកាលនៃប្រព័ន្ធបច្ចុប្បន្ន និងការរៀបចំប្រព័ន្ធថ្មី ដើម្បីគាំទ្រដល់ការផ្ទេរមុខងារនានាជាបឋម[១២] រួមទាំងធនធានដែលពាក់ព័ន្ធ។ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការត្រូវរៀបចំឡើងដើម្បីផ្តល់ជាហេដ្ឋារចនាសម្ព័ន្ធស្ថាប័នចាំបាច់សម្រាប់ឱ្យក្រុមប្រឹក្សា គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា

[១២] ការវិភាគមុខងារ និងនីតិវិធីសម្រាប់ផ្ទេរមុខងារនឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១០។

មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ន សង្គមស៊ីវិល និងផ្នែកឯកជនធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព។ ហេដ្ឋារចនាសម្ព័ន្ធនេះនឹងសម្រួលដល់**ទំនាក់ទំនងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** និង**ទំនាក់ទំនងអន្តររដ្ឋបាល** ដែលចាំបាច់ដើម្បីសម្របសម្រួលការផ្តល់សេវាសាធារណៈ ការរៀបចំផែនការអន្តរវិស័យ និងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការវិភាជន៍ធនធាននានា។

នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែអភិវឌ្ឍន៍ ត្រូវខិតខំរៀបចំឱ្យមានប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់នៅតាមថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅពេលដែលរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការដាក់ឱ្យប្រើប្រាស់និងមានដំណើរការកាន់តែរលូន រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានលទ្ធភាពផ្តោតការយកចិត្តទុកដាក់ទៅលើការកសាងសមត្ថភាពឱ្យបានស៊ីជម្រៅបន្ថែមទៀតដើម្បីកំណត់អំពីបេសកកម្ម យុទ្ធសាស្ត្រនិងការអភិវឌ្ឍរបស់ខ្លួន និងផ្តោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់ការបំពេញការងាររបស់ខ្លួន ដើម្បីឈានទៅសម្រេចបាននូវការផ្តល់សេវាសាធារណៈប្រកបដោយគុណភាពនិងមាននិរន្តរភាព ព្រមទាំងមានលទ្ធភាពបំពេញការងាររបស់ខ្លួនស្របតាមស្តង់ដារបំពេញការងារ និងស្តង់ដារគណនេយ្យភាព។

គោលបំណងរបស់សមាសធាតុកម្មវិធីទី១ មានសង្គតិភាពជាមួយគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ជាពិសេសសមាសធាតុកម្មវិធីនេះ បង្ហាញពីវិធីសាស្ត្រដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចមានលទ្ធភាពផ្លាស់ប្តូររបៀបរបបការងារពី**រចនាសម្ព័ន្ធមុខងារ**ទៅជា**រចនាសម្ព័ន្ធប្រតិបត្តិការ**។

## ៣.១.២. គោលបំណងសមាសធាតុកម្មវិធី

សមាសធាតុកម្មវិធីទី១ មានគោលបំណងដើម្បីបង្កើតស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងមួយ តាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ ដែលមាននីតិវិធីប្រតិបត្តិការរបៀបរបបគ្រប់គ្រងជាប្រព័ន្ធមួយដែលឆ្លើយតបនឹងខ្សែគណនេយ្យភាពថ្មី សម្រាប់ធានាឱ្យមានអភិបាលកិច្ចប្រកបដោយតម្លាភាពនិងមានគណនេយ្យភាព សំដៅធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។

## ៣.១.៣. ការងារជាអាទិភាពនានា

ការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងបង្កើតឱ្យមានផ្នែកគ្រប់គ្រង និងផ្នែករដ្ឋបាល ដែលអាចបញ្ចូលនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុ។

ការងារជាអាទិភាពនៅក្នុងដំណាក់កាលនីមួយៗនៃសមាសធាតុកម្មវិធីទី១ ដែលបានកំណត់នៅក្នុងតារាង **៣.១.ក្របខ័ណ្ឌតក្កភាពសមាសធាតុកម្មវិធីទី១** មានដូចខាងក្រោម :

## ក). ការងារជាអាទិភាពនៅថ្នាក់ឃុំ សង្កាត់

**ដំណាក់កាលទី១ :** ដើម្បីបន្តកិច្ចអភិវឌ្ឍនៅឃុំ សង្កាត់ ចាំបាច់ត្រូវបង្កើតអង្គភាពគាំទ្រនៅថ្នាក់ក្រុង ស្រុក ស្របតាមលិខិតបទដ្ឋានគតិយុត្តអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ការរៀបចំនេះត្រូវឆ្លុះបញ្ចាំងពីស្ថានភាពគាំទ្រខុសៗគ្នារវាងឃុំ សង្កាត់នៅក្នុងស្រុក និងសង្កាត់នៅក្នុងក្រុង។ ចំណុចសំខាន់នៅក្នុងការរៀបចំអង្គភាពគាំទ្រនេះ គឺការផ្ទេរតួនាទី និងការទទួលខុសត្រូវជាជំហានៗក្នុងការគាំទ្រឃុំ សង្កាត់ពីអង្គភាពគាំទ្របច្ចេកទេសនៃគណៈកម្មាធិការប្រតិបត្តិខេត្ត និងការគាំទ្រដទៃទៀតដែលមានភាពចាំបាច់របស់រដ្ឋបាលខេត្ត ទៅឱ្យរដ្ឋបាលក្រុង និងស្រុក ហើយការរៀបចំអង្គភាពគាំទ្រនេះត្រូវគោរពគោលការណ៍ស្វ័យភាព និងគណនេយ្យភាពរបស់ឃុំ សង្កាត់។

ជាមួយគ្នានេះដែរ ការងារជាអាទិភាពមួយទៀត គឺការរៀបចំ និងផ្ទេរមុខងារជាបឋមមួយចំនួនទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមុខងារទាំងនេះអាចជ្រើសរើសចេញពីមុខងារទាំងឡាយ ដែលធ្លាប់បានអនុវត្តដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងមុខងារផ្សេងទៀតដែលសមស្រប។

**ដំណាក់កាលទី២ :** តាមការរំពឹងទុក ឃុំ សង្កាត់នឹងទទួលបានការផ្ទេរមុខងារមួយចំនួន ប៉ុន្តែដោយសារសមត្ថភាពនៅថ្នាក់ឃុំ សង្កាត់នៅមានកម្រិត និងផ្អែកតាមគោលការណ៍នៃសេដ្ឋកិច្ចវិមាត្រ ចាំបាច់ត្រូវរៀបចំឱ្យមានប្រព័ន្ធអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងឬប្រព័ន្ធអន្តររដ្ឋបាលដើម្បីផ្តល់សេវាសាធារណៈដោយផ្អែកលើវិធានច្បាប់ និងដោយប្រើប្រាស់យន្តការផ្តល់សេវាសាធារណៈផ្សេងៗទៀត ដូចជាការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន ឬកិច្ចព្រមព្រៀងផ្តល់សេវាសាធារណៈជាមួយរដ្ឋបាលក្រុង ស្រុក ឬការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន ក្នុងគោលបំណងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

## ខ). ការងារជាអាទិភាពនៅថ្នាក់ក្រុង ស្រុក ខណ្ឌ

**ដំណាក់កាលទី១ :** បច្ចុប្បន្ន ថ្នាក់ក្រុង ស្រុក ខណ្ឌ មានហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលតិចតួចបំផុត ដូច្នេះ នៅក្នុងដំណាក់កាលទី១ ចាំបាច់ត្រូវដោះស្រាយបញ្ហានេះដើម្បីឱ្យថ្នាក់ក្រុង ស្រុក ខណ្ឌ អាចទទួលយកនូវការផ្ទេរមុខងាររួមទាំងធនធាននិងបុគ្គលិក និងការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈដោយផ្ទាល់។ សម្រាប់រយៈពេលខ្លី គឺត្រូវរៀបចំប្រព័ន្ធរដ្ឋបាលចាំបាច់ ដើម្បីធានាឱ្យក្រុមប្រឹក្សាមានសមត្ថភាពរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនៅក្នុងមូលដ្ឋានរបស់ខ្លួន និងអាចធ្វើសេចក្តីសម្រេចក្នុងការវិភាជន៍ថវិកាដែលខ្លួនមានសម្រាប់កម្មវិធីវិនិយោគក្នុងមូលដ្ឋានរបស់ខ្លួន។ ផែនការអភិវឌ្ឍន៍ត្រូវឆ្លុះបញ្ចាំងអំពីផែនការសមាហរណកម្មជាមួយឃុំ សង្កាត់ និងធនធានចាំបាច់នានា ដើម្បីផ្តល់សេវាសាធារណៈនៅក្នុងក្រុង ស្រុក ខណ្ឌរបស់ខ្លួន។

ជាមួយគ្នានេះដែរ ការងារជាអាទិភាពមួយទៀត គឺការរៀបចំ និងផ្ទេរមុខងារជាបឋមទៅឱ្យក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដែលមុខងារទាំងនេះអាចជ្រើសរើសចេញពីមុខងារទាំងឡាយ ដែលធ្លាប់បានអនុវត្តដោយក្រុមប្រឹក្សាទាំងនេះ (ដូចជាមុខងារពាក់ព័ន្ធនឹងគម្រោងការិយាល័យច្រកចេញចូលតែមួយ និងកម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ក្រុង ស្រុក ខណ្ឌ) និងមុខងារផ្សេងទៀតដែលសមស្រប។

**ដំណាក់កាលទី២ :** នៅពេលដែលប្រព័ន្ធរដ្ឋបាលជាមូលដ្ឋាននៅថ្នាក់ក្រុង ស្រុក ខណ្ឌ ចាប់ផ្តើមដំណើរការ ក្រុមប្រឹក្សា និងមន្ត្រីរបស់ខ្លួនត្រូវរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័នរយៈពេលមធ្យម ដោយត្រូវកំណត់អំពីតម្រូវការនានា របស់ក្រុមប្រឹក្សាក្នុងការត្រៀមទទួលយកមុខងារ និងធនធានថ្មីៗដែលនឹងត្រូវផ្ទេរជាបន្តបន្ទាប់ទៅឱ្យក្រុង ស្រុក ខណ្ឌ។

### គ). ការងារជាអាទិភាពនៅរាជធានី ខេត្ត

**ដំណាក់កាលទី១ :** តម្រូវការជាបន្ទាន់សម្រាប់រាជធានី ខេត្ត គឺការរៀបចំស្ថាប័ននៅរដ្ឋបាលរាជធានី ខេត្ត ដោយត្រូវកំណត់អំពីសកម្មភាពចាំបាច់នានា ដើម្បីដាក់បញ្ចូលគ្នានូវប្រព័ន្ធ បុគ្គលិក និងយុទ្ធសាស្ត្រសម្រាប់រៀបចំប្រព័ន្ធ និងនីតិវិធីប្រតិបត្តិការរបស់ស្ថាប័នឱ្យស្របតាមមុខងារដែលកំពុងអនុវត្តបច្ចុប្បន្ននៅរាជធានី ខេត្ត។

ជាមួយគ្នានេះដែរ ការងារជាអាទិភាពមួយទៀត គឺការរៀបចំ និងផ្ទេរមុខងារជាបឋមទៅឱ្យក្រុមប្រឹក្សា រាជធានី ខេត្ត ដែលមុខងារទាំងនេះអាចជ្រើសរើសចេញពីមុខងារទាំងឡាយ ដែលធ្លាប់បានអនុវត្តដោយថ្នាក់រាជធានី ខេត្ត និងមុខងារផ្សេងទៀតដែលសមស្រប។

**ដំណាក់កាលទី២ :** រាជធានី ខេត្តនឹងមានតួនាទីសម្របសម្រួលកិច្ចអភិវឌ្ឍដ៏ទូលំទូលាយនៅទូទាំងរាជធានី ខេត្តកាន់តែច្រើនជាងមុន។ ហេតុនេះ រាជធានី ខេត្តចាំបាច់ត្រូវរៀបចំដំណើរការកសាងផែនការអភិវឌ្ឍន៍ និងការ អនុវត្តផែនការ ដោយត្រូវធ្វើសមាហរណកម្មនូវរាល់តម្រូវការនៃតំបន់ផ្សេងៗគ្នានៅទូទាំងរាជធានី ខេត្ត ឱ្យស្របនឹង គោលនយោបាយជាតិ។ ចំពោះរាជធានីភ្នំពេញ ដែលជាមជ្ឈមណ្ឌលនយោបាយ និងសេដ្ឋកិច្ចរបស់ជាតិចាំបាច់ត្រូវពិនិត្យ មើលឡើងវិញ និងកែសម្រួលយុទ្ធសាស្ត្រអភិវឌ្ឍន៍នាពេលបច្ចុប្បន្នរបស់ខ្លួន ក្នុងនោះ **ទីមួយ**ត្រូវកែសម្រួលឡើងវិញនូវ រចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរបស់រាជធានី ខណ្ឌ សង្កាត់ ដើម្បីរៀបចំរដ្ឋបាលរាជធានីភ្នំពេញឱ្យក្លាយទៅជាស្ថាប័នដែល មានផែនការសេដ្ឋកិច្ច សង្គមឯកភាពតែមួយ។ កិច្ចដំណើរការនេះទាមទារឱ្យមានការរៀបចំមូលដ្ឋានថ្មីមួយសម្រាប់ ទំនាក់ទំនងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិនៅរាជធានី ដោយលើកកម្ពស់តួនាទីរបស់ក្រុមប្រឹក្សាសង្កាត់ដែលកើតចេញ ពីការបោះឆ្នោតដោយផ្ទាល់ក្នុងអភិបាលកិច្ចរបស់រាជធានីភ្នំពេញ។ **ទីពីរ** ត្រូវកែសម្រួលយុទ្ធសាស្ត្រអភិវឌ្ឍន៍ឱ្យស្រប នឹងតម្រូវការអភិវឌ្ឍន៍ថ្មីៗ ព្រមទាំងមុខងារ និងធនធានដែលបានផ្ទេរ។

## ៣.១.៤. ក្របខ័ណ្ឌតក្កភាព

ក្របខ័ណ្ឌតក្កភាពសម្រាប់សមាសធាតុកម្មវិធីទី១ មាននៅក្នុងតារាងក្របខ័ណ្ឌតក្កភាព ៣.១។

## តារាង៣.១ : ក្របខណ្ឌគុណភាពនៃសមាសធាតុកម្មវិធីទី១

| សមាសធាតុកម្មវិធីទី១ : ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី១** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| បង្កើតស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងមួយ ផ្អែកតាមគោលការណ៍នៃការចូលរួមតាមបែបប្រជាធិបតេយ្យ ។ | • ភាគរយនៃក្រុមប្រឹក្សាដែលឆ្លើយថា ខ្លួនពេញចិត្តដោយបានធ្វើសេចក្តីសម្រេចដោយខ្លួនឯង ដោយមិនចាំបាច់ស្នើសុំការយល់ព្រមពីថ្នាក់លើ<br>• ភាគរយនៃផែនការអភិវឌ្ឍន៍ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានដាក់បញ្ចូលនូវផែនការ និងថវិការបស់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន<br>• ភាពច្បាស់លាស់នៃគោលដៅ និងគោលបំណងនានាដែលពាក់ព័ន្ធនឹងគណនេយ្យភាព និងកម្មវិធីសាកល្បងនូវយន្តការគណនេយ្យភាពនានា<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះនានា ដែលពេញចិត្តចំពោះការបំពេញការងារនៃរដ្ឋបាលរបស់ខ្លួន<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះនានា ដែលបានកំណត់ ថាក្រុមប្រឹក្សា គឺជាអង្គដែលមានសិទ្ធិដាក់ចេញនូវបេសកកម្ម និងគោលដៅនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងបញ្ហានានា | • ដាក់ឱ្យអនុវត្តនូវព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាសទាំងឡាយ ដែលចែងពីតួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងរវាងបណ្តាថ្នាក់រដ្ឋបាលនានា នៅឆ្នាំ២០១០<br>• កំណត់នូវតួនាទី និងសិទ្ធិដែលមានលក្ខណៈសមស្របសម្រាប់ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រុមប្រឹក្សាទទួលបានសិទ្ធិអំណាចផ្ទៃក្នុងរដ្ឋបាលក្នុងការរៀបចំនីតិវិធីធ្វើការងាររបស់ខ្លួន ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន<br>• មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសចាំបាច់ដើម្បីកំណត់ និងរៀបចំរចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួន<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំនានាទាក់ទងនឹងសិទ្ធិទទួលបានព័ត៌មាន សិទ្ធិចូលរួម និងពិគ្រោះយោបល់របស់ប្រជាពលរដ្ឋនៅក្នុងការកសាងផែនការនិងថវិកា និងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| សមាសធាតុកម្មវិធីទី១ : ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី១** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| | • ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះដែលបានចូលរួមក្នុងការវាយតម្លៃការបំពេញការងាររបស់ក្រុមប្រឹក្សា និងសកម្មភាពផ្សេងៗទៀត ដូចមានកំណត់នៅផ្នែកគណនេយ្យភាព<br>• ភាគរយនៃក្រុមប្រឹក្សាដែលយកចិត្តទុកដាក់ និងគាំទ្រលើការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី។ | • ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ការងារគណនេយ្យភាពមានកំណត់ច្បាស់លាស់នៅក្នុងគោលដៅ និងគោលបំណងនានារបស់រាជរដ្ឋាភិបាល<br>• រាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការងារគណនេយ្យភាពក្នុងការអនុវត្តគោលដៅ និងគោលបំណងនានា តាមរយៈការពិនិត្យឡើងវិញនូវយន្តការនានាដែលមានស្រាប់ពាក់ព័ន្ធនឹងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ហើយប្រើប្រាស់នូវបទពិសោធន៍ទាំងនេះ ដើម្បីជាមូលដ្ឋានរៀបចំ និងសាកល្បងយន្តការគណនេយ្យភាពថ្មីៗ<br>• រាជរដ្ឋាភិបាលអនុវត្តសាកល្បងនូវយន្តការគណនេយ្យភាពអន្តររដ្ឋបាលនានា ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំ និងនីតិវិធីប្រតិបត្តិការនានា។ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ១.១. បង្កើតរចនាសម្ព័ន្ធជាមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានសមស្របតាមកម្រិតថ្នាក់រដ្ឋបាលនីមួយៗ | • រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់ស្តីពីទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធភាពរវាងឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ<br>• រៀបចំឱ្យមានប្រព័ន្ធមួយតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីជំនួសឱ្យប្រព័ន្ធគ្រប់គ្រងផ្សេងៗគ្នាដែលមាននៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | • ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានអនុម័ត និងអនុវត្ត ស្របជាមួយនឹងមុខងារ ធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវថ្មីរបស់ខ្លួន | • រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែសម្រួល និងបំពេញមុខងារពេញលេញក្នុងការសម្របសម្រួល និងអនុវត្តនូវមុខងារ ធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវថ្មី |
| ១.២. រៀបចំប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិស្តង់ដារ ដើម្បីគាំទ្រខ្សែគណនេយ្យភាពថ្មី និងការទទួលខុសត្រូវផ្នែកគ្រប់គ្រង | • បង្កើតនីតិវិធីប្រតិបត្តិស្តង់ដារសមស្របនឹងការទទួលខុសត្រូវថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងយន្តការសម្រាប់វាយតម្លៃនីតិវិធីនេះ ហើយបណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• អនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រង និងការកត់ត្រាព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត<br>• រៀបចំគោលការណ៍ គោលដៅ និងគោលបំណងនានាដែលពាក់ព័ន្ធនឹងការងារគណ | • ពិនិត្យ និងកែសម្រួលនីតិវិធីប្រតិបត្តិស្តង់ដារ និងយន្តការវាយតម្លៃនីតិវិធីនេះ<br>• ដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់នូវប្រព័ន្ធគ្រប់គ្រង និងកត់ត្រាព័ត៌មានរបស់រដ្ឋបាលថ្នាក់រាជធានី ខេត្ត<br>• ពិនិត្យមើលឡើងវិញនូវការអនុវត្តសាកល្បង ដើម្បីរៀបចំយន្តការគណនេយ្យភាពថ្មី សម្រាប់អនុវត្ត និងជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំ និងនីតិវិធីប្រតិបត្តិការនានា | • បន្តពិនិត្យ និងកែសម្រួលនីតិវិធីប្រតិបត្តិស្តង់ដារ និងយន្តការវាយតម្លៃនីតិវិធីនេះ<br>• ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង និងការកត់ត្រាព័ត៌មាននៅរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំយន្តការគណនេយ្យភាពថ្មី និងប្រព័ន្ធតាមដានការអនុវត្តការងារ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | នេយ្យភាព ព្រមទាំងពិនិត្យឡើងវិញនូវយន្តការគណនេយ្យភាពនានាដែលមានស្រាប់ និងអនុវត្តសាកល្បង | | |
| ១.៣. រៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីនានាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ | • រៀបចំសេចក្តីណែនាំស្តីពីសិទ្ធិ និងការចូលរួមរបស់ប្រជាពលរដ្ឋ និងបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសេចក្តីណែនាំ និងនីតិវិធីស្តីពីសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ និងការផ្សព្វផ្សាយព័ត៌មានសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងអនុវត្តគម្រោងសាកល្បង អំពីវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ និងវិធីសាស្ត្រផ្សេងទៀត នៃការចូលរួមរបស់សាធារណជនក្នុងកិច្ចប្រជុំ និងការធ្វើសេក្តីសម្រេចរបស់ក្រុមប្រឹក្សា | • រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំកម្មវិធីច្បាស់លាស់សម្រាប់ការលើកកម្ពស់សិទ្ធិ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចនៅមូលដ្ឋាន<br>• រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តកម្មវិធីអប់រំផ្សព្វផ្សាយដល់សាធារណជនអំពីសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិក្នុងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចមូលដ្ឋាន<br>• ពង្រឹងកិច្ចដំណើរការវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ និងវិធីសាស្ត្រផ្សេងទៀតនៃការចូលរួមរបស់សាធារណជនក្នុងកិច្ចប្រជុំ និងការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា | • អភិវឌ្ឍព័ត៌មានវិទ្យាក្នុងការគាំទ្រព័ត៌មានសាធារណៈ និងកម្មវិធីចូលរួមរបស់ប្រជាពលរដ្ឋ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ១.៤. រៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធទំនាក់ទំនងអន្តររដ្ឋបាល | • រៀបចំសេចក្តីណែនាំស្តីពីការបង្កើតប្រព័ន្ធគ្រប់គ្រងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រព័ន្ធទំនាក់ទំនងអន្តររដ្ឋបាល | • រៀបចំ និងអនុវត្តនូវទំនាក់ទំនងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ (ដូចជាកិច្ចព្រមព្រៀងសេវាសាធារណៈរវាងស្រុក និងឃុំសង្កាត់) និងទំនាក់ទំនងអន្តររដ្ឋបាលឱ្យស្របតាមតម្រូវការជាក់ស្តែង | • ពិនិត្យវាយតម្លៃ និងកែលម្អនូវទំនាក់ទំនងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងទំនាក់ទំនងអន្តររដ្ឋបាល |
| ១.៥. ដាក់បញ្ចូលស្តង់ដារសមភាព និងសមធមិយេនឌ័រទៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | • រៀបចំ និងបណ្តុះបណ្តាលសេចក្តីណែនាំ និងនីតិវិធីស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • រៀបចំ និងអនុវត្តនីតិវិធីសវនកម្មយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • ពិនិត្យ និងវាយតម្លៃដើម្បីកែលម្អនីតិវិធីសវនកម្មយេនឌ័រ |
| ១.៦. ដាក់ឱ្យអនុវត្តនូវកម្មវិធីព័ត៌មានវិទ្យា និងទំនាក់ទំនងតាមប្រព័ន្ធព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • សិក្សាវាយតម្លៃសមត្ថភាពផ្នែកព័ត៌មានវិទ្យា និងទំនាក់ទំនងតាមប្រព័ន្ធព័ត៌មានវិទ្យារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំផែនការស្តីពីព័ត៌មានវិទ្យា និងទំនាក់ទំនងតាមប្រព័ន្ធព័ត៌មានវិទ្យា សំដៅឆ្លើយតបទៅនឹងការទទួលខុសត្រូវថ្មី | • រៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនូវផែនការគ្រប់គ្រងស្ថាប័នដោយប្រើប្រាស់ព័ត៌មានវិទ្យានៅរាជធានី ខេត្ត<br>• ដាក់ឱ្យអនុវត្តនូវផែនការគ្រប់គ្រងស្ថាប័នដោយប្រើប្រាស់ព័ត៌មានវិទ្យានៅរាជធានី និងគ្រប់ខេត្ត | • រៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនូវផែនការគ្រប់គ្រងស្ថាប័នដោយប្រើប្រាស់ព័ត៌មានវិទ្យានៅថ្នាក់ក្រុង ស្រុក ខណ្ឌ<br>• រៀបចំ និងអនុវត្តការគាំទ្រសមត្ថភាព និងផែនការពាក់ព័ន្ធនឹងព័ត៌មានវិទ្យា និងទំនាក់ទំនងតាមព័ត៌មានវិទ្យានៅរដ្ឋបាលថ្នាក់ក្រោមជាតិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ១.៧. រៀបចំ និងអនុវត្តនូវកម្មវិធីសម្រាប់ដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការកសាងផែនការ ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • រៀបចំក្របខ័ណ្ឌជាតិស្តីពីការសិក្សាវាយតម្លៃអំពីការសម្របសម្រួលទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ<br>• វាយតម្លៃសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំផែនការសម្របសម្រួល និងកាត់បន្ថយបញ្ហាប្រែប្រួលអាកាសធាតុ<br>• រៀបចំសេចក្តីណែនាំ នីតិវិធី និងបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • រដ្ឋបាលថ្នាក់ក្រោមជាតិអនុម័ត និងអនុវត្តផែនការសម្របសម្រួល និងកាត់បន្ថយបញ្ហាប្រែប្រួលអាកាសធាតុ | |

## ៣.២. សមាសធាតុកម្មវិធីទី២ ៖ ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

### ៣.២.១. សនិទានភាព

សមាសធាតុកម្មវិធីទី២ លើកឡើងអំពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ដំណើរការរៀបចំស្ថាប័នដូចដែលមានចែងក្នុងសមាសធាតុកម្មវិធីទី១។ ដើម្បីសម្រេចបាននូវគោលបំណងរបស់សមាសធាតុកម្មវិធីនេះ សកម្មភាពនានាត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងកិច្ចការចំនួនបី គឺ (១)ការផ្ទេរជាបន្តបន្ទាប់នូវបុគ្គលិករបស់ក្រសួង ស្ថាប័ន ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិស្របជាមួយការផ្ទេរមុខងារ និងធនធាន និងការជ្រើសរើសបុគ្គលិកដោយក្រុមប្រឹក្សា (២)ការបង្កើតគោលនយោបាយ នីតិវិធី និងកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក និង (៣)ការកសាងសមត្ថភាព និងកម្មវិធីចាំបាច់ក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចអភិវឌ្ឍធនធានមនុស្ស។ សកម្មភាពទាំងនេះរៀបចំឡើងដោយផ្អែកតាមការប្តេជ្ញាចិត្តខាងគោលនយោបាយ ពោលគឺរដ្ឋបាលថ្នាក់ក្រោមជាតិនឹងកាន់តែមានសិទ្ធិក្នុងការគ្រប់គ្រង ចាត់ចែងបុគ្គលិករបស់ខ្លួន។

ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកត្តាចាំបាច់សម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សនឹងពង្រឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដោយឈរលើមូលដ្ឋានច្បាប់ ដែលក្នុងនោះមានដូចជា ការតែងតាំង និងការប្រគល់មុខងារដល់មន្ត្រីត្រូវមានតម្លាភាព ការដំឡើងថ្នាក់ ឋានន្តរសក្តិដោយផ្អែកលើលទ្ធផលនៃការបំពេញការងារ និងការប្រើប្រាស់នូវវិធានការដាក់ពិន័យ។ ប្រព័ន្ធនេះនឹងនាំឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗនូវរបៀបរបបការងាររបស់មន្ត្រីរាជការ ពីការគ្រាន់តែបំពេញការងាររបស់ខ្លួនឱ្យរួចតាមការកំណត់ដោយមិនគិតពីលទ្ធផល ប្រសិទ្ធភាព និងការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាសាធារណៈ ទៅជាអ្នកផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព។

ស្របជាមួយនឹងការធ្វើស្ថាប័នភាវូបនីយកម្មនូវរបៀបរបបថ្មីនៃការគ្រប់គ្រងធនធានមនុស្ស ចាំបាច់ត្រូវកំណត់និងរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ដែលនឹងបង្កើតឱ្យមានវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ តាមរយៈការអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្សនឹងកសាងសមត្ថភាពដល់អង្គភាពគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានលទ្ធភាពអភិវឌ្ឍធនធានមនុស្សទៅតាមតម្រូវការជាក់ស្តែងរបស់ខ្លួន។ អាស្រ័យហេតុនេះ អង្គភាពគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាពក្នុងការកំណត់អំពីតម្រូវការនានានៃការអភិវឌ្ឍសមត្ថភាពសម្រាប់ការអនុវត្តកម្មវិធីជាតិនៅក្នុងដំណាក់កាលទី២។

### ៣.២.២. គោលបំណងសមាសធាតុកម្មវិធី

សមាសធាតុកម្មវិធីទី២ មានគោលបំណងដើម្បីរៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។

### ៣.២.៣. ការធានាអាទិភាពនានា

**ក). ដំណាក់កាលទី១ : រៀបចំតាក់តែងក្របខ័ណ្ឌច្បាប់សម្រាប់មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងឆ្នាំដំបូងៗ សកម្មភាពកម្មវិធីនឹងផ្តោតលើការរៀបចំបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការជាមូលដ្ឋានដើម្បីសម្របសម្រួលដល់ការផ្ទេរបុគ្គលិក នៅពេលដែលមុខងារត្រូវបានប្រគល់ ឬធ្វើប្រតិភូកម្ម និងដើម្បីអនុញ្ញាតឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិក្នុងការវាយតម្លៃការបំពេញការងារ និងការផ្តល់ប្រាក់ឧបត្ថម្ភដល់បុគ្គលិកទាំងនោះ។ ដើម្បីធានាឱ្យក្រុមប្រឹក្សាអាចគ្រប់គ្រងមន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាពបាន ចាំបាច់ត្រូវមានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តនានាដើម្បីអនុវត្តលក្ខន្តិកៈដោយឡែកនេះ។

**ខ). ដំណាក់កាលទី២ : កសាងសមត្ថភាពដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស**

ក្នុងឆ្នាំជាបន្តបន្ទាប់ សកម្មភាពនានាត្រូវផ្តោតជាសំខាន់ទៅលើការកសាងសមត្ថភាពរបស់អង្គភាពគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យអង្គភាពនេះមានសមត្ថភាពក្នុងការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស។

### ៣.២.៤. ក្របខ័ណ្ឌតក្កភាព

ក្របខ័ណ្ឌតក្កភាពសម្រាប់សមាសធាតុកម្មវិធីទី២ មាននៅក្នុងតារាងក្របខ័ណ្ឌតក្កភាព ៣.២។

## តារាង៣.២ : ក្របខំណត្តក្កភាពនៃសមាសធាតុកម្មវិធីទី២

| សមាសធាតុកម្មវិធីទី២ : ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស | | |
|---|---|---|
| **គោលដៅសមាសធាតុកម្មវិធីទី២** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| រៀបចំឱ្យមានមន្ត្រីរាជការស៊ីវិលប្រកបដោយវិជ្ជាជីវៈ និងមានឆន្ទៈមោះមុតក្នុងការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា និងគ្រប់គ្រងដោយក្រុមប្រឹក្សា។ | • ភាគរយនៃអ្នកធ្វើការទាំងពីរភេទនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវតែងតាំងជាបុគ្គលិករបស់ក្រុមប្រឹក្សា<br>• ភាគរយនៃមន្ត្រីរាជការស៊ីវិលទាំងពីរភេទទទួលបានការបណ្តុះបណ្តាល<br>• ភាគរយនៃស្ត្រីដែលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃស្ត្រីដែលត្រូវបានដំឡើងថ្នាក់ ឋានន្តរសក្តិ និងការតែងតាំងក្នុងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលរាយការណ៍ថា បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិយកចិត្តទុកដាក់ក្នុងការបម្រើ និងគោរពសិទ្ធិរបស់ប្រជាពលរដ្ឋ<br>• ភាគរយនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានចំណាយសម្រាប់ការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ។ | • ធ្វើសមាហរណកម្មបុគ្គលិកក្រសួងមហាផ្ទៃ ដែលសព្វថ្ងៃកំពុងបំពេញការងារនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិសមស្របណាមួយ ដោយភ្ជាប់ជាមួយនូវការធ្វើប្រតិភូកម្មក្នុងការគ្រប់គ្រងមន្ត្រីទាំងនោះ នៅឆ្នាំ២០១០<br>• ដាក់ចេញនូវព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងដំណាក់កាលទី១នៃកម្មវិធីជាតិ<br>• គ.ជ.អ.ប ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវសហការសម្របសម្រួលរៀបចំយុទ្ធសាស្ត្រសម្រាប់កែសម្រួលប្រព័ន្ធលើកទឹកចិត្តជាបណ្តើរៗ ដើម្បីឈានទៅប្រើប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍បុគ្គលិកដែលផ្អែកតាមសមត្ថភាព និងស្នាដៃរបស់មន្ត្រីម្នាក់ៗ<br>• គ.ជ.អ.ប សម្របសម្រួលឱ្យមានការរៀបចំ និងការដាក់ចេញនូវព្រះរាជក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដែលផ្តល់អំណាចឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិកាន់តែច្រើនឡើងលើការគ្រប់គ្រងបុគ្គលិក (ដូចជាការជ្រើសរើស ការដំឡើងថ្នាក់ ឋានន្តរសក្តិ ការតែងតាំង ការលើកសរសើរ ការដាក់ពិន័យ និងការបញ្ឈប់ពីការងារ) |

| | | |
|---|---|---|
| | | • ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ២.១. រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ ដើម្បីផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង និងចាត់ចែងមន្ត្រី បុគ្គលិករបស់ខ្លួន តាមរយៈការបង្កើតនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស | • រៀបចំលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងការគ្រប់គ្រងធនធានមនុស្ស និងការគាំទ្រដល់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កើតប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងប្រាក់បៀវត្សរ៍ ប្រាក់ឧបត្ថម្ភ និងកំណត់ត្រាប្រវត្តិការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិកំណត់អំពីមុខតំណែង ល័ក្ខខ័ណ្ឌការងារ និងការពិពណ៌នាការងារបុគ្គលិករបស់ខ្លួន<br>• ដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី | • សិក្សាវាយតម្លៃ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការទទួលបានឱកាសស្មើភាពក្នុងការធ្វើការងារ<br>• រៀបចំឱ្យមានកម្មវិធីត្រួតពិនិត្យឡើងវិញនូវការធ្វើចំណាត់ថ្នាក់ និងការប្រគល់មុខតំណែងដល់បុគ្គលិក ដើម្បីគាំទ្រដល់ការផ្ទេរមុខងារ និងកិច្ចដំណើរការត្រួតពិនិត្យឡើងវិញនូវប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក<br>• បង្កើតឱ្យមានកម្មវិធីប្រចាំឆ្នាំដើម្បីពិនិត្យមើលឡើងវិញនូវការបំពេញការងារផ្អែកតាមស្នាដៃរបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • ដាក់ឱ្យប្រើប្រាស់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានដំណើរការយ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាព<br>• ពិនិត្យ និងកែសម្រួលសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | | • បង្កើតកម្មវិធីលើកកម្ពស់ការបំពេញការងាររបស់បុគ្គលិកសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិនិត្យ និងកែសម្រួលសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី | |
| ២.២. បុគ្គលិករបស់ក្រសួង ស្ថាប័ននានាត្រូវបានរៀបចំឡើងវិញ ដោយផ្អែកលើមុខងារដែលបានផ្ទេរតាមរយៈដំណើរការមួយប្រកបដោយតម្លាភាព | • ក្រសួង ស្ថាប័នកសាងផែនការរៀបចំបុគ្គលិកដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់គាំទ្រដល់ការរៀបចំបុគ្គលិករបស់ខ្លួនឡើងវិញ<br>• ក្រសួង ស្ថាប័នអនុវត្តការផ្ទេរបុគ្គលិករបស់ខ្លួនស្របជាមួយនឹងការផ្ទេរមុខងារ | • ក្រសួង ស្ថាប័នរៀបចំផែនការបុគ្គលិករយៈពេលវែង និងបន្តផ្ទេរបុគ្គលិកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមយុទ្ធសាស្ត្រផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន(ពាក់ព័ន្ធជាមួយសមាសធាតុកម្មវិធីទី៣) | • ធ្វើបច្ចុប្បន្នភាពនូវផែនការបុគ្គលិកឱ្យស្របតាមការផ្ទេរមុខងារ |
| ២.៣. បង្កើតឱ្យមានកម្មវិធីសម្រាប់ការអភិវឌ្ឍធនធានមនុស្ស | • រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំ និងអនុម័តយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្ស<br>• បង្កើតឱ្យមានកម្មវិធីវាយតម្លៃសមត្ថភាពធនធានមនុស្សដើម្បីគាំទ្រកម្មវិធីអភិវឌ្ឍន៍បុគ្គលិក | • បង្កើត អនុវត្ត និងវាយតម្លៃឱ្យបានទៀងទាត់នូវកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈនៃការកសាងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិបញ្ចូលកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័ន<br>• ជ្រើសរើសរដ្ឋបាលថ្នាក់ក្រោមជាតិមួយ | • សិក្សាវាយតម្លៃ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធដំឡើងថ្នាក់ ឋានន្តរសក្តិ និងការតែងតាំងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកតាមសមត្ថភាព និងលទ្ធផលការងារ<br>• បង្កើតឱ្យមានកម្មវិធីធ្វើការងារជាក្រុមរបស់បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បី |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | | ចំនួនដើម្បីអនុវត្តកម្មវិធីកសាងអាជីព ដោយផ្អែកតាមសមត្ថកិច្ច | លើកកម្ពស់ដល់គោលការណ៍នៃការផ្តល់សេវាសាធារណៈនិងការបំពេញការងាររបស់បុគ្គលិកប្រកបដោយវិជ្ជាជីវៈ ព្រមទាំងការយកចិត្តទុកដាក់អំពីសមភាពយេនឌ័រ |
| ២.៤. បញ្ជ្រាបយេនឌ័រក្នុងកម្មវិធីគ្រប់គ្រងធនធានមនុស្ស និងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព | • រៀបចំ និងអនុវត្តសេចក្តីណែនាំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ និងឱកាសការងារដល់ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បញ្ជ្រាបគោលនយោបាយសមភាពយេនឌ័រនៅក្នុងប្រព័ន្ធគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កើតឱ្យមានកម្មវិធីលើកកម្ពស់ស្ត្រីដើម្បីចូលរួមក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងជាពិសេសតួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេច | • ធ្វើសវនកម្មទៅលើវឌ្ឍនភាពនៃការអនុវត្តការបញ្ជ្រាបយេនឌ័រនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• អនុវត្តសមភាពយេនឌ័រនៅក្នុងចំណោមបុគ្គលិកដែលបានជ្រើសរើស និងនៅក្នុងការដំឡើងថ្នាក់ ឋានន្តរសក្តិ<br>• បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកសាងសមត្ថភាពទាក់ទងនឹងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី | • សិក្សាវាយតម្លៃការបំពេញការងាររបស់បុគ្គលិកពាក់ព័ន្ធនឹងការលើកកម្ពស់សមភាពយេនឌ័រ<br>• បង្កើត និងអនុវត្តកម្មវិធីផ្តល់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកទាំងពីរភេទដែលមានស្នាដៃក្នុងការងារយេនឌ័រ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ២.៥. បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបាននូវការលើកកម្ពស់ឱ្យក្លាយជាបុគ្គលិកប្រកបដោយវិជ្ជាជីវៈ | • ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីដែលបានធ្វើសមាហរណកម្មទៅក្នុងអង្គភាពនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានសមត្ថភាពក្នុងការឆ្លើយតបការទទួលខុសត្រូវថ្មីរបស់ស្ថាប័ន | • ផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់មន្ត្រីដែលមានមុខតំណែងសំខាន់ៗនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កើត និងអនុវត្តកម្មវិធីសិក្សាកម្រិតខ្ពស់ទាក់ទងនឹងការងារគ្រប់គ្រងរដ្ឋបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • ផ្តល់សមត្ថភាពនូវភាពជាអ្នកដឹកនាំផ្នែករដ្ឋបាល និងប្រតិបត្តិការដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ |

## ៣.៣. សមាសធាតុកម្មវិធីទី៣ : ការផ្ទេរមុខងារ

### ៣.៣.១. សនិទានភាព

កម្មវិធីផ្ទេរមុខងាររួមមានទិដ្ឋភាពសំខាន់ពីរគឺ : ទិដ្ឋភាពទីមួយទាក់ទងនឹងដំណើរការផ្ទេរមុខងារ និងទីពីរទាក់ទងនឹងតម្រូវការផ្នែកស្ថាប័នដែលចាំបាច់ ដើម្បីបន្តលើកកម្ពស់ការកែលម្អគុណភាពសេវាសាធារណៈ ដែលទាក់ទងនឹងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្ទេរមុខងារ។ ពាក់ព័ន្ធនឹងទិដ្ឋភាពទីមួយ កិច្ចដំណើរការដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់ការពិនិត្យមើលឡើងវិញនូវមុខងារដែលបានអនុម័តដោយ គ.ជ.អ.ប ត្រូវស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំមុខងារ ដែលជាវិធីសាស្ត្ររួមមួយដ៏សំខាន់សម្រាប់ក្រសួង ស្ថាប័នទាំងអស់យកទៅប្រើប្រាស់ និងដកស្រង់បទពិសោធន៍។ ការរៀបចំកិច្ចដំណើរការសម្រាប់ការពិនិត្យមើលមុខងារឡើងវិញនេះ នឹងមិនធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការផ្ទេរមុខងារជាបឋមក្នុងឆ្នាំ២០១០ ទៅឱ្យក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

ការអនុវត្តសកម្មភាពចាំបាច់នានាទាក់ទងនឹងការផ្ទេរមុខងារ និងការធ្វើស្ថាប័នភាវូបនីយកម្មដើម្បីបន្តលើកកម្ពស់សេវាសាធារណៈ ទាមទារឱ្យមានការសម្របសម្រួលជាមួយនឹងយុទ្ធសាស្ត្រតាមវិស័យសម្រាប់ការលើកកម្ពស់សេវាសាធារណៈ។ ការសម្របសម្រួលនេះ ត្រូវធ្វើឡើងតាមរយៈអនុគណៈកម្មាធិការមុខងារ និងធនធានរបស់ គ.ជ.អ.ប និងក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន ដោយមានការគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប។ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានតំណាងរបស់ខ្លួននៅក្នុងអនុគណៈកម្មាធិការមុខងារ និងធនធានរបស់ គ.ជ.អ.ប នឹងមានលទ្ធភាពទាមទារ និងការពារផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការលើកកម្ពស់សេវាសាធារណៈ គឺជាដំណើរការដែលមានលក្ខណៈពីក្រោមឡើងលើ ដូច្នេះត្រូវរៀបចំយន្តការគណនេយ្យភាពនានាដែលមានភាពរឹងមាំ ដើម្បីធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋ និងសង្គមស៊ីវិល អាចប្រើប្រាស់នូវយន្តការទាំងនេះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាទាំងនេះ។

#### ក). ការផ្ទេរមុខងារ

មុខងារ គឺជាសកម្មភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ តាមរយៈទង្វើប្រកបដោយនិរន្តរភាព ហើយផ្តល់ផលប្រយោជន៍ដល់សហគមន៍។ ការផ្ទេរមុខងារត្រូវអនុវត្តដោយភ្ជាប់ជាមួយនូវ :

- ការទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងការកំណត់ និងឆ្លើយតបចំពោះតម្រូវការដែលមិនទាន់បានបំពេញ និងចំពោះហានិភ័យនានាដែលទាក់ទងនឹងមុខងារនោះ
- សិទ្ធិតាមផ្លូវច្បាប់ក្នុងការត្រួតពិនិត្យ បញ្ជា ឬកំណត់អំពីសកម្មភាពចាំបាច់នានា ដើម្បីសម្រេចបាននូវការទទួលខុសត្រូវដែលបានផ្ទេរ ហើយដែលសកម្មភាពទាំងនេះគ្របដណ្តប់លើបញ្ហាជាច្រើន ដូចជាការរៀបចំគោលនយោបាយ ការកំណត់និងការអនុវត្តកម្មវិធី និងការផ្តល់សេវាសាធារណៈ។

ការផ្ទេរមុខងារឱ្យទៅក្រុមប្រឹក្សាប្រភេទណាមួយ ត្រូវផ្អែកតាមគោលការណ៍ដូចមានចែងក្នុងមាត្រា២២០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៤៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដូច្នេះ ចាំបាច់ត្រូវធានាថា គោលការណ៍នៃការផ្ទេរមុខងារនេះ មិនរារាំងដល់ការផ្ទេរមុខងារឱ្យទៅឃុំ សង្កាត់ឡើយ។

ការផ្ទេរមុខងារនឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើដំណើរការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានអធិប្បាយនៅក្នុងសមាសធាតុកម្មវិធីទី១។ ដូចនេះ ក្នុងការរៀបចំបង្កើតគោលនយោបាយនៃការផ្ទេរមុខងារ ត្រូវវិភាគឱ្យបានស៊ីជម្រៅ ដោយសាររដ្ឋបាលថ្នាក់ផ្សេងគ្នាមានគោលបំណងផ្សេងៗគ្នា និងមានស្ថានភាពខុសៗគ្នាដូចជា សេដ្ឋកិច្ចវិមាត្រ ភាពស័ក្តិសិទ្ធិនៃការវិភាជន៍ធនធាន និងផលប៉ះពាល់ដែលហួសពីព្រំដែនរបស់រដ្ឋបាលនោះ។

បទពិសោធន៍កន្លងមកបានបង្ហាញឱ្យឃើញថា មុខងារត្រូវបានផ្ទេរតាមបែបវិសហមជ្ឈការប្រសើរជាងតាមបែបវិមជ្ឈការ គឺចំពោះមុខងារដែលមានផលប៉ះពាល់លើសពីដែនសមត្ថកិច្ចរបស់ខេត្តមួយ(ឧទាហរណ៍ គុណភាពទឹក ឬគុណភាពខ្យល់) ឬដំណោះស្រាយដែលមានលក្ខណៈច្នៃប្រឌិតឬមិនទាន់បានសាកល្បង ឬដំណោះស្រាយដែលនៅមិនទាន់ដឹងច្បាស់ ឬការឆ្លើយតបដែលផ្តោតជាសំខាន់ទៅលើភាពស័ក្តិសិទ្ធិ។ ផ្ទុយទៅវិញ មុខងារដែលបានផ្ទេរតាមបែបវិមជ្ឈការប្រសើរជាងតាមបែបវិសហមជ្ឈការ គឺចំពោះបញ្ហាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចជាក់លាក់របស់រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ ការគ្រប់គ្រងការរីកលូតលាស់នៃទីប្រជុំជន ឬការផ្គត់ផ្គង់ទឹកស្អាត) ឬបញ្ហាដែលមានលក្ខណៈខុសៗគ្នាតាមតំបន់ ឬបញ្ហាដែលមានផលប៉ះពាល់តែនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ ផ្លូវលំជនបទ) ឬដំណោះស្រាយត្រូវបានសាកល្បងរួចមកហើយ ឬការឆ្លើយតបដែលផ្តោតទៅលើភាពស័ក្តិសិទ្ធិឬដែលមានសារៈសំខាន់ជាងភាពស័ក្តិសិទ្ធិ។

ដំណើរការនៃការពិនិត្យមើលឡើងវិញនូវមុខងារ ត្រូវធ្វើឡើងក្នុងលក្ខណៈជាប្រព័ន្ធ មានសនិទានភាព មាននិរន្តរភាព និងផ្អែកលើគោលការណ៍នីតិរដ្ឋ។ ដំណើរការទូទៅនៃការពិនិត្យមើលមុខងារនេះ ត្រូវផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវមុខងារ និងត្រូវមានវិធីសាស្ត្ររួមដែលអាចប្រើប្រាស់បាន ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យក្រសួង ស្ថាប័ននានាអាចដកស្រង់នូវបទពិសោធន៍ពីគ្នាទៅវិញទៅមក។ ការផ្ទេរមុខងារជាក់ស្តែងត្រូវធ្វើឡើងស្របជាមួយនឹង :

- ការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (សមាសធាតុកម្មវិធីទី១)
- ការផ្ទេរបុគ្គលិក និងការបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិក(សមាសធាតុកម្មវិធីទី២) និង
- ការផ្ទេរធនធានហិរញ្ញវត្ថុ និងការបង្កើតប្រព័ន្ធគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិ (សមាសធាតុកម្មវិធីទី៤)។

ក្រសួង ស្ថាប័ននានាត្រូវកែសម្រួលបេសកកម្ម ការចាត់ចែងការងារ និងនីតិវិធីរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្ទេរការទទួលខុសត្រូវ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយត្រូវធានាថា សកម្មភាពទាំងនេះអនុវត្តតាមមធ្យោបាយមួយដែលមានលក្ខណៈជាប្រចាំ មានការសម្របសម្រួល និងមានការពិគ្រោះយោបល់ ព្រមទាំងធ្វើឡើង

ដោយមានការវិភាគបច្ចេកទេសត្រឹមត្រូវ។ ការផ្ទេរមុខងារជាក់ស្តែងត្រូវធ្វើឡើងស្របជាមួយនឹងវដ្តនៃការរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីធានាឱ្យធនធានហិរញ្ញវត្ថុត្រូវបានដាក់បញ្ចូលទៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការផ្ទេរមុខងារជាក់ស្តែងនីមួយៗ ត្រូវបញ្ជាក់ឱ្យបានជាក់លាក់អំពីមុខងារដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ណាមួយ។ ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា គឺជាផ្នែកមួយនៃផែនការសកម្មភាពផ្នែកច្បាប់ដែលត្រូវរៀបចំដោយ គ.ជ.អ.ប ដូចមានអធិប្បាយនៅក្នុងសមាសធាតុកម្មវិធីទី៥។

## ខ). កម្មវិធីលើកកម្ពស់សេវាសាធារណៈ

ការផ្ទេរមុខងារមានគោលបំណងជំរុញឱ្យបរិមាណ គុណភាព និងការផ្តល់សេវាសាធារណៈបានកាន់តែល្អប្រសើរដល់ប្រជាពលរដ្ឋ ហេតុនេះទាមទារឱ្យមានការបង្កើតរចនាសម្ព័ន្ធចាំបាច់សម្រាប់ការ ប្រើប្រាស់ធនធាននានាប្រកបដោយប្រសិទ្ធភាព។ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគិតគូរអំពី សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះក្នុងការបន្តលើកកម្ពស់ការផ្តល់សេវាសាធារណៈប្រកបដោយនិរន្តរភាព។ អាស្រ័យហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវបង្កើតយន្តការ និងកម្មវិធីនានា ដើម្បីបន្តចាត់ចែងកែលម្អសេវាសាធារណៈទាំងនោះឱ្យកាន់តែប្រសើរឡើង។ យន្តការ និងកម្មវិធីទាំងនេះអាចធ្វើឡើងតាមមធ្យោបាយផ្សេងៗ ដូចជា កិច្ចសហការជាមួយអង្គការសង្គមស៊ីវិល ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជន និងការចុះកិច្ចព្រមព្រៀងជាមួយអង្គភាពរដ្ឋបាលផ្សេងៗទៀតក្នុងការផ្តល់សេវាសាធារណៈ។ ការសម្រេចចិត្តនានាទាក់ទងនឹងបរិមាណ គុណភាព និងអាទិភាពនៃសេវាសាធារណៈត្រូវផ្អែកតាមតម្រូវការរបស់ប្រជាពលរដ្ឋតាមរយៈដំណើរការនៃការចូលរួមប្រកបដោយតម្លាភាព។ ដូច្នេះ យន្តការនានាដើម្បីធានាឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរួមបញ្ចូលនូវវិធានការដាក់វិន័យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្តល់សេវាសាធារណៈមិនបានសមស្រប។

កម្រិតនៃការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិទៅលើគុណភាពសេវាសាធារណៈ គឺអាស្រ័យទៅលើវិធីនៃការផ្ទេរមុខងារទាំងនោះ។ ចំពោះមុខងារដែលផ្ទេរដោយប្រតិភូកម្ម ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នដែលកំពុងបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែកចំពោះមុខងារដែលផ្ទេរដោយការប្រគល់ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការទទួលខុសត្រូវជាអតិបរមាក្នុងការបំពេញមុខងារនោះ។

## ៣.៣.២. គោលបំណងសមាសធាតុកម្មវិធី

សមាសធាតុកម្មវិធីទី៣ មានគោលបំណងដើម្បីលើកកម្ពស់បរិមាណ និងគុណភាពសេវាសាធារណៈតាមរយៈការផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារទាំងនោះ។

### ៣.៣.៣. ការងារជាអាទិភាពនានា

### ក). ដំណាក់កាលទី១

### ក.១). ការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការផ្ទេរមុខងារ

ការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងការផ្ទេរមុខងារ ដោយផ្តោតទៅលើប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងស្របតាមគោលការណ៍នានាសម្រាប់ការផ្ទេរមុខងារ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ពិតជាមានសារៈសំខាន់ណាស់។ គោលនយោបាយនេះត្រូវអនុម័តដោយរាជរដ្ឋាភិបាលផ្អែកតាមការផ្តល់យោបល់របស់ គ.ជ.អ.ប។ មូលដ្ឋានសម្រាប់រៀបចំគោលនយោបាយនេះមានរៀបរាប់នៅក្នុងផ្នែក១.២ ជំពូកទី១។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការក្នុងតួនាទីជាអ្នកផ្តល់យោបល់ទៅលើការប្រើប្រាស់ធនធានថវិកា ត្រូវចូលរួមក្នុងការរៀបចំគោលនយោបាយនេះ ដោយផ្អែកលើទស្សនៈវិស័យអភិវឌ្ឍន៍ច្បាស់លាស់។ ជាមួយគ្នានេះដែរ យន្តការមួយចំនួនត្រូវបង្កើតឡើងដើម្បីពិនិត្យឡើងវិញ វិភាគ និងកំណត់អំពីមុខងារដែលត្រូវផ្ទេរឱ្យទៅថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរៀបចំគោលនយោបាយនេះក៏ត្រូវគិតគូរអំពីការផ្ទេរមុខងារជាបឋមដល់ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

### ក.២). ការរៀបចំ និងការផ្ទេរមុខងារជាបឋមទៅឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

មេរៀនបទពិសោធន៍នានាដែលទទួលបានតាមរយៈមុខងារដែលបានអនុវត្តនៅថ្នាក់ក្រោមជាតិ រួមទាំងថ្នាក់ឃុំ សង្កាត់ក្នុងរយៈពេលកន្លងមកនឹងត្រូវបានរៀបចំចងក្រងយ៉ាងច្បាស់លាស់។ ព័ត៌មានដែលប្រមូលបាននេះនឹងក្លាយជាមូលដ្ឋានក្នុងការរៀបចំមុខងារជាបឋមនានាសម្រាប់ផ្ទេរឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ អាចអនុវត្តបណ្តើររៀនសូត្របណ្តើរក្នុងបរិយាកាសថ្មីនៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។

### ក.៣). ធានាថា ការផ្ទេរមុខងាររួមទាំងការផ្ទេរធនធាន សិទ្ធិអំណាច និងការទទួលខុសត្រូវ ត្រូវបានធ្វើឡើងដោយមានភាពជាដៃគូជាមួយក្រសួង ស្ថាប័ន ព្រមទាំងផ្អែកលើវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ និងទាន់ពេលវេលា

ដំណើរការពិនិត្យមើលមុខងារឡើងវិញ ត្រូវមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អនុគណៈកម្មាធិការមុខងារនិងធនធានរបស់ គ.ជ.អ.ប ក្រសួង ស្ថាប័នជាសមាជិកតាមរយៈក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ និងយន្តការគាំទ្រនានារបស់ គ.ជ.អ.ប។ ក្នុងការវិភាគមុខងារសម្រាប់ផ្ទេរ ត្រូវកំណត់ថា មុខងារនោះជាមុខងារជាកាតព្វកិច្ច ឬមុខងារជាជម្រើស។ គ.ជ.អ.ប ត្រូវរៀបចំ និងអនុវត្តនូវដំណើរការដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់ការពិនិត្យមើលឡើងវិញនូវមុខងារ ហើយត្រូវផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំឡើងវិញនូវមុខងារ

និងវិធីសាស្ត្ររួមដែលអាចឱ្យក្រសួង ស្ថាប័នទាំងអស់ប្រើប្រាស់ និងរៀនសូត្រពីគ្នាទៅវិញទៅមក។ ការរៀបចំគោលនយោបាយនេះ ក៏ត្រូវគិតគូរអំពីការផ្ទេរមុខងារជាបឋមដល់ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

មុខងារទាំងឡាយដែលត្រូវផ្ទេរក្នុងដំណាក់កាលទី១នៃកម្មវិធីជាតិ មានលក្ខណៈដូចខាងក្រោម :

- មុខងារប្រតិភូកម្មដែលបាន និងកំពុងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងមុខងារដែលកំពុងអនុវត្តក្នុងគម្រោងសាកល្បងនានា ដូចជាគម្រោងការិយាល័យច្រកចេញចូលតែមួយ និងកម្មវិធីពង្រឹងតួនាទីថ្នាក់ក្រុង ស្រុក ខណ្ឌ
- មុខងារដែលមានប្រភពធនធាន ដូចជាកម្រៃ ឬមូលនិធិនានាដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចប្រមូលបានដើម្បីអនុវត្តមុខងារនោះ
- មុខងារដែលងាយស្រួលក្នុងការកំណត់អំពីបុគ្គលិកដើម្បីផ្ទេរ
- មុខងារដែលពុំទាមទារឱ្យមានបច្ចេកទេសស្មុគស្មាញក្នុងការអនុវត្តមុខងារនោះ
- មុខងារដែលជាអាទិភាពខ្ពស់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- មុខងារដែលជាតម្រូវការផ្នែករដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលយកចិត្តទុកដាក់ដល់ការគ្រប់គ្រងហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

### ក.៤). បន្តគាំទ្រដល់ក្រសួង ស្ថាប័ន

នៅពេលដែលការផ្ទេរមុខងារមានវឌ្ឍនភាព សកម្មភាពគាំទ្រនានាត្រូវឆ្លើយតបទៅនឹងការប្រែប្រួលនៃតួនាទីការទទួលខុសត្រូវ និងទំនាក់ទំនងរបស់ក្រសួង ស្ថាប័នជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការផ្ទេរមុខងារទាមទារឱ្យក្រសួង ស្ថាប័ននានាកែសម្រួលតួនាទី ការទទួលខុសត្រូវ និងទំនាក់ទំនងរបស់ខ្លួន។ ក្រសួង ស្ថាប័ននានាត្រូវចូលរួមគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន និងវិស័យរបស់ខ្លួន។

## ខ). ដំណាក់កាលទី២

### ខ.១). បន្ត និងពិនិត្យឡើងវិញនូវដំណើរការផ្ទេរមុខងារ

ក្នុងដំណើរការផ្ទេរមុខងារ និងការអនុវត្តមុខងារដែលបានផ្ទេរ ចាំបាច់ត្រូវធ្វើការតាមដាន និងវាយតម្លៃ ដោយពិចារណាទៅលើការប្រែប្រួលកត្តាប្រជាសាស្ត្រ និងចំណាកស្រុក ដែលធ្វើឱ្យប៉ះពាល់ដល់តម្រូវការនៃសេវាសាធារណៈនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

### ខ.២). បន្តរៀបចំកម្មវិធីលើកកម្ពស់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ការផ្ទេរមុខងារត្រូវធ្វើឡើងជាជំហានៗ ទៅតាមសមត្ថភាពរបស់ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការបន្តលើកកម្ពស់ការផ្តល់សេវាសាធារណៈ។ ការលើកកម្ពស់សេវាសាធារណៈពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចអំពីការចាត់តាំងបុគ្គលិក និងការវិភាជន៍ធនធានសម្រាប់កិច្ចប្រតិបត្តិការ ការថែទាំ និងទុនវិនិយោគសម្រាប់សេវាសាធារណៈជាក់លាក់ណាមួយ។ កម្មវិធីលើកកម្ពស់សេវាសាធារណៈ ត្រូវឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងនៅក្នុងគម្រោងថវិកាប្រតិបត្តិការ និងវិនិយោគប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ត្រូវធ្វើឡើងតាមរយៈដំណើរការពីក្រោមឡើងលើ ដូច្នេះត្រូវរៀបចំនូវយន្តការគណនេយ្យភាពនានាដែលមានលក្ខណៈរឹងមាំ ដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ប្រជាពលរដ្ឋ និងសង្គមស៊ីវិល អាចចូលរួមក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈទាំងនេះ។

## ៣.៣.៤. ក្របខ័ណ្ឌតក្កភាព

ក្របខ័ណ្ឌតក្កភាពសម្រាប់សមាសធាតុកម្មវិធីទី៣ មាននៅក្នុងតារាងក្របខ័ណ្ឌតក្កភាព ៣.៣។

## តារាង៣.៣ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៣

| សមាសធាតុកម្មវិធីទី៣ : ការផ្ទេរមុខងារ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី៣** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| លើកកម្ពស់បរិមាណ និងគុណភាពសេវាសាធារណៈតាមរយៈការផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានដែលពាក់ព័ន្ធនឹងការអនុវត្តមុខងារទាំងនោះ ។ | • ភាគរយនៃមុខងារដែលបានផ្ទេរ (រួមទាំងការប្រគល់ ឬធ្វើប្រតិភូកម្ម) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃមុខងារដែលបានផ្ទេរ ធៀបនឹងមុខងារ ដែលកំណត់នៅក្នុងផែនការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ន<br>• ភាគរយនៃមុខងារដែលបានផ្ទេរមានភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាននានា<br>• ភាគរយប្រជាពលរដ្ឋទាំងពីរភេទ និងក្រុមជនងាយរងគ្រោះមានលទ្ធភាពទទួលបានសេវាសាធារណៈនានា ដូចជា :<br>– អត្រាចូលរៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ<br>– ការប្រើប្រាស់សេវាសុខភាព ដូចជាការពិគ្រោះជំងឺ<br>– ភាគរយកុមារអាយុក្រោមមួយឆ្នាំទទួលបានវ៉ាក់សាំងការពារជំងឺកញ្ជ្រិល<br>– ភាគរយកំណើតដែលផ្តល់សេវាដោយបុគ្គលិកសុខាភិបាល<br>– ភាគរយប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់<br>– ភាគរយប្រជាពលរដ្ឋដែលទទួលបានសេវាអនាម័យ | • អនុម័តនូវនីតិវិធីក្នុងការពិនិត្យមើលឡើងវិញ និងការផ្ទេរមុខងារនៅឆ្នាំ២០១០<br>• សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនូវការផ្ទេរមុខងារ ហើយអនុវត្តការផ្ទេរនេះក្នុងលក្ខណៈជាប្រព័ន្ធ ដោយភ្ជាប់ជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានសមស្រប<br>• រៀបចំ និងផ្ទេរមុខងារបឋមទៅឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១០<br>• គ.ជ.អ.ប អនុម័តនូវដំណើរការដែលមានលក្ខណៈជាប្រព័ន្ធមួយអំពីការពិនិត្យឡើងវិញនូវមុខងារនៅឆ្នាំ២០១០<br>• មុខងារភាគច្រើនដែលបានផ្ទេរឱ្យថ្នាក់ក្រោមជាតិ គឺជាមុខងារដែលផ្ទេរតាមការប្រគល់<br>• រាល់ការផ្ទេរមុខងារពីក្រសួង ស្ថាប័ននានា ត្រូវអនុវត្តដោយមានលក្ខណៈជាប្រព័ន្ធ ដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>• រាជរដ្ឋាភិបាលកំណត់ច្បាស់លាស់ពីសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ |

| សមាសធាតុកម្មវិធីទី៣ : ការផ្ទេរមុខងារ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី៣** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| | • ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលឆ្លើយថា ខ្លួនទៅរកក្រុមប្រឹក្សា ឬបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយបញ្ហាសេវាសាធារណៈ<br>• ភាគរយនៃថវិកាជាតិដែលបានចំណាយដោយរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទ និងសមាជិកក្រុមប្រឹក្សាទាំងពីរភេទដែលដឹងពីសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ | និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។ |

| **លទ្ធផលរំពឹងទុក** | **សកម្មភាពសំខាន់ៗ** | | |
|---|---|---|---|
| | **ដំណាក់កាលទី១** | **ដំណាក់កាលទី២** | **ដំណាក់កាលទី៣** |
| ៣.១. ពិនិត្យមើលមុខងារឡើងវិញ និងផ្ទេរមុខងារស្របតាមវិធីសាស្ត្រ និងដំណើរការដែលមានការពិគ្រោះយោបល់ មានការគ្រោងទុក មានសនិទានភាព និងមានលក្ខណៈជាប្រព័ន្ធ | • រៀបចំដំណើរការពិគ្រោះយោបល់ដែលមានលក្ខណៈជាប្រព័ន្ធ និងប្រកបដោយតម្លាភាពសម្រាប់ពិនិត្យមុខងារឡើងវិញ ដើម្បីជាមូលដ្ឋានក្នុងការផ្ទេរមុខងារ (រួមទាំងការពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់លេខាធិការដ្ឋានគ.ជ.អ.ប អនុគណៈកម្មាធិការមុខងារនិងធនធាន និងក្រុម | • ពិនិត្យវាយតម្លៃលើដំណើរការផ្ទេរមុខងារក្នុងដំណាក់កាលបឋម និងបន្តផ្ទេរមុខងារបន្ថែមទៀតឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិនិត្យមើលឡើងវិញ និងកែសម្រួលមុខងារដែលក្រសួង ស្ថាប័ននានាបានស្នើសុំផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិនិត្យឡើងវិញនូវយន្តការនានារបស់ក្រុម | • បន្តពិនិត្យវាយតម្លៃលើដំណើរការផ្ទេរមុខងារដើម្បីបន្តផ្ទេរមុខងារ សំដៅធានាថា នៅចុងបញ្ចប់នៃការអនុវត្តកម្មវិធីជាតិនេះ មុខងារនៃការផ្តល់សេវាសាធារណៈជាមូលដ្ឋាន និងមុខងារនៃការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន ត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | ការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន)<br>• រៀបចំសេចក្តីណែនាំស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្ទេរមុខងារនិងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុវត្តនូវការផ្ទេរមុខងារនិងធនធាននៅដំណាក់កាលបឋម<br>• ចងក្រងមេរៀនបទពិសោធន៍ដែលទទួលបានពីកម្មវិធីកសាកល្បងនានា (ដូចជាគម្រោងការិយាល័យច្រកចេញចូលតែមួយ កម្មវិធីពង្រឹងតួនាទីថ្នាក់ក្រុង ស្រុក ខណ្ឌ គម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់) ពាក់ព័ន្ធនឹងការផ្ទេរមុខងារ និងបទពិសោធន៍នៃការផ្ទេរមុខងារដទៃទៀតដែលបានអនុវត្តនៅថ្នាក់ក្រោមជាតិ និងពិនិត្យលទ្ធភាពបន្សុំកម្មវិធីសាកល្បងទាំងនេះជាមួយនឹងការផ្ទេរមុខងារជាទូទៅ | ប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់វាយតម្លៃផែនការផ្ទេរមុខងារតាមវិស័យ និងការអនុវត្តការងាររបស់ខ្លួនពាក់ព័ន្ធនឹងផែនការទាំងនោះ ដោយយកចិត្តទុកដាក់ទៅលើសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ | |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | • កំណត់ និងផ្ទេរមុខងារបឋមទៅឱ្យក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងមុខងារសមស្របសម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ<br>• អនុវត្តសាកល្បងនូវយន្តការនានារបស់ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់វាយតម្លៃផែនការផ្ទេរមុខងារតាមវិស័យ និងការអនុវត្តការងាររបស់ខ្លួនពាក់ព័ន្ធនឹងផែនការទាំងនោះ | | |
| ៣.២. ការទទួលខុសត្រូវ និងសិទ្ធិអំណាចសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ ត្រូវបានអនុវត្តដោយពុំមានការរំខានដល់ការផ្តល់សេវាសាធារណៈនានា | • ផ្ទេរធនធាននានា រួមទាំងធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងធនធានមនុស្ស ឱ្យស្របជាមួយការផ្ទេរមុខងារ<br>• រៀបចំឱ្យមានយន្តការសមស្របសម្រាប់តាមដាន និងពិនិត្យឡើងវិញនូវការអនុវត្តមុខងារដែលបានផ្ទេរ<br>• រៀបចំ និងអនុវត្តសាកល្បងនូវស្តង់ដារ | • កំណត់នូវសិទ្ធិអំណាចច្បាស់លាស់រវាងប្រភេទរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលទាំងនោះជាមួយក្រសួង ស្ថាប័ននានានៅពេលផ្ទេរមុខងារ និងធនធាន<br>• កំណត់ខ្សែគណនេយ្យភាពច្បាស់លាស់រវាងក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា | • ពិនិត្យមើលឡើងវិញ និងកែសម្រួលមុខងារដែលបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ប្រគល់ ឬធ្វើប្រតិភូកម្មនូវមុខងារជាកាតព្វកិច្ចជាច្រើនបន្ថែមទៀត ដោយមានការបញ្ជាក់ច្បាស់លាស់អំពីការទទួលខុសត្រូវ និងសិទ្ធិអំណាចរវាងប្រភេទរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | សេវាសាធារណៈលើមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | • ប្រគល់ ឬធ្វើប្រតិភូកម្មនូវមុខងារជាកាតព្វកិច្ចជាច្រើនបន្ថែមទៀត ដោយមានបញ្ជាក់ច្បាស់លាស់អំពីការទទួលខុសត្រូវ និងសិទ្ធិអំណាចរវាងប្រភេទរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិនិត្យ និងវាយតម្លៃលើការអនុវត្តសាកល្បងនូវស្តង់ដារសេវាសាធារណៈលើមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនូវស្តង់ដារសេវាសាធារណៈចាំបាច់មួយចំនួន | • បង្កើតស្តង់ដារសេវាសាធារណៈលើមុខងារដែលត្រូវបានផ្ទេរបន្ថែមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣.៣. រៀបចំ និងអនុវត្តផែនការស្តីពីការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័នឱ្យបានច្បាស់លាស់ | • គាំទ្រក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នក្នុងការពិនិត្យ និងវិភាគមុខងារដែលត្រូវផ្ទេរ<br>• កៀរគរការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យ និងវិភាគមុខងារតាមវិស័យដែលត្រូវផ្ទេរ | • យកចិត្តទុកដាក់ក្នុងការធ្វើសមាហរណកម្មនូវរាល់ការគាំទ្រនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិនិត្យ និងកែសម្រួលច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យមួយចំនួនឱ្យបានសមស្របជាមួយនឹងច្បាប់ស្តីពីការ | • ពិនិត្យ និងកែសម្រួលនូវផែនការតាមវិស័យសម្រាប់ការផ្ទេរមុខងារបន្ថែម<br>• ពិនិត្យ និងកែសម្រួលច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យទាំងអស់ឱ្យបានសមស្របជាមួយនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | • បន្សុំផែនការ កម្មវិធី និងយុទ្ធសាស្ត្រស្តីពីការផ្ទេរមុខងាររបស់ក្រសួង ស្ថាប័ននានាជាមួយកម្មវិធីជាតិ<br>• រៀបចំឱ្យមានយន្តការគាំទ្រនានាដើម្បីធានាការបន្សុំតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន | គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ | ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ |
| ៣.៤. យកចិត្តទុកដាក់ដល់ការលើកកម្ពស់សមភាពយេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះនានានៅក្នុងការផ្ទេរមុខងារ | • កំណត់មុខងារ ការទទួលខុសត្រូវ និងគណនេយ្យភាពនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដើម្បីធានាដល់ការលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងទំនាក់ទំនង និងការសម្របសម្រួលខ្សែទទឹងនៃអន្តររដ្ឋបាល ព្រមទាំងការលើកកម្ពស់គណនេយ្យភាពចំពោះប្រជាពលរដ្ឋ | • កំណត់ និងអនុវត្តមុខងារ ការទទួលខុសត្រូវ និងគណនេយ្យភាពដែលទាក់ទងនឹងគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ | • ពិនិត្យ និងកែសម្រួលមុខងារ ការទទួលខុសត្រូវ និងគណនេយ្យភាពដែលទាក់ទងនឹងគោលនយោបាយលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៣.៥. លើកកម្ពស់ការទទួលបាន និងការប្រើប្រាស់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ | • រៀបចំប្រព័ន្ធលើកទឹកចិត្តដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំឱ្យមានកិច្ចព្រមព្រៀងផ្តល់សេវាសាធារណៈរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន វិស័យឯកជន និងអង្គការសង្គមស៊ីវិល<br>• កំណត់ឱ្យបានច្បាស់លាស់អំពីអ្នកដែលមានសិទ្ធិអំណាចក្នុងការវាយតម្លៃពីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | • រៀបចំ និងអនុវត្តផែនការបុគ្គលិក និងវិភាជន៍ធនធានហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ<br>• រៀបចំយន្តការសម្រាប់ពិនិត្យមើលឡើងវិញនូវគុណភាពនៃការផ្តល់សេវាសាធារណៈដូចជាតាមរយៈវេទិកាពិគ្រោះយោបល់និងផ្សព្វផ្សាយជាសាធារណៈ ឬកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាដើម<br>• អនុវត្តសាកល្បងនូវយន្តការផ្សេងទៀតក្នុងការលើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋក្នុងការវាយតម្លៃពីប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | • ពិនិត្យមើលឡើងវិញ និងកែសម្រួលនូវយន្តការត្រួតពិនិត្យគុណភាពសេវាសាធារណៈដែលបានផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ |

## ៣.៤. សមាសធាតុកម្មវិធីទី៤ : ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.៤.១. សនិទានភាព

ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការមួយដ៏ស្មុគស្មាញ ដែលតម្រូវឱ្យការរៀបចំប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបច្ចុប្បន្នផង និងត្រូវឱ្យស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងដាក់ឱ្យប្រើប្រាស់នៅពេលខាងមុខផង។ សមាសធាតុកម្មវិធីនេះ មានសង្គតិភាពជាមួយនឹងគោលបំណងទី២៧នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលចែងអំពីការពង្រឹង និងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិមជ្ឈការហិរញ្ញវត្ថុ។ កត្តាសន្ទតសំខាន់មួយ គឺច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវអនុម័តនៅអំឡុងឆ្នាំ២០១០។ ប្រសិនបើច្បាប់នេះមិនត្រូវបានអនុម័តតាមកាលកំណត់នេះទេ កិច្ចការចាំបាច់និងបន្ទាន់គឺត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួន ដែលទាក់ទងនឹងការងារថវិកា រតនាគារ និងគណនេយ្យសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌនិងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ។

ការអនុវត្តសមាសធាតុកម្មវិធីទី៤នេះនឹងមិនអាចសម្រេចបានជោគជ័យទេ ប្រសិនបើបណ្តាសមាសធាតុកម្មវិធីដទៃទៀតមិនទទួលបានជោគជ័យ។ គណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចអនុវត្តទៅបាន លុះត្រាតែមានបុគ្គលិកប្រកបដោយសមត្ថភាព និងមានការលើកទឹកចិត្ត។ ការផ្តល់ធនធាន និងសិទ្ធិអំណាចបន្ថែមនឹងពុំមានសារៈសំខាន់នោះទេ ប្រសិនបើការទទួលខុសត្រូវ សិទ្ធិអំណាច និងគណនេយ្យភាព មិនបានភ្ជាប់មកជាមួយមុខងារដែលបានផ្ទេរនោះ។ ម្យ៉ាងទៀត យន្តការគណនេយ្យភាពចំពោះថ្នាក់ក្រោមត្រូវតែរឹងមាំ ដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិ ប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព សំដៅឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដាក់ឱ្យដំណើរការតាំងពីឆ្នាំ២០០៥មក ដោយផ្អែកលើចក្ខុវិស័យរបស់រាជរដ្ឋាភិបាលដែលបានកំណត់ថា *"ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជាពិសេសតាមរយៈការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការបង្កើនភាពស័ក្តិសិទ្ធិក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ"* ។

ជំហានទី២នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលទី២ បានរៀបចំឡើងផ្អែកលើរបកគំហើញថ្មីៗនៃភាពជឿទុកចិត្តនៃថវិកា ដើម្បីសម្រេចឱ្យបាននូវគណនេយ្យភាពហិរញ្ញវត្ថុមួយដ៏ល្អប្រសើរ។ ក្នុងន័យនេះ គ្រប់តួអង្គទាំងអស់ដែលពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺមិនមែនតែក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប៉ុណ្ណោះទេ ពោលគឺក្រសួង ស្ថាប័ន និងរដ្ឋបាលទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានថវិកា ចាំបាច់ត្រូវតែចូលរួមក្នុងដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

គោលបំណងទី២៧នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺដើម្បីពង្រឹង និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិមជ្ឈការហិរញ្ញវត្ថុ ហើយត្រូវបានតាក់តែងឡើងមុនការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ផែនការអនុវត្តសមាសធាតុកម្មវិធីទី៤នៃកម្មវិធីជាតិនេះ បានរួមបញ្ចូលនូវតម្រូវការដើម្បីពិនិត្យមើល និងកែសម្រួលឡើងវិញនូវគោលបំណងទី២៧នេះ និងបានបញ្ចូលនូវសកម្មភាពសំខាន់ៗមួយចំនួនរបស់គោលបំណងទី២៧នេះ មកក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះដែរ គោលបំណងនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី២ ដំណាក់កាលទី២ ដែលស្ថិតក្រោមសមត្ថកិច្ចអគ្គនាយកដ្ឋាន និងនាយកដ្ឋានសំខាន់ៗដទៃទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ត្រូវទាមទារឱ្យមានការកែសម្រួលសកម្មភាពរបស់ខ្លួនឡើងវិញ ដើម្បីបង្កើត និងពង្រឹងរបបគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋាន និងនាយកដ្ឋានសំខាន់ៗរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមមានអគ្គនាយកដ្ឋានរតនាគារ អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានថវិកា នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នាយកដ្ឋានលទ្ធកម្ម នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន និងនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ។ សកម្មភាពទាំងនេះនឹងត្រូវកំណត់ឡើងឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បន្ទាប់ពីច្បាប់នេះបានអនុម័តរួច និងជាមួយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតសម្រាប់អនុវត្តច្បាប់នេះ។

ពាក់ព័ន្ធនឹងការគ្រប់គ្រងនិងកំណែទម្រង់តាមវិស័យ ក្រសួង ស្ថាប័ននានាត្រូវ :

- រៀបចំយន្តការគ្រប់គ្រងធនធានផ្ទៃក្នុងឱ្យមានតម្លាភាព ដោយផ្អែកលើការព្យាករណ៍ថវិកាដ៏ច្បាស់លាស់
- ផ្ទេរមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ដូច្នេះ ការបន្ស៊ីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនមែនពាក់ព័ន្ធតែរវាងក្រសួងមហាផ្ទៃជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈ គ.ជ.អ.ប ប៉ុណ្ណោះទេ តែក៏មានការពាក់ព័ន្ធជាមួយក្រសួង ស្ថាប័នដទៃទៀតដែរ ជាពិសេសនៅពេលដែលមុខងារត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

គណនេយ្យភាព គឺជាប្រធានបទសំខាន់នៅក្នុងសមាសធាតុកម្មវិធីទី៤។ គណនេយ្យភាពផ្ទៃក្នុងនឹងត្រូវបានធានាតាមរយៈការអនុវត្តសវនកម្មផ្ទៃក្នុង និងជាពិសេស តាមរយៈទំនាក់ទំនង និងរបៀបរបបការងាររវាងក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពនានារបស់ក្រុមប្រឹក្សាដែលពាក់ព័ន្ធនឹងការអនុវត្តថវិកា។ គណនេយ្យភាពអន្តររដ្ឋបាល

ថ្នាក់ក្រោមជាតិនឹងត្រូវស្តែងឡើងតាមរយៈការអនុវត្តការបែងចែកចំណូលរវាងថ្នាក់ស្រុកជាមួយនឹងថ្នាក់ឃុំ សង្កាត់នៅក្នុងស្រុក។ ចំណែកគណនេយ្យភាពអន្តររដ្ឋបាល គឺត្រូវអនុវត្តតាមរយៈការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ទៅលើកិច្ចការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណែកឯគណនេយ្យភាពចំពោះប្រជាពលរដ្ឋនឹងត្រូវស្តែងឡើងតាមរយៈការរៀបចំ ការបែងចែក និងការអនុវត្តថវិកា ព្រមទាំងតាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការងារថវិកា ការងារវិនិយោគ និងការងារអភិវឌ្ឍន៍នានា។

### ៣.៤.២. គោលបំណងសមាសធាតុកម្មវិធី

សមាសធាតុកម្មវិធីទី៤ មានគោលបំណងបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពកៀរគរ និងទទួលបានធនធានគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងបែងចែកធនធានទាំងនោះប្រកបដោយតម្លាភាព និងគណនេយ្យភាព។

### ៣.៤.៣. ការងារជាអាទិភាពនានា

#### ក). ដំណាក់កាលទី១

ល័ក្ខខ័ណ្ឌជាបឋមមួយដើម្បីគាំទ្រដល់សកម្មភាពជាអាទិភាពនានាសម្រាប់រយៈពេលខ្លី គឺការអនុម័តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រសិនបើច្បាប់នេះមិនត្រូវបានអនុម័តនៅឆ្នាំ២០១០ទេ ចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារថវិកា ហិរញ្ញវត្ថុ គណនេយ្យ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តក្នុងពេលអន្តរកាល។ គោលដៅ គឺត្រូវអនុម័ត និងដាក់ឱ្យដំណើរការឱ្យបានឆាប់រហ័សនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ដែលបានតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

#### ក.១). បង្កើតឱ្យមានប្រព័ន្ធចាំបាច់សម្រាប់ការរៀបចំ ការអនុម័ត ការអនុវត្ត និងការរាយការណ៍អំពីថវិកា

ទោះបីជាការផ្ទេរមុខងារជាដំណើរការដែលនឹងធ្វើជាបន្តបន្ទាប់ក៏ដោយ ក៏ចាំបាច់ត្រូវបង្កើតឱ្យបានឆាប់នូវមាតិកាថវិកា នីតិវិធីរៀបចំនិងអនុម័តថវិកា ព្រមទាំងប្រព័ន្ធអនុវត្តថវិកាដែលមានភ្ជាប់ជាមួយនូវការគ្រប់គ្រងគណនេយ្យ និងសាច់ប្រាក់ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញមុខងារថ្មី និងអាចផ្តល់សេវាសាធារណៈតាមការរំពឹងទុករបស់ខ្លួន។ ប្រព័ន្ធនេះត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈរបស់ជាតិ ហើយត្រូវឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រថ្មីៗ ដូចមានចែងក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឆ្លុះបញ្ចាំងអំពីល័ក្ខខ័ណ្ឌឬស្ថានភាពជាក់លាក់នៃការគ្រប់គ្រង និងប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅដំណាក់កាលដំបូងត្រូវយកចិត្តទុកដាក់ជាពិសេសនៅថ្នាក់ក្រុង ស្រុក។

### ក.២). ធានាថាមានមន្ត្រីសំខាន់ៗត្រូវបានបណ្តុះបណ្តាល ដើម្បីអនុវត្តការងារគ្រប់គ្រងថវិកានិងសាច់ប្រាក់ និងកិច្ចដំណើរការលទ្ធកម្មឱ្យបានសមស្រប

រដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចមានលទ្ធភាពទទួលខុសត្រូវលើការងារថវិកា ហិរញ្ញវត្ថុ និងគណនេយ្យបានទេ ប្រសិនបើគ្មានមន្ត្រីដែលមានជំនាញនិងទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់។ ដូច្នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃត្រូវយកចិត្តទុកដាក់ផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សានីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការតែងតាំងប្រធានហិរញ្ញវត្ថុ និងគណនេយ្យករនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ ត្រូវរៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈជាមូលដ្ឋាន ដូចជាការកសាងសមត្ថភាពទាក់ទងទៅនឹងប្រព័ន្ធនិងនីតិវិធីថ្មីៗនៃថវិកា និងគណនេយ្យផងដែរ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលស្តីពីគណនេយ្យ ដែលរៀបចំឡើងតាមរយៈកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជំហានទី២។

### ក.៣). រៀបចំក្របខ័ណ្ឌដើម្បីធានាឱ្យមានប្រព័ន្ធគ្រប់គ្រងចំណូលមួយដែលរឹងមាំ អាចព្យាករណ៍បាន និងប្រកបដោយតម្លាភាព

នៅក្នុងដំណាក់កាលទី១នៃការអនុវត្តកម្មវិធីជាតិ ត្រូវយកចិត្តទុកដាក់លើ (១)ការរៀបចំនីតិវិធីដែលមានលក្ខណៈជាប្រព័ន្ធសម្រាប់កំណត់ ឬគណនាធនធានដែលត្រូវភ្ជាប់ជាមួយមុខងារដែលត្រូវផ្ទេរ សំដៅបង្កើតជារូបមន្តមួយដែលមានតម្លាភាព និងមានលក្ខណៈវិនិច្ឆ័យច្បាស់លាស់ (២)ការរៀបចំឱ្យមានមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ដែលទំហំនៃមូលនិធិនោះត្រូវសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមនៅតាមមូលដ្ឋាននីមួយៗ (៣)ការកំណត់ថ្លៃឈ្នួលមិនមែនសារពើពន្ធ និងកម្រៃសម្រាប់ការផ្តល់សេវាសាធារណៈក្នុងការអនុវត្តមុខងារដែលបានផ្ទេរ។

កិច្ចការជាបឋម គឺការរៀបចំគោលនយោបាយស្តីពីប្រភេទចំណូលពន្ធមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងចំណូលពន្ធដែលត្រូវផ្ទេរពីថ្នាក់ស្រុកឱ្យទៅថ្នាក់ឃុំ សង្កាត់នៅក្នុងស្រុករបស់ខ្លួន។ ជាមួយគ្នានេះដែរ ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីគោលការណ៍ គោលដៅ និងគោលបំណងនានាដែលពាក់ព័ន្ធនឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងការចំណាយ និងគ្រប់គ្រងថវិកាសាធារណៈ។

### ក.៤). ធានាឱ្យដំណើរការផ្ទេរទ្រព្យសម្បត្តិប្រព្រឹត្តទៅដោយរលូន

ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចបំពេញមុខងារដែលផ្ទេរប្រកបដោយប្រសិទ្ធភាព លុះត្រាតែទ្រព្យសម្បត្តិសម្រាប់បម្រើឱ្យការបំពេញមុខងារនោះ ត្រូវបានផ្ទេរព្រមជាមួយនឹងធនធានហិរញ្ញវត្ថុចាំបាច់សម្រាប់ប្រតិបត្តិការ និងថែទាំទ្រព្យសម្បត្តិនោះផង។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់លម្អិតនូវនីតិវិធីសម្រាប់ការផ្ទេរទ្រព្យសម្បត្តិឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ហេតុនេះ គ.ជ.អ.ប ត្រូវធានាថា ក្រសួង ស្ថាប័នពាក់ព័ន្ធអនុវត្តតាមនីតិវិធីទាំងនេះ។

## ខ). ដំណាក់កាលទី២

### ខ.១). បន្តពិនិត្យមើលឡើងវិញ និងគាំទ្រដល់ការគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ គណនេយ្យ និងសាច់ប្រាក់

ដោយសារមានភាពស្មុគស្មាញក្នុងការរៀបចំឱ្យបានសមស្រប និងគ្រប់ជ្រុងជ្រោយនូវប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ គណនេយ្យនិងសាច់ប្រាក់ និងក្នុងការកែសម្រួលប្លង់គណនេយ្យនៅថ្នាក់ឃុំ សង្កាត់ ចាំបាច់ត្រូវពិនិត្យមើលឡើងវិញជាប្រចាំនូវគោលនយោបាយ និងកិច្ចប្រតិបត្តិការទាំងនោះ ដើម្បីកំណត់អំពី (១)បញ្ហាចម្បងៗ ដូចជាវិធាន ឬការបកស្រាយអំពីវិធាន (២)ភាពខ្វះចន្លោះក្នុងការរៀបចំប្រព័ន្ធនិងនីតិវិធី (៣)ភាពខ្សោយដោយសារពុំមានសមត្ថភាពគ្រប់គ្រង ឬអនុវត្ត។ ផ្អែកលើលទ្ធផលនៃការពិនិត្យមើលឡើងវិញនេះ ត្រូវចាត់វិធានការរៀបចំកែសម្រួលឡើងវិញ ដូចជា កែសម្រួលគោលនយោបាយដែលពាក់ព័ន្ធ ឬរៀបចំវគ្គបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ខ.២). បង្កើនកម្រិតសិទ្ធិអំណាចឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមមុខងារដែលបានផ្ទេរ និងលើកកម្ពស់សមត្ថភាពគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងរយៈពេលមធ្យម គោលការណ៍ទូទៅស្តីពីប្រព័ន្ធចំណូលនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកែលម្អឱ្យកាន់តែច្បាស់លាស់បន្ថែមទៀត ដើម្បី (១)បញ្ចូលគ្នានូវមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌតាមវិស័យ (២)បង្វែរមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌមួយចំនួនទៅជាមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ (៣)ផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់អត្រាថ្លៃឈ្នួលនិងកម្រៃសេវាសាធារណៈសម្រាប់ចំណូលមិនមែនសារពើពន្ធ (៤)ផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការវិភាគ និងកំណត់អត្រាពន្ធមូលដ្ឋាននៅក្នុងចន្លោះអត្រាដែលកំណត់ដោយថ្នាក់ជាតិ។

### ខ.៣). បន្តពិនិត្យមើលឡើងវិញ និងគាំទ្រដល់ប្រព័ន្ធ និងសមត្ថភាពគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

បន្ទាប់ពីមុខងារសំខាន់ៗ និងទ្រព្យសម្បត្តិពាក់ព័ន្ធទាំងឡាយត្រូវបានផ្ទេរឬត្រូវបានគ្រោងសម្រាប់ផ្ទេរ កិច្ចការបន្ទាប់ដែលត្រូវយកចិត្តទុកដាក់ គឺការកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិបានត្រឹមត្រូវនិងទាន់ពេលវេលា និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ការរៀបចំប្រព័ន្ធទាំងនេះត្រូវគិតបញ្ចូលទាំងទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរឱ្យ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង។ ជាមួយគ្នានេះ ក៏ត្រូវយកចិត្តទុកដាក់ដល់ការពិនិត្យមើលឡើងវិញនូវវិធាននៃការប្រើប្រាស់ទ្រព្យសម្បត្តិនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

### ខ.៤). រៀបចំឱ្យមានប្រព័ន្ធសវនកម្មផ្ទៃក្នុង និងសវនកម្មផ្ទៃក្រៅ និងប្រព័ន្ធគណនេយ្យភាព

គណនេយ្យភាពផ្នែកច្បាប់ រដ្ឋបាល និងផ្នែកនយោបាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ គឺជាគន្លឹះដែលកំណត់ពីជោគជ័យ ឬបរាជ័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងមូល។ ដូចនេះការបង្កើតប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យដែលមានដំណើរការល្អ គឺជាមូលដ្ឋានគ្រឹះក្នុងការសម្រេច

បាននូវការងារខាងលើ បន្ទាប់មកត្រូវបង្កើតឱ្យមាននីតិវិធីនិងប្រព័ន្ធសវនកម្មផ្ទៃក្នុង និងរៀបចំមន្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទទួលបន្ទុកការងារនេះ ព្រមទាំងត្រូវពង្រឹងសមត្ថភាពផ្នែកសវនកម្មឱ្យបានសមស្របដល់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ។ ជាមួយគ្នានេះដែរ ត្រូវរៀបចំ និងអនុវត្តគម្រោងសាកល្បងស្តីពីការប្រើប្រាស់សវនកម្មផ្នែកសង្គម ការពិនិត្យតាមដានការចំណាយសាធារណៈ និងការពិភាក្សាអំពីថវិកា ដើម្បីវាយតម្លៃការប្រើប្រាស់ថវិកាទាំងនេះ ដែលជាមធ្យោបាយមួយសម្រាប់ពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៣.៤.៤. ក្របខ័ណ្ឌតក្កភាព

ក្របខ័ណ្ឌតក្កភាពសម្រាប់សមាសធាតុកម្មវិធីទី៤ មាននៅក្នុងតារាងក្របខ័ណ្ឌតក្កភាព ៣.៤។

## តារាង៣.៤ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៤

| សមាសធាតុកម្មវិធីទី៤ : ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី៤** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| បង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានលទ្ធភាពកៀរគរ និងទទួលបានធនធានគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចក្នុងការគ្រប់គ្រង និងបែងចែកធនធានទាំងនោះ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ | • ភាគរយនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំ និងអនុវត្តផែនការពិនិត្យមើលឡើងវិញលើយន្តការគណនេយ្យភាពនានាដែលមានស្រាប់ និងដែលបានធ្វើការសាកល្បងយន្តការទាំងនោះដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំនានាស្តីពីការចូលរួមផ្តល់យោបល់របស់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ទៅលើគម្រោងថវិការបស់ក្រុមប្រឹក្សាប្រភេទផ្សេងៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃក្រុមប្រឹក្សានៃថ្នាក់ក្រោមជាតិដែលមានផែនការអភិវឌ្ឍន៍ និងថវិកា ដែលបានរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រួតពិនិត្យអនុម័តដោយក្រុមប្រឹក្សា<br>• ភាគរយនៃមូលនិធិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានផ្ទេរទាន់ពេលវេលា<br>• ភាគរយជាមធ្យមនៃភាពមិនប្រក្រតី ទាក់ទងនឹងការងារលទ្ធកម្មដែលបានរកឃើញដោយការធ្វើសវនកម្មនៅឆ្នាំកន្លងមក<br>• ភាគរយនៃក្រុមប្រឹក្សាដែលឆ្លើយថា រដ្ឋបាលរបស់ខ្លួនបានធ្វើសវនកម្មផ្ទៃក្នុង និងរាយការណ៍ពីលទ្ធផលជាទៀងទាត់ | • រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានសិទ្ធិអំណាចទៅលើថវិកា និងធនធានច្រើនជាងមុន<br>• អនុម័តនូវច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅឆ្នាំ២០១០<br>• អនុម័តនូវបទប្បញ្ញត្តិស្តីពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ នៅឆ្នាំ២០១០<br>• រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានមូលនិធិផ្ទេរដោយមានភ្ជាប់ល័ក្ខខ័ណ្ឌ និងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌសម្រាប់អនុវត្តមុខងារដែលផ្ទេរតាមការប្រគល់ និងការធ្វើប្រតិភូកម្ម បន្ថែមលើប្រភពចំណូលមូលដ្ឋានរបស់ខ្លួន<br>• ផ្តល់ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសគ្រប់គ្រាន់ដល់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការបណ្តុះបណ្តាលស្តីពីការរៀបចំថវិកាដែលឆ្លើយតបនឹងការបញ្ជ្រាបយេនឌ័រ<br>• កំណត់នីតិវិធីធ្វើការងារ និងតួនាទីរបស់គណៈកម្មាធិការលទ្ធកម្ម និងប្រធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| សមាសធាតុកម្មវិធីទី៤ : ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី៤** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| | • ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលដឹងថា អ្នកណាដែលខ្លួនអាចសួរដឹងបានអំពីចំនួន និងការបែងចែកថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគាំទ្រដល់ការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី<br>• ភាគរយនៃការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹង :<br>– ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ<br>– ការលើកកម្ពស់សេវាអប់រំ<br>– ការលើកកម្ពស់សេវាសុខភាព<br>– ការលើកកម្ពស់អនាម័យ និងទឹកស្អាត<br>• ភាគរយប្រជាពលរដ្ឋដែលចូលរួមក្នុងការពិនិត្យមើលឡើងវិញនូវការអនុវត្តថវិកា និងកិច្ចលទ្ធកម្ម ។ | • បង្កើតយន្តការនានាដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិសាកសួរ និងទទួលបានព័ត៌មានស្តីពីហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• កំណត់គោលដៅ និងគោលបំណងនានាសម្រាប់គណនេយ្យភាពចំពោះប្រជាពលរដ្ឋពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៤.១. បង្កើតប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍និងថវិកា និងប្រព័ន្ធគណនេយ្យសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលលើកកម្ពស់គណនេយ្យភាព តម្លាភាព និងដែលមានសង្គតិភាពជាមួយនឹងគោលការណ៍នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវប្រកាសស្តីពីថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវប្រកាសស្តីពីទម្រង់ និងចំណាត់ថ្នាក់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម<br>• រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន ដែលផ្សារភ្ជាប់ជាមួយនឹងដំណើរការរៀបចំថវិកា<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវសេចក្តីណែនាំស្តីពីទម្រង់របាយការណ៍ និងការចុះបញ្ជីគណនេយ្យនៃការអនុវត្តថវិកា<br>• បណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំរបាយការណ៍ និងការចុះ | • វាយតម្លៃ និងកែសម្រួលដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិការបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ<br>• វាយតម្លៃ និងកែសម្រួលដំណើរការរៀបចំ អនុម័ត និងអនុវត្តថវិការបស់ឃុំ សង្កាត់<br>• វាយតម្លៃ និងកែសម្រួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្សារភ្ជាប់ជាមួយនឹងដំណើរការរៀបចំ និងអនុវត្តថវិកា<br>• វាយតម្លៃ និងកែសម្រួលផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងការផ្ទេរមុខងារ និងធនធាន<br>• បន្តបណ្តុះបណ្តាល និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិលើការងារផែនការ និងថវិកា<br>• រៀបចំ និងអនុវត្តសាកល្បងនូវវិធីសាស្ត្រ និងយន្តការនានានៃគណនេយ្យភាពចំពោះ | • វាយតម្លៃលើប្រសិទ្ធភាពនៃប្រព័ន្ធ និងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បន្តវាយតម្លៃអំពីផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងការផ្ទេរមុខងារ និងធនធាន<br>• បន្តបណ្តុះបណ្តាលកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងការរៀបចំថវិកា ផ្អែកតាមលទ្ធផលនៃការវាយតម្លៃខាងលើ<br>• ពិនិត្យវាយតម្លៃឡើងវិញនូវយន្តការ និងសេចក្តីណែនាំនានាស្តីពីគណនេយ្យភាពចំពោះប្រជាពលរដ្ឋ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | បញ្ជីគណនេយ្យនៃការអនុវត្តថវិកា<br>• កំណត់ច្បាស់លាស់ពីគោលដៅ និងគោលបំណងនានាពាក់ព័ន្ធនឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងការពិនិត្យមើលឡើងវិញនូវយន្តការគណនេយ្យភាពនានាដែលមានស្រាប់<br>• យកចិត្តទុកដាក់ផ្តល់សិទ្ធិឱ្យក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការចូលរួមផ្តល់យោបល់លើគម្រោងថវិកានានារបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | ប្រជាពលរដ្ឋ<br>• ដាក់ឱ្យប្រើប្រាស់នូវយន្តការ និងសេចក្តីណែនាំនានាស្តីពីគណនេយ្យភាពចំពោះប្រជាពលរដ្ឋ | |
| ៤.២. ប្រព័ន្ធកសាងផែនការ និងថវិកាបានលើកកម្ពស់សមភាពយេនឌ័រ និងឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ | • ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការរៀបចំផែនការ និងថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ<br>• កំណត់ និងផ្តល់ធនធានសម្រាប់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្នុងការអនុវត្តតួនាទីរបស់ខ្លួន | • ពិនិត្យវាយតម្លៃឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការរៀបចំផែនការ និងថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ<br>• សិក្សាវាយតម្លៃផលប៉ះពាល់នៃការវិភាជន៍មូលនិធិសម្រាប់យេនឌ័រ | • បន្តពិនិត្យវាយតម្លៃឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការរៀបចំផែនការ និងថវិកាដែលឆ្លើយតបទៅនឹងយេនឌ័រ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៤.៣. ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ដែលមានលក្ខណៈឆ្លើយតប និងមានប្រសិទ្ធភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវសេចក្តីណែនាំស្តីពីគណនេយ្យសាធារណៈ<br>• សិក្សាអំពីលទ្ធភាពក្នុងការរៀបចំ និងបង្កើតឱ្យមានការិយាល័យរតនាគារនៅក្រុង ស្រុក<br>• សិក្សា និងសាកល្បងការប្រើប្រាស់ធនាគារពាណិជ្ជ | • ពិនិត្យឡើងវិញអំពីប្រសិទ្ធភាពនៃការប្រើប្រាស់ធនាគារពាណិជ្ជ<br>• ពិនិត្យឡើងវិញនូវប្លង់គណនីឃុំ សង្កាត់ ដើម្បីបន្សីជាមួយប្រព័ន្ធគណនេយ្យថវិកាឃុំ សង្កាត់ | • វាយតម្លៃឡើងវិញនូវប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកែសម្រួលឱ្យបានសមស្រប |
| ៤.៤. ផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានទាន់ពេលវេលា ដោយមានការផ្តល់នូវសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការប្រើប្រាស់ និងការបែងចែកដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានតម្លាភាព | • រៀបចំ និងអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការគ្រប់គ្រងមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ<br>• ដាក់បញ្ចូលគ្នានូវមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌក្នុងពេលដែលមុខងារត្រូវបានផ្ទេរ | • ពិនិត្យវាយតម្លៃឡើងវិញនូវការអនុវត្តមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមការវិវឌ្ឍនៃការផ្ទេរមុខងារ និងធនធាន<br>• កំណត់កញ្ចប់ថវិកាសម្រាប់រយៈពេល៣ឆ្នាំជាបន្តបន្ទាប់<br>• ពិនិត្យវាយតម្លៃ និងកែសម្រួលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីធានាដល់ការដាក់បញ្ចូលគ្នានូវមូលនិធិផ្ទេរមានភ្ជាប់ល័ក្ខខ័ណ្ឌ | • បន្តពិនិត្យវាយតម្លៃឡើងវិញនូវការអនុវត្តមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមការវិវឌ្ឍនៃការផ្ទេរមុខងារ និងធនធាន<br>• បន្តកំណត់កញ្ចប់ថវិកាសម្រាប់រយៈពេល៣ឆ្នាំជាបន្តបន្ទាប់<br>• បន្តពិនិត្យវាយតម្លៃ និងកែសម្រួលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ ដើម្បីធានាដល់ការដាក់បញ្ចូលគ្នានូវមូលនិធិផ្ទេរមានភ្ជាប់ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | | និងការបង្វែរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌមួយចំនួនទៅជាមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ | ល័ក្ខខ័ណ្ឌ និងការបង្វែរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌមួយចំនួនទៅជាមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ |
| ៤.៥. ប្រគល់ប្រភេទចំណូលពន្ធមូលដ្ឋានដ៏ច្បាស់លាស់ (១០០% ឬចែករំលែកជាមួយថ្នាក់រដ្ឋបាលផ្សេងទៀត) ឱ្យទៅប្រភេទរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ | • ដាក់ចេញនូវគោលនយោបាយស្ដីពីប្រភេទពន្ធមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីប្រភេទពន្ធមូលដ្ឋាន ព្រមទាំងមានសេចក្ដីណែនាំលម្អិតសម្រាប់ការអនុវត្ត | • ពិនិត្យឡើងវិញនូវគោលនយោបាយស្ដីពីប្រភេទពន្ធមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការប្រមូលចំណូល ការចែករំលែកព័ត៌មាន និងគណនេយ្យភាព | • រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិសម្រេចអំពីអត្រាប្រមូលពន្ធមូលដ្ឋានក្នុងចន្លោះអត្រាដែលកំណត់ដោយថ្នាក់ជាតិ |
| ៤.៦. ប្រគល់ប្រភេទចំណូលមិនមែនសារពើពន្ធមួយចំនួន និងសិទ្ធិចាត់ចែងចំណូលមិនមែនសារពើពន្ធទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | • រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិពិនិត្យមើលការប្រមូលចំណូលមិនមែនសារពើពន្ធដោយអង្គភាពផ្សេងៗ និងទាមទារឱ្យអង្គភាពប្រមូលចំណូលទាំងនោះមានគណនេយ្យភាពចំពោះខ្លួន<br>• រៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តស្ដីពីប្រភេទ អត្រា និងយន្តការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • ពិនិត្យ និងកែសម្រួលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តស្ដីពីប្រភេទ អត្រា និងយន្តការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • បន្តពិនិត្យ និងកែសម្រួលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តស្ដីពីប្រភេទ អត្រា និងយន្តការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៤.៧. ឃុំ សង្កាត់ក្នុងស្រុកទទួលបានចំណូលចែករំលែក ដែលត្រូវបានផ្តល់ឱ្យតាមមធ្យោបាយមួយ ប្រកបដោយតម្លាភាព និងសមធម៌ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការចែករំលែកចំណូលមូលដ្ឋានរវាងស្រុកជាមួយឃុំ សង្កាត់នៅក្នុងស្រុក ផ្អែកតាមរូបមន្តច្បាស់លាស់ | • ពិនិត្យវាយតម្លៃឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការចែករំលែកចំណូលមូលដ្ឋានរវាងស្រុកជាមួយឃុំ សង្កាត់នៅក្នុងស្រុក ផ្អែកតាមរូបមន្តច្បាស់លាស់ | • បន្តពិនិត្យវាយតម្លៃឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តស្តីពីការចែករំលែកចំណូលមូលដ្ឋានរវាងស្រុកជាមួយឃុំ សង្កាត់នៅក្នុងស្រុក ផ្អែកតាមរូបមន្តច្បាស់លាស់ |
| ៤.៨. ផ្ទេរ និងផ្តល់ទ្រព្យសម្បត្តិចាំបាច់ឱ្យបានទាន់ពេលវេលាសម្រាប់អនុវត្តមុខងារនានា និងបង្កើតប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | • រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិ និងការធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាព និងគណនេយ្យភាព<br>• រៀបចំនីតិវិធីសម្រាប់ផ្ទេរទ្រព្យសម្បត្តិនៅដំណាក់កាលដំបូងនៃការផ្ទេរមុខងារ<br>• ផ្តល់មូលនិធិផ្នែកមូលធន និងមូលនិធិសម្រាប់ការថែទាំនូវមូលធនទាំងនោះដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | • ពិនិត្យវាយតម្លៃឡើងវិញអំពីកិច្ចដំណើរការផ្ទេរទ្រព្យសម្បត្តិ<br>• ពិនិត្យវាយតម្លៃឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បន្តផ្តល់មូលនិធិផ្នែកមូលធន និងមូលនិធិសម្រាប់ការថែទាំនូវមូលធនទាំងនោះដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | • ពិនិត្យវាយតម្លៃឡើងវិញទៅលើការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិ និងប្រព័ន្ធរបាយការណ៍ប្រចាំឆ្នាំស្តីពីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បណ្តុះបណ្តាលបន្ថែមទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងទ្រព្យសម្បត្តិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | • អនុវត្តដំណើរការតាមដានដើម្បីធានាថាការផ្ទេរមុខងារត្រូវមានភ្ជាប់មកជាមួយនូវការផ្ទេរហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងមុខងារទាំងនោះ<br>• ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ចេញនូវសេចក្តីណែនាំ ( ទម្រង់បែបបទ និងគំរូ) សម្រាប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំឱ្យមានប្រព័ន្ធ នីតិវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិរាយការណ៍អំពីការគ្រប់គ្រងទ្រព្យសម្បត្តិ | | |
| ៤.៩. រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធ និងនីតិវិធីលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយឈរលើគោលការណ៍តម្លាភាព និងប្រសិទ្ធភាព | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រកាសអន្តរក្រសួងស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការលទ្ធកម្ម<br>• បណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីកិច្ចលទ្ធកម្មសាធារណៈ | • ពិនិត្យឡើងវិញនូវគណៈកម្មាធិការលទ្ធកម្ម និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បណ្តុះបណ្តាលឡើងវិញដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីកិច្ចលទ្ធកម្មសាធារណៈ | • ពិនិត្យឡើងវិញនូវគណៈកម្មាធិការលទ្ធកម្ម និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៤.១០. រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • រៀបចំ និងអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តស្តីពីសវនកម្មផ្ទៃក្នុង<br>• ផ្តល់ជំនួយបច្ចេកទេសក្នុងការបង្កើតប្រព័ន្ធនីតិវិធីសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីនីតិវិធីសវនកម្មហិរញ្ញវត្ថុ | • ក្រុង ស្រុកជួយគាំទ្រក្នុងការរៀបចំប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់ឃុំ សង្កាត់<br>• ពិនិត្យឡើងវិញនូវមុខងារសវនកម្មផ្ទៃក្នុងរបស់រាជធានី ខេត្ត ក្រុង ស្រុក | • ពិនិត្យឡើងវិញនូវមុខងារសវនកម្មផ្ទៃក្នុងរបស់ឃុំ សង្កាត់<br>• វាយតម្លៃឡើងវិញនូវប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែលម្អឱ្យបានសមស្រប |
| ៤.១១. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើអធិការកិច្ចហិរញ្ញវត្ថុទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តតាមច្បាប់ និងនីតិវិធីនានា | • រៀបចំ និងដាក់ឱ្យប្រើប្រាស់នូវលិខិតបទដ្ឋានគតិយុត្តស្តីពីវិធាន ប្រព័ន្ធ និងដំណើរការនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំរបាយការណ៍វិភាគផ្អែកលើលទ្ធផលនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីផ្តល់អនុសាសន៍ក្នុងការកែសម្រួលគោលនយោបាយ | • ពិនិត្យវាយតម្លៃឡើងវិញនូវវិធាន ប្រព័ន្ធនិងដំណើរការនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកែសម្រួលឱ្យបានសមស្រប<br>• ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំរបាយការណ៍វិភាគផ្អែកលើលទ្ធផលនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីផ្តល់អនុសាសន៍ក្នុងការកែសម្រួលគោលនយោបាយ | • ពិនិត្យវាយតម្លៃឡើងវិញនូវវិធាន ប្រព័ន្ធនិងដំណើរការនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីកែសម្រួលឱ្យបានសមស្រប |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៤.១២. គាំទ្រផ្នែកស្ថាប័ន និងការកសាងសមត្ថភាពដល់អាជ្ញាធរសវនកម្មជាតិក្នុងការធ្វើសវនកម្មទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ | • កំណត់អំពីតម្រូវការបុគ្គលិក និងការបណ្តុះបណ្តាលដើម្បីធានាឱ្យអាជ្ញាធរសវនកម្មជាតិអាចអនុវត្តសវនកម្មផ្ទៃក្រៅបានទាន់ពេលវេលាទៅលើការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• រៀបចំ និងអនុវត្តផែនការសកម្មភាពក្នុងការកសាងសមត្ថភាពអាជ្ញាធរសវនកម្មជាតិ<br>• រៀបចំឱ្យមាននីតិវិធីសវនកម្មជាក់លាក់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុវត្តសាកល្បងនូវនីតិវិធីនេះនៅរដ្ឋបាលមួយចំនួននៃរដ្ឋបាលថ្នាក់ក្រោមជាតិ | • អនុវត្តនីតិវិធីសវនកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ពិនិត្យឡើងវិញ និងកែលម្អនូវនីតិវិធីនៃការធ្វើសវនកម្ម<br>• បន្តបណ្តុះបណ្តាលដល់បុគ្គលិកអាជ្ញាធរសវនកម្មជាតិ | • ពង្រីកការធ្វើសវនកម្មរដ្ឋបាលថ្នាក់ក្រោមជាតិដោយអាជ្ញាធរសនវកម្មជាតិនៅពេលដែលចំនួនបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលមានការកើនឡើង<br>• វាយតម្លៃឡើងវិញនូវនីតិវិធីនៃការធ្វើសវនកម្ម |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៤.១៣. រដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពរៀបចំផែនការប្រកបដោយតម្លាភាព ដោយយកចិត្តទុកដាក់លើការចំណាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ | • រៀបចំនីតិវិធី និងសេចក្តីណែនាំនានាស្តីពីការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តុះបណ្តាលអំពីនីតិវិធី និងសេចក្តីណែនាំទាំងនេះ<br>• រៀបចំ និងសាកល្បងនីតិវិធី និងប្រព័ន្ធនានាដែលពាក់ព័ន្ធនឹងការគណនាពីការចំណាយសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | • ធ្វើសមាហរណកម្មបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគ និងថវិកា ព្រមទាំងវាយតម្លៃ និងកែសម្រួលដំណើរការអនុវត្តផែនការ និងថវិកាទាំងនេះ<br>• ធ្វើសមាហរណកម្មការគិតគូរពិចារណាអំពីបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការលទ្ធកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បណ្តុះបណ្តាលអំពីប្រធានបទនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ | |

## ៣.៥. សមាសធាតុកម្មវិធីទី៥ : ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

### ៣.៥.១. សនិទានភាព

ការងារកំណែទម្រង់ដែលបានលើកឡើងនៅក្នុងកម្មវិធីជាតិរយៈពេល១០ឆ្នាំ ទាមទារឱ្យមានការកសាងសមត្ថភាពដល់ស្ថាប័ននៅថ្នាក់ជាតិ និងស្ថាប័នមិនមែនរដ្ឋាភិបាល ដើម្បីអនុវត្តគោលនយោបាយ ចក្ខុវិស័យ និងកម្មវិធីនានាដែលមានចែងនៅក្នុងកម្មវិធីជាតិ។ ការគាំទ្រស្ថាប័នសម្រាប់ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការពុំមែនធ្វើឡើងតែនៅក្នុងអំឡុងពេលនៃដំណើរការផ្ទេរមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធាននោះឡើយ ពោលគឺត្រូវរៀបចំឱ្យមានស្ថាប័នរឹងមាំសម្រាប់ធ្វើការជាប្រចាំជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ សកម្មភាពទាំងឡាយដែលមានចែងក្នុងសមាសធាតុកម្មវិធីទី៥ នឹងគាំទ្រដល់ការធ្វើអន្តរកាលនៃស្ថាប័នថ្នាក់ជាតិ និងបំពេញភាពខ្វះចន្លោះនានានៅក្នុងការរៀបចំស្ថាប័នទាំងនោះ សំដៅឆ្លើយតបនឹងខ្សែគណនេយ្យភាពថ្មីនានា និងធានាដល់ការបំពេញ តួនាទីរបស់ស្ថាប័នគាំទ្រទាំងនោះក្នុងការផ្តល់ជំនួយបច្ចេកទេសដល់ការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងដំណើរការកំណែទម្រង់នេះ យ៉ាងហោចណាស់ស្ថាប័នគាំទ្រនានាត្រូវមានលទ្ធភាពក្នុងការបំពេញការងារដូចខាងក្រោម :

#### ក). ការអនុម័តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានកំណត់តាមរយៈការអនុម័ត និងការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹង :

- ការរៀបចំស្ថាប័ន រចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្ទេរមុខងារ ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិ ព្រមទាំងបុគ្គលិកចាំបាច់នានាសម្រាប់រៀបចំរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានការទទួលខុសត្រូវ សិទ្ធិអំណាច និងធនធានចាំបាច់នានាក្នុងការផ្តល់សេវាសាធារណៈ
- ការសម្រេចបាននូវគណនេយ្យភាពពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតជាសំខាន់ទៅលើគណនេយ្យភាពរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។

ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ បានផ្តល់អាណត្តិដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ក្នុងការសម្របសម្រួល និងដឹកនាំការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

ហេតុនេះនៅក្នុងបេសកម្មរបស់ខ្លួន គ.ជ.អ.ប ត្រូវសម្របសម្រួលក្នុងការរៀបចំសេចក្តីព្រាង និងការពិនិត្យឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដល់ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការនានារបស់ក្រសួង ស្ថាប័ន ដែលទាក់ទងនឹងការគ្រប់គ្រង ការបែងចែកការទទួលខុសត្រូវ និង

ការផ្ទេរធនធាននានាដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ជាពិសេស គឺការសម្របសម្រួលកំណែទម្រង់ផ្នែកច្បាប់ដែលចាំបាច់ក្នុងការគាំទ្រដល់ការផ្ទេរមុខងារ ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក ។

## ខ). ការពិនិត្យមើល និងការគាំទ្រផ្នែកច្បាប់ដល់ក្រសួង ស្ថាប័ននានា

ដំណើរការកំណែទម្រង់នៅថ្នាក់ជាតិអាស្រ័យទៅនឹងការផ្លាស់ប្តូរនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធនឹងកត្តាសំខាន់ៗ ដូចជាការផ្ទេរមុខងារ និងការរៀបចំរដ្ឋបាលឯកភាពជាដើម ។ ក្នុងពេលដែលមុខងារត្រូវបានផ្ទេរ តួនាទីរបស់ក្រសួង ស្ថាប័ន និងទីភ្នាក់ងារថ្នាក់ជាតិដែលពាក់ព័ន្ធនឹងទិដ្ឋភាពទាំងបួននៃការគ្រប់គ្រងរដ្ឋ ពោលគឺការរៀបចំបទប្បញ្ញត្តិ ការងាររដ្ឋបាល ការងារវិនិយោគ និងការផ្តល់សេវាសាធារណៈនឹងមានការផ្លាស់ប្តូរ ។ ក្រសួង ស្ថាប័ន និងទីភ្នាក់ងារថ្នាក់ជាតិត្រូវដាក់បញ្ចូលនូវមតិយោបល់ និងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលទទួលបានតាមរយៈការប្រាស្រ័យទាក់ទាក់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ពាក់ព័ន្ធនឹងគោលការណ៍នៃរដ្ឋបាលឯកភាព រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រគល់នូវការទទួលខុសត្រូវក្នុងការសម្របសម្រួលសកម្មភាពនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ យន្តការនេះបង្កើតបាននូវខ្សែគណនេយ្យភាពប្រយោលមួយរវាងប្រជាពលរដ្ឋ និងក្រសួង ស្ថាប័ន ដែលប្រព័ន្ធនេះតម្រូវឱ្យប្រជាពលរដ្ឋធ្វើទំនាក់ទំនងផ្ទាល់ជាមួយក្រុមប្រឹក្សា និងគណៈអភិបាល ហើយក្រុមប្រឹក្សា និងគណៈអភិបាលត្រូវបន្តធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន ។ ដូច្នេះជាលទ្ធផល :

- នៅពេលដែលមុខងារត្រូវបានផ្ទេរ ភារកិច្ចនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទាក់ទងនឹងការគ្រប់គ្រងនឹងមានការផ្លាស់ប្តូរ ពោលគឺក្រសួង ស្ថាប័នត្រូវបំពេញតួនាទីពិនិត្យមើល និងតាមដាន ដោយផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធាននានា និងការកំណត់វិធីសាស្ត្រនានាដើម្បីសម្រេចបាននូវលទ្ធផលទាំងនោះ ។ ឧទាហរណ៍ នៅក្នុងការពិនិត្យមើលនិងការតាមដាន ក្រសួងស្ថាប័នត្រូវធានាថា មុខងារដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគោរពតាមស្តង់ដារជាតិ ។
- យុទ្ធសាស្ត្រ និងកម្មវិធីនានារបស់ក្រសួង ស្ថាប័នត្រូវដាក់បញ្ចូលនូវមតិយោបល់ដែលទទួលបានពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិ ជាអ្នកទទួលខុសត្រូវក្នុងការសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅតាមថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងជាអ្នកទទួលបានយោបល់ពីប្រជាពលរដ្ឋអំពីតម្រូវការសេវាសាធារណៈ និងកម្មវិធីចាំបាច់នានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## គ). ការសម្រុះសម្រួលវិវាទ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងមួយ ដែលទាមទារឱ្យមានការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងក្រសួង ស្ថាប័ន និងមន្ទីរ ការិយាល័យខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន ។ ដូចនេះ ចាំបាច់ត្រូវមានយន្តការច្បាស់លាស់សម្រាប់ដោះស្រាយវិវាទនានាដែលអាចកើតមានឡើងនៅក្នុងចំណោមថ្នាក់រដ្ឋបាលទាំងនោះ ។

## ឃ). ការតាមដាន និងវាយតម្លៃកម្មវិធីជាតិ

គ.ជ.អ.ប ត្រូវអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃឱ្យមានប្រសិទ្ធភាព ដើម្បីវាស់វែងផលប៉ះពាល់ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ(រួមទាំងការកសាងសមត្ថភាព)។ ដើម្បីសម្រេចបាននូវកិច្ចការនេះ ចាំបាច់ត្រូវផ្តល់ការគាំទ្របច្ចេកទេសដល់អ្នកគ្រប់គ្រង និងបុគ្គលិកជំនាញដែលទទួលខុសត្រូវផ្នែកនេះ អំពីរបៀបអនុវត្តការវាស់វែងលទ្ធផលបំពេញការងារ(រួមទាំងផ្នែកបច្ចេកទេស) និងអំពីរបៀបប្រើប្រាស់ព័ត៌មានដែលប្រមូលបាន។

## ង). ការកសាងសមត្ថភាព

រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នដទៃទៀត ត្រូវការនូវការគាំទ្របច្ចេកទេស និងការបណ្តុះបណ្តាលតាមប្រព័ន្ធបណ្តុះបណ្តាលជាក់លាក់មួយ ដើម្បីធានាឱ្យបុគ្គលិក និងស្ថាប័នទាំងនេះ អាចសម្រេចបាននូវលទ្ធផលរំពឹងទុកនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដូចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសទៅលើ :

- ការកសាងក្រុមអ្នកមានវិជ្ជាជីវៈវ័យក្មេង ដែលនឹងចូលរួមបម្រើការងារជាមន្ត្រីរាជការសម្រាប់មុខតំណែងនានា និងសម្រាប់បន្តវេនពីមន្ត្រីរាជការចូលនិវត្តន៍ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ
- ការធានាថា មន្ត្រីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការទទួលខុសត្រូវរបស់ខ្លួន
- ការធានាឱ្យមន្ត្រីរាជការដែលបំពេញការងារនៅថ្នាក់ក្រោមជាតិមានទម្លាប់ និងឥរិយាបទថ្មីជាមួយខ្សែគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋរបស់ខ្លួន
- ការកសាងសមត្ថភាពដល់បេក្ខជនក្រុមប្រឹក្សាអាណត្តិបន្ទាប់
- ប្រជាពលរដ្ឋដែលមានការចាប់អារម្មណ៍នៅក្នុងកិច្ចដំណើរការអភិបាលកិច្ចនិងអភិវឌ្ឍន៍មូលដ្ឋាន ឬក្រុមប្រឹក្សាដែលទើបជាប់ឆ្នោតថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបញ្ជ្រាបយេនឌ័រ និងការលើកស្ទួយស្ត្រីនៅក្នុងក្រុមប្រឹក្សា និងនៅក្នុងមន្ត្រីរាជការ។

នៅក្នុងការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័ននេះ ទាមទារឱ្យមានការចូលរួមទាំងស្ថាប័នសាធារណៈ និងឯកជនដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងនេះ។ ស្ថាប័នទាំងនេះ ជាពិសេសសាលារដ្ឋបាលសាធារណៈនានាត្រូវរៀបចំកម្មវិធីសិក្សាមួយ ដែលឆ្លើយតបទៅនឹងស្ថានភាពអភិបាលកិច្ចជាក់ស្តែងនៅថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ ត្រូវសិក្សារៀបចំឱ្យមានស្ថាប័ន(សាលា វិទ្យាស្ថាន មជ្ឈមណ្ឌល) ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈអំពីជំនាញរដ្ឋបាលមូលដ្ឋាន។ កម្មវិធីបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈរបស់ស្ថាប័នរាជរដ្ឋាភិបាលដែលមានបច្ចុប្បន្ន ជាពិសេសអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ នឹងត្រូវបានសិក្សាវាយតម្លៃក្នុងការកំណត់អំពីតម្រូវការនៃការកសាងសមត្ថភាពរបស់ស្ថាប័នបណ្តុះបណ្តាលទាំងនេះ ដើម្បីអាចឆ្លើយតបបានទៅនឹងតម្រូវការរបស់រដ្ឋបាលមូលដ្ឋាន។ កម្មវិធីកសាងសមត្ថភាពរបស់ក្រសួង ស្ថាប័ន នឹងមិនអាចបំពេញនូវតម្រូវការនៃការកសាងសមត្ថភាពដ៏ធំធេងនេះបានទេ ដូច្នេះចាំបាច់ត្រូវសហការជាមួយអង្គការសង្គមស៊ីវិល និងស្ថាប័នបណ្តុះបណ្តាលឯកជននានា។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការកសាងសមត្ថភាពបុគ្គលិក និងស្ថាប័ន ទាមទារឱ្យមានវិធីសាស្ត្រថ្មីៗបន្ថែមទៀតក្នុងការផ្ទេរចំណេះដឹង ជាពិសេសវិធីសាស្ត្រជាយុទ្ធសាស្ត្រចំនួន២ គឺ**ការរៀនបណ្តើរធ្វើបណ្តើរ** និង**ការគ្រប់គ្រងចំណេះដឹង**។ របៀបអនុវត្តវិធីសាស្ត្ររៀនបណ្តើរធ្វើបណ្តើរ មានអធិប្បាយលម្អិតនៅក្នុងផែនការកសាងសមត្ថភាព។ វិធីសាស្ត្រគ្រប់គ្រងចំណេះដឹង ទាមទារឱ្យមានការប្រមូល និងចងក្រងនូវមេរៀនបទពិសោធន៍កន្លងមក តាមរយៈការបង្កើតនូវប្រព័ន្ធគ្រប់គ្រងចំណេះដឹង ដើម្បីឱ្យអ្នកពាក់ព័ន្ធនានានៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានលទ្ធភាពប្រើប្រាស់ឯកសារ និងសម្ភារៈបណ្តុះបណ្តាលនានាដែលទាក់ទងនឹងបទពិសោធន៍នៃការងារកំណែទម្រង់។ ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងចំណេះដឹងចាំបាច់ត្រូវកំណត់ :

១. អំពីមុខសញ្ញាអ្នកដែលត្រូវការចំណេះដឹង និងអំពីគោលបំណង។ មុខសញ្ញាអ្នកដែលត្រូវការចំណេះដឹងរួមមាន រដ្ឋបាលថ្នាក់ក្រោមជាតិ គ.ជ.អ.ប ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាដែលរួមចំណែកក្នុងការរៀបចំគោលនយោបាយនានាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តមុខងាររបស់ខ្លួន។
២. អំពីរបៀបដែលត្រូវបង្កើនចំណេះដឹង (ឧទាហរណ៍ របាយការណ៍ និងការសិក្សាវាយតម្លៃរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដៃគូអភិវឌ្ឍន៍ និងការសិក្សាវាយតម្លៃរបស់អង្គការសង្គមស៊ីវិលនានា)
៣. អំពីរបៀបថែរក្សា និងតម្កល់ឯកសារ
៤. អំពីតម្រូវការផ្នែកច្បាប់ និងកិច្ចសន្យា

### ច). ការគាំទ្រគោលនយោបាយ

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំរាជធានី ខេត្ត ព្រមទាំងសមាគមក្រុមប្រឹក្សាតាមប្រភេទផ្សេងទៀត គឺជាសំឡេងមួយដ៏សំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងចាំបាច់ត្រូវទទួលបាននូវការគាំទ្រនានាក្នុងគោលបំណងលើកកម្ពស់ផលប្រយោជន៍រួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងស្វ័យភាពនិងការចូលរួមរបស់រដ្ឋបាលទាំងនេះនៅក្នុងការរៀបចំគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ព្រមទាំងការកំណត់និងការលើកឡើងនូវសេចក្តីត្រូវការផ្នែកកសាងសមត្ថភាពរបស់ខ្លួន។

## ៣.៥.២. គោលបំណងសមាសធាតុកម្មវិធី

សមាសធាតុកម្មវិធីទី៥ មានគោលបំណងដើម្បីពង្រឹងស្ថាប័នថ្នាក់ជាតិនានាសម្រាប់ដឹកនាំការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.៥.៣. ការងារចំាអាទិភាពនានា

### ក). ដំណាក់កាលទី១

#### ក.១). អនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប រៀបចំផែនការការងារប្រចាំឆ្នាំ ស្របជាមួយនឹងកម្មវិធីជាតិ

អនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប គឺជាយន្តការអន្តរក្រសួង ស្ថាប័នដែលមានតួនាទីក្នុងការសម្របសម្រួលជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល និង

ធ្វើការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ និងពិនិត្យឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តនានា មុននឹងដាក់ជូន គ.ជ.អ.ប ពិនិត្យសម្រេច។ អនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ត្រូវរៀបចំ និងអនុវត្តផែនការការងារប្រចាំឆ្នាំរបស់ខ្លួនសម្រាប់គាំទ្រការអនុវត្តកម្មវិធីជាតិ។ ផែនការការងារនេះត្រូវបរិយាយអំពីជំនួយបច្ចេកទេសសម្រាប់អនុវត្តសកម្មភាពនានាដែលទាក់ទងនឹងអាណត្តិរបស់ខ្លួន។

### ក.២). ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំយុទ្ធសាស្ត្រសម្រាប់ផ្ទេរមុខងារដែលបានគ្រោងទុក

ការគាំទ្រត្រូវផ្តល់ជាបន្ទាន់ដល់ក្រសួង ស្ថាប័ននានាដែលត្រូវផ្ទេរមុខងារ បុគ្គលិក និងធនធានហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូច្នេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធានាឱ្យមានសង្គតិភាពនៃការគាំទ្រផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការពិនិត្យមុខងារឡើងវិញនៅក្នុងក្រសួង ស្ថាប័នទាំងអស់។ ការគាំទ្រនេះត្រូវធ្វើឡើងដោយមានកិច្ចសហការជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងផ្អែកតាមផែនការសកម្មភាពមួយដោយផ្តោតការគាំទ្រចំពោះក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការដែលជាក្រុមត្រូវទទួលបាននូវការគាំទ្រមុនគេ។ ការគាំទ្រនេះត្រូវរួមបញ្ចូលទាំងការពិនិត្យ និងកែសម្រួលឡើងវិញនូវច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដែលត្រូវធ្វើវិសោធនកម្ម ដើម្បីរំលេចឱ្យឃើញនូវតួនាទី និងការទទួលខុសត្រូវថ្មីនានារបស់ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ និងអង្គភាពខ្សែបណ្តោយនានា។ ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធានាឱ្យមានឱកាសសិក្សារៀនសូត្រពីគ្នាទៅវិញទៅមករវាងក្រសួង ស្ថាប័នទាំងអស់។

### ក.៣). រៀបចំផែនការកសាងសមត្ថភាពដល់ស្ថាប័នបណ្តុះបណ្តាលសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ការធ្វើស្ថាប័នភាវូបនីយកម្មនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងមូល ទាមទារឱ្យមានការផ្លាស់ប្តូរនូវយុទ្ធសាស្ត្រ និងប្រព័ន្ធបណ្តុះបណ្តាលកសាងសមត្ថភាពរបស់ស្ថាប័ននានា ដែលធ្វើការបណ្តុះបណ្តាលអំពីការងាររដ្ឋបាល ជាពិសេសរដ្ឋបាលមូលដ្ឋាននៅកម្ពុជា។ នៅក្នុងដំណាក់កាលដំបូងនេះ ចាំបាច់ត្រូវកំណត់អំពីយុទ្ធសាស្ត្រនៃការកសាងសមត្ថភាព និងសិក្សាវាយតម្លៃអំពីសមត្ថភាពរបស់ស្ថាប័នបណ្តុះបណ្តាលនានាដែលមានបច្ចុប្បន្ន ដើម្បីដាក់បញ្ចូលយុទ្ធសាស្ត្រថ្មីនេះទៅក្នុងកម្មវិធីសិក្សា។

### ក.៤). សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកែសម្រួលឱ្យស្របទៅនឹងស្ថានភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការវាយតម្លៃពីសមត្ថភាព និងអាណត្តិបច្ចុប្បន្នរបស់ខ្លួន។ ការវាយតម្លៃនេះត្រូវយកចិត្តទុកដាក់ទៅលើតម្រូវការនានា និងការរៀបចំស្ថាប័ន ដែលឆ្លុះបញ្ចាំងពីគោលនយោបាយស្តីពីការរៀបចំមុខងារឡើងវិញរបស់រាជរដ្ឋាភិបាល។ ការវាយតម្លៃនេះក៏ត្រូវយកចិត្តទុកដាក់ផងដែរទៅលើសមត្ថភាព និងយន្តការចាំបាច់នានាដើម្បីធានាដល់គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងយកចិត្តទុកដាក់ទៅលើ

តម្រូវការនានាដើម្បីធានាឯករាជភាពរបស់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នដទៃទៀតដែលគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ខ). ដំណាក់កាលទី២

### ខ.១). បន្តរៀបចំបរិយាកាសអំណោយផលក្នុងការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងរយៈពេល១០ឆ្នាំនៃកម្មវិធីជាតិ គ.ជ.អ.ប នឹងត្រូវការជំនួយក្នុងការរៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធ និងកម្មវិធីចាំបាច់នានា ដើម្បីបង្កើតឱ្យមានបរិយាកាសអំណោយផលសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

### ខ.២). បង្កើនការទទួលខុសត្រូវរបស់ស្ថាប័នបណ្តុះបណ្តាលក្នុងការអនុវត្តផែនការកសាងសមត្ថភាពដែលមានចែងក្នុងកម្មវិធីជាតិ

ការអនុវត្តផែនការកសាងសមត្ថភាពរបស់កម្មវិធីជាតិ ត្រូវរៀបចំឱ្យមានយុទ្ធសាស្ត្រសមស្របមួយសម្រាប់ផ្ទេរការទទួលខុសត្រូវដល់ស្ថាប័នបណ្តុះបណ្តាលនានាក្នុងការកសាងសមត្ថភាពអំពីការងាររដ្ឋបាលមូលដ្ឋាន។ យុទ្ធសាស្ត្រនេះនឹងជួយពង្រឹងកិច្ចដំណើរការកសាងសមត្ថភាព ដើម្បីធានាដល់ការសម្រេចបាននូវលទ្ធផលដែលរំពឹងទុក។ ការសិក្សាវាយតម្លៃស្ថាប័នបណ្តុះបណ្តាល និងកម្មវិធីកសាងសមត្ថភាពស្ថាប័ននឹងត្រូវបានអនុវត្ត ដូចមានចែងនៅក្នុងតារាងក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៥ និងផែនការកសាងសមត្ថភាពរបស់កម្មវិធីជាតិ។

### ខ.៣). រៀបចំឱ្យមានសម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

ការគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានលទ្ធភាពបំពេញមុខងារបានប្រកបដោយប្រសិទ្ធភាព មានស្វ័យភាព និងមានគណនេយ្យភាព ចាំបាច់ត្រូវបង្កើតស្ថាប័នគាំទ្រនានា ដើម្បីជួយពង្រឹងអាណត្តិតាមផ្លូវច្បាប់ និងកិច្ចប្រតិបត្តិការរបស់រដ្ឋបាលទាំងនោះ។ នៅក្នុងន័យនេះ ត្រូវសិក្សារៀបចំឱ្យមាននូវសម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថភាពនិងធនធានសមស្រប ដើម្បីលើកកម្ពស់តួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមក្នុងការកសាងវិជ្ជាជីវៈមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣.៥.៤. ក្របខ័ណ្ឌតក្កភាព

ក្របខ័ណ្ឌតក្កភាពសម្រាប់សមាសធាតុកម្មវិធីទី៥ មាននៅក្នុងតារាងក្របខ័ណ្ឌតក្កភាព ៣.៥។

## តារាង៣.៥ : ក្របខ័ណ្ឌតក្កភាពនៃសមាសធាតុកម្មវិធីទី៥

| សមាសធាតុកម្មវិធីទី៥ : ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | | |
|---|---|---|
| **គោលបំណងសមាសធាតុកម្មវិធីទី៥** | **សូចនាករ** | **ការសន្មតសំខាន់ៗ** |
| ពង្រឹងស្ថាប័នថ្នាក់ជាតិនានាសម្រាប់ដឹកនាំការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ | • ចំនួននិស្សិតទាំងពីរភេទដែលទទួលបានសញ្ញាបត្ររដ្ឋបាល និងគោលនយោបាយសាធារណៈ និងភាគរយនៃនិស្សិតទាំងនេះបានចូលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃសម្ព័ន្ធភាព និងសមាគមរដ្ឋបាលថ្នាក់ក្រោមជាតិ មានផែនការ និងថវិកាសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ភាគរយនៃប្រជាពលរដ្ឋទាំងពីរភេទដែលបង្ហាញថា ខ្លួនយល់ដឹងពីសមភាព និងសមធមិយេនឌ័រនៅក្នុងអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • ស្ថាប័ននៅថ្នាក់ជាតិទទួលបានជំនួយបច្ចេកទេសដែលចាំបាច់ក្នុងការកែតម្រូវ និងផ្តល់ការណែនាំដល់អង្គភាពរបស់ខ្លួនស្របតាមគោលការណ៍នានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• វិធីសាស្ត្រនៃការកសាងសមត្ថភាពមានលក្ខណៈ សមស្របតាមស្ថានភាពដោយឡែកៗរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ក្រសួង ស្ថាប័នកសាងសមត្ថភាពផ្ទៃក្នុងស្ថាប័ន ដើម្បីចូលរួមចំណែកក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ<br>• កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យត្រូវចូលរួមគាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៥.១. គ.ជ.អ.ប រៀបចំ និងអនុម័តលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីប្រតិបត្តិការសមស្រប សម្រាប់ការអនុវត្តកម្មវិធីជាតិ | • គ.ជ.អ.ប រៀបចំ និងអនុវត្តផែនការសកម្មភាពក្នុងការអនុម័តលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីចាំបាច់នានា | • បន្តអនុវត្តផែនការសកម្មភាពក្នុងការអនុម័តលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីចាំបាច់នានា | • ពិនិត្យឡើងវិញលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានដាក់ឱ្យអនុវត្តដើម្បីកែលម្អ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីថ្មីៗបន្ថែមទៀត |
| ៥.២. ជួយគាំទ្រក្រសួង ស្ថាប័នក្នុងការពិនិត្យមើល និងរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងដំណើរការដែលឆ្លុះបញ្ចាំងពីតួនាទី និងការទទួលខុសត្រូវថ្មីរបស់ខ្លួនចំពោះរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ | • ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៅតាមក្រសួង ស្ថាប័នរៀបចំ និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ផ្ទេរមុខងារ ធនធានជាបឋម ស្របតាមវិធីសាស្ត្រផ្អែកតាមវិស័យ និងតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>• ក្រសួង ស្ថាប័នរៀបចំ និងអនុវត្តផែនការសកម្មភាពដើម្បីកែសម្រួលយុទ្ធសាស្ត្រតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនឱ្យស្របជាមួយនឹងការផ្ទេរមុខងារ និងធនធាន | • ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័ន បន្តរៀបចំ និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ផ្ទេរមុខងារ និងធនធានសម្រាប់ដំណាក់កាលទី២<br>• ក្រសួង ស្ថាប័នរៀបចំ និងអនុវត្តផែនការសកម្មភាពដើម្បីកែសម្រួលយុទ្ធសាស្ត្រតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ឱ្យស្របជាមួយនឹងការផ្ទេរមុខងារ និងធនធាន | • ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្ថាប័នបន្តរៀបចំ និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ផ្ទេរមុខងារ និងធនធានសម្រាប់ដំណាក់កាលទី៣ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ៥.៣. បង្កើតឱ្យមានយន្តការសម្របសម្រួលកិច្ចការរដ្ឋបាល និងសម្រុះសម្រួលវិវាទរដ្ឋបាល | • បង្កើតឱ្យមានយន្តការសម្របសម្រួលកិច្ចការរដ្ឋបាលសម្រាប់សម្រុះសម្រួលវិវាទរបស់អន្តររដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | • ពង្រឹងយន្តការសម្របសម្រួលកិច្ចការរដ្ឋបាលសម្រាប់សម្រុះសម្រួលវិវាទ និងបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ | • ពិនិត្យ និងវាយតម្លៃយន្តការ និងដំណើរការសម្រុះសម្រួលវិវាទអន្តររដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែសម្រួលឱ្យបានសមស្រប |
| ៥.៤. គ.ជ.អ.ប ត្រូវរៀបចំឡើងវិញនូវអង្គភាពតាមដាន និងវាយតម្លៃរបស់ខ្លួន ដើម្បីអនុវត្តកម្មវិធីតាមដាន និងវាយតម្លៃរបស់កម្មវិធីជាតិ | • បង្កើតអនុគណៈកម្មាធិការតាមដាន និងវាយតម្លៃរបស់ គ.ជ.អ.ប<br>• កំណត់អំពីសូចនាករនានា<br>• រៀបចំនូវទិន្នន័យគោល<br>• ដាក់ចេញនូវសេចក្តីណែនាំស្តីពីការតាមដាន និងការវាយតម្លៃ | • រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃ និងដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត<br>• វាយតម្លៃការអនុវត្តកម្មវិធីជាតិនៅពាក់កណ្តាលកម្មវិធី | • រៀបចំរបាយការណ៍តាមដាន និងវាយតម្លៃ និងដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត<br>• វាយតម្លៃការអនុវត្តកម្មវិធីជាតិរយៈពេល ១០ឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីជាតិនៅក្នុងដំណាក់កាលបន្ទាប់ទៀត |
| ៥.៥. បង្កើតយន្តការត្រួតពិនិត្យនីត្យានុកូលភាពនៃការកែសម្រួលលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • រៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានសមស្រប | • បន្តរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឱ្យបានសមស្រប | • បន្តរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការឱ្យបានសមស្រប |
| ៥.៦. រៀបចំបង្កើតស្ថាប័នបណ្តុះបណ្តាល ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក និងស្ថាប័នដែលទទួលខុសត្រូវចំពោះ | • រៀបចំទិន្នន័យគោលអំពីតម្រូវការក្នុងការកសាងសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | • បង្កើតបណ្តាញការងារនៃស្ថាប័នកសាងសមត្ថភាពថ្នាក់តំបន់ និងថ្នាក់ជាតិ ដោយឆ្លុះបញ្ចាំងនូវយុទ្ធសាស្ត្រផ្ទេរចំណេះដឹង | • បន្តពង្រឹងស្ថាប័នបណ្តុះបណ្តាល |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ | • សិក្សាវាយតម្លៃអំពីការបណ្តុះបណ្តាល និងការផ្ទេរចំណេះដឹងនៃស្ថាប័នសាធារណៈ និងឯកជន ព្រមទាំងកសាងនូវយុទ្ធសាស្ត្រមួយដែលឆ្លើយតបនឹងតម្រូវការកសាងសមត្ថភាពរយៈពេលវែង<br>• គ.ជ.អ.ប ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងដៃគូអភិវឌ្ឍន៍ឯកភាពគ្នាលើយុទ្ធសាស្ត្រស្តីពីការផ្ទេរចំណេះដឹង និងប្រព័ន្ធគ្រប់គ្រងចំណេះដឹងដែលគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ លើមូលដ្ឋាននៃទិន្នន័យគោលស្តីពីតម្រូវការកសាងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នសាធារណៈ និងឯកជន | និងប្រព័ន្ធគ្រប់គ្រងចំណេះដឹង<br>• គ.ជ.អ.ប សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំសេចក្តីព្រាងនៃកម្មវិធីសិក្សាអំពីការអភិវឌ្ឍ ការគ្រប់គ្រង និងអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ<br>• អនុវត្តសាកល្បងនូវកម្មវិធីស្តីពីការពង្រឹងភាពជាអ្នកដឹកនាំសម្រាប់គាំទ្រក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំ និងអនុវត្តផែនការសកម្មភាពសម្រាប់ពង្រឹងភាពជាអ្នកដឹកនាំឱ្យបានមុនអាណត្តិទី២នៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | |
| ៥.៧. ស្ថាប័ននានាសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បង្កើន និងជំរុញការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សមភាពនិងសមធម៌ | • រៀបចំ និងអនុវត្តនូវមេរៀនទាក់ទងនឹងសមភាពនិងសមធម៌យេនឌ័រនៅក្នុងកម្មវិធីសិក្សារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | • បញ្ចប់ការវាយតម្លៃលើកម្មវិធីយេនឌ័រពាក់ព័ន្ធទៅនឹងការលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ស្ត្រី នៅរដ្ឋបាលថ្នាក់ក្រោម | |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| យេនឌ័រ និងការឆ្លើយតបចំពោះក្រុមជនងាយរងគ្រោះ | • បង្កើតឱ្យមានសមាគម ឬបណ្តាញការងាររបស់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិជាស្ត្រី<br>• រៀបចំ និងអនុវត្តនូវកម្មវិធីបណ្តុះបណ្តាលស្តីពីការងារតាមដាន និងការស្វែងរកការគាំទ្រការងារយេនឌ័រ | ជាតិ និងដាក់ជូន គ.ជ.អ.ប ដើម្បីផ្តល់អនុសាសន៍សម្រាប់អនុវត្ត | |
| ៥.៨. សម្ព័ន្ធភាពជាតិ និងសមាគមនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានសមត្ថភាព និងថវិកាសមស្របសម្រាប់រៀបចំកម្មវិធី ដើម្បីឆ្លើយតបនឹងតម្រូវការនានា | • សម្ព័ន្ធភាពជាតិ និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ កែសម្រួលកម្មវិធី និងយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធរដ្ឋបាលនៅថ្នាក់ក្រោមជាតិ<br>• សិក្សាអំពីលទ្ធភាព និងរៀបចំបង្កើតសម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សាប្រភេទផ្សេងៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បង្កើតកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពដល់សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ<br>• សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សា | • បន្តសិក្សាអំពីលទ្ធភាព និងរៀបចំបង្កើតសម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សាប្រភេទផ្សេងៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យមើលឡើងវិញនូវកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាព និងផែនការសកម្មភាព ដើម្បីកៀរគរធនធានពីប្រភពនានា<br>• បង្កើតឱ្យមានកម្មវិធីគាំទ្រដើម្បីតាមដានវឌ្ឍនភាព និងវាយតម្លៃផលប៉ះពាល់នៃយន្តការបញ្ជ្រាបយេនឌ័រ | • ពិនិត្យមើលឡើងវិញនូវកិច្ចដំណើរការ និងប្រសិទ្ធភាពការងាររបស់សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែសម្រួលឱ្យបានសមស្រប<br>• សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាព និងថវិកាសមស្របពីប្រភពផ្សេងៗ ដើម្បីឆ្លើយតបនឹងតម្រូវការនានារបស់ខ្លួន<br>• រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងផលប៉ះ |

| លទ្ធផលរំពឹងទុក | សកម្មភាពសំខាន់ៗ | | |
|---|---|---|---|
| | ដំណាក់កាលទី១ | ដំណាក់កាលទី២ | ដំណាក់កាលទី៣ |
| | រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំផែនការសកម្មភាព ដើម្បីកៀរគរធនធានពីប្រភពនានាសម្រាប់បម្រើឱ្យផែនការសកម្មភាពរបស់ខ្លួន<br>• សម្ព័ន្ធភាពជាតិ និងសមាគមនៃក្រុមប្រឹក្សាប្រភេទផ្សេងៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំកម្មវិធី និងសកម្មភាពចាំបាច់ ដើម្បីធ្វើសមាហរណកម្មគោលនយោបាយយេនឌ័រនៅក្នុងស្ថាប័នរបស់ខ្លួន<br>• រៀបចំយន្តការក្នុងការចូលរួមរៀបចំគោលនយោបាយនានា | | ពាល់នៃយន្តការបញ្ជ្រាបយេនឌ័រ |

# ជំពូកទី៤
# ការគ្រប់គ្រងកម្មវិធីជាតិ

# ជំពូកទី៤
# ការគ្រប់គ្រងកម្មវិធីជាតិ

## ៤.១. ការរៀបចំចាត់ចែងសម្រាប់ការគ្រប់គ្រងកម្មវិធីជាតិ

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលនឹងសម្រេចឱ្យបាននូវលទ្ធផលនានាតាមរយៈ (១)គោលនយោបាយ (ដូចជា លិខិតបទដ្ឋាននានាសម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់) (២)ស្ថាប័ន (រចនាសម្ព័ន្ធ និងប្រព័ន្ធនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និង(៣)ការលើកកម្ពស់សេវាសាធារណៈ (តាមរយៈការវិនិយោគលើប្រព័ន្ធគ្រប់គ្រងនិងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គម)។ ការអនុវត្តកម្មវិធីជាតិនេះនឹងមានផលប៉ះពាល់ទៅលើក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិ រួមទាំងអង្គភាព និងស្ថាប័ននៅថ្នាក់ក្រោមជាតិផងដែរ។ ដូចនេះ ការគ្រប់គ្រងកម្មវិធីជាតិទាមទារឱ្យមានទាំងយន្តការបច្ចេកទេស និងយន្តការនយោបាយដែលមានការចូលរួមពីតំណាងនៃថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការរៀបចំចាត់ចែងសម្រាប់ការគ្រប់គ្រងកម្មវិធីជាតិនេះ ត្រូវតែមានលទ្ធភាពអាចរ៉ាប់រងបាននូវរាល់កិច្ចការទាំងអស់ដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការណែនាំផ្នែកគោលនយោបាយស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ ការសម្របសម្រួលកម្មវិធីជាតិ និងការគ្រប់គ្រងដំណើរការអនុវត្តកម្មវិធីជាតិ។

### ៤.១.១. ការណែនាំខាងគោលនយោបាយស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ

ជោគជ័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺអាស្រ័យទាំងស្រុងទៅលើការប្តេជ្ញាចិត្តកម្រិតខ្ពស់របស់រាជរដ្ឋាភិបាល។ ចំណុចនេះបញ្ជាក់ឱ្យឃើញថា ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រួមទាំងការអនុវត្តកម្មវិធីជាតិ ទាមទារឱ្យមាននូវការណែនាំផ្នែកគោលនយោបាយយ៉ាងច្បាស់លាស់ និងជាប់ជាប្រចាំពីរាជរដ្ឋាភិបាល។ ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ បានប្រគល់អាណត្តិក្នុងការដឹកនាំកិច្ចដំណើរការនេះដល់គណៈកម្មាធិការអន្តរក្រសួងមួយ ពោលគឺគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (ហៅកាត់ថា"គ.ជ.អ.ប")។

គ.ជ.អ.ប ក្នុងនាមជាស្ថាប័នទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តកម្មវិធីជាតិ ត្រូវធានាថា ការអនុវត្តសមាសធាតុទាំងអស់នៃកម្មវិធីជាតិ បានអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។ ផ្អែកតាមកម្មវិធីជាតិដែលបានអនុម័តដោយរាជរដ្ឋាភិបាល គ.ជ.អ.ប ត្រូវពិនិត្យ ពិភាក្សា និងអនុម័តក្នុងការដាក់បញ្ចូលនូវរាល់សកម្មភាពទាំងអស់នៃកម្មវិធីជាតិដែលបានគ្រោងឡើងនៅដំណាក់កាលទាំងបី ទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ដើម្បីវាស់វែងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិ គ.ជ.អ.ប ត្រូវតាមដាន និងវាយតម្លៃនៅពេលបញ្ចប់ដំណាក់កាល

នីមួយៗ នៅពាក់កណ្ដាលកម្មវិធី និងនៅពេលបញ្ចប់កម្មវិធី។ ទន្ទឹមនេះ រាជរដ្ឋាភិបាលអនុញ្ញាតឱ្យមានបេសកកម្មតាមដាន និងវាយតម្លៃរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍(តាមរយៈបេសកកម្មពិគ្រោះយោបល់ម្ដងម្កាល ការវាយតម្លៃនៅពេលបញ្ចប់ដំណាក់កាលនីមួយៗ និងការសិក្សាស៊ីជម្រៅនានា) ដើម្បីផ្ដល់អនុសាសន៍សម្រាប់លើកកម្ពស់វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិ។

គ.ជ.អ.ប ត្រូវសម្របសម្រួលជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការកំណត់នូវមុខងារ ដោយភ្ជាប់ជាមួយធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក ដើម្បីផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចបានរៀបរាប់ក្នុងកម្មវិធីជាតិនេះ។ ម្យ៉ាងទៀត គ.ជ.អ.ប ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីតម្រឹមកម្មវិធីទាំងបី គឺកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

យោងតាមអាណត្តិរបស់ខ្លួន គ.ជ.អ.ប ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិប្រចាំឆ្នាំ និងតាមតម្រូវការ។ កិច្ចដំណើរការនេះនឹងជួយឱ្យរាជរដ្ឋាភិបាលឱ្យមានលទ្ធភាពត្រួតពិនិត្យមើលនូវផលប៉ះពាល់នានានៃកម្មវិធីជាតិនេះ និងរក្សាបាននូវការប្ដេជ្ញាចិត្តខាងគោលនយោបាយយ៉ាងរឹងមាំ។

យោងតាមអាណត្តិរបស់ខ្លួន អនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ត្រូវជួយពិនិត្យមើលបញ្ហានីមួយៗដែលពាក់ព័ន្ធតួនាទី ការទទួលខុសត្រូវរបស់ខ្លួននៅក្នុងការអនុវត្តសមាសធាតុទាំងអស់នៃកម្មវិធីជាតិ។

## ៤.១.២. ការសម្របសម្រួលកម្មវិធីជាតិ

អនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប គឺជាយន្តការអន្តរក្រសួង ដែលមានបេសកកម្មជាចម្បងក្នុងការសម្របសម្រួលជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាល ព្រមទាំងត្រូវធ្វើការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីតាក់តែង និងពិនិត្យមើលឡើងវិញនូវលិខិតបទដ្ឋានគតិយុត្ត និងសេចក្ដីណែនាំនានា មុននឹងដាក់ជូន គ.ជ.អ.ប ពិនិត្យសម្រេច។ លិខិតបទដ្ឋានគតិយុត្ត និងសេចក្ដីណែនាំទាំងនេះ ជាធាតុចូលយ៉ាងសំខាន់នៃសមាសធាតុកម្មវិធីទាំងប្រាំ ដើម្បីឱ្យកម្មវិធីជាតិសម្រេចបាននូវលទ្ធផលនានាតាមការរំពឹងទុក។ អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ត្រូវរួមបញ្ចូលនូវតំណាងមកពីសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីលើកកម្ពស់សំឡេងរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំ និងអនុវត្តគោលនយោបាយ។

អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ ត្រូវធ្វើការជិតស្និទ្ធជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យមើល និងធានានូវការសម្របសម្រួលការអនុវត្តសមាសធាតុកម្មវិធីទី៤នៃកម្មវិធីជាតិ។ លទ្ធផលរំពឹងទុកជាចម្បងនៅក្នុងសមាសធាតុកម្មវិធីទី៤នេះ គឺការបង្កើតប្រព័ន្ធថវិកា ប្រព័ន្ធផ្ដល់ហិរញ្ញប្បទាន និងប្រព័ន្ធគណនេយ្យ។ ដូច្នេះ អនុគណៈកម្មាធិការសារពើពន្ធ និងហិរញ្ញវត្ថុ

ត្រូវទទួលខុសត្រូវក្នុងការរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត តាមរយៈយន្តការនៃគណៈកម្មាធិការដឹកនាំការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអនុគណៈកម្មាធិការសារពើពន្ធនិងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវអំពីបែបផែននៃការកៀរគរ និងការផ្ទេរធនធាន ដើម្បីគាំទ្រការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល ត្រង់ចំណុចទី២ ទី៣ ទី៥ ទី៦ និងចំណុចទី៨ ដែលបានអធិប្បាយនៅក្នុងផ្នែកទី២.២ ជំពូកទី២នៃឯកសារកម្មវិធីជាតិនេះ។

អនុគណៈកម្មាធិការមុខងារ និងធនធាននៃ គ.ជ.អ.ប ត្រូវធ្វើការជាមួយគ្រប់ក្រសួង ស្ថាប័នទាំងអស់ ជាពិសេសត្រូវពិនិត្យមើល និងធានានូវការសម្របសម្រួលការអនុវត្តសមាសធាតុកម្មវិធីទី១ ទី៣ និងទី៥។ ជាពិសេស អនុគណៈកម្មាធិការនេះ ត្រូវជួយដល់ គ.ជ.អ.ប ក្នុងការពិគ្រោះពិភាក្សាជាមួយក្រសួង ស្ថាប័ននៅថ្នាក់ជាតិអំពីដំណើរការកំណត់មុខងារ និងការទទួលខុសត្រូវ ដែលមានភ្ជាប់ជាមួយនូវធនធាន ទ្រព្យសម្បត្តិ និងបុគ្គលិកសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាលត្រង់ចំណុចទី១ ទី៣ និងទី៤ ដែលបានអធិប្បាយនៅក្នុងផ្នែកទី២.២ ជំពូកទី២នៃឯកសារកម្មវិធីជាតិនេះ។

អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវត្រួតពិនិត្យមើល និងធានាការសម្របសម្រួលសកម្មភាពនៃសមាសធាតុកម្មវិធីទី១ និងទី២ ជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ព្រមទាំងធានាឱ្យមានការបន្សុីគ្នារវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាមួយកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីសម្រេចបានតាមការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាលត្រង់ចំណុចទី៧ ដែលបានអធិប្បាយនៅក្នុងផ្នែកទី២.២ ជំពូកទី២នៃឯកសារកម្មវិធីជាតិនេះ។

អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយអនុគណៈកម្មាធិការទាំងបីខាងលើក្នុងការត្រួតពិនិត្យមើល និងធានាការសម្របសម្រួលការអនុវត្តសមាសធាតុកម្មវិធីទី១ ទី៣ និងទី៤ នៃកម្មវិធីជាតិ។

ក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការគឺជាយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ យន្តការនេះត្រូវរៀបចំឡើងវិញ តាមរយៈការបង្កើតជាអនុក្រុមការងារនានា ឱ្យស្របជាមួយនឹងអាណត្តិការងាររបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប។ អនុក្រុមការងារនីមួយៗ ដែលមានតំណាងពីរាជរដ្ឋាភិបាល និងពីដៃគូអភិវឌ្ឍន៍ ត្រូវទទួលខុសត្រូវលើសមាសធាតុកម្មវិធីនីមួយៗនៃកម្មវិធីជាតិ។ បច្ចុប្បន្ន ក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ គឺជាយន្តការពិគ្រោះពិភាក្សាលើបញ្ហាសំខាន់ៗនានាពាក់ព័ន្ធនឹងការពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមការងារបច្ចេកទេសនេះ ត្រូវពិភាក្សា និងចែករំលែកព័ត៌មានអំពីដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានា ព្រមទាំងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការកៀរគរធនធាន និងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តកម្មវិធីជាតិ។

ក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ មានលក្ខណៈខុសប្លែកពីអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ពីព្រោះក្រុមការងារបច្ចេកទេសនេះមានសមាសភាពមកពីរាជរដ្ឋាភិបាលផង និងមកពីដៃគូអភិវឌ្ឍន៍ផង ហើយសម្របសម្រួលលើទិដ្ឋភាពអន្តរវិស័យ។ សមាជិកអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ដែលជាមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាលនៅក្នុងក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ។ ភាពជាតំណាងនេះ មានសារៈសំខាន់ណាស់ក្នុងការបង្កឱ្យមានការពិគ្រោះពិភាក្សាដោយរលូន និងការភ្ជាប់ទំនាក់ទំនងរវាងដំណើរការផ្នែកបច្ចេកទេសជាមួយនឹងដំណើរការធ្វើសេចក្តីសម្រេចផ្នែកនយោបាយ។ ក្នុងន័យនេះ យន្តការក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានប្រើប្រាស់ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការគាំទ្រពីរាជរដ្ឋាភិបាល និងពីដៃគូអភិវឌ្ឍន៍សម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងការអនុវត្តកម្មវិធីជាតិ។

ក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ត្រូវបំពេញការងារតាមរយៈលេខាធិការដ្ឋាន គ.ជ.អ.ប។ បច្ចុប្បន្ននេះ លេខាធិការដ្ឋាន គ.ជ.អ.ប មានអង្គភាពចំណុះចំនួនបី។ **អង្គភាពគាំទ្រគោលនយោបាយ**មានភារកិច្ចជាចម្បងក្នុងការជួយរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំនានាដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តកម្មវិធីជាតិ។ **អង្គភាពអន្តរក្រសួង**មានភារកិច្ចសម្របសម្រួលជាមួយក្រសួងស្ថាប័ននានា និងជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗ។ **អង្គភាពគាំទ្រកម្មវិធី**មានភារកិច្ចជួយគាំទ្រ គ.ជ.អ.ប ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ៤.១.៣. ការសម្របសម្រួលកម្មវិធីជាតិជាមួយដៃគូអភិវឌ្ឍន៍

ថ្វីត្បិតតែកម្មវិធីជាតិនេះជាកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលក៏ដោយ ក៏ប៉ុន្តែការអនុវត្តកម្មវិធីនេះ ទាមទារឱ្យមាននូវធនធាន និងការគាំទ្រពីរាជរដ្ឋាភិបាល និងពីសំណាក់ដៃគូអភិវឌ្ឍន៍នានាផងដែរ។ ដូចនេះ ដើម្បីកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងធនធានឱ្យមានប្រសិទ្ធភាព គ.ជ.អ.ប ត្រូវរៀបចំកិច្ចប្រជុំប្រចាំឆ្នាំដើម្បីអនុម័តលើផែនការសកម្មភាព និងថវិការបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងត្រូវពិនិត្យឡើងវិញអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិនេះ។ គ.ជ.អ.ប អាចរៀបចំកិច្ចប្រជុំវិសាមញ្ញជាមួយអ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាលើបញ្ហាជាក់លាក់នានាដែលពាក់ព័ន្ធនឹងកម្មវិធីជាតិ។

កិច្ចប្រជុំប្រចាំឆ្នាំស្តីពីកម្មវិធីជាតិរវាង គ.ជ.អ.ប ជាមួយដៃគូអភិវឌ្ឍន៍ អាចធ្វើការពិភាក្សាលើបញ្ហានានាដូចខាងក្រោម :

- របាយការណ៍ស្តីពីការអនុវត្តកម្មវិធីជាតិ ដោយរួមមានទាំងរបាយការណ៍ស្តីពីវឌ្ឍនភាព ការចំណាយ និងសវនកម្ម
- ពិនិត្យឡើងវិញផ្នែកបច្ចេកទេស និងការសិក្សានានា ដែលបានធ្វើឡើងដោយ គ.ជ.អ.ប ដោយដៃគូអភិវឌ្ឍន៍ ឬដោយអ្នកសិក្សាឯករាជ្យដទៃទៀត

- របាយការណ៍ស្តីពីគំនិតផ្តួចផ្តើមថ្មីៗ ដែលសមស្របជាមួយកិច្ចខិតខំប្រឹងប្រែងក្នុងការងារកំណែទម្រង់
- ការពិភាក្សាលើក្របខ័ណ្ឌធនធាន និងយន្តការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីជាតិ
- អនុសាសន៍នានាដែលផ្តល់ដោយជំនាញការអន្តរជាតិ ស្ថាប័នបណ្តុះបណ្តាល សង្គមស៊ីវិលនានា និង
- ការផ្តល់អនុលោមភាពលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីជាតិ ។

## ៤.១.៤. រចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីជាតិ

ការអនុវត្តសមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ មានការពាក់ព័ន្ធជាមួយតួអង្គ និងអ្នកអនុវត្តន៍ជាច្រើន ។ តួអង្គ និងអ្នកអនុវត្តន៍ដែលសំខាន់ជាងគេ គឺក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលនៅថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ។ នៅក្នុងការអនុវត្តនេះ ក៏ត្រូវមានការចូលរួមពីស្ថាប័នបណ្តុះបណ្តាល ស្ថាប័នឯករាជ្យ និងសង្គមស៊ីវិលនានាផងដែរ ។ ដើម្បីអនុវត្តនិងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះឱ្យមានភាពរលូន លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវរៀបចំឱ្យមានការិយាល័យសមស្របនានាដែលមានល័ក្ខខ័ណ្ឌការងារច្បាស់លាស់ មានផែនការសកម្មភាព ព្រមទាំងមានបុគ្គលិក និងទីប្រឹក្សាជាតិនិងអន្តរជាតិគ្រប់គ្រាន់ ។ ការទទួលខុសត្រូវចម្បងៗរបស់លេខាធិការដ្ឋាន គ.ជ.អ.ប រួមមាន :

- ការសម្របសម្រួលរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់កម្មវិធីជាតិ
- ការសម្របសម្រួល និងការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងលំហូរមូលនិធិ
- កិច្ចការរដ្ឋបាល ដូចជា រៀបចំរបាយការណ៍រីកចម្រើន និងរបាយការណ៍ហិរញ្ញវត្ថុ
- ការរៀបចំ និងអនុវត្តប្រព័ន្ធតាមដាន វាយតម្លៃ និងប្រព័ន្ធរបាយការណ៍
- ការធានានូវភាពត្រឹមត្រូវក្នុងការប្រើប្រាស់ហិរញ្ញប្បទាន រួមមាន សវនកម្មផ្ទៃក្នុងនិងពីខាងក្រៅ និងយន្តការគណនេយ្យភាពដទៃទៀត
- ទំនាក់ទំនង និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នៃកម្មវិធីជាតិ
- ការផ្តល់ការណែនាំផ្នែកគោលនយោបាយ និងផ្នែកកម្មវិធី ព្រមទាំងការធ្វើទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកអនុវត្តន៍កម្មវិធីជាតិដទៃទៀត
- ការគ្រប់គ្រងជំនួយបច្ចេកទេសសម្រាប់កម្មវិធីជាតិ
- កិច្ចសហការជិតស្និទ្ធជាមួយយន្តការធានាភាពត្រឹមត្រូវរបស់ដៃគូអភិវឌ្ឍន៍ ។

## ៤.១.៥. តម្លាភាពព័ត៌មាន ការតាមដាន និងការរៀបចំរបាយការណ៍សម្រាប់កម្មវិធីជាតិ

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធានាថា រាល់ឯកសារពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិ រួមមាន របាយការណ៍រីកចម្រើន ផែនការសកម្មភាព ថវិកា ការពិនិត្យឡើងវិញនូវផ្នែកបច្ចេកទេស និងការសិក្សានានា ត្រូវបានរៀបចំឡើង និងដាក់ឱ្យមានការពិភាក្សាដោយមានការចូលរួមនិងមានតម្លាភាព តាមរយៈកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានា នៃ គ.ជ.អ.ប និងសិក្ខាសាលានានា ។ បន្ទាប់ពី គ.ជ.អ.ប បានអនុម័តឯកសារទាំងនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈ តាមរយៈបណ្ណាល័យ គេហទំព័រ និងព្រឹត្តិបត្រព័ត៌មានរបស់ គ.ជ.អ.ប ព្រមទាំងមធ្យោបាយផ្សព្វផ្សាយព័ត៌មានដទៃទៀត ។ ព្រឹត្តិបត្រព័ត៌មាន និងសេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.អ.ប ត្រូវចុះផ្សាយបន្ថែម

នូវព័ត៌មាន និងឯកសារបណ្តុះបណ្តាលកសាងសមត្ថភាព ដែលរៀបចំឡើងដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើបច្ចុប្បន្នភាពដល់សាធារណជនទូទៅអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិ ។

លេខាធិការដ្ឋាន គ.ជ.អ.ប អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រគល់ការទទួលខុសត្រូវក្នុងការតាមដាន និងការត្រួតពិនិត្យដោយផ្ទាល់ទៅលើការអនុវត្តកម្មវិធីជាតិ ទៅតាមជំនាញ និងសមត្ថកិច្ចរបស់ខ្លួន។ លើសពីនេះទៀត កម្មវិធី និងគម្រោងនានារបស់ដៃគូអភិវឌ្ឍន៍ ក៏ត្រូវរួមចំណែកដល់ការផ្តល់ទីប្រឹក្សាបច្ចេកទេសផ្នែកកសាងសមត្ថភាព និងផ្នែកគោលនយោបាយ ព្រមទាំងបុគ្គលិកដែលទទួលខុសត្រូវក្នុងការធានាភាពត្រឹមត្រូវនៃការប្រើប្រាស់ធនធានហិរញ្ញវត្ថុ។ ជាមួយគ្នានេះដែរ បេសកកម្មនានារបស់ដៃគូអភិវឌ្ឍន៍ ក៏អាចជួយជាមធ្យោបាយបន្ថែមក្នុងការតាមដានវឌ្ឍនភាព និងតម្រង់ទិសដល់ការអនុវត្តកម្មវិធីជាតិផងដែរ ។

គ.ជ.អ.ប ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចបានអធិប្បាយខាងលើ ។ របាយការណ៍វឌ្ឍនភាពនៃកម្មវិធីជាតិ ត្រូវដកស្រង់ចេញពីក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃរបស់ គ.ជ.អ.ប ហើយត្រូវប្រើប្រាស់ជារបាយការណ៍ប្រចាំឆ្នាំរបស់ គ.ជ.អ.ប សម្រាប់រាយការណ៍ជូនរាជរដ្ឋាភិបាល។ តាមរយៈការធ្វើរបាយការណ៍ និងការតាមដាននូវការអនុវត្តសូចនាករសំខាន់ៗ គ.ជ.អ.ប នឹងមានលទ្ធភាពពិចារណា និងពិនិត្យឡើងវិញនូវកិច្ចដំណើរការនៃការអនុវត្តកម្មវិធីជាតិ និងសមាសធាតុសំខាន់ៗនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដើម្បីកែសម្រួលឱ្យបានសមស្របទៅនឹងដំណាក់កាលជាបន្តបន្ទាប់ ដោយផ្អែកលើសមិទ្ធផល បញ្ហាប្រឈម និងឧបសគ្គនានាដែលបានរកឃើញតាមរយៈលទ្ធផលនៃសូចនាករតាមដាន និងវាយតម្លៃ ។

## ៤.១.៦. សវនកម្មកម្មវិធីជាតិ

បន្ថែមលើយន្តការធានាឱ្យមានភាពត្រឹមត្រូវក្នុងការប្រើប្រាស់ហិរញ្ញប្បទាន ដែលអនុវត្តដោយទីប្រឹក្សា និងការិយាល័យដៃគូអភិវឌ្ឍន៍ប្រចាំប្រទេស ការប្រើប្រាស់ធនធានទាំងអស់នៃកម្មវិធីជាតិត្រូវមានការធ្វើសវនកម្ម។

ចំពោះសវនកម្មផ្ទៃក្នុង ត្រូវធ្វើឡើងដោយសវនករ ដែលជ្រើសរើសពីក្នុងចំណោមមន្ត្រីដែលមានសមត្ថភាពរបស់រាជរដ្ឋាភិបាល។ ដោយឡែក សវនកម្មផ្ទៃក្រៅដែលមានលក្ខណៈឯករាជ្យ ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នាចំពោះធនធានរបស់រាជរដ្ឋាភិបាល និងធនធានរបស់ដៃគូអភិវឌ្ឍន៍ ។

ចំពោះធនធានរបស់រាជរដ្ឋាភិបាលដែលបានផ្តល់ដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អាជ្ញាធរសវនកម្មជាតិ ត្រូវចូលរួមធ្វើសវនកម្មប្រចាំឆ្នាំ ដោយមានល័ក្ខខ័ណ្ឌការងារ និងផែនការសកម្មភាពច្បាស់លាស់។ សវនកម្មប្រចាំឆ្នាំនេះ ត្រូវធ្វើឡើងនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួន ដែលបានជ្រើសរើសឡើងតាមរយៈវិធីសាស្ត្រធ្វើសំណាកសមស្រប ។

ចំពោះធនធានពីដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុនសវនកម្មឯកជននឹងត្រូវអញ្ជើញឱ្យចូលរួមដេញថ្លៃដើម្បីអនុវត្តសវនកម្ម ដោយផ្អែកលើក្របខ័ណ្ឌពេលវេលា និងតម្រូវការដែលបានកំណត់ដោយដៃគូអភិវឌ្ឍន៍។ ដោយសារធនធានរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានប្រើប្រាស់ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដូចនេះ ការធ្វើសវនកម្មឯករាជ្យនេះត្រូវធ្វើឡើងទាំងនៅថ្នាក់ជាតិ និងនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់មួយចំនួនដែលបានជ្រើសរើស។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវពិភាក្សាអំពីរបកគំហើញនិងអនុសាសន៍នានានៃសវនកម្ម និងត្រូវធានាក្នុងការចាត់វិធានការសមស្រប ដើម្បីទប់ស្កាត់នូវភាពមិនប្រក្រតីនៃការអនុវត្តនីតិវិធី និងការប្រើប្រាស់ហិរញ្ញប្បទាន។ ក្នុងការបំពេញការងារនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវរៀបចំលិខិតឆ្លើយតបចំពោះរបកគំហើញសវនកម្ម និងរៀបចំរបាយការណ៍ស្តីពីការចាត់វិធានការនានាជូន គ.ជ.អ.ប និងដៃគូអភិវឌ្ឍន៍។ របាយការណ៍សវនកម្មជាផ្លូវការ និងឯកសារនានាដែលពាក់ព័ន្ធនឹងសវនកម្មនេះ ត្រូវផ្សព្វផ្សាយជាសាធារណៈតាមរយៈគេហទំព័ររបស់ គ.ជ.អ.ប និងតាមមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា។

## ៤.២. ការតាមដាន និងវាយតម្លៃ

គ.ជ.អ.ប ត្រូវធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការវិភាគ និងការពិនិត្យឡើងវិញឱ្យបានច្បាស់លាស់លើការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ គ.ជ.អ.ប ត្រូវរៀបចំប្រព័ន្ធមួយ ដែលមិនគ្រាន់តែជាយន្តការសម្រាប់ធ្វើរបាយការណ៍ប៉ុណ្ណោះទេ ប៉ុន្តែជាប្រព័ន្ធដែលអាចប្រើប្រាស់សម្រាប់ការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេច។ ដើម្បីអនុវត្តការងារនេះ ចាំបាច់ត្រូវបង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃមួយដែលមានលក្ខណៈឌីណាមិច និងដោយមានធនធានគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការ។ តាមមធ្យោបាយនេះ គ.ជ.អ.ប នឹងមានលទ្ធភាពតាមដានលើរាល់ការអនុវត្តសកម្មភាពរបស់កម្មវិធីជាតិ និងកែតម្រូវកម្មវិធីជាតិប្រកបដោយតម្លាភាពនិងការឆ្លើយតប ព្រមទាំងអាចរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីការជះឥទ្ធិពលជាទូទៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ គ.ជ.អ.ប នឹងប្រើប្រាស់ក្របខ័ណ្ឌតាមដាន និងវាយតម្លៃនេះសម្រាប់ការវាស់វែងលទ្ធផល និងសម្រាប់ការគ្រប់គ្រងនិងលើកកម្ពស់សេវាសាធារណៈផងដែរ។ ដូច្នេះក្របខ័ណ្ឌនេះត្រូវបានប្រើប្រាស់សម្រាប់គោលបំណងចម្បងពីរ ពោលគឺការពង្រឹងគណនេយ្យភាព និងការលើកកម្ពស់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។

### ៤.២.១. ទំនាក់ទំនងរវាងក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃជាមួយនឹងសមាសធាតុកម្មវិធីនានា និងគោលបំណងនានានៃវិមជ្ឈការ និងវិសហមជ្ឈការ

ក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃ នឹងគាំទ្រដល់ដំណើរការបង្កើតបន្ថែមនូវសូចនាករចាំបាច់នានានៅក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំនេះ។ ផ្អែកតាមក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃនេះ គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ នឹងអាចតាមដានលើការអនុវត្តសមាសធាតុកម្មវិធីនីមួយៗ

អាចវាយតម្លៃទៅលើការសម្រេចបាននូវលទ្ធផលរំពឹងទុកនានា និងអាចជួយរៀបចំបង្កើតឡើងនូវគោលនយោបាយ និងកម្មវិធីសម្រាប់អន្តរាគមន៍ទៅលើបញ្ហានានាដែលបានកើតឡើង។

ក្របខ័ណ្ឌតក្កភាពនៃកម្មវិធីជាតិ បានកំណត់នូវលទ្ធផលរំពឹងទុកនានា ដែលលទ្ធផលរំពឹងទុកទាំងនោះបង្កើតបានជាមូលដ្ឋាននៃក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃ។ សូចនាករនៃលទ្ធផលដែលបានកំណត់នៅក្នុងក្របខ័ណ្ឌតក្កភាព គឺជាសូចនាករគន្លឹះៗសម្រាប់ការតាមដាន និងការរៀបចំរបាយការណ៍ជាទៀងទាត់របស់ គ.ជ.អ.ប ដោយសារសូចនាករទាំងនេះជួយតាមដានលើដំណើរការអនុវត្ត និងផលប៉ះពាល់នៃការអនុវត្តកម្មវិធីជាតិ។

## ៤.២.២. ការរៀបចំរបៀបរបបគ្រប់គ្រងសម្រាប់ការតាមដាន និងវាយតម្លៃ

ដើម្បីធានាឱ្យប្រព័ន្ធតាមដាន និងវាយតម្លៃកម្មវិធីជាតិអាចអនុវត្តទៅបាន និងផ្តល់នូវព័ត៌មានដែលមានប្រយោជន៍ដល់ការរៀបចំគោលនយោបាយ និងការធ្វើសេចក្តីសម្រេចនានាលើកម្មវិធីជាតិរយៈពេល១០ឆ្នាំនេះ គ.ជ.អ.ប ត្រូវបង្កើតនូវអនុគណៈកម្មាធិការតាមដាននិងវាយតម្លៃមួយ ដើម្បីពិនិត្យមើលការអនុវត្តការងារតាមដាននិងវាយតម្លៃរបស់កម្មវិធីជាតិ។ ការពិនិត្យមើលនេះ រួមមានការបង្កើតសូចនាករ ការកំណត់ប្រភពទិន្នន័យនានា ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ការផ្សព្វផ្សាយលទ្ធផលវិភាគផ្សេងៗដល់អ្នកធ្វើសេចក្តីសម្រេចនិងអ្នកពាក់ព័ន្ធដទៃទៀត និងការប្រើប្រាស់ព័ត៌មានក្នុងការធ្វើគោលនយោបាយនិងការធ្វើសេចក្តីសម្រេចនានា។ សេចក្តីណែនាំលម្អិតស្តីពីការអនុវត្តក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃនឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងឆមាសទី១ឆ្នាំ២០១០។

អនុគណៈកម្មាធិការតាមដាន និងវាយតម្លៃ ត្រូវមានតំណាងមន្ត្រីជាន់ខ្ពស់មកពីក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងជំនាញយ៉ាងតិចចំនួនបីទៀត ដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាតំណាងឱ្យវិស័យសំខាន់ៗក្នុងការផ្តល់សេវាសាធារណៈដែលមានផលប៉ះពាល់នៅមូលដ្ឋាន។ តំណាងក្រសួង ស្ថាប័នដទៃទៀត តំណាងដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញផ្នែកការងារតាមដាន និងវាយតម្លៃ ឬអ្នកជំនាញការផ្សេងទៀត អាចអញ្ជើញឱ្យចូលរួមក្នុងអនុគណៈកម្មាធិការនេះ។

អនុគណៈកម្មាធិការតាមដាន និងវាយតម្លៃ ត្រូវមានក្រុមការងារតាមដាន និងវាយតម្លៃមួយ ដែលមានអ្នកជំនាញក្នុងការបង្កើតសូចនាករ អ្នកជំនាញផ្នែកអង្កេត អ្នកជំនាញវិភាគទិន្នន័យ និងអ្នកជំនាញសិក្សាស្រាវជ្រាវ។ ទន្ទឹមនេះ ត្រូវរៀបចំឱ្យមានក្រុមផ្តល់យោបល់មួយដែលមានសមាសភាពមកពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីជួយគាំទ្រដល់អនុគណៈកម្មាធិការនេះផងដែរ។ ក្រុមផ្តល់យោបល់នេះត្រូវដើរតួនាទីដ៏សំខាន់ក្នុងការផ្តល់នូវទស្សនវិស័យរបស់ដៃគូអភិវឌ្ឍន៍ និងជួយជាយោបល់ដល់ គ.ជ.អ.ប លើការងារតាមដាន និងវាយតម្លៃ។

តួនាទីរបស់អនុគណៈកម្មាធិការតាមដាន និងវាយតម្លៃ គឺមិនមែនជាអ្នកប្រមូលទិន្នន័យផ្ទាល់នោះទេ តែត្រូវធានាលើ(១)ការបង្កើតសូចនាករឱ្យបានសមស្រប (២)ការស្នើសុំនិងការទទួលយកទិន្នន័យសូចនាករឱ្យបានទាន់ពេលវេលាពីប្រព័ន្ធទិន្នន័យដែលមានស្រាប់របស់ក្រសួង ស្ថាប័ននានា (ដូចជាពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំរបស់ក្រសួងអប់រំ

យុវជន និងកីឡាជាដើម) ដើម្បីធ្វើការដាក់បញ្ចូលជាមួយនឹងប្រព័ន្ធទិន្នន័យរបស់ គ.ជ.អ.ប និង(៣) ការផ្តួចផ្តើមបង្កើតឧបករណ៍និងនីតិវិធីថ្មីៗសម្រាប់ប្រមូលទិន្នន័យ។ អនុគណៈកម្មាធិការនេះត្រូវធានាថា ព័ត៌មាននិងទិន្នន័យពាក់ព័ន្ធសំខាន់ៗ ត្រូវបានប្រមូល និងរក្សាទុកសម្រាប់សម្រួលដល់ការរៀបចំការសិក្សាទិន្នន័យគោល និងការសិក្សាផ្សេងៗ។ ការទទួលខុសត្រូវដ៏សំខាន់មួយទៀតរបស់អនុគណៈកម្មាធិការតាមដាន និងវាយតម្លៃ គឺការត្រួតពិនិត្យមើលលើការវិភាគទិន្នន័យ និងធានាឱ្យមានការធ្វើរបាយការណ៍ទៀងទាត់ស្តីពីទិន្នន័យទាំងនោះ ដើម្បី គ.ជ.អ.ប ប្រើប្រាស់ក្នុងការរៀបចំគោលនយោបាយ និងការធ្វើសេចក្តីសម្រេចនានា។

### ៤.២.៣. សំណើនានាសម្រាប់ការតាមដាន និងវាយតម្លៃចំពោះថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

កម្មវិធីជាតិនឹងប្រើប្រាស់ប្រភពព័ត៌មាននានាក្នុងការប្រមូលទិន្នន័យ ដូចខាងក្រោម :

- **ការអង្កេតតាមគ្រួសារ :** ការអង្កេតតាមគ្រួសារដែលកំណត់នូវសំណាកដោយចៃដន្យនៃលំដាប់លេខរៀងគ្រួសារត្រូវធ្វើឡើងចំនួនបួនដងក្នុងរយៈពេល១០ឆ្នាំ។ ការអង្កេតលើកទី១ត្រូវធ្វើឡើងនៅឆ្នាំ២០១០ ដើម្បីបង្កើតបានជាទិន្នន័យគោល ចំណែកឯការអង្កេតបីដងទៀតត្រូវធ្វើក្នុងឆ្នាំទី៣ ទី៦ និងទី៩។ ការអង្កេតតាមគ្រួសារនេះ ត្រូវធ្វើឡើងចំពោះអ្នកពេញវ័យនៅក្នុងគ្រួសារដែលជ្រើសរើសតាមវិធីសាស្ត្រចៃដន្យ ដោយសាកសួរអំពីការពេញចិត្តលើគុណភាពសេវាសាធារណៈ ការទទួលបានសេវាសាធារណៈ ការទទួលបានព័ត៌មាននានា ព្រមទាំងសាកសួរអំពីព័ត៌មានទាក់ទងនឹងមនុស្សសាស្ត្រ ដូចជា អាយុ ស្ថានភាពបុគ្គល ចំណូល និងការអប់រំជាដើម ដែលអាចយកមកធ្វើការវិភាគបានច្រើនប្រភេទ។ ទោះបីទិន្នន័យនេះ ត្រូវបានប្រមូលតាមឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងខេត្តមួយចំនួនក៏ដោយ ក៏មិនត្រូវយកទិន្នន័យទាំងនេះមកធ្វើការវិភាគសម្រាប់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ឬខេត្តនីមួយៗនោះទេ។
- **កំណត់ត្រារដ្ឋបាល :** នៅពេលក្រសួង ស្ថាប័ននានាធ្វើការផ្ទេរមុខងារជាបណ្តើរៗ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងារតាមដាននិងវាយតម្លៃត្រូវបង្កើតទម្រង់គំរូសម្រាប់កត់ត្រាព័ត៌មាន ដើម្បីរាយការណ៍ជាប្រចាំជូនក្រសួង ស្ថាប័ន និង គ.ជ.អ.ប សម្រាប់ធ្វើការវិភាគ។
- **ការអង្កេតលើក្រុមប្រឹក្សា និងបុគ្គលិករបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ :** ទិន្នន័យនេះត្រូវប្រមូលពីសមាជិកក្រុមប្រឹក្សានិងបុគ្គលិកមួយចំនួន ដែលតំណាងឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ បុគ្គលិកទាំងនោះ មានជាអាទិ៍ មន្ត្រីហិរញ្ញវត្ថុ ប្រធានអង្គភាពគ្រប់គ្រងធនធានមនុស្សជាដើម ដែលអ្នកទាំងនោះត្រូវផ្តល់ព័ត៌មានអំពីបញ្ហាជាក់លាក់ ប្រចាំត្រីមាស ប្រចាំឆមាស ឬប្រចាំឆ្នាំ និងតាមការចាំបាច់។

### ៤.២.៤. ការតម្រឹមដៃគូអភិវឌ្ឍន៍ជាមួយក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃនៃកម្មវិធីជាតិ

ចំណុចគោលដៅនានាដែលបានកំណត់នៅក្នុងក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃនៃកម្មវិធីជាតិ និងតាមរយៈកិច្ចដំណើរការរៀបចំក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃនាពេលខាងមុខ នឹងកំណត់អំពីលទ្ធផលរំពឹងទុកនានានៃការអនុវត្តគោលនយោបាយ និងជាប្រធានបទជាគន្លឹះក្នុងការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍នៅក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិនេះ។ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានប្តេជ្ញាចិត្តក្នុងការអនុវត្តតាមសេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពជំនួយ។ ដូចនេះ ការតម្រឹមដៃគូអភិវឌ្ឍន៍ជាមួយនឹងក្របខ័ណ្ឌការងារតាមដាន និងវាយតម្លៃរួមមានទិដ្ឋភាពពីរគឺ (១)ការប្រើប្រាស់ក្របខ័ណ្ឌការងារតាមដាននិងវាយតម្លៃដើម្បីកំណត់ និងឯកភាពគ្នាលើលទ្ធផលរំពឹងទុកនានាសម្រាប់កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅកម្ពុជា និង(២)ការបន្ទុំកិច្ចខិតខំប្រឹងប្រែងក្នុងការងារធ្វើរបាយការណ៍ ការងារតាមដាន និងការវាយតម្លៃ ដើម្បីកាត់បន្ថយនូវការប្រមូលទិន្នន័យដោយដៃគូអភិវឌ្ឍន៍ ឬដោយគម្រោងនីមួយៗ និងតម្រូវការឱ្យមានរបាយការណ៍ដោយឡែកៗពីគ្នា ដើម្បីឈានទៅប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាលជាបណ្តើរៗ។

## ៤.៣. ហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យនៃកម្មវិធីជាតិ

ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា ក្នុងគោលបំណងធានានូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកិច្ចដំណើរការដ៏លំបាកស្មុគស្មាញ និងមានផលប៉ះពាល់ដល់គ្រប់ស្ថាប័នបច្ចេកទេស និងនយោបាយរបស់រាជរដ្ឋាភិបាល។ ជោគជ័យនៃការអនុវត្តកម្មវិធីជាតិ នឹងលើកតម្កើងដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ លើកកម្ពស់គុណភាពនិងការទទួលបាននូវសេវាសាធារណៈ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅទូទាំងប្រទេស ជាពិសេសសម្រាប់ក្រុមជនងាយរងគ្រោះ។

ដោយសារកំណែទម្រង់នេះមានលក្ខណៈស្មុគស្មាញ មានវិសាលភាពដ៏ទូលំទូលាយ និងមានផលប៉ះពាល់លើការគ្រប់គ្រងរដ្ឋបាលនៅគ្រប់កម្រិត ដូច្នេះ ការអនុវត្តកំណែទម្រង់នេះនឹងអាចកើតមានឡើងនូវហានិភ័យជាច្រើន។ ការបន្ទុំគ្នារវាងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យ ជាមួយនឹងកម្មវិធីជាតិ គឺជាបញ្ហាប្រឈមមួយដែលនឹងជួបប្រទះនៅក្នុងពេលអនុវត្ត។

**តារាង៤.១** ខាងក្រោមអធិប្បាយអំពីហានិភ័យចម្បងៗដែលអាចនឹងកើតមាននៅក្នុងអំឡុងពេលអនុវត្តកម្មវិធីជាតិ និងសកម្មភាពកាត់បន្ថយហានិភ័យទាំងនោះ។ កូឡោនទី១នៃតារាងនេះ បរិយាយអំពីហានិភ័យចម្បងៗដែលនឹងអាចកើតឡើង ពាក់ព័ន្ធនឹងការសម្រេចបាននូវគោលដៅ គោលបំណង និងលទ្ធផលនៃដំណាក់កាលនីមួយៗរបស់សមាសធាតុកម្មវិធីទាំង៥។ កូឡោនទី២ បរិយាយអំពីលទ្ធភាពដែលអាចកើតមានហានិភ័យនេះ ដោយធ្វើចំណាត់ថ្នាក់ជាកម្រិតខ្ពស់ មធ្យម និងទាប។ កូឡោនទី៣ បរិយាយអំពីកម្រិតនៃផលប៉ះពាល់ដែលអាចកើតឡើងពីហានិភ័យនីមួយៗ ដោយត្រូវវាស់វែងជាកម្រិតខ្ពស់ មធ្យម និងទាប។ កូឡោនទី៤ បរិយាយអំពីសកម្មភាពដែលត្រូវអនុវត្តដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។

## តារាង៤.១ : ហានិភ័យ និងសកម្មភាពកាត់បន្ថយហានិភ័យ

| ហានិភ័យ | លទ្ធភាពអាចកើតមានឡើង | ផលប៉ះពាល់ | សកម្មភាពកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ក្រុមប្រឹក្សាមិនទទួលបាននូវសិទ្ធិអំណាចផ្នែកស្ថាប័ន ដែលត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលរាល់សកម្មភាពទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | មធ្យម | មធ្យម | • សមាសធាតុកម្មវិធីទី១ រួមមានកិច្ចដំណើរការក្នុងការបង្កើតនូវសិទ្ធិអំណាច សមត្ថកិច្ច ប្រព័ន្ធ និងរចនាសម្ព័ន្ធ ព្រមទាំងកិច្ចដំណើរការក្នុងការកំណត់នូវការទទួលខុសត្រូវ តួនាទី និងគណនេយ្យភាពផ្ទៃក្នុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ<br>• ផែនការអភិវឌ្ឍន៍សមត្ថភាពត្រូវជួយកសាងសមត្ថភាពក្នុងការត្រួតពិនិត្យមើល និងភាពជាអ្នកដឹកនាំរបស់សមាជិកក្រុមប្រឹក្សា<br>• តាមរយៈសកម្មភាពរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការនានាត្រូវលើកកម្ពស់ការអប់រំផ្សព្វផ្សាយដល់មន្ត្រីនៃមន្ទីរ អង្គភាពខ្សែបណ្តោយ និងដល់សាធារណជនអំពីច្បាប់ និងគោលការណ៍នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនិងគោលការណ៍នៃរដ្ឋបាលឯកភាព |
| គ.ជ.អ.ប និងក្រសួង ស្ថាប័ននានាមិនបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវមុខងារ និងសមត្ថកិច្ចផ្តល់សេវាសាធារណៈច្បាស់លាស់( ទាំងមុខងារប្រតិភូកម្ម និងមុខងារប្រគល់) ដោយភ្ជាប់ទៅជាមួយនូវការទទួលខុសត្រូវ សិទ្ធិអំណាច និងគណនេយ្យភាព | មធ្យម | ខ្ពស់ | • ក្នុងករណីក្រសួង ស្ថាន័ននានាអូសបន្លាយការផ្ទេរមុខងារសំខាន់ៗ ដូចបានកំណត់នៅក្នុងផែនការរបស់ក្រសួង ស្ថាប័ននីមួយៗ រាជរដ្ឋាភិបាល និងឬ គ.ជ.អ.ប ត្រូវធ្វើសេចក្តីសម្រេចក្នុងការផ្ទេរមុខងារនានាដើម្បីធានាការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ |
| ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សចាំបាច់ ដោយភ្ជាប់ជាមួយនូវសិទ្ធិអំណាចមិនត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ | មធ្យម | ខ្ពស់ | • ក្នុងឆ្នាំទីមួយនៃការអនុវត្តកម្មវិធីជាតិចាំបាច់ត្រូវអនុម័តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាល |

| ហានិភ័យ | លទ្ធភាពអាចកើតមានឡើង | ផលប៉ះពាល់ | សកម្មភាពកាត់បន្ថយហានិភ័យ |
|---|---|---|---|
| ក្រោមជាតិ | | | ថ្នាក់ក្រោមជាតិ។ ចំពោះលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចឱ្យបាននៅក្នុងដំណាក់កាលទី១។ ក្នុងពេលមិនទាន់មានលក្ខន្តិកៈនេះ ចាំបាច់ត្រូវមានលិខិតបទដ្ឋានគតិយុត្តដើម្បីកំណត់អំពីការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិក |
| យន្តការគណនេយ្យភាពចំពោះប្រជាពលរដ្ឋ រៀបចំមិនទាន់បានគ្រប់គ្រាន់ និងមានភាពទន់ខ្សោយ | មធ្យម | ខ្ពស់ | • កិច្ចដំណើរការនៃការផ្ទេរមុខងារនិងធនធានដែលភ្ជាប់ជាមួយនឹងការកំណត់សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ គឺជាជំហានទីមួយនៃការបង្កើតឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។<br>• បន្ទាប់មក ត្រូវពង្រឹងសមត្ថភាពរដ្ឋបាលនីមួយៗនៃថ្នាក់ក្រោមជាតិដើម្បីឱ្យរដ្ឋបាលទាំងនេះមានការទទួលខុសត្រូវ និងមានគណនេយ្យភាពក្នុងការអនុវត្តនូវប្រព័ន្ធដែលមានការចូលរួម ការពិគ្រោះយោបល់ តម្លាភាព និងព័ត៌មានច្បាស់លាស់។<br>• ជាមួយនឹងដំណើរការនេះ ចាំបាច់ត្រូវរៀបចំ និងពង្រឹងយន្តការសម្រុះសម្រួល និងដោះស្រាយបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងច្បាប់ និងការសម្រេចនានា សំដៅលើកកម្ពស់សិទ្ធិប្រជាពលរដ្ឋ។ |
| ការសម្របសម្រួលរវាងកម្មវិធីជាតិជាមួយកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ មិនអាចធ្វើទៅបាន | មធ្យម | មធ្យម | • ត្រូវបង្កើតឱ្យមានក្រុមការងាររួមមួយរវាង គ.ជ.អ.ប គណៈកម្មាធិការកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ |

| ហានិភ័យ | លទ្ធភាពអាចកើតមានឡើង | ផលប៉ះពាល់ | សកម្មភាពកាត់បន្ថយហានិភ័យ |
|---|---|---|---|
| | | | សកម្មភាពរួម ដែលពាក់ព័ន្ធនឹងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ។ |
| កំណើនសេដ្ឋកិច្ចយឺត (អាចបណ្តាលមកពីវិបត្តិហិរញ្ញវត្ថុក្នុងស្រុកឬពិភពលោក) ដែលមានផលប៉ះពាល់ជាអវិជ្ជមានទៅលើចំណូលជាតិសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទៅលើទំហំនៃការប្រមូលចំណូលមូលដ្ឋាន និងទៅលើការផ្តល់ហិរញ្ញប្បទានពីខាងក្រៅ នឹងបង្កឱ្យមានវិបត្តិផ្នែកថវិកា និងការផ្តល់សេវាសាធារណៈ ។ | មធ្យម | មធ្យម | • មានជម្រើសបីសម្រាប់ដោះស្រាយបញ្ហានេះ : ១).ប្រព័ន្ធផ្ទេរមូលនិធិដែលផ្សារភ្ជាប់ជាមួយការចែករំលែកនៃចំណូលថវិកាជាតិ នឹងជួយពង្រឹងស្ថិរភាពចំណាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ២).ការវិភាជន៍ចំណាយសាធារណៈត្រូវផ្តល់អាទិភាពលើវិស័យចម្បងៗដែលមានឥទ្ធិពលខ្លាំងដល់ការជំរុញកំណើនសេដ្ឋកិច្ច និង ៣).បង្កើនចំណូលពីប្រភពផ្សេងៗ ដូចជាថ្លៃឈ្នួល និងកម្រៃពីអ្នកប្រើប្រាស់សេវាសាធារណៈដែលផ្តល់សេវាដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |
| ដៃគូអភិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ពុំបានធ្វើសុខដុមនីយកម្មនៅក្នុងស្ថាប័នរបស់ខ្លួនអំពីការគាំទ្រតាមវិស័យនានា និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលករណីនេះនឹងនាំឱ្យមានការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពនានានៅថ្នាក់ក្រោមជាតិ មានលក្ខណៈមិនសមស្រប ។ | ខ្ពស់ | មធ្យម | • ទីប្រឹក្សាបច្ចេកទេស និងក្រុមសម្របសម្រួលត្រូវបានរៀបចំឡើងដើម្បីផ្តល់ជាយន្តការសម្រាប់ធ្វើសុខដុមនីយកម្មនូវវិធីសាស្ត្រនានារបស់ដៃគូអភិវឌ្ឍន៍ដែលអាចគាំទ្រដល់សកម្មភាពនានានៅថ្នាក់ក្រោមជាតិដោយផ្អែកតាមគោលការណ៍នៃរដ្ឋបាលឯកភាព និងគោលការណ៍ថវិកាតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ |
| ដៃគូអភិវឌ្ឍន៍នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មិនប្រតិបត្តិតាមគោលការណ៍នៃភាពជាតំណាង ឬសំឡេងតែមួយ | មធ្យម | មធ្យម | • តាមរយៈកិច្ចព្រមព្រៀងនៃភាពជាដៃគូ នឹងជួយកំណត់នូវតួនាទី និងការទទួលខុសត្រូវច្បាស់លាស់ទៅតាមក្រុមការងាររបស់ដៃគូអភិវឌ្ឍន៍នានា ដែលទទួលបន្ទុកលើប្រធាន |

| ហានិភ័យ | លទ្ធភាពអាចកើតមានឡើង | ផលប៉ះពាល់ | សកម្មភាពកាត់បន្ថយហានិភ័យ |
|---|---|---|---|
| | | | បទណាមួយ និងទំនាក់ទំនងរវាងក្រុមការងារនោះជាមួយអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ។<br>• ក្រុមការងារបច្ចេកទេសស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ គឺជាយន្តការសម្រាប់សំយោគមតិ និងភាពជាតំណាងរបស់ដៃគូអភិវឌ្ឍន៍នានា ។ |

# ជំពូកទី៥

# ហិរញ្ញវត្ថុ និងថវិកានៃកម្មវិធីជាតិ

# ជំពូកទី៥
# ហិរញ្ញវត្ថុ និងថវិកានៃកម្មវិធីជាតិ

## ៥.១. ការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីជាតិ

រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តក្នុងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តកម្មវិធីជាតិ។ ក្នុងគោលដៅនៃការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ ក្នុងរយៈពេលវែងដើម្បីគាំទ្រដល់កំណែទម្រង់នេះ ក៏ទាមទារឱ្យដៃគូអភិវឌ្ឍនានាមានការប្តេជ្ញាចិត្តក្នុងការគាំទ្រដល់ការអនុវត្តកម្មវិធីជាតិនេះផងដែរ។ ផ្នែកខាងក្រោមនេះនឹងគូសបញ្ជាក់អំពីបញ្ហាជាក់លាក់នានាពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានដល់កម្មវិធីជាតិ ដែលរួមមានយន្តការសម្រាប់ការផ្តល់ហិរញ្ញប្បទាន យុទ្ធសាស្ត្រអន្តរកាលនៃទម្រង់ផ្តល់ហិរញ្ញប្បទាន និងការប៉ាន់ស្មានចំណាយ។

### ៥.១.១. ការផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីជាតិ ត្រូវផ្អែកលើកម្មវិធី និងត្រូវឆ្លុះបញ្ចាំងនៅក្នុងថវិកា

ទម្រង់ផ្តល់ហិរញ្ញប្បទានសម្រាប់កម្មវិធីជាតិ ត្រូវមានសង្គតិភាពជាមួយនឹងគោលការណ៍នានា ដែលកើតចេញពីការប្តេជ្ញាចិត្តខាងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចមានរៀបរាប់ក្នុងជំពូកទី២នៃឯកសារកម្មវិធីនេះ និងត្រូវមានសង្គតិភាពជាមួយការរៀបចំសមាសធាតុទាំងប្រាំនៃកម្មវិធីជាតិ។ ជាងនេះទៀត ក្នុងរយៈពេល១០ឆ្នាំនៃកម្មវិធីជាតិនេះ វិធីសាស្ត្រផ្តល់ហិរញ្ញប្បទាននឹងត្រូវបានអនុវត្តដើម្បីឈានឆ្ពោះទៅសម្រេចឱ្យបានជោគជ័យតាមស្មារតីនៃសេចក្តីថ្លែងការណ៍ស្តីពីការបង្កើនប្រសិទ្ធភាពជំនួយរបស់កម្ពុជា ដែលបានចុះហត្ថលេខានៅខែតុលា ឆ្នាំ២០០៦។

ទោះបីជាកម្មវិធីជាតិត្រូវបានរៀបចំនៅក្នុងអំឡុងពេលនៃសម្ពាធសេដ្ឋកិច្ច និងហិរញ្ញវត្ថុមកលើធនធានសាធារណៈ ដោយសារតែវិបត្តិហិរញ្ញវត្ថុពិភពលោកក៏ដោយ ក៏កម្មវិធីជាតិនេះពុំមែនរៀបចំឡើងក្នុងគោលបំណងដោះស្រាយវិបត្តិនេះក្នុងរយៈពេលខ្លីមួយឡើយ។ វិធីសាស្ត្រដែលផ្អែកលើកម្មវិធីត្រូវបានរំពឹងថា នឹងដំណើរការស្របគ្នាជាមួយកម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ក្នុងការព្យាយាមដោះស្រាយតម្រូវការចំពោះមុខ ដែលកើតចេញពីវិបត្តិហិរញ្ញវត្ថុនេះ។

គោលការណ៍គន្លឹះមួយនៃការផ្តល់ហិរញ្ញប្បទានកម្មវិធីជាតិ ពោលគឺទោះបីជាការផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ណាមួយក៏ដោយ ក៏លំហូរមូលនិធិត្រូវតែឆ្លុះបញ្ចាំងនៅក្នុងថវិកាជាតិ និងថ្នាក់ក្រោមជាតិ។ ការឆ្លុះបញ្ចាំងថវិកាត្រូវបានរៀបចំជាមូលនិធិផ្នែកចំណូល និងចំណាយ ប៉ុន្តែមូលនិធិទាំងនេះអាចចាំបាច់ ឬមិនចាំបាច់ត្រូវបានគ្រោង ឬរៀបចំតាមប្រព័ន្ធហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលនៅក្នុងឆ្នាំដំបូងៗនោះឡើយ។

កិច្ចដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ បានផ្តល់នូវយន្តការសមស្របមួយ សម្រាប់កៀរគរកំណត់អាទិភាព និងវិភាជន៍ធនធានរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រដល់ឃុំ សង្កាត់នានា និងកម្មវិធីគាំទ្រនានានៅរាជធានី ខេត្ត និងដើម្បីធានាដល់ការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងសាកល្បងនានា ដូចជាគម្រោងសាកល្បងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ កិច្ចដំណើរការរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនឹងត្រូវពិនិត្យ និងកែសម្រួលឡើងវិញ ដូចមានចែងនៅក្នុងផ្នែកទី៥.២នៃជំពូកទី៥នេះ។

### ៥.១.២. លំហូរមូលនិធិ និងយន្តការផ្តល់មូលនិធិ

កម្មវិធីជាតិកំណត់អំពីលំហូរនិងយន្តការផ្តល់មូលនិធិ ដោយប្តូរពីក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ ទៅជាវិធីសាស្ត្រដែលផ្អែកលើកម្មវិធី ដើម្បីសម្រេចបាននូវលទ្ធផលច្រើនវិស័យជាងមុន។ រចនាសម្ព័ន្ធរបស់កម្មវិធី តម្រូវឱ្យមានការយកចិត្តទុកដាក់ពិចារណាទៅលើការធ្វើចំណាត់ថ្នាក់ថ្មីនៃលំហូរមូលនិធិ និងវិធីសាស្ត្រនៃការផ្តល់មូលនិធិ។ ការប៉ាន់ស្មានការចំណាយរបស់កម្មវិធីជាតិសម្រាប់ឆ្នាំ២០១០ មានបរិយាយក្នុងផ្នែកទី៥.៤នៃជំពូកទី៥នេះ ដែលឆ្លុះបញ្ចាំងអំពីធនធានពីរាជរដ្ឋាភិបាល និងធនធានពីដៃគូអភិវឌ្ឍន៍។

#### ក). លំហូរមូលនិធិ

កម្មវិធីជាតិមានលក្ខណៈស្មុគស្មាញ ដែលតម្រូវឱ្យមានការរួមចំណែកពីអ្នកពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ប្រភេទនៃការគាំទ្រជាក់លាក់ដែលនឹងត្រូវការចាំបាច់ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណង និងគោលដៅនានារបស់កម្មវិធីជាតិ តាមរយៈធាតុចូលរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ត្រូវបានកំណត់និយមន័យដូចខាងក្រោម :

**ប្រភេទចំណាយទី១"ការគាំទ្រស្ថាប័ននិងការកសាងសមត្ថភាព"**: ការលើកកម្ពស់ និងការបង្កើនសមត្ថភាពរបស់ស្ថាប័ន និងបុគ្គលក្នុងការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីប្រតិបត្តិការរបស់រាជរដ្ឋាភិបាល។ ការចំណាយប្រភេទទី១នេះ រួមមាន :

- **១.១. ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប** : ការអភិវឌ្ឍគោលនយោបាយ និងកិច្ចប្រតិបត្តិការ ឬការអភិវឌ្ឍប្រព័ន្ធ។
- **១.២. ការចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែករូបវន្ត** : ការបង្កើតនូវល័ក្ខខ័ណ្ឌបំពេញការងារជាមូលដ្ឋានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌដែលបង្កើតថ្មី។ ការចំណាយនេះ រួមមាន អគារ យានយន្ត ម៉ាស៊ីនភ្លើងខ្នាតតូច កុំព្យូទ័រ ឧបករណ៍ព័ត៌មានវិទ្យា គ្រឿងសង្ហារិមការិយាល័យ ។ល។
- **១.៣. ការចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែកអរូបវន្ត** : ការចំណាយលើការបណ្តុះបណ្តាល ប្រេងឥន្ធនៈ ប្រាក់បេសកកម្ម និងសម្ភារៈការិយាល័យ។
- **១.៤. ការគ្រប់គ្រង និងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ** : ការចំណាយទៅលើការពិនិត្យមើល និងការគ្រប់គ្រងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ និងទៅលើកិច្ចដំណើរការនានាដែលធានាថា មូលនិធិដែលផ្តល់ដោយក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិឌ្ឍន៍ ត្រូវបានចំណាយដោយមានប្រសិទ្ធភាពនិងមានភាពស័ក្តិសិទ្ធិ ស្របតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍន៍ និងស្របតាមនីតិវិធីប្រតិបត្តិការស្តង់ដារ ។ល។

**ប្រភេទចំណាយទី២"ការវិនិយោគ":** ការកសាងគម្រោងជាក់លាក់នានាដើម្បីលើកកម្ពស់ បង្កើន និងកែលម្អការផ្តល់សេវាសាធារណៈដោយថ្នាក់រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយការចំណាយលើប្រតិបត្តិការ និងការថែទាំគម្រោងទាំងនោះ ត្រូវបានគ្រោងនៅក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គម្រោងវិនិយោគដែលអាចទទួលបានហិរញ្ញប្បទានក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិ គឺជាគម្រោងវិនិយោគដែលជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

តារាង៥.១.ក ខាងក្រោម បង្ហាញពីការប្រែប្រួលនៃការគាំទ្រដែលរំពឹងថានឹងទទួលបានពីដៃគូអភិវឌ្ឍន៍ ទៅតាមប្រភេទចំណាយនីមួយៗ។ គ្រប់ប្រភេទចំណាយទាំងអស់ ត្រូវបានរំពឹងថា ហិរញ្ញប្បទាននិងធាតុចូលរបស់រាជរដ្ឋាភិបាលនឹងមានការកើនឡើង នៅពេលដែលការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍មានការថយចុះ ដើម្បីធានាឱ្យប្រព័ន្ធផ្តល់ហិរញ្ញប្បទានដល់រដ្ឋបាលថ្នាក់ក្រោមជាតិមាននិរន្តរភាព។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើនចំណាយរបស់រាជរដ្ឋាភិបាល និងការកាត់បន្ថយចំណាយរបស់ដៃគូអភិវឌ្ឍន៍ក្នុងដំណាក់កាលនីមួយៗនៃកម្មវិធីជាតិ មានកម្រិតខុសគ្នាអាស្រ័យលើប្រភេទចំណាយ។

ការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍ គឺជាប្រភពហិរញ្ញប្បទានដ៏សំខាន់សម្រាប់ទ្រទ្រង់ការអនុវត្តកម្មវិធីជាតិ ជាពិសេសចំពោះប្រភេទចំណាយទី១"ការគាំទ្រស្ថាប័ននិងការកសាងសមត្ថភាព" ដែលពាក់ព័ន្ធនឹងការចំណាយសម្រាប់ "ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប" និង"ការគ្រប់គ្រងនិងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ" និងប្រភេទចំណាយទី២ "ការវិនិយោគ"។

ការផ្តល់មូលនិធិរួមគ្នា ដែលក្នុងនោះមានការកើនឡើងនូវការរួមចំណែករបស់រាជរដ្ឋាភិបាលទៅលើចំណាយខាងលើនេះ នឹងចាប់ផ្តើមនៅដំណាក់កាលទី៣។

ការចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែករូបវន្ត គឺជាតម្រូវការសម្រាប់គាំទ្ររយៈពេលខ្លីទៅមធ្យមចំពោះការចំណាយដែលពាក់ព័ន្ធនៅក្នុងការចាប់ផ្តើមដំបូង ដើម្បីបង្កើត និងបំពាក់សម្ភារៈបរិក្ខារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ក្រុងនិងស្រុក។ ការចំណាយសម្រាប់ការចាប់ផ្តើមដំបូងទាំងនេះនឹងមានចំនួនច្រើននៅក្នុងដំណាក់កាលទី១ ហើយអាចបន្តដល់ដើមដំណាក់កាលទី២ ប៉ុន្តែទោះជាករណីណា ក៏ដោយគួរតែបញ្ចប់នៅចុងដំណាក់កាលទី២។

ចំណាយចរន្តសម្រាប់កិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានបង្ហាញនៅក្នុង "ការចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែកអរូបវន្ត"។ ការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍សម្រាប់ការចំណាយនេះនឹងត្រូវកាត់បន្ថយជាច្រើន ឬទាំងស្រុងនៅពេលចាប់ផ្តើមដំណាក់កាលទី៣ ដោយត្រូវបានជំនួសដោយថវិការាជរដ្ឋាភិបាលតាមរយៈការផ្ទេរ ឬតាមរយៈចំណូលពីពន្ធឬកម្រៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានបរិមាណគ្រប់គ្រាន់។ ប្រសិនបើពុំមានការរៀបចំឱ្យមានដំណាក់កាលអន្តរកាលដូច្នេះទេ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងមិនអាចដំណើរការប្រកបដោយនិរន្តរភាពឡើយ។

## តារាង៥.១.ក : ការប្រែប្រួលនៃការផ្តល់ការគាំទ្រពីដៃគូអភិវឌ្ឍន៍នៅក្នុង ដំណើរការអនុវត្តកម្មវិធីជាតិ

| ប្រភេទចំណាយ | ដំណាក់កាលទី១ (២០១០-២០១២) | ដំណាក់កាលទី២ (២០១៣-២០១៥) | ដំណាក់កាលទី៣ (២០១៦-២០១៩) |
|---|---|---|---|
| ១. ការគាំទ្រស្ថាប័ន និងការកសាងសមត្ថភាព | | | |
| ១.១. ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប | *** | *** | ** |
| ១.២. ចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែករូបវន្ត | *** | ** | |
| ១.៣. ចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែកអរូបវន្ត | ** | ** | |
| ១.៤. ការគ្រប់គ្រង និងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ | *** | ** | ** |
| ២. ការវិនិយោគ | *** | *** | ** |

### ខ). យន្តការសម្រាប់ការផ្តល់មូលនិធិ

យន្តការលំហូរមូលនិធិនានា មានបង្ហាញនៅក្នុងតារាង៥.១.ខ ទៅតាមប្រភេទចំណាយ និងយន្តការសម្រាប់ការផ្តល់ហិរញ្ញប្បទាន។ លំហូរក្នុងការផ្តល់មូលនិធិនឹងមានភាពបត់បែនដើម្បីឱ្យស្របទៅតាមតម្រូវការ និងភាពមានកម្រិតផ្នែកស្ថាប័នរបស់ដៃគូអភិវឌ្ឍន៍ជាក់លាក់នីមួយៗ ក្នុងពេលដែលដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវខិតខំគោរពទៅតាមគោលដៅរួមនៃការធ្វើដំណើរឆ្ពោះទៅរកមូលដ្ឋាននៃកម្មវិធីមួយ។ យន្តការផ្តល់មូលនិធិជាចម្បងចំនួនបួន រួមមាន :

### ខ.១). ការគាំទ្រថវិកាដោយផ្ទាល់តាមរយៈរតនាគារជាតិ

ការគាំទ្រចំពោះយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌ និងគ្មានភ្ជាប់ល័ក្ខខ័ណ្ឌ គួរផ្សារភ្ជាប់ជាមួយនឹងការផ្ទេរជាក់ស្តែងនៃមុខងារ និងមូលនិធិរបស់រាជរដ្ឋាភិបាលសម្រាប់មុខងារទាំងនោះ។ ពាក់ព័ន្ធនឹងការបង្កើតឱ្យមានមូលនិធិផ្ទេរគ្មានភ្ជាប់ល័ក្ខខ័ណ្ឌថ្មីសម្រាប់ថ្នាក់រាជធានី ខេត្ត ក្រុង និងស្រុក ចាំបាច់ត្រូវកំណត់ជាបឋមនូវរូបមន្ត ដោយផ្អែកលើការបែងចែកថវិកា និងការចុះបញ្ជីគណនេយ្យរវាងចំណាយចរន្ត និងចំណាយមូលធន ដើម្បីធានាឱ្យមានការចំណាយសម្រាប់កិច្ចប្រតិបត្តិការ និងការថែទាំឱ្យបានគ្រប់គ្រាន់ ដូចមានគូសបញ្ជាក់នៅក្នុងផ្នែកផ្សេងៗនៃកម្មវិធីជាតិ។

### ខ.២). កញ្ចប់មូលនិធិវិមជ្ឈការនិងវិសហមជ្ឈការរបស់កម្មវិធីជាតិ

មូលនិធិរបស់ដៃគូអភិវឌ្ឍន៍នានានឹងត្រូវដាក់ជាកញ្ចប់រួមមួយ ហើយត្រូវគ្រប់គ្រងដោយទីភ្នាក់ងារដែលមានការជឿទុកចិត្ត ឬដោយអ្នកគ្រប់គ្រងកញ្ចប់មូលនិធិរបស់ គ.ជ.អ.ប។ គ.ជ.អ.ប អាចពិចារណាក្នុងការប្រើប្រាស់ដំណើរការលទ្ធកម្មដែលមានលក្ខណៈប្រកួតប្រជែងដើម្បីជ្រើសរើសអ្នកគ្រប់គ្រងកញ្ចប់មូលនិធិ។ កញ្ចប់មូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ នឹងត្រូវសម្របសម្រួលតាមគណនីមូលនិធិនានាសម្រាប់ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប និងសម្រាប់កិច្ចប្រតិបត្តិការរដ្ឋបាលដែលមិនមែនជាប្រាក់បៀវត្សរ៍ក្នុងអំឡុងពេលនៃការចាប់ផ្តើម។ តាមរយៈ

កិច្ចដំណើរការនេះ គណនីមួយចំនួននឹងត្រូវបង្កើតឡើង ហើយការព្រមព្រៀងស្តីពីថវិកាត្រូវបានឯកភាពគ្នា ដែលនឹងត្រូវគ្រប់គ្រងដោយលេខាធិការដ្ឋាន គ.ជ.អ.ប ។

### ខ.៣). កញ្ចប់មូលនិធិចែករំលែកលើការចំណាយសម្រាប់ការគ្រប់គ្រង និងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវនៃការប្រើប្រាស់មូលនិធិ

ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវរួមចំណែកចំពោះ**មូលនិធិចែករំលែកលើការចំណាយ** ដែលគាំទ្រកិច្ចប្រតិបត្តិការរបស់ គ.ជ.អ.ប និងការចំណាយនានានៅក្នុងការអនុវត្តកិច្ចព្រមព្រៀងថវិកា ការធ្វើសវនកម្មលើការបំពេញការងារ និងការធានានូវការអនុវត្តនីតិវិធីនានាទាក់ទងនឹងការអនុវត្តកម្មវិធី។ តាមរយៈកិច្ចដំណើរការនេះ យន្តការសម្រាប់ដឹកនាំមូលនិធិចែករំលែកលើការចំណាយនេះនឹងត្រូវបង្កើតឡើង។

### ខ.៤). កិច្ចព្រមព្រៀងទ្វេភាគីរវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍

កិច្ចព្រមព្រៀងទ្វេភាគីនឹងផ្តល់មូលនិធិសម្រាប់ចំណាយទាក់ទងនឹងការគាំទ្រស្ថាប័ន និងការកសាងសមត្ថភាព (លើកលែងតែការចំណាយរដ្ឋបាលដែលមិនមែនប្រាក់បៀវត្សរ៍ផ្នែកអរូបវន្ត) និងការវិនិយោគ។ ដើម្បីជំរុញឱ្យមានការតម្រឹមដៃគូអភិវឌ្ឍន៍ និងធានាដល់សុខដុមនីយកម្មនៅក្នុងចំណោមកម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ គ.ជ.អ.ប ត្រូវសម្របសម្រួលឱ្យមានកិច្ចព្រមព្រៀងទ្វេភាគីនានាស្តីពីការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងប្រើប្រាស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការអនុវត្តគម្រោងនានា។

**តារាង៥.១.ខ : ជម្រើសនានានៃលំហូរមូលនិធិតាមប្រភេទចំណាយ**

| ប្រភេទចំណាយ | ខ.១.ការគាំទ្រថវិកាផ្ទាល់តាមរយៈរតនាគារជាតិ | ខ.២.កញ្ចប់មូលនិធិវិមជ្ឈការនិងវិសហមជ្ឈការរបស់កម្មវិធីជាតិ | ខ.៣.កញ្ចប់មូលនិធិចែករំលែកលើការចំណាយសម្រាប់ការគ្រប់គ្រង និងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវនៃការប្រើប្រាស់មូលនិធិ | ខ.៤.កិច្ចព្រមព្រៀងទ្វេភាគីរវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|
| ១. ការគាំទ្រស្ថាប័ន និងការកសាងសមត្ថភាព | | | | |
| ១.១. ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប | | ✓ | | ✓ |
| ១.២. ចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែករូបវន្ត | ✓ | ✓ | | ✓ |
| ១.៣. ចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែកអរូបវន្ត | | ✓ | ✓ | |
| ១.៤. ការគ្រប់គ្រង និងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ | | | ✓ | ✓ |
| ២. ការវិនិយោគ | ✓ | | | ✓ |

ពាក់ព័ន្ធនឹងទម្រង់លំហូរមូលនិធិ គប្បីត្រូវពិចារណាលើយន្តការផ្តល់ជំនួយបច្ចេកទេសតាមរយៈកិច្ចសន្យាផ្អែកលើពេលវេលា ឬក្របខ័ណ្ឌកិច្ចព្រមព្រៀងដែលផ្អែកលើសមាសធាតុកម្មវិធីនានា និងទៅតាមតម្រូវការចាំបាច់។

## ៥.១.៣. ការផ្តល់ហិរញ្ញប្បទានទៅតាមសមាសធាតុកម្មវិធីទាំងប្រាំ

តារាង៥.១.គ បង្ហាញអំពីប្រភេទចំណាយតាមសមាសធាតុកម្មវិធីនានានៃកម្មវិធីជាតិ។ ប្រភេទចំណាយទាំងអស់ ពុំមែនសុទ្ធតែមានការពាក់ព័ន្ធជាមួយសមាសធាតុកម្មវិធីនីមួយៗនោះឡើយ ហើយជាទូទៅ លំហូរមូលនិធិនានាក៏ពុំមែនសុទ្ធតែទាមទារឱ្យមាននៅគ្រប់ដំណាក់កាលទាំងបីនោះដែរ។

ការចំណាយសម្រាប់ "ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប" និង "ការគ្រប់គ្រងនិងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ" មានការពាក់ព័ន្ធជាមួយសមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ។

ក្នុងពេលអនុវត្តកម្មវិធីជាតិ ដៃគូអភិវឌ្ឍន៍នីមួយៗអាចសម្រេចជ្រើសរើសផ្តល់ការគាំទ្រទៅលើការចំណាយណាមួយ និងសម្រេចប្រើប្រាស់យន្តការលំហូរមូលនិធិណាមួយ ព្រមទាំងអាចផ្តោតការគាំទ្ររបស់ខ្លួនទៅលើថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ឬថ្នាក់ទាំងពីររួមគ្នា (ឬថ្នាក់រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ)។

**តារាង៥.១.គ ៖ ប្រភេទចំណាយតាមសមាសធាតុកម្មវិធី**

<table>
<tr><th>ប្រភេទចំណាយ</th><th>សមាសធាតុ កម្មវិធីទី១ ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ</th><th>សមាសធាតុ កម្មវិធីទី២ ការគ្រប់គ្រងធនធានមនុស្ស</th><th>សមាសធាតុ កម្មវិធីទី៣ ការផ្ទេរមុខងារ</th><th>សមាសធាតុ កម្មវិធីទី៤ ថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ</th><th>សមាសធាតុ កម្មវិធីទី៥ ស្ថាប័នគាំទ្រ</th></tr>
<tr><td colspan="6">១. ការគាំទ្រស្ថាប័ន និងការកសាងសមត្ថភាព</td></tr>
<tr><td>១.១. ជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប</td><td>ជំនួយបច្ចេកទេសសម្រាប់ពេលចាប់ផ្តើមដំបូងនៅដំណាក់កាលទី១ និងដើមដំណាក់កាលទី២</td><td colspan="4">ជំនួយបច្ចេកទេសសម្រាប់ដំណាក់កាលទី១ ទី២ និងទី៣ និងតាមសមាសធាតុនីមួយៗ។ កំណត់សម្គាល់ ៖ ជំនួយបច្ចេកទេសខាងក្រោម អាចបំពេញឱ្យគ្នាទៅវិញទៅមកនៅក្នុង ៖<br>• សមាសធាតុទី២ ជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ<br>• សមាសធាតុទី៣ ជាមួយកម្មវិធីកំណែទម្រង់តាមវិស័យ<br>• សមាសធាតុទី៤ ជាមួយកម្មវិធីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (យ៉ាងហោចក៏រហូតដល់ចុងដំណាក់កាលទី២)</td></tr>
<tr><td>១.២. ចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្អែករូបវន្ត</td><td>ដំណាក់កាលទី១ និងដើមដំណាក់កាលទី២</td><td></td><td></td><td>ដំណាក់កាលទី១ និងទី២ អាស្រ័យទៅលើការរៀបចំប្រព័ន្ធគណនេយ្យ និងព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ</td><td></td></tr>
</table>

| ប្រភេទចំណាយ | សមាសធាតុ កម្មវិធីទី១ ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ | សមាសធាតុ កម្មវិធីទី២ ការគ្រប់គ្រងធនធានមនុស្ស | សមាសធាតុ កម្មវិធីទី៣ ការផ្ទេរមុខងារ | សមាសធាតុ កម្មវិធីទី៤ ថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ | សមាសធាតុ កម្មវិធីទី៥ ស្ថាប័នគាំទ្រ |
|---|---|---|---|---|---|
| ១.៣. ចំណាយរដ្ឋបាលមិនមែនប្រាក់បៀវត្សរ៍ផ្នែកអរូបវន្ត | ដំណាក់កាលទី១ និងដើមដំណាក់កាលទី២ | | | | ដំណាក់កាលទី១ ទី២ និងទី៣ |
| ១.៤. ការគ្រប់គ្រង និងការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ | តម្រូវឱ្យមាននៅដំណាក់កាលទី១ ទី២ និងទី៣ និងនៅក្នុងសមាសធាតុកម្មវិធីទាំងអស់។ | | | | |
| ២. ការវិនិយោគ | ដំណាក់កាលទី១ | | ដំណាក់កាលទី១ ទី២ និងទី៣ | | |

### ៥.១.៤. អនុស្សរណៈនៃការយោគយល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

គោលការណ៍នៃភាពជាដៃគូដែលនឹងត្រូវចរចានៅក្នុងអំឡុងពេលខាងមុខ ត្រូវផ្អែកទៅលើយន្តការផ្តល់ហិរញ្ញប្បទានដែលមានការឯកភាពគ្នា។ គោលការណ៍សម្រាប់ "**កិច្ចព្រមព្រៀងនៃភាពជាដៃគូរួម**" គឺត្រូវបង្កើតយន្តការប្រមូលផ្តុំមូលនិធិជាកញ្ចប់ ដើម្បីផ្តល់មូលនិធិដល់សមាសធាតុកម្មវិធីនានានៃកម្មវិធីជាតិ (ដូចជាជំនួយបច្ចេកទេសដើម្បីបង្កើតបរិយាកាសសមស្រប និងការគាំទ្រដល់កិច្ចប្រតិបត្តិការរដ្ឋបាលជាដើម)។

## ៥.២. យុទ្ធសាស្ត្រអន្តរកាល

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាកំណែទម្រង់ដែលមានលក្ខណៈអន្តរវិស័យ ដូច្នេះ ក្នុងការអនុវត្តកម្មវិធីជាតិតម្រូវឱ្យមានការតម្រឹម និងការធ្វើសុខដុមនីយកម្មរវាងសកម្មភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ក្នុងលក្ខណៈជាជំហានៗ ដើម្បីធានាមិនឱ្យមានការរំខានដល់ការផ្តល់សេវាសាធារណៈ ព្រមទាំងកម្មវិធីនិងគម្រោងនានាដែលកំពុងដំណើរការ។ ដោយឈរលើគោលការណ៍នេះ ការអនុវត្តកម្មវិធីជាតិតម្រូវឱ្យមានយុទ្ធសាស្ត្រអន្តរកាលមួយដើម្បីកែសម្រួលការបែងចែកធនធានរបស់កម្មវិធីនិងគម្រោងទាំងនោះសម្រាប់គាំទ្រដល់ការរៀបចំស្ថាប័ន និងប្រព័ន្ធរបស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចឱ្យបាននូវគោលដៅនានានៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

### ៥.២.១. ការតម្រឹម និងការធ្វើសុខដុមនីយកម្មរវាងកំណែទម្រង់ទាំងបី (កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ)

រចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីជាតិតម្រូវឱ្យមានការតម្រឹម និងការធ្វើសុខដុមនីយកម្មនៅក្នុងការអនុវត្តកំណែទម្រង់ធំៗទាំងបីខាងលើនេះ។ កិច្ចសហការរវាងកំណែទម្រង់ទាំងបី មានសារៈសំខាន់ណាស់ក្នុងការផ្លាស់ប្តូរពីប្រព័ន្ធ

គ្រប់គ្រងហិរញ្ញវត្ថុនិងបុគ្គលិកតាមបែបមជ្ឈការ និងតាមរយៈខ្សែបណ្តោយ ទៅកាន់ប្រព័ន្ធគ្រប់គ្រងមួយតាមបែបវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

គ.ជ.អ.ប ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវសហការគ្នាដើម្បីកំណត់ក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងបញ្ហាប្រឈមដែលមានលក្ខណៈរួមគ្នាពាក់ព័ន្ធទៅនឹងកំណែទម្រង់នីមួយៗ ដោយបង្កើតឱ្យមានផែនការសកម្មភាព និងកាលវិភាគការងារឱ្យបានច្បាស់លាស់ដើម្បីអនុវត្តផែនការសកម្មភាពនេះឱ្យបានជោគជ័យ ។ ការងារជាបន្ទាន់មួយចំនួនរួមមាន :

១. ការរៀបចំ និងការអនុម័តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងប្រព័ន្ធគណនេយ្យ កិច្ចលទ្ធកម្ម ថវិកា និងធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

២. ការកែសម្រួលឡើងវិញនូវប្រព័ន្ធថវិកា ហិរញ្ញវត្ថុ គណនេយ្យ និងលទ្ធកម្មរបស់រាជធានី ខេត្តដែលមានស្រាប់ឱ្យស្របជាមួយគោលការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣. ការពិនិត្យឡើងវិញនូវមូលនិធិឃុំ សង្កាត់ដើម្បីធ្វើចំណាត់ថ្នាក់នៃការចំណាយចរន្ត និងចំណាយមូលធនឡើងវិញឱ្យសមស្របតាមចំណាត់ថ្នាក់ថវិកាជាតិ សំដៅធានាឱ្យមាននិរន្តរភាពក្នុងការផ្តល់សេវាសាធារណៈ ។

៤. ការតាក់តែងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងច្បាប់រៀបចំអង្គការ ។

### ៥.២.២. ការតម្រឹម និងការធ្វើសុខដុមនីយកម្មនៃកម្មវិធីនិងគម្រោងនានាដែលកំពុងដំណើរការ

ជំហានដំបូងនៃការអនុវត្តកម្មវិធីជាតិ ត្រូវអនុវត្តក្នុងអំឡុងពេលនៃដំណាក់កាលអន្តរកាលមួយ ដែលនឹងចាប់ផ្តើមពីដើមឆ្នាំ២០១០រហូតដល់ចប់ដំណាក់កាលទីមួយ ។ នៅក្នុងអំឡុងពេលនេះ ត្រូវធានាឱ្យកម្មវិធីនិងគម្រោងអភិវឌ្ឍន៍ដែលមានបច្ចុប្បន្ន អាចសម្រេចបាននូវគោលបំណងរបស់ខ្លួនដោយមានការរំខានតិចតួច ព្រមទាំងអាចមានភាពបត់បែននូវសកម្មភាពនិងការគាំទ្ររបស់ខ្លួនដើម្បីរួមចំណែកក្នុងការសម្រេចនូវគោលបំណង និងលទ្ធផលរំពឹងទុកនានារបស់កម្មវិធីជាតិផងដែរ ។

យោងតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៩របស់ គ.ជ.អ.ប រួមមានកម្មវិធីនិងគម្រោងប្រមាណដប់ប្រាំ( ១៥) ដែលទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការពីសំណាក់ដៃគូអភិវឌ្ឍន៍នានា ដូចមានបង្ហាញក្នុងតារាង ៥.២ខាងក្រោម ។

## តារាង៥.២ : កម្មវិធី និងគម្រោងដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍

| ល.រ | ឈ្មោះកម្មវិធី ឬគម្រោង | ឆ្នាំចាប់ផ្តើម | ឆ្នាំបញ្ចប់ |
|---|---|---|---|
| ១ | គម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការនិងវិសហមជ្ឈការ (PSDD) | ២០០៧ | ២០១០ |
| ២ | គម្រោងអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ (DDLG) | ២០០៦ | ២០១០ |
| ៣ | គម្រោងកាត់បន្ថយភាពក្រីក្រនៅជនបទ (RPRP-IFAD) | ២០០៦ | ២០១០ |
| ៤ | គម្រោងកែលម្អជីវភាពនៅជនបទ (RULIP-IFAD) | ២០០៨ | ២០១២ |
| ៥ | គម្រោងអភិបាលកិច្ចមូលដ្ឋាន និងវិនិយោគជនបទ (RILGP-WB) | ២០០៧ | ២០១០ |
| ៦ | គម្រោងបែងចែកដីធ្លីសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច (LASED-WB) | ២០០៨ | ២០១៣ |
| ៧ | តម្រូវការសម្រាប់អភិបាលកិច្ចល្អ (DfGG-WB) | ២០០៩ | ២០១២ |
| ៨ | ការអភិវឌ្ឍកសិកម្មនៅតំបន់រងគ្រោះដោយសារគ្រាប់មីននៃប្រទេសកម្ពុជា (ADMAC) | ២០០៦ | ២០០៩ |
| ៩ | គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងទ្រទ្រង់ជីវភាព (NRM&L) | ២០០៦ | ២០១០ |
| ១០ | កម្មវិធីសិទ្ធិកុមារ (Seth Koma-UNICEF) | ១៩៩៦ | ២០១០ |
| ១១ | គម្រោងគាំទ្រវិមជ្ឈការ និងអភិវឌ្ឍន៍មូលដ្ឋាន (IDLD) | ២០០៨ | ២០១០ |
| ១២ | គម្រោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ដំណាក់កាលទី២ (CCDP2) | ២០០៧ | ២០០៩ |
| ១៣ | គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប (TSSL) | ២០០៦ | ២០១០ |
| ១៤ | កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (LAAR) | ២០០៦ | ២០១០ |
| ១៥ | មូលនិធិអង្គការសហប្រជាជាតិដើម្បីសកម្មភាពប្រជាជន (UNFPA) | ២០០៦ | ២០១០ |

កម្មវិធីនិងគម្រោងមួយចំនួនក្នុងចំណោមកម្មវិធីនិងគម្រោងខាងលើនេះ នឹងបន្តរហូតដល់ឆ្នាំ២០១៣។ ដូច្នេះ កម្មវិធីនិងគម្រោងទាំងនេះ ចាំបាច់ត្រូវមានយុទ្ធសាស្ត្រអន្តរកាលមួយច្បាស់លាស់ មុននឹងធ្វើការតម្រឹមយ៉ាងពេញលេញជាមួយនឹងកម្មវិធីជាតិ។ យុទ្ធសាស្ត្រក្នុងការតម្រឹមកម្មវិធីនិងគម្រោងទាំងនេះ មានដូចខាងក្រោម :

- រាល់កម្មវិធី និងគម្រោងនានារបស់ដៃគូអភិវឌ្ឍន៍ដែលគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ហើយដែលបាននិងកំពុងអនុវត្តដោយអង្គភាពផ្សេងៗរបស់ក្រសួងមហាផ្ទៃ ត្រូវខិតខំតម្រឹមជាមួយនឹងកម្មវិធីជាតិ ដោយប្រគល់ការទទួលខុសត្រូវលើការត្រួតពិនិត្យជារួមដល់រចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីជាតិរបស់ គ.ជ.អ.ប។ កិច្ចដំណើរការនេះនឹងកាត់បន្ថយការចំណាយរដ្ឋបាលក្នុងករណីដែលមានអង្គភាពអនុវត្តគម្រោងពីរស្របគ្នាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងមានផលប៉ះពាល់វិជ្ជមានជាអតិបរមាដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។
- កម្មវិធី និងគម្រោងនីមួយៗ អាចនឹងធ្វើអន្តរកាលក្នុងពេលខុសៗគ្នា ប៉ុន្តែត្រូវអនុលោមតាមគោលការណ៍ដូចមានរៀបរាប់នៅក្នុងផ្នែកស្តីពីក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ សម្រាប់

"**កិច្ចព្រមព្រៀងនៃភាពជាដៃគូរួម**" ដែលជាឯកសារតម្រង់ទិសសម្រាប់កិច្ចដំណើរការនេះ។ ជោគជ័យនៃការធ្វើអន្តរកាលនេះ នឹងតម្រឹម និងធ្វើសុខដុមនីយកម្មការកសាងផែនការ ថវិកា ការផ្តល់ហិរញ្ញប្បទាន (រួមទាំងការងារលទ្ធកម្ម) និងការធ្វើរបាយការណ៍(រួមមានការងារតាមដាននិងវាយតម្លៃ) របស់ដៃគូអភិវឌ្ឍន៍ជាមួយនឹងប្រព័ន្ធរបស់រាជរដ្ឋាភិបាល ដែលនឹងជំរុញឱ្យកាន់តែមានតម្លាភាព និងគណនេយ្យភាព។

## ក). ការគាំទ្រកម្មវិធីរបស់ គ.ជ.អ.ប

គម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ហៅកាត់ថា PSDD គឺជាគម្រោងស្នូលមួយដែលបានផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងប្រតិបត្តិការដល់ការអនុវត្តរាល់គម្រោងវិមជ្ឈការ និងវិសហមជ្ឈការផ្សេងៗទៀត ជាពិសេសទាក់ទងនឹងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប។ គម្រោង PSDD នឹងបញ្ចប់នៅចុងឆ្នាំ២០១០ ហេតុនេះការធ្វើអន្តរកាលគម្រោងនេះឱ្យបានឆាប់រហ័ស នឹងធ្វើឱ្យមានផលប៉ះពាល់ជាវិជ្ជមានដល់គម្រោងនានាដែលកំពុងគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ដូច្នេះក្នុងដំណាក់កាលទីមួយឆ្នាំ២០១០-២០១២នេះ គម្រោងដែលបន្តវេនពី PSDD ត្រូវតែតម្រឹមនូវគោលបំណង និងសកម្មភាពរបស់ខ្លួនឱ្យបានពេញលេញជាមួយកម្មវិធីជាតិ។ ដោយសារគម្រោងនានារបស់អង្គការសហប្រជាជាតិនឹងបញ្ចប់ក្នុងឆ្នាំ២០១០ អាស្រ័យហេតុនេះ អង្គការសហប្រជាជាតិចាំបាច់ត្រូវបង្កើតកម្មវិធីរួមមួយក្នុងចំណោមទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិដែលពាក់ព័ន្ធនឹងការងារវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីគាំទ្រដល់កម្មវិធីជាតិ។ ការបញ្ចូលគ្នានេះនឹងត្រូវធ្វើឡើងដោយមានការពិនិត្យមើលយ៉ាងប្រុងប្រយ័ត្ន ដើម្បីធានាថា សមាសភាគ និងលទ្ធផលដែលបានរំពឹងទុក (ដូចជាការគាំទ្រដល់សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ និងការលើកកម្ពស់សំឡេងរបស់យុវជននិងស្ត្រីនៅក្នុងគម្រោងផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ដូចជាគម្រោងអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនិងវិមជ្ឈការ និងកម្មវិធីសិទ្ធិកុមារ) ត្រូវបានដាក់បញ្ចូល និងរក្សាទុក។

នៅក្នុងការងារនេះ គួរមានការពិចារណាលើបញ្ហាមួយចំនួន ដូចខាងក្រោម :

១. ត្រូវរៀបចំឱ្យដាច់ដោយឡែកនូវការចំណាយ សម្រាប់ការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ ចេញពីការចំណាយសម្រាប់ជំនួយការបច្ចេកទេសរបស់គម្រោង PSDD ដើម្បីធានានូវការគាំទ្រផ្នែកជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ និងដើម្បីរៀបចំយុទ្ធសាស្ត្រសម្រាប់ការធ្វើសមាហរណកម្មនូវការទទួលខុសត្រូវលើការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវ ទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

២. ស្របតាមក្របខ័ណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ត្រូវរៀបចំឱ្យមានកិច្ចព្រមព្រៀងមួយទាក់ទងនឹងការផ្តល់ជំនួយបច្ចេកទេស សំដៅធានាឱ្យបានថា រចនាសម្ព័ន្ធនៃជំនួយបច្ចេកទេសនេះឆ្លុះបញ្ចាំងនៅក្នុងគ្រប់សមាសធាតុកម្មវិធីនៃកម្មវិធីជាតិ និងកាត់បន្ថយនូវការចំណាយរួមគ្នាទៅលើការពិនិត្យមើលដើម្បីធានាឱ្យមានភាពត្រឹមត្រូវនៅក្នុងដំណាក់កាលអន្តរកាល។

### ខ). ថវិការបស់ គ.ជ.អ.ប

កម្មវិធីជាតិត្រូវបានតាក់តែងឡើង ដើម្បីផ្លាស់ប្តូរជាបណ្តើរៗ ពីការផ្តោតតែលើការគ្រប់គ្រង និងការអនុវត្តគម្រោងអភិវឌ្ឍន៍ ទៅជាការយកចិត្តទុកដាក់លើការកសាងសមត្ថភាពស្ថាប័នសម្រាប់អនុវត្តគម្រោងទាំងនោះ ដោយប្រើប្រាស់សិទ្ធិអំណាច និងធនធាន ដើម្បីធានាថា ការវិនិយោគត្រូវបានការពារ គុណភាពនិងបរិមាណនៃសេវាសាធារណៈត្រូវបានលើកកម្ពស់ និងធានាឱ្យមាននិរន្តរភាព។ នៅពេលដែលមុខងារត្រូវបានផ្ទេរ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគិតគូរអំពីការបន្តផ្តល់សេវាសាធារណៈជាប្រចាំ ជាជាងការគិតគូរអំពីគម្រោង។ លើសពីនេះទៀត រចនាសម្ព័ន្ធនៃថវិកាប្រតិបត្តិការ និងថវិកាមូលធនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវមានការផ្លាស់ប្តូរផងដែរ។ អាស្រ័យហេតុនេះ នៅក្នុងអំឡុងដំណាក់កាលទីមួយ ចាំបាច់ត្រូវតម្រឹមថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប ជាមួយនឹងការធ្វើចំណាត់ថ្នាក់ថវិកា ដើម្បីធានាថា លំហូរនៃមូលនិធិរបស់ គ.ជ.អ.ប នឹងឆ្លុះបញ្ចាំងអំពីថវិកាប្រតិបត្តិការនានា ដោយរៀបចំមូលនិធិដែលវិភាជន៍សម្រាប់ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងស្ថាប័ន ឱ្យដាច់ដោយឡែកពីមូលនិធិដែលវិភាជន៍សម្រាប់ការចំណាយមូលធន និងការចំណាយប្រតិបត្តិការ។

## ៥.៣. កម្មវិធីប៉ាន់ស្មានរយៈពេល៣ឆ្នាំនៃកម្មវិធីជាតិ

ក្របខ័ណ្ឌតក្កភាពនានាដែលបានរៀបរាប់លម្អិតក្នុងជំពូកទី៣ គូសបញ្ជាក់ពីសកម្មភាពសំខាន់ៗ ដែលចាំបាច់ក្នុងការសម្រេចនូវគោលដៅ និងគោលបំណងនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងរយៈពេល១០ឆ្នាំខាងមុខ។ ផ្នែកទី២.៧នៃជំពូកទី២ អធិប្បាយអំពីលទ្ធផលរំពឹងទុកនានាដែលត្រូវសម្រេចឱ្យបានជាបន្ទាន់សម្រាប់ដំណាក់កាលទីមួយៗ។ ចំណែកផ្នែកទី៥.៣នេះ អធិប្បាយអំពីវិធីសាស្ត្រអនុវត្តន៍ និងកម្មវិធីប៉ាន់ស្មានរយៈពេល៣ឆ្នាំ។

### ៥.៣.១. វិធីសាស្ត្រអនុវត្តន៍

កម្មវិធីជាតិទាមទារឱ្យមានការពិចារណាទៅលើការអនុវត្តដែលមានលក្ខណៈអសមប្បមាណ។ ដោយសាររដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមច្បាប់ដែលមានបច្ចុប្បន្ន ហេតុដូច្នេះ លទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តច្បាប់ទាំងនោះ នឹងត្រូវពឹងផ្អែកទៅលើសមត្ថភាពបុគ្គលិក មន្ត្រី និងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ សកម្មភាពមួយចំនួនដែលបានកំណត់នៅក្នុងកម្មវិធីជាតិ ត្រូវបានអនុវត្តតាមវិធីសាស្ត្រដែលមានលក្ខណៈទូទៅ ហើយសកម្មភាពមួយចំនួនទៀត ត្រូវបានអនុវត្តតាមវិធីសាស្ត្រដែលមានលក្ខណៈជាការចាប់ផ្តើមជាមុនសិន មុននឹងឈានដល់ការពង្រីកវិសាលភាពនៃការអនុវត្តជាទូទៅ។

### ក). វិធីសាស្ត្រដែលមានលក្ខណៈទូទៅ

វិធីសាស្ត្រដែលមានលក្ខណៈទូទៅ ត្រូវបានប្រើប្រាស់ចំពោះសកម្មភាពនានាទាក់ទងនឹងផ្នែកទាំងឡាយដែលភាពមិនប្រក្រតីនឹងកើតមានឡើងក្នុងការប្រើប្រាស់មូលនិធិសាធារណៈ។ ជារួម មានបញ្ហាសំខាន់ៗចំនួន៣ គឺ :

- ការទទួលខុសត្រូវក្នុងការធានាឱ្យមានភាពត្រឹមត្រូវ នៃការប្រើប្រាស់ហិរញ្ញប្បទានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសង្គតិភាពជាមួយនឹងការគ្រប់គ្រងចំណូល និងហិរញ្ញវត្ថុ។ ប្រសិនបើពុំមានការគាំទ្រគ្រប់គ្រាន់នៅក្នុងផ្នែកនេះទេ នោះអាចនឹងបណ្តាលឱ្យកើតមានទូវភាពមិនជឿទុកចិត្តពីសាធារណជន ព្រមទាំងអាចបង្កឱ្យមានសកម្មភាពពុករលួយ។
- ក្រុមប្រឹក្សាត្រូវមានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចលើការវិភាជន៍ធនធាន ដែលមានលក្ខណៈឆ្លើយតបនឹងតម្រូវការរបស់មូលដ្ឋាន។ ការធ្វើសេចក្តីសម្រេចទៅលើការប្រើប្រាស់ធនធានរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាមរយៈដំណើរការកសាងផែនការ និងកម្មវិធីវិនិយោគមួយដែលមានការចូលរួម និងការឆ្លើយតប។ អាស្រ័យហេតុនេះ ក្នុងឆ្នាំដំបូងៗត្រូវយកចិត្តទុកដាក់ទៅលើការគាំទ្រដល់ក្រុមប្រឹក្សាក្នុងការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន។
- តារាងប្រាក់បៀវត្សរ៍ : នៅពេលដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានប្រគល់ការទទួលខុសត្រូវចំពោះផ្នែកមួយចំនួននៃការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងតារាងប្រាក់បៀវត្សរ៍ច្បាស់លាស់ ដើម្បីធានាដល់ការការពារសិទ្ធិរបស់មន្ត្រី និងធានាដល់ការផ្តល់ប្រាក់បៀវត្សរ៍ឱ្យបានត្រឹមត្រូវទៅតាមប្រព័ន្ធប្រាក់បៀវត្សរ៍ដែលបានកំណត់។ ទន្ទឹមនេះ ត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃបុគ្គលិកឱ្យបានច្បាស់លាស់ ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីប្រជាពលរដ្ឋមកលើមន្ត្រីរាជការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ១). វិធីសាស្ត្រដែលមានលក្ខណៈជាការចាប់ផ្តើមជាមុនសិន មុននឹងឈានដល់ការពង្រីកវិសាលភាពនៃការអនុវត្តជាទូទៅ

វិធីសាស្ត្រនេះនឹងត្រូវអនុវត្តចំពោះសកម្មភាពណាមួយដែលផ្អែកទៅលើតម្រូវការ និងសមត្ថភាពរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការសិក្សាវាយតម្លៃអំពីសមត្ថភាពដើម្បីរៀបចំទិន្នន័យគោលសម្រាប់ការកសាងសមត្ថភាព នឹងបង្ហាញលម្អិតអំពីវិធីសាស្ត្រក្នុងការអនុវត្តកម្មវិធីជាតិតាមមធ្យោបាយចំនួនពីរ។ **ទីមួយ** ការសិក្សាវាយតម្លៃសមត្ថភាពនឹងបង្ហាញអំពីចំណុចខ្វះខាតនៃចំណេះដឹង និងធនធានសម្រាប់អនុវត្តសកម្មភាពនានា ដែលពាក់ព័ន្ធនឹងបញ្ហាដែលមានលក្ខណៈជាទូទៅ ព្រមទាំងអាចផ្តល់ជាព័ត៌មានដល់ គ.ជ.អ.ប ក្នុងការស្វែងរកធនធានសម្រាប់ដោះស្រាយបញ្ហាសំខាន់ៗទាំងនេះ។ **ទីពីរ** ការសិក្សាវាយតម្លៃសមត្ថភាពក៏នឹងផ្តល់ព័ត៌មានដល់ គ.ជ.អ.ប ផងដែរអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬតំបន់ជាក់លាក់ណាមួយដែលមានលទ្ធភាព និងតម្រូវការក្នុងការអនុវត្តនូវ របៀបរបបថ្មី។

ការបង្កើននូវការផ្ទេរមុខងារនិងធនធាន ក៏ត្រូវបានយកចិត្តទុកដាក់ពិចារណាផងដែរ។ មុខងារមួយចំនួននឹងត្រូវបានផ្ទេរឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងទម្រង់ជាការប្រគល់ ឬការធ្វើប្រតិភូកម្ម។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយក៏មុខងារ និងធនធានត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ឬតំបន់ជាក់លាក់ណាមួយដោយផ្អែកលើទិន្នន័យស្តីពីតម្រូវការរបស់ប្រជាពលរដ្ឋ និងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៥.៣.២. កម្មវិធីប៉ាន់ស្មានសម្រាប់រយៈពេល៣ឆ្នាំ

ដើម្បីបង្កើត និងធ្វើស្ថាប័នភាវូបនីយកម្មរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដែលធានាដល់ការអនុវត្តគោលនយោបាយ និងឈានឆ្ពោះទៅរកការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ត្រូវមានសកម្មភាពអន្តរកាល និងសកម្មភាពចាប់ផ្តើមជាច្រើនសម្រាប់សមាសធាតុកម្មវិធីទាំងប្រាំនៅក្នុងដំណាក់កាលទី១។ សកម្មភាពជាអាទិភាពទាំងនោះរួមមាន ការរៀបចំ និងអនុម័តនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា ព្រមទាំងរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនានាសម្រាប់កិច្ចដំណើរការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានកំណត់នៅក្នុងតារាងក្របខ័ណ្ឌតក្កភាពសមាសធាតុកម្មវិធីនានា និងបរិយាយលម្អិតនៅក្នុងកម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១០ និងកម្មវិធីប៉ាន់ស្មានសម្រាប់រយៈពេល៣ឆ្នាំជាបន្តបន្ទាប់។ កម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១០ត្រូវបានរៀបចំឡើងនៅក្នុងផែនការសកម្មភាពរបស់ គ.ជ.អ.ប ឆ្នាំ២០១០។ កម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១១-២០១៣ នឹងត្រូវរៀបចំឡើងនៅអំឡុងត្រីមាសទី១ឆ្នាំ២០១០ ដោយផ្អែកលើសមាសធាតុកម្មវិធីនៃកម្មវិធីជាតិ និងផែនការសកម្មភាពរបស់ គ.ជ.អ.ប ឆ្នាំ២០១០។ កម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១៤-២០១៦ នឹងត្រូវរៀបចំឡើងនៅដើមឆ្នាំ២០១៣ ដោយផ្អែកលើសមាសធាតុកម្មវិធីនៃកម្មវិធីជាតិ និងការពិនិត្យឡើងវិញនូវការអនុវត្តកម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១១-២០១៣។ ចំណែកឯកម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១៧-២០១៩ នឹងត្រូវរៀបចំឡើងនៅដើមឆ្នាំ២០១៦ ដោយផ្អែកលើសមាសធាតុកម្មវិធីនៃកម្មវិធីជាតិ និងការពិនិត្យឡើងវិញនូវការអនុវត្តកម្មវិធីប៉ាន់ស្មានសម្រាប់ឆ្នាំ២០១៤-២០១៦។

ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីប៉ាន់ស្មានសម្រាប់រយៈពេល៣ឆ្នាំនេះនឹងត្រូវធ្វើការពិនិត្យមើលឡើងវិញ ដើម្បីរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ។

## ៥.៤. ការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់កម្មវិធីជាតិ

ដើម្បីសម្រេចបានជោគជ័យក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីជាតិតម្រូវឱ្យមានការផ្លាស់ប្តូររចនាសម្ព័ន្ធ ប្រព័ន្ធ និងរបៀបរបបធ្វើការងារកន្លងមក និងទាមទារឱ្យមានការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុពីសំណាក់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ផ្នែកទី៥.១ និងផ្នែកទី៥.២នៃជំពូកទី៥នេះ បានបរិយាយយ៉ាងលម្អិតអំពីយន្តការផ្តល់មូលនិធិ ព្រមទាំងលទ្ធភាពនៃការធ្វើអន្តរកាលកម្មវិធី និងគម្រោងដែលមានបច្ចុប្បន្នទៅក្នុងប្រព័ន្ធរបស់រាជរដ្ឋាភិបាល។ ផ្នែកនេះនឹងបរិយាយអំពីវិសាលភាព ការណែនាំសំខាន់ៗក្នុងការវិភាជន៍ធនធាន និងការប៉ាន់ស្មានអំពីតម្រូវធនធានចាំបាច់សម្រាប់ឆ្នាំ២០១០។

### ៥.៤.១. វិសាលភាព

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានផលប៉ះពាល់ទៅលើវិស័យទាំងអស់ ដែលនឹងត្រូវអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដូចនេះ ប្រភេទចំណាយទាំងអស់ត្រូវបានធ្វើចំណាត់ថ្នាក់ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពាក់ព័ន្ធជាមួយស្ថាប័ននានា ការលើកកម្ពស់គុណភាពសេវាសាធារណៈ និងការផ្តល់សេវាសាធារណៈ។ នៅក្នុងរយៈពេលអនុវត្តកម្មវិធីជាតិ រាជរដ្ឋាភិបាលនឹងផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

នូវមុខងារដែលមានលក្ខណៈជាកាតព្វកិច្ច និងជាជម្រើស ដោយមានភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកសមស្រប។

## ៥.៤.២. ការណែនាំសំខាន់ៗក្នុងការបែងចែកធនធាន

កម្មវិធីជាតិបានកំណត់ពីសកម្មភាពនានាដែលទាមទារឱ្យមានការគាំទ្រនូវធនធានពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ អាស្រ័យដោយធនធានមានកម្រិតដែលតម្រូវឱ្យមានជម្រើសជាយុទ្ធសាស្ត្រក្នុងការប្រើប្រាស់ធនធាន ដូចជាការផ្តោតទៅលើការផ្តល់ជំនួយបច្ចេកទេស ការកសាងសមត្ថភាពសំខាន់ៗដល់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការវិនិយោគជាដើម ហេតុដូច្នេះ ចាំបាច់ត្រូវមានការណែនាំច្បាស់លាស់អំពីការប្រើប្រាស់ធនធានទាំងនេះ។ ពាក់ព័ន្ធនឹងបញ្ហានេះ កម្មវិធីជាតិបានកំណត់ការណែនាំក្នុងការបែងចែកធនធានដូចខាងក្រោម :

១. រយៈពេលកន្លងមក ថ្នាក់ក្រុង ស្រុក ខណ្ឌមានសិទ្ធិអំណាចតិចតួច និងពុំមែនជាអង្គភាពថវិកាឡើយ។ ប៉ុន្តែក្រុង ស្រុក គឺជាថ្នាក់រដ្ឋបាលសមស្របមួយសម្រាប់ការផ្តល់សេវាសាធារណៈដែលឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋផ្ទាល់ ឬតម្រូវការពីឃុំ សង្កាត់ ហេតុនេះការគាំទ្រដល់ក្រុមប្រឹក្សា និងរដ្ឋបាលក្រុង ស្រុក នាពេលខាងមុខ គឺជាសកម្មភាពដែលមានអាទិភាពខ្ពស់។ ដូច្នេះ ការបែងចែកធនធាន គប្បីត្រូវផ្តល់ឱ្យបានគ្រប់គ្រាន់ទៅឱ្យថ្នាក់ក្រុង ស្រុក ដើម្បីពង្រឹងសមត្ថភាពឱ្យបានសមស្របដែលអាចមានលទ្ធភាពទទួលខុសត្រូវ និងអនុវត្តនូវមុខងារមួយចំនួនដែលនឹងត្រូវបានផ្ទេរនាពេលខាងមុខ។

២. ការកសាងសមត្ថភាពឃុំ សង្កាត់បានទទួលជោគជ័យគួរឱ្យកត់សម្គាល់ ហេតុដូច្នេះ ចាំបាច់ត្រូវក្តោបយកនូវកម្លាំងចលករនេះ ព្រមទាំងត្រូវរក្សាការពារនូវសមិទ្ធផលនានានៃការវិនិយោគដែលមានកន្លងមក ដោយត្រូវប្រមូលចងក្រងនូវរាល់មេរៀនបទពិសោធន៍ដែលទទួលបាននៅថ្នាក់ឃុំ សង្កាត់។ មេរៀនបទពិសោធន៍ទាំងនេះនឹងបង្ហាញអំពីទំនាក់ទំនងរវាងឃុំ សង្កាត់ជាមួយនឹងក្រុង ស្រុក ខណ្ឌ ដែលអាចជួយពង្រឹងគណនេយ្យភាពរបស់ក្រុង ស្រុក ខណ្ឌចំពោះឃុំ សង្កាត់ ព្រមទាំងបង្ហាញអំពីតម្រូវការនៃការគាំទ្ររបស់ក្រុង ស្រុក ខណ្ឌ ចំពោះឃុំ សង្កាត់។

៣. រដ្ឋបាលរាជធានី ខេត្ត មានសមត្ថភាពច្រើនជាងថ្នាក់រដ្ឋបាលដទៃទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដូច្នេះ រាជធានី ខេត្តនឹងមានលទ្ធភាពក្នុងការប្រកាន់យកនូវការទទួលខុសត្រូវផ្នែកការងាររដ្ឋបាល និងអនុវត្តសិទ្ធិអំណាចរបស់ខ្លួនស្របតាមការផ្ទេរមុខងារ។ អាទិភាពសំខាន់នៅថ្នាក់នេះ គឺការធ្វើសមាហរណកម្មប្រព័ន្ធនានា ដែលកំពុងអនុវត្តដោយផ្នែកនានារបស់គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍រាជធានី ខេត្ត និងការកែសម្រួលការអនុវត្តការងាររដ្ឋបាលបច្ចុប្បន្ន ឱ្យស្របជាមួយរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. ដើម្បីពង្រីកការយល់ដឹងជាទូទៅ អំពីគោលដៅនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការដល់សាធារណជន ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានការបែងចែកធនធានសមស្រប សម្រាប់កិច្ចការងារនេះ។

## ៥.៤.៣. ការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់កម្មវិធីជាតិ

ដើម្បីធានាដល់ការអនុវត្តកម្មវិធីជាតិ ចាំបាច់ត្រូវរៀបចំឱ្យមានការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់រយៈពេល៣ឆ្នាំជាបន្តបន្ទាប់។ ដោយសារតែឆ្នាំ២០១០ គឺជាឆ្នាំអន្តរកាល ដែលគម្រោងគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ដៃគូអភិវឌ្ឍន៍មួយចំនួននឹងត្រូវបញ្ចប់ ហើយគម្រោងមួយចំនួនបាននិងកំពុងរៀបចំតាក់តែងឡើងដើម្បីចូលរួមចំណែកនិងបន្សុីជាមួយកម្មវិធីជាតិ។ ដូចនេះ ការប៉ាន់ស្មានអំពីតម្រូវការធនធានឆ្នាំ២០១០នៃកម្មវិធីជាតិត្រូវផ្អែកតាមផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០០៩របស់ គ.ជ.អ.ប និងតួលេខថវិការបស់រាជធានី ខេត្ត ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩។

តម្រូវការធនធានសរុបសម្រាប់ឆ្នាំ២០១០ : **៨៩៩.២៤៦.៤០០.០០០រៀល** (ប្រាំបីរយកៅសិបប្រាំបួនពាន់ពីររយសែសិបប្រាំមួយលានប្រាំបួនរយពាន់រៀល) សមមូលនឹង **២១៦.៦៨៦.០០០ដុល្លារសហរដ្ឋអាមេរិក** (ពីររយដប់ប្រាំមួយលានប្រាំមួយរយប៉ែតសិបប្រាំមួយពាន់ដុល្លារសហរដ្ឋអាមេរិក) ដែលក្នុងនោះធនធានពី :

- **រាជរដ្ឋាភិបាល : ៥១២.៥២៥.០០០.០០០រៀល** (ប្រាំរយដប់ពីរពាន់ប្រាំរយម្ភៃប្រាំលានរៀល) សមមូលនឹង**១២៣.៥០០.០០០ដុល្លារសហរដ្ឋអាមេរិក**(មួយរយម្ភៃបីលានប្រាំរយពាន់ដុល្លារសហរដ្ឋអាមេរិក)។
- **ដៃគូអភិវឌ្ឍន៍ : ៣៨៦.៧២១.៤០០.០០០** (បីរយប៉ែតសិបប្រាំមួយពាន់ប្រាំពីររយម្ភៃមួយលានប្រាំបួនរយពាន់រៀល) សមមូលនឹង **៩៣.១៨៦.០០០ដុល្លារសហរដ្ឋអាមេរិក** (កៅសិបបីលានមួយរយប៉ែតសិបប្រាំមួយពាន់ដុល្លារសហរដ្ឋអាមេរិក)។

ដើម្បីធានាដល់ការកៀរគរធនធានសម្រាប់អនុវត្តកម្មវិធីជាតិ ចាំបាច់ត្រូវធ្វើការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់រយៈពេល៣ឆ្នាំជាបន្តបន្ទាប់។ ការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់ឆ្នាំ២០១១-២០១៣នៃកម្មវិធីជាតិនឹងត្រូវរៀបចំនៅក្នុងអំឡុងខែមេសា-ឧសភា ឆ្នាំ២០១០។ ការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់ឆ្នាំ២០១៤-២០១៦នៃកម្មវិធីជាតិនឹងត្រូវរៀបចំនៅដើមឆ្នាំ២០១៣ ដោយផ្អែកលើការពិនិត្យឡើងវិញនៃការអនុវត្តថវិកាឆ្នាំ២០១១-២០១៣ និងស្ថានភាពជាក់ស្តែងនៃការរីកចម្រើនសេដ្ឋកិច្ច។ ចំណែកឯការប៉ាន់ស្មានអំពីតម្រូវការធនធានសម្រាប់ឆ្នាំ២០១៧-២០១៩នៃកម្មវិធីជាតិនឹងត្រូវរៀបចំនៅដើមឆ្នាំ២០១៦ ដោយផ្អែកលើការពិនិត្យឡើងវិញនៃការអនុវត្តថវិកាឆ្នាំ២០១៤-២០១៦ និងស្ថានភាពជាក់ស្តែងនៃការរីកចម្រើនសេដ្ឋកិច្ច។

ឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០ ដល់២០១៩) ត្រូវបានឆ្លងកិច្ចប្រជុំលើកទី៤របស់ គ.ជ.អ.ប នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ និងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។

# ឧបសម្ព័ន្ធទី១

# របាយការណ៍សង្ខេប

# ស្តីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំងថ្នាក់លើក

# ឧបសម្ព័ន្ធទី១
# របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃកិច្ចប្រជុំពិភាក្សាទាំងប្រាំលើក

## ១. វិធីសាស្ត្រក្នុងការរៀបចំកិច្ចពិភាក្សារបស់កម្មវិធីជាតិ

ការរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល ១០ឆ្នាំ បានផ្តើមចេញពីសមិទ្ធផលទាំងឡាយដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងការអភិវឌ្ឍប្រទេសជាតិ ក្នុងរយៈពេល១៥ឆ្នាំកន្លងមក។ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍បោះជំហានទៅមុខជានិច្ច និងមានការគិតគូរច្បាស់លាស់ និងទទួលស្គាល់ថា ការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ នឹងត្រូវអនុវត្តជាក់ស្តែងបានលុះត្រាតែមានការប្តេជ្ញាចិត្ត និងការគាំទ្រដ៏ទូលំទូលាយពីគ្រប់មជ្ឈដ្ឋាន និងពីគ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ ការរៀបចំតាក់តែងកម្មវិធីជាតិនេះ បានជ្រើសរើសយកវិធីសាស្ត្រមួយដែលលើកទឹកចិត្តឱ្យមានការចូលរួមដ៏សកម្មពីតំណាងក្រសួង ស្ថាប័ន មន្ត្រីនៅថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានា។ ដំណើរការនៃការតាក់តែងកម្មវិធីជាតិក៏បានយកចិត្តទុកដាក់ផងដែរទៅលើបទពិសោធន៍កន្លងមក ដើម្បីជាមូលដ្ឋានសម្រាប់ការកែទម្រង់នៅជំហានបន្ទាប់។

ដោយប្រកាន់ខ្ជាប់នូវគោលគំនិតខាងលើ ការតាក់តែងកម្មវិធីជាតិបានរៀបចំឱ្យមានកិច្ចពិភាក្សាជាបន្តបន្ទាប់ សំដៅទទួលបាននូវគំនិត និងការឯកភាពជារួមលើបញ្ហាជាគន្លឹះនានា ដើម្បីកំណត់ជាគោលការណ៍ និងវង្វង់សមត្ថកិច្ចសម្រាប់កំណែទម្រង់ទាំងមូល។ ប្រធានបទសម្រាប់កិច្ចពិភាក្សានីមួយៗ ផ្តោតលើទិដ្ឋភាពសំខាន់ៗសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដូចមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ប្រធានបទទាំងនោះរួមមាន :

- គោលដៅ និងយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ
- ការផ្ទេរមុខងារ និងការទទួលខុសត្រូវឱ្យទៅថ្នាក់ក្រោមជាតិ
- ហិរញ្ញវត្ថុ និងថវិកាថ្នាក់ក្រោមជាតិ
- គណនេយ្យភាព ការពិនិត្យមើល និងការឆ្លើយតបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

លើសពីនេះទៀត ក្នុងកិច្ចដំណើរការតាក់តែងកម្មវិធីជាតិក៏បានរៀបចំឱ្យមានកិច្ចពិភាក្សាដោយឡែកៗ ជាមួយក្រសួង ស្ថាប័នមួយចំនួនអំពីការផ្ទេរមុខងារ ធនធាន និងបុគ្គលិក។ កិច្ចប្រជុំជាមួយក្រសួង ស្ថាប័នសំខាន់ៗ ត្រូវបានធ្វើឡើងទាំងមុន និងក្រោយកិច្ចពិភាក្សា ក្នុងគោលបំណងកសាងនូវយុទ្ធសាស្ត្រដ៏លម្អិតសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យជាអាទិភាពបន្ថែមទៀត។

លទ្ធផលដែលទទួលបានពីកិច្ចពិភាក្សាទាំងនេះ បានបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការចាប់ផ្តើមអនុវត្តសកម្មភាពរៀបចំតាក់តែងកម្មវិធីជាតិនេះ។ លទ្ធផលដែលទទួលបានពីកិច្ចពិភាក្សាទាំងនេះមានដូចខាងក្រោម :

**ទី១ :** វិធីសាស្ត្រនៃកិច្ចពិភាក្សានេះ បានជំរុញឱ្យមានការចូលរួមពីបណ្តាមន្ត្រីរបស់រាជរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ជាលទ្ធផល មន្ត្រីទាំងនោះមានការយល់ដឹងអំពីតម្រូវការ និងវិសាសភាពនៃបញ្ហាប្រឈម ដែលនឹងអាចកើតឡើងនៅពេលអនុវត្តកំណែទម្រង់នេះ។

**ទី២ :** ការយកចិត្តទុកដាក់ទៅលើភាពប្រទាក់ក្រឡាគ្នារវាងកំណែទម្រង់សំខាន់ៗទាំងបី គឺកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ មានទំនាក់ទំនងដាច់ដោយឡែកផង និងមានទំនាក់ទំនងជារួមផងជាមួយនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ កម្មវិធីជាតិរយៈពេល១០ឆ្នាំ នឹងសង្កត់ធ្ងន់ទៅលើកំណែទម្រង់ទាំងបីខាងលើ ដើម្បីធានាឱ្យបាននូវកិច្ចសហប្រតិបត្តិការ និងការធ្វើកំណែទម្រង់ជាបន្តបន្ទាប់ក្នុងការផ្ទេរមុខងារ ហិរញ្ញវត្ថុ និងបុគ្គលិក ដោយមិនរំខានដល់សកម្មភាពរបស់រាជរដ្ឋាភិបាល។ ចំណុចដែលគួរធ្វើការកត់សម្គាល់ គឺថាក្រសួង ស្ថាប័ននានាបានបង្កើតឱ្យមានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ និងកំពុងពិចារណាអំពីរបៀបដាក់បញ្ចូលនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទៅក្នុងកម្មវិធីកំណែទម្រង់តាមវិស័យដែលពាក់ព័ន្ធក្រសួង ស្ថាប័ននីមួយៗនោះ។

**ទី៣ :** ដំណើរការនៃកិច្ចពិភាក្សា និងការជួបប្រជុំជាបន្តបន្ទាប់ បានឈានទៅដល់ការឯកភាពគ្នាលើគោលការណ៍សំខាន់ៗមួយចំនួនទាក់ទងទៅនឹងដំណើរការ និងផលប៉ះពាល់របស់កំណែទម្រង់ ជាពិសេសទៅលើចំណុចនានាដែលពាក់ព័ន្ធទៅនឹងទំហំរបស់រាជរដ្ឋាភិបាល និងធនធានដែលមាន។ ឆ្លងតាមការពិភាក្សា ក្រសួង ស្ថាប័ននានា មានការយល់ឯកភាពគ្នាថា កំណែទម្រង់នេះនឹងមានផលប៉ះពាល់ទាំងទំនាក់ទំនងពីលើទៅក្រោម និងពីក្រោមឡើងលើ។ អាស្រ័យហេតុនេះ ប្រសិនបើការគ្រប់គ្រងដំណើរការកំណែទម្រង់នេះមិនបានល្អ នឹងបណ្តាលឱ្យមានការបង្កើនបន្ថែមនូវទំហំរបស់រាជរដ្ឋាភិបាល ដែលករណីនេះ កំណែទម្រង់នេះនឹងមិនអាចធ្វើឱ្យប្រសិទ្ធភាពការងារនៅថ្នាក់ក្រោមជាតិបានប្រសើរឡើងឡើយ។ ដូច្នេះ ចាំបាច់ដែលត្រូវរៀបចំឱ្យមានការគ្រប់គ្រងមួយយ៉ាងត្រឹមត្រូវនូវដំណើរការអនុវត្តកម្មវិធីជាតិ ដើម្បីធានាឱ្យបាននូវការប្រព្រឹត្តទៅរបស់រាជរដ្ឋាភិបាល និងកំណត់បាននូវទំហំរបស់រាជរដ្ឋាភិបាល ហើយត្រូវពន្យល់ដល់មន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យបានយល់ថា វិមជ្ឈការ និងវិសហមជ្ឈការ គឺជាការទាមទារឱ្យមានការផ្លាស់ប្តូរនូវទម្រង់នៃការគ្រប់គ្រង មិនមែនជាការពង្រីកនូវទំហំនៃការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលឱ្យធំជាងមុននោះឡើយ។

## ២. សង្ខេបអំពីកិច្ចពិភាក្សាទាំងប្រាំលើក

### ២.១. កិច្ចពិភាក្សាលើកទី១ ស្តីពីគោលដៅ និងយុទ្ធសាស្ត្ររួមនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨)

គោលបំណងរួមក្នុងកិច្ចពិភាក្សាលើកទី១ ផ្តោតទៅលើការពិភាក្សាស៊ីជម្រៅលើទស្សនៈ និងគោលបំណងរបស់ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ អ្នកចូលរួមមកពីក្រសួង ស្ថាប័នដែលជាសមាជិក

គ.ជ.វ.វ (បច្ចុប្បន្ន គ.ជ.អ.ប) ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត និងអ្នកអនុវត្តផ្ទាល់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់) បានធ្វើការពិភាក្សា ស្រាយបំភ្លឺ និងសម្រេចបាននូវការព្រមព្រៀងឯកភាពគ្នាទៅលើទស្សនវិស័យ និងគោលបំណងរួមនៃកម្មវិធីជាតិសម្រាប់រយៈពេល១០ឆ្នាំខាងមុខ។ លើសពីនេះទៀត កិច្ចពិភាក្សាក៏បានកំណត់ និងយល់ស្របចំពោះវិធីសាស្ត្រនានាសម្រាប់ដាក់ចេញនូវផែនការសកម្មភាព ដើម្បីរៀបចំកម្មវិធីជាតិតាមពេលវេលាកំណត់។

ការព្រមព្រៀងនានានៅក្នុងកិច្ចពិភាក្សាលើកទី១ រួមមាន :

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនឹងមានផលប៉ះពាល់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងទាមទារឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយកំណែទម្រង់សំខាន់ៗផ្សេងទៀតរបស់រាជរដ្ឋាភិបាល ដូចជា កម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទើបអាចសម្រេចគោលដៅរួមបាន។
- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវផ្អែកលើស្ថានភាពប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ សេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា និងត្រូវអនុវត្តដោយមានការប្រុងប្រយ័ត្ន តាមលំដាប់លំដោយជាជំហានៗ។
- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងផ្លាស់ប្ដូរតួនាទីថ្នាក់ជាតិឱ្យមកនៅត្រឹមការកំណត់ស្តង់ដារ គោលនយោបាយ និងការផ្ដល់ការតម្រង់ទិសដល់ថ្នាក់ក្រោមជាតិ ជាជាងការចុះអនុវត្តដោយខ្លួនឯងផ្ទាល់។
- ក្រសួង ស្ថាប័ននានា មានការយល់ដឹងអំពីវិមជ្ឈការ និងវិសហមជ្ឈការមិនដូចគ្នាទេ ដូចនេះទាមទារឱ្យមានការពិភាក្សាលើទស្សនាទាន និងអត្ថន័យនៃពាក្យទាំងពីរនេះជាបន្ថែមទៀត។
- ចាំបាច់ត្រូវធ្វើការពិភាក្សាបន្ថែមលើបញ្ហាធំៗចំនួន៤ទៀត រួមមាន :
  - រដ្ឋបាល និងអំណាច
  - ថវិកា និងហិរញ្ញវត្ថុ
  - បច្ចេកទេស និងសមត្ថភាព
  - ការគ្រប់គ្រងបុគ្គលិក

## ២.២. កិច្ចពិភាក្សាលើកទី២ ស្ដីពីការផ្ទេរមុខងារ និងការទទួលខុសត្រូវឱ្យទៅថ្នាក់ក្រោមជាតិ (ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨)

ក្នុងបរិបទនៃក្របខ័ណ្ឌយុទ្ធសាស្ត្រស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ កិច្ចពិភាក្សាលើកទី២បានផ្ដោតការពិភាក្សាលើការផ្ទេរមុខងារពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅឱ្យថ្នាក់ក្រោមជាតិ ដែលរួមមានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។

ការព្រមព្រៀងនានានៅក្នុងកិច្ចពិភាក្សាលើកទី២ រួមមាន :

- មុខងារត្រូវផ្ទេរដោយភ្ជាប់ជាមួយការទទួលខុសត្រូវ និងសិទ្ធិអំណាចសមស្របក្នុងការចាត់ចែងហិរញ្ញវត្ថុ រួមទាំងទ្រព្យសម្បត្តិ និងធនធានមនុស្ស។

- ជារួមមានការងារជាច្រើនដែលត្រូវបន្តធ្វើជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យមានការឯកភាព និង សម្រេចបាននូវការផ្ទេរមុខងារដែលមានអត្ថន័យពេញលេញ។
- គោលបំណងជាចម្បងនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជំរុញឱ្យមានការអភិវឌ្ឍតាម បែបប្រជាធិបតេយ្យ និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ។
- ក្រសួងមួយចំនួន រួមមានក្រសួងអប់រំ យុវជននិងកីឡា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងនីតិយុវសម្បទា ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល បានកំណត់នូវមុខងារដែលអាចជាបេក្ខភាពសម្រាប់ការផ្ទេរក្នុងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។

## ២.៣. កិច្ចពិភាក្សាលើកទី៣ ស្តីពីហិរញ្ញវត្ថុ និងថវិកាថ្នាក់ក្រោមជាតិ (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩)

កិច្ចពិភាក្សានេះត្រូវបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។ អ្នកចូលរួម ក្នុងកិច្ចពិភាក្សាលើកទី៣ រួមមានប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់រាជធានី ខេត្ត និងប្រធាន អនុប្រធាននាយកដ្ឋាន នានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ថែមលើចំនួនអ្នកដែលធ្លាប់ចូលរួមក្នុងកិច្ចពិភាក្សាមុនៗ បានធ្វើការពិភាក្សា លើការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ និងថវិកាថ្នាក់ក្រោមជាតិ។ បញ្ហាសំខាន់ៗដែលបានពិភាក្សា រួមមាន កម្រិតធនធាន ដែលមានសម្រាប់ធ្វើការផ្ទេរ ប្រភពចំណូល ពេលវេលា និងនីតិវិធីក្នុងការផ្ទេរ រួមមាននីតិវិធីក្នុងការរៀបចំ អនុវត្ត និងរាយការណ៍អំពីការអនុវត្តថវិកាប្រចាំឆ្នាំជាដើម។ ក្នុងការពិភាក្សា អ្នកចូលរួមបានកំណត់បញ្ហា និងបានឯកភាពគ្នា លើភាពចាំបាច់ក្នុងការបន្ស៊ីផែនការសកម្មភាព រវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ និងកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេល១០ឆ្នាំខាងមុខ។

ការព្រមព្រៀងនានាក្នុងកិច្ចពិភាក្សាលើកទី៣ រួមមាន :

- ថវិកា និងធនធានផ្សេងទៀត ត្រូវផ្ទេរតាមពីក្រោយការផ្ទេរមុខងារ។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ នឹងធ្វើការរួមគ្នាដើម្បីកែសម្រួលផែនការសកម្មភាព នៅក្នុងគោលបំណងទី២៧ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឆ្លុះបញ្ចាំង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់ និង កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- ក្រសួង ស្ថាប័នជំនាញដែលកំពុងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវគិតគូរ ដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដោយប្រើយន្តការក្រុមការងារកំណែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ។
- ថវិកាដែលមាននាពេលបច្ចុប្បន្ននៅថ្នាក់រាជធានី ខេត្ត នឹងត្រូវកែសម្រួលដើម្បីឱ្យសមស្របតាមស្មារតីនៃ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់។
- ត្រូវរៀបចំប្រព័ន្ធថវិកានៅថ្នាក់ក្រុង ស្រុក។

## ២.៤. កិច្ចពិភាក្សាលើកទី៤ ស្តីពីគណនេយ្យភាព ការពិនិត្យមើល និងការឆ្លើយតបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩)

គោលបំណងនៃកិច្ចពិភាក្សានេះ គឺដើម្បីកំណត់បានជាជំហាន១នូវការព្រមព្រៀងឯកភាពគ្នាទៅលើបញ្ហា និងវិធីសាស្ត្រនានាពាក់ព័ន្ធនឹងគណនេយ្យភាព ការពិនិត្យមើល និងការឆ្លើយតបនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ជាពិសេស ការពិភាក្សាបានផ្តោតលើខ្សែគណនេយ្យភាព ដែលរួមមានខ្សែបណ្តោយ (គណនេយ្យភាពមកថ្នាក់លើ) ខ្សែគណនេយ្យភាពផ្ទៃក្នុងរវាងក្រុមប្រឹក្សា និងគណៈអភិបាល និងបណ្តាអង្គភាពនានានៅថ្នាក់រដ្ឋបាលនីមួយ១ និងខ្សែគណនេយ្យភាពទៅក្រោម (គណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាជនក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលនីមួយ១) ស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់។ លើសពីនេះទៀត កិច្ចពិភាក្សាក៏បានលើកឡើងអំពីយន្តការចាំបាច់នានាដើម្បីធានាឱ្យមានគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ ដែលនឹងត្រូវអនុវត្តជាក់ស្តែងដើម្បីបង្កើននូវការឆ្លើយតបចំពោះប្រជាពលរដ្ឋ និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។

ការព្រមព្រៀងនានានៅក្នុងកិច្ចពិភាក្សាលើកទី៤ រួមមាន :

- ដើម្បីអាចឱ្យរដ្ឋបាលមួយមានគណនេយ្យភាពបាន លុះត្រាតែការទទួលខុសត្រូវ សិទ្ធិអំណាចក្នុងការចាត់ចែងហិរញ្ញវត្ថុ និងបុគ្គលិករបស់រដ្ឋបាលនោះ ត្រូវបានកំណត់ និងបញ្ជាក់ច្បាស់លាស់។ ក្នុងន័យនេះ ធនធាន រួមមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ចាំបាច់ត្រូវតែធ្វើការកែសម្រួលឡើងវិញ។
- រដ្ឋបាលថ្នាក់ក្រោមជាតិ មានគណនេយ្យភាពជាបឋមជាមួយប្រជាជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងជាមួយរាជរដ្ឋាភិបាល។
- គណនេយ្យភាព(ទៅក្រោម)ចំពោះអ្នកបោះឆ្នោត មានសារៈសំខាន់ណាស់ក្នុងការពង្រឹងសេចក្តីទុកចិត្តលើប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
- យោងតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា។
- យន្តការនានាដើម្បីធានាឱ្យមានការផ្តល់ព័ត៌មានជាសាធារណៈ (តាមរយៈការប្រជុំជាសាធារណៈ ក្តារព័ត៌មាន និងមធ្យោបាយដទៃទៀត) និងការប្រឹក្សាជាសាធារណៈ (តាមរយៈការប្រជុំជាសាធារណៈ វេទិកាពិភាក្សាជាសាធារណៈ និងដំណើរការធ្វើផែនការមានលក្ខណៈចូលរួម)។

## ២.៥. កិច្ចពិភាក្សាលើកទី៥ ស្តីពីការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩)

កិច្ចពិភាក្សាលើកទី៥ បានលើកឡើងពីបញ្ហានានាដែលពាក់ព័ន្ធក្នុងការធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានសមត្ថភាពក្នុងការអនុវត្តការទទួលខុសត្រូវ និងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

អ្នកចូលរួមបានផ្ដោតការពិភាក្សាទៅលើមុខងារស្ថាប័ន និងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសសង្កត់ធ្ងន់ទៅលើខ្សែគណនេយ្យភាពផ្ទៃក្នុងរវាងបណ្ដាអង្គភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ជាមួយនឹងគណៈអភិបាល និងក្រុមប្រឹក្សា) ខ្សែគណនេយ្យភាព(ទទឹង)ជាមួយបណ្ដាមន្ទីរ ស្ថាប័នជំនាញ និងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយក្រុមប្រឹក្សាស្រុក ខណ្ឌ ក្រុង ខេត្ត និងរាជធានី។ កិច្ចពិភាក្សាក៏បានពិចារណាលើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ និងការផ្ទេរមន្ត្រី បុគ្គលិក និងបញ្ហាទូទៅពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស។

ការព្រមព្រៀងនានានៅក្នុងកិច្ចពិភាក្សាលើកទី៥ រួមមាន :

- ត្រូវកំណត់អំពីតួនាទី ការទទួលខុសត្រូវ នីតិវិធី និងទំនាក់ទំនងធ្វើការងាររបស់ក្រុមប្រឹក្សា គណៈអភិបាល គណៈកម្មាធិការនានា និងអង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានច្បាស់លាស់ មុននឹងផ្ទេរនូវមុខងារ ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងទ្រព្យសម្បត្តិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
- រចនាសម្ព័ន្ធនៃរដ្ឋបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវឆ្លើយតបទៅនឹងគោលដៅ និងតួនាទីរបស់រដ្ឋបាលថ្នាក់នោះ។
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ នឹងធ្វើការរួមគ្នាដើម្បីបង្កើតក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- បង្កើតប្រព័ន្ធគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយយោងតាមគោលការណ៍ច្បាប់រួមមួយសម្រាប់ទូទាំងប្រទេស (ច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា) ដោយមិនបង្កើតប្រព័ន្ធគ្រប់គ្រងមួយដាច់ដោយឡែកនោះឡើយ។
- ចាំបាច់ត្រូវបង្កើតឱ្យមានយន្តការសម្រាប់ផ្ដល់សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ចាំបាច់ត្រូវបង្កើតបទបញ្ជាផ្ទៃក្នុង និងនីតិវិធីអភិបាលកិច្ច ដែលបង្ហាញពីទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល។
- មន្ត្រី បុគ្គលិករបស់ក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យខ្សែបណ្ដោយរបស់ក្រសួង ស្ថាប័ន នឹងត្រូវដាក់ពង្រាយឡើងវិញទៅតាមការផ្ទេរមុខងារ។ ក្នុងករណីដែលមុខងារត្រូវបានប្រគល់ឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកបម្រើការក្នុងមុខងារនោះត្រូវក្លាយជាបុគ្គលិករបស់ក្រុមប្រឹក្សា។
- ធានាមិនឱ្យចំនួនមន្ត្រី បុគ្គលិកធ្វើការនៅថ្នាក់ក្រោមជាតិកើនឡើង (មិនសមស្រប)។

# ឧបសម្ព័ន្ធទី២

# ការបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ឧបសម្ព័ន្ធទី២
# ការបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩) បានគូសបញ្ជាក់យ៉ាងច្បាស់ថា ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនឹងអាចដំណើរការកាន់តែមានប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាព លុះត្រាតែមានការយកចិត្តទុកដាក់ដោះស្រាយបញ្ហាវិសមភាពយេនឌ័រ។ លើសពីនេះទៀត កម្មវិធីជាតិបានទទួលស្គាល់នូវសារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រ ជាប្រធានបទអន្តរវិស័យ ដែលចាំបាច់ត្រូវអនុវត្តនៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ ដើម្បីពង្រឹងអភិបាលកិច្ច លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ឯកសារនេះនឹងអធិប្បាយអំពីក្របខ័ណ្ឌគតិយុត្ត យន្តការ និងការបញ្ជ្រាបយេនឌ័រនៅក្នុងការអនុវត្តកម្មវិធីជាតិ។

## ១. ក្របខ័ណ្ឌគតិយុត្ត និងយន្តការនានា

### ១.១. ក្របខ័ណ្ឌគតិយុត្ត

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈការអនុម័តលើសេចក្តីថ្លែងការណ៍ និងអនុសញ្ញាអន្តរជាតិនានា ហើយបានបញ្ចូលនូវគោលការណ៍ទាំងនេះទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ដែលមានជាអាទិ៍ :

***រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*** ទទួលស្គាល់ទាំងស្រុងនូវសិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស រួមមានសិទ្ធិមនុស្ស សមភាពចំពោះមុខច្បាប់ ការលុបបំបាត់រាល់ទម្រង់នៃការរើសអើង និងការធានានូវសិទ្ធិក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌នៃប្រទេសជាតិ ។

***យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាលកម្ពុជា*** ទទួលស្គាល់នូវការលើកកម្ពស់សមភាពនិងសមធម៌យេនឌ័រ ជាសមាសធាតុគន្លឹះនៃយុទ្ធសាស្ត្រនេះ។ ស្ត្រីត្រូវបានទទួលស្គាល់ថាជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ហើយយុទ្ធសាស្ត្រនេះកំណត់ថា ស្ត្រីទាំងអស់មានសិទ្ធិទទួលបានដោយស្មើភាពនូវសេវាថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលជំនាញ ការទទួលបានធនធាន និងចូលរួមសកម្មភាពសេដ្ឋកិច្ច និងតួនាទីធ្វើសេចក្តីសម្រេចនៅគ្រប់ថ្នាក់និងគ្រប់វិស័យ។ សមភាពយេនឌ័រ ត្រូវបានទទួលស្គាល់ថា ជាធាតុដ៏ចាំបាច់មួយនៅក្នុងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល រួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងយុត្តិធម៌ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

***ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ*** ដែលបានអនុម័តនៅឆ្នាំ២០០៥ កំណត់នូវគោលនយោបាយ និងគោលការណ៍សំខាន់៧សម្រាប់ណែនាំកំណែទម្រង់រដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងពង្រឹងកំណែទម្រង់ដែលមានស្រាប់នៅរដ្ឋបាលឃុំ សង្កាត់ អនុលោមតាមការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះធានាថា "កំណែទម្រង់នឹងនាំមកនូវ

ប្រព័ន្ធនិងនីតិវិធីចាំបាច់នានា ព្រមទាំងធានាថាប្រជាពលរដ្ឋ ជាពិសេសស្ត្រី ក្រុមជនងាយរងគ្រោះ និងជនជាតិភាគតិច អាចចូលរួមនៅក្នុងការសម្រេចចិត្តនៅថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់"។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះក៏បានចែងថា "ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវបានបង្កើតឡើងដោយការបោះឆ្នោតអសកល ហើយធានាឱ្យមានតំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សានៃរដ្ឋបាលទាំងនេះ"។

**ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** បានផ្តល់នូវសមភាពយេនឌ័រក្នុងការចូលរួមដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ។ ច្បាប់នេះបានបញ្ចូលនូវបញ្ញត្តិជាច្រើនដែលទាក់ទងនឹងសមភាពយេនឌ័រ ដោយឆ្លើយតបនឹងបញ្ហាសមភាពយេនឌ័រក្នុងការតែងតាំង ការគ្រប់គ្រងបុគ្គលិក និងការធ្វើផែនការថវិកានៅគ្រប់ថ្នាក់ ព្រមទាំងបញ្ញត្តិសម្រាប់ការរៀបចំរបៀបវារៈ និងការប្រឹក្សាយោបល់អំពីសិទ្ធិស្ត្រី និងបញ្ហាសមភាពយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ នឹងត្រូវបានបង្កើតឡើងនៅក្រោមក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំ ហើយទន្ទឹមនឹងនេះ ក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពក៏ត្រូវបានរៀបចំឡើងផងដែរ ដើម្បីគាំទ្រដល់គណៈកម្មាធិការដែលទើបនឹងបង្កើតថ្មីនេះ ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាព។

**នារីរតនៈទី៣ :** ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៩-២០១៣ របស់ក្រសួងកិច្ចការនារី បានចែងអំពីសមាសធាតុយុទ្ធសាស្ត្រគន្លឹះ ដូចជាការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ច និងការធ្វើសេចក្តីសម្រេចជាដើម។ កម្មវិធីបញ្ជ្រាបយេនឌ័រផ្តោតការយកចិត្តទុកដាក់ទៅលើគោលនយោបាយជាតិ គោលនយោបាយតាមវិស័យ ដូចជាការបង្កើតនិងតាមដានការអនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ និងកម្មវិធីកំណែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាល ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការជាដើម។

## ១.២. យន្តការនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ក្រសួងកិច្ចការនារីជាយន្តការថ្នាក់ជាតិមួយដើម្បីលើកកម្ពស់ស្ថានភាព តួនាទី និងឋានៈរបស់ស្ត្រីកម្ពុជា ហើយដើរតួជាកាតាលីករ ជាអ្នកសម្របសម្រួលនិងស្វែងរកការគាំទ្រមតិក្នុងការលើកទឹកចិត្តស្ថាប័នរដ្ឋ សង្គមស៊ីវិល និងវិស័យឯកជនឱ្យចូលរួមលើកកម្ពស់សមភាពយេនឌ័រតាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ខ្លួន ព្រមទាំងធ្វើការតាមដាន និងវាយតម្លៃលើអនុវត្តគោលនយោបាយនិងកម្មវិធីទាំងនោះ។ ក្រសួងកិច្ចការនារី គឺជាសមាជិកនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) និងជាសមាជិកអនុគណៈកម្មាធិការរបស់ គ.ជ.អ.ប ដែលនាំមុខលើការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ទន្ទឹមនឹងនេះ ក្រសួង និងស្ថាប័នជាតិសំខាន់ៗមួយចំនួន បានបង្កើតក្រុមការងារ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ហើយក្រសួង ស្ថាប័នទាំងនោះ ក៏ជាសមាជិករបស់ គ.ជ.អ.ប ផងដែរ។

អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃបានបង្កើតនូវ**យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ខ្លួន** ដែលមានចក្ខុវិស័យជាយុទ្ធសាស្ត្រ គឺប្រជាពលរដ្ឋនិងមន្ត្រីទាំងបុរសនិងស្ត្រី ចូលរួមដោយស្មើភាពនៅក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ស្ត្រីនិងបុរសទទួលបានផលប្រយោជន៍ដោយស្មើគ្នាពីគោលនយោបាយ សេចក្តីសម្រេចកម្មវិធី និងការផ្តល់សេវានៅថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត នាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃបានបង្កើតក្រុមការងារយេនឌ័រមួយ សម្រាប់សម្របសម្រួល និងតាមដានការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះដើម្បីធានាសម្រេចបាននូវគោលដៅ និងផ្តល់អនុសាសន៍ដើម្បីកែលម្អ។

នៅថ្នាក់ក្រោមជាតិ មន្ទីរកិច្ចការនារីរាជធានី ខេត្ត ដែលជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិ និងគណៈកម្មាធិការអភិវឌ្ឍន៍រាជធានី ខេត្ត មានភារកិច្ចគាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅរាជធានី ខេត្ត។ ក្រុមការងារបញ្ជ្រាបយេនឌ័រ និងមន្ត្រីបង្គោលយេនឌ័រត្រូវបានតែងតាំងនៅក្នុងមន្ទីរ អង្គភាពជំនាញនៅរាជធានី ខេត្ត។

**គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ** នឹងត្រូវបង្កើតឡើងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ គណៈកម្មាធិការនេះមានតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងទំនាក់ទំនង និងការកសាងទំនុកចិត្តរវាងសហគមន៍ជាមួយក្រុមប្រឹក្សានានា និងរវាងក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការលើកឡើងនូវតម្រូវការនិងបញ្ហានានារបស់ស្ត្រី និងកុមារ។

**គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់** បានបង្កើតឡើងនៅឆ្នាំ២០០៧។ គណៈកម្មាធិការនេះជួយពាំនាំ និងបញ្ចូលនូវបញ្ហានានាទាក់ទងនឹងស្ត្រី និងកុមារទៅក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ និងជួយគាំទ្រដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

## ២. ការបញ្ជ្រាបយេនឌ័រនៅក្នុងការអនុវត្តកម្មវិធីជាតិ

ការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីជាតិ នឹងប្រើប្រាស់វិធីសាស្ត្រដែលមានលក្ខណៈទូលាយគ្រប់ជ្រុងជ្រោយដើម្បីពង្រឹងស្ថាប័ន និងអង្គការចាត់តាំងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កើនការចូលរួមរបស់ស្ត្រី ព្រមទាំងការជំរុញនិងគាំទ្រដល់ស្ត្រីនិងបុរសឱ្យក្លាយជាតួអង្គនយោបាយដោយស្របច្បាប់ និងស្មើភាព។ ក្នុងន័យនេះ ត្រូវធានានូវតុល្យភាពយេនឌ័រនៅក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានគោលនយោបាយសម្រាប់គ្រប់គ្រងរដ្ឋបាល និងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ដែលមានការយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ និងមានផលប្រយោជន៍សម្រាប់ស្ត្រី ទទួលស្គាល់និងអនុវត្តនូវសិទ្ធិរបស់ស្ត្រីឱ្យទទួលបាននូវសមភាពយេនឌ័រ។ អភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ ត្រូវមានសមភាពយេនឌ័រ និងយុត្តិធម៌សង្គមជាមូលដ្ឋានដែលក្នុងនោះទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលស្គាល់សេចក្តីត្រូវការខុសគ្នារវាងស្ត្រីនិងបុរស និងធ្វើកិច្ចការយ៉ាងសកម្មដើម្បីដោះស្រាយនូវបញ្ហាវិសមភាពយេនឌ័រ ដែលមាននៅក្នុងមូលដ្ឋាន និងសហគមន៍ផ្ទាល់របស់ខ្លួន។

ដើម្បីធានាថាបញ្ហាយេនឌ័រត្រូវបានដោះស្រាយ ចាំបាច់ត្រូវផ្តោតការបញ្ជ្រាបយេនឌ័រជាលក្ខណៈអន្តរវិស័យដោយបញ្ចូលគោលការណ៍សមភាព និងសមធម៌យេនឌ័រទៅក្នុងកម្មវិធីជាតិទាំងមូល។ កិច្ចការនេះអាចសម្រេចបានតាមរយៈការផ្លាស់ប្តូររបៀបធ្វើការងារ និងទំនាក់ទំនងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងកម្រិតបុគ្គល កម្រិតអង្គការចាត់តាំង និងកម្រិតស្ថាប័ន។

- **កម្រិតបុគ្គល :**
  - ការបង្កឱកាស និងបង្កើនភាពអង់អាចដល់ប្រជាពលរដ្ឋជាស្ត្រីមានលទ្ធភាពអនុវត្តនូវសិទ្ធិ និងចូលរួមពេញលេញនៅក្នុងដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
  - ការបង្កើនភាពអង់អាចដល់មន្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាស្ត្រី ដើម្បីចូលរួម និងបង្កើនការឆ្លើយតបនឹងតម្រូវការ និងអាទិភាពយេនឌ័រក្នុងដំណើរការអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
  - ការបង្កើនការយល់ដឹង និងការគាំទ្ររបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិជាបុរសអំពីសមភាពយេនឌ័រ ដោយបញ្ចូលនូវការយកចិត្តទុកដាក់យេនឌ័រ ទៅក្នុងការអនុវត្តការងាររបស់ខ្លួន។
- **កម្រិតអង្គការចាត់តាំង :**
  - ការពង្រឹងសមត្ថភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបញ្ជ្រាបយេនឌ័រពាក់ព័ន្ធទៅនឹងគោលនយោបាយ ការអនុវត្ត និងធនធាន) និង
  - ការពង្រឹងរបៀបរបបក្នុងការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- **កម្រិតស្ថាប័ន :**
  - ការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ និងសង្គមស៊ីវិលក្នុងការផ្លាស់ប្តូរឥរិយាបថ ទម្លាប់ និងការប្រព្រឹត្តជាអវិជ្ជមានដែលរារាំងដល់ការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ច។

## ២.១. វិធីសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ

កម្មវិធីជាតិបានផ្តល់នូវចំណុចចាប់ផ្តើម និងកាលានុវត្តភាព ដែលបានកំណត់នៅក្នុងសមាសធាតុកម្មវិធីទាំងប្រាំសំដៅបង្កើនឱកាសនិងភាពអង់អាចដល់ស្ត្រី និងធានាថាសេវាទាំងអស់ដែលជាតម្រូវការរបស់ស្ត្រីត្រូវបានឆ្លើយតប។ សកម្មភាពនានាដែលបានលើកឡើងនៅក្នុងសមាសធាតុកម្មវិធីនៃកម្មវិធីជាតិ នឹងបង្កើនលទ្ធភាពដល់ស្ត្រី យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិចក្នុងការទទួលបាននូវសេវាសាធារណៈ ព្រមទាំងបង្កើនការគ្រប់គ្រងធនធានអភិវឌ្ឍន៍សម្រាប់លើកកម្ពស់ជីវភាពរស់នៅ។

### ២.១.១. ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ

ការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីនេះ នឹងផ្តោតសំខាន់ទៅលើការរៀបចំ និងបញ្ចូលនូវស្តង់ដារសមភាព និងសមធម៌យេនឌ័រនៅក្នុងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កើនការគិតគូរអំពីយេនឌ័រនៅក្នុងស្ថាប័ន និងដំណើរការអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ក). ក្របខ័ណ្ឌគោលនយោបាយ**

- បង្កើត និងបញ្ចូលបញ្ញត្តិនានាដែលបានមកពីបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិពាក់ព័ន្ធបញ្ហាយេនឌ័រ (ឧទាហរណ៍ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ផែនការយុទ្ធសាស្ត្រនារីរតនៈ និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ) ទៅក្នុងការបង្កើតស្ថាប័ន និងអង្គការចាត់តាំងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

- បញ្ចូលគោលការណ៍នៃការលើកកម្ពស់សិទ្ធិស្ត្រី (ដែលមាននៅក្នុងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ) ជាចំណុចសំខាន់នៃការតាក់តែងគោលនយោបាយ និងការផ្តល់សេវាសាធារណៈ ។
- បង្កើតនីតិវិធី និងគោលនយោបាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការដោះស្រាយនូវរាល់ទម្រង់នៃការរើសអើងនានានៅក្នុងកិច្ចដំណើរការប្រតិបត្តិការ និងស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះ ។
- បង្កើតកម្មវិធី និងគោលនយោបាយដោយផ្អែកលើព័ត៌មាន និងទិន្នន័យដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ព្រមទាំងធានាឱ្យមានធនធានសម្រាប់អនុវត្តកម្មវិធី និងគោលនយោបាយទាំងនោះ ។
- បង្កើតឱ្យមានដំណើរការ និងនីតិវិធីនៃការតាក់តែងគោលនយោបាយ ដែលធានាឱ្យមានការចូលរួមដោយស្មើភាពពីអ្នកពាក់ព័ន្ធទាំងស្ត្រី និងបុរស ។
- អនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ ដោយមានការចូលរួម និងកិច្ចសហការពីក្រុមការងារបញ្ជ្រាបយេនឌ័រ (ក្រសួងមហាផ្ទៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ល ។)

**ខ). ការធានាឱ្យមានតំណាងរបស់ស្ត្រី និងក្រុមតំណាងផលប្រយោជន៍ប្រជាពលរដ្ឋ នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- រៀបចំដំណើរការនៃការតាក់តែងគោលនយោបាយឆ្លើយតបនឹងបញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិ តាមរយៈការធានា និងផ្តល់លទ្ធភាពក្នុងការចូលរួមរបស់បុរស និងស្ត្រីនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- បញ្ចូលគោលការណ៍សម្រាប់ការកសាងផែនការ និងការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ នៅរាល់លិខិតបទដ្ឋាន និងសេចក្តីណែនាំទាំងអស់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការគាំទ្រផ្នែកការអភិវឌ្ឍសមត្ថភាព និងបច្ចេកទេស ។

**គ). កិច្ចដំណើរការពិនិត្យមើលឡើងវិញ**

- បង្កើតសេចក្តីណែនាំសម្រាប់ធ្វើសវនកម្មយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់អំពីការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ ការអនុវត្ត និងការផ្តល់សេវាសាធារណៈនានាក្នុងការលើកកម្ពស់សមភាព និងសមធមិយេនឌ័រ ។
- ធ្វើសវនកម្មយេនឌ័រជាទៀងទាត់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់អំពីវឌ្ឍនភាព និងបញ្ហានានា ព្រមទាំងធ្វើការកែលម្អស្ថានភាពសមភាពយេនឌ័ររបស់ស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងនៅក្នុងការផ្តល់សេវាសាធារណៈ និងនៅក្នុងអង្គការចាត់តាំងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

### ២.១.២. ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីនេះនឹងបញ្ចូលគោលការណ៍សមភាព និងសមធម៌យេនឌ័រនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

#### ក). គោលនយោបាយស្តីពីឱកាសស្មើភាព

- បង្កើតគោលនយោបាយនិងនីតិវិធីស្តីពីការគ្រប់គ្រងធនធានមនុស្ស ដែលមានបញ្ចូលនូវបញ្ញត្តិនានា ទាក់ទងនឹងសមភាព និងសមធម៌យេនឌ័រ ដើម្បីធានា និងផ្តល់ឱកាសស្មើភាពដល់ស្ត្រីក្នុងការទទួលបានការងារ និងមុខតំណែងដែលមានសិទ្ធិអំណាចនៅក្នុងស្ថាប័ន ។ល ។
- បង្កើតគោលនយោបាយ និងប្រព័ន្ធលើកទឹកចិត្តសម្រាប់ការគ្រប់គ្រងធនធានមនុស្ស ដែលធានាថា បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិគោរពតាមគោលការណ៍សមភាព និងសមធម៌យេនឌ័រ ។
- បង្កើតគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗ ដែលបង្កឱ្យមានសមភាព និងសមធម៌យេនឌ័រនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងគោលនយោបាយស្តីពីឱកាសស្មើគ្នានៅគ្រប់អង្គការចាត់តាំងទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

#### ខ). គោលនយោបាយស្តីពីធនធានមនុស្ស

- បង្កើតគោលនយោបាយដែលកំណត់អំពីមុខងារ ការទទួលខុសត្រូវ និងគណនេយ្យភាពសម្រាប់សកម្មភាពបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- សិក្សាវាយតម្លៃ និងរៀបចំទិន្នន័យគោលអំពីយេនឌ័រនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបែងចែកទិន្នន័យទៅតាមភេទនៃបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត (អ្នកគ្រប់គ្រងជាន់ខ្ពស់ អ្នកគ្រប់គ្រងកណ្តាល បុគ្គលិកបច្ចេកទេស និងបុគ្គលិកបម្រើសេវាគាំទ្រ) ។
- រៀបចំវិធានការចាំបាច់នានា ដើម្បីជំរុញការចូលរួមរបស់ស្ត្រីនៅក្នុងអភិបាលកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត (ឧទាហរណ៍ ការរៀបចំមានប្រព័ន្ធកូតា វិធានការលើកទឹកចិត្ត ធនធានហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងបង្កើនភាពអង់អាច) ។

#### គ). ប្រព័ន្ធលើកទឹកចិត្តដើម្បីលើកកម្ពស់សមភាពយេនឌ័រ

- ពង្រឹងយន្តការ និងបណ្តាញសម្រាប់គាំទ្រការបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ មន្ទីរកិច្ចការនារី និងក្រុមការងារយេនឌ័រនៅតាមមន្ទីរ អង្គភាពពាក់ព័ន្ធ) តាមរយៈការបណ្តុះបណ្តាល និងការផ្តល់ធនធានសមស្របសម្រាប់បំពេញតួនាទីក្នុងការជំរុញការអនុវត្ត និងតាមដានការបញ្ជ្រាបយេនឌ័ររបស់ស្ថាប័ន ។
- កំណត់អំពីការលើកទឹកចិត្តដល់បុគ្គលដែលបានបំពេញការងារទាក់ទងនឹងសមភាពយេនឌ័រ (វាយតម្លៃទៅលើការបំពេញការងារបុគ្គលិកក្នុងការលើកកម្ពស់សមភាពយេនឌ័រ ផ្តល់រង្វាន់ដល់អ្នកមានស្នាដៃទាំងស្ត្រី និងបុរសក្នុងការគាំទ្រការងារយេនឌ័រ ។ល ។) ។

- បង្កើតបរិយាកាសការងារដែលអំណោយផលដល់ស្ត្រី និងបុរសក្នុងការបំពេញភារកិច្ច (ពេលវេលាធ្វើការងារដែលអាចបត់បែនបាន និងការឧបត្ថម្ភសម្រាប់ការថែទាំកូនជាដើម) ដើម្បីផ្តល់លទ្ធភាពដល់ស្ត្រីក្នុងការបំពេញតួនាទី និងកាត់បន្ថយកម្រិតអវត្តមានពីការងារ ។

### ឃ). ការអភិវឌ្ឍសមត្ថភាព

- រៀបចំកម្មវិធី និងឯកសារបណ្តុះបណ្តាលរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបញ្ចូលគោលឃោបាយសមភាព និងសមធម៌យេនឌ័រ ។
- បណ្តុះបណ្តាលដល់យន្តការ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ ដើម្បីបំពេញតួនាទីប្រកបដោយប្រសិទ្ធភាព ។
- បណ្តុះបណ្តាលបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីគោលនយោបាយ និងគោលការណ៍សមភាពនិងសមធម៌យេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី ។

## ២.១.៣. ការផ្ទេរមុខងារ

ការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីនេះនឹងកំណត់អំពីមុខងារ និងការទទួលខុសត្រូវដែលពាក់ព័ន្ធដើម្បីសម្របសម្រួល និងធ្វើឱ្យមានសង្គតិភាពនូវសកម្មភាពបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- រៀបចំលិខិតបទដ្ឋានចាំបាច់នានាសម្រាប់គាំទ្រគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដូចជាប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ។ ប្រកាសនេះក៏នឹងកំណត់ផងដែរអំពីតួនាទី ភារកិច្ច ការទទួលខុសត្រូវ ខ្សែគណនេយ្យភាព និងនីតិវិធីនានាសម្រាប់ធានា និងពង្រឹងការផ្តល់យោបល់របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- បង្កើតនីតិវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំគោលនយោបាយ ដែលគិតគូរ និងឆ្លើយតបនឹងបញ្ហាយេនឌ័រ ដោយធានាបាននូវតុល្យភាពរវាងស្ត្រីនិងបុរសនៅក្នុងដំណើរការពិភាក្សា ។
- កំណត់ និងផ្ទេរមុខងារដែលឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ស្ត្រី កុមារ និងក្រុមជនងាយរងគ្រោះនានា ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ពង្រឹងទំនាក់ទំនងនិងការសម្របសម្រួលខ្សែទទឹងនៃអន្តររដ្ឋបាល និងលើកកម្ពស់គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។
- តាមដានការអនុវត្តគោលនយោបាយ និងគោលការណ៍សមភាពនិងសមធម៌យេនឌ័រ ក្នុងការផ្ទេរមន្ត្រីបុគ្គលិកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ២.១.៤. ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីនេះនឹងធានាថាតម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរស ដែលមានលក្ខណៈផ្សេងគ្នា ត្រូវបានគិតគូរ និងឆ្លើយតបនៅក្នុងការរៀបចំផែនការហិរញ្ញវត្ថុ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះ ត្រូវមានថវិកាសមស្របសម្រាប់ការកសាងសមត្ថភាពបុគ្គលិក និងក្រុមការងារដែលទទួលបន្ទុកយេនឌ័រ ព្រមទាំងការផ្តួចផ្តើមនានាទាក់ទងនឹងសមភាពយេនឌ័រនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្តល់សេវាសាធារណៈ។ លើសពីនេះទៀត ចាំបាច់ត្រូវមានការវិភាគដោយផ្អែកលើទស្សនទានយេនឌ័រអំពីផលប៉ះពាល់ជារួមនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ។

- រៀបចំនីតិវិធីសម្រាប់ការរៀបចំថវិកា និងការផ្តល់សេវាសមស្រប (ឧទាហរណ៍ បង្កើតឱ្យមានប្រព័ន្ធតាមដានសម្រាប់វាយតម្លៃអំពីភាពជោគជ័យក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើតឱ្យមានយន្តការត្រួតពិនិត្យការប្រើប្រាស់ថវិកាដោយប្រជាពលរដ្ឋ ជាពិសេសពីក្រុមប្រជាពលរដ្ឋក្រីក្រទាំងស្ត្រី និងបុរស)។
- បង្កើត និងអនុវត្តគោលនយោបាយសារពើពន្ធ នីតិវិធី និងសេចក្តីណែនាំស្តីពីការរៀបចំថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលឆ្លើយតបនឹងយេនឌ័រ ផ្អែកតាមមេរៀនបទពិសោធន៍ក្នុងការរៀបចំថវិកាដែលឆ្លើយតបនឹងយេនឌ័រនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ផ្សារភ្ជាប់ការផ្ទេរសារពើពន្ធ និងការវិភាជន៍ថវិកាជាមួយនឹងសូចនាករសមភាពយេនឌ័រ ការកាត់បន្ថយភាពក្រីក្រ និងសូចនាករផ្សេងៗទៀត ដើម្បីធានាថាការចំណាយនឹងផ្តល់ផលប្រយោជន៍ដល់ស្ត្រី និងក្រុមជនងាយរងគ្រោះ។
- ផ្តល់ធនធានដល់យន្តការ និងបណ្តាញការងារលើកកម្ពស់សមភាពយេនឌ័រ ដើម្បីបំពេញតួនាទីក្នុងការបញ្ជ្រាបយេនឌ័រ។
- ផ្តល់ថវិកាដល់កម្មវិធីដែលផ្តោតការយកចិត្តទុកដាក់លើបញ្ហាជាក់លាក់របស់ស្ត្រី និងការបញ្ជ្រាបយេនឌ័រ។

## ២.១.៥. ស្ថាប័នគាំទ្រកំណែទម្រង់និមជ្ឈការ និងវិសហមជ្ឈការ

ការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធីនេះ នឹងធានាដល់ការកសាងមូលដ្ឋានដ៏ទូលំទូលាយសម្រាប់ការយល់ដឹងអំពីគោលការណ៍សមភាពយេនឌ័រ ការដោះស្រាយបញ្ហាប្រឈមនានាទាក់ទងនឹងវិសមភាពយេនឌ័រនៅក្នុងសហគមន៍ និងការលើកកម្ពស់សិទ្ធិរបស់ស្ត្រី។ រដ្ឋបាលថ្នាក់ក្រោមជាតិនឹង ៖

- រៀបចំកម្មវិធីបណ្តុះបណ្តាលអំពីសមភាពយេនឌ័រសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ឯកសារបណ្តុះបណ្តាលរបស់ក្រសួងកិច្ចការនារីដែលមានបច្ចុប្បន្ន (ឧទាហរណ៍ ឯកសារការបណ្តុះបណ្តាលស្តីពីយេនឌ័រនិងការវិភាគយេនឌ័រ ការស្វែងរកការគាំទ្រមតិនិងតាមដានអាទិភាពយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ យេនឌ័រនិងអភិបាលកិច្ចនៅកម្ពុជាជាដើម)។

- រៀបចំកម្មវិធីដើម្បីបង្កើតបរិយាកាសក្នុងការលើកកម្ពស់សមភាពយេនឌ័រ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការអភិវឌ្ឍចំណេះដឹង ជំនាញ និងអាកប្បកិរិយា (ឧទាហរណ៍ ធ្វើការជំរុញឱ្យមានការគាំទ្រផ្នែកនយោបាយ និងបង្កើតឱ្យមានទម្លាប់និងវប្បធម៌ក្នុងការអនុវត្តការងារប្រចាំថ្ងៃដែលឆ្លើយតបនឹងយេនឌ័រ)។
- ធ្វើការងារជាមួយសហគមន៍ និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនការយល់ដឹងអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសម្រាប់ប្រជាពលរដ្ឋទូទៅ ទាំងស្ត្រី និងបុរស ដោយបង្កលក្ខណៈឱ្យប្រជាពលរដ្ឋទាំងពីរភេទមានលទ្ធភាពចូលរួមក្នុងដំណើរការអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ ការចូលរួមនៅក្នុងការប្រជុំពិគ្រោះយោបល់សហគមន៍ ការរៀបចំឱ្យមានយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ និងការបង្កលក្ខណៈដល់ប្រជាពលរដ្ឋទាំងពីរភេទអាចចូលរួមអនុវត្តសកម្មភាពអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ)។
- រៀបចំយុទ្ធនាការ និងធ្វើការងារយ៉ាងសកម្មជាមួយសហគមន៍ ដើម្បីឈានទៅដល់ការសម្រេចឱ្យបាននូវការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ដែលមាននៅក្នុងតួនាទី និងទម្លាប់នៃការគ្រប់គ្រង។
- លើកកម្ពស់តំណាងរបស់ស្ត្រីនៅក្នុងសកម្មភាពអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្តជាអវិជ្ជមានមកលើស្ត្រី (ឧទាហរណ៍ ការលុបបំបាត់នូវផ្នត់គំនិតដែលថា ស្ត្រីមិនអាច ឬមិនគួរចូលរួមនៅក្នុងអភិបាលកិច្ចមូលដ្ឋាន)។
- លើកទឹកចិត្តដល់អ្នកមានស្នាដៃក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ។
- បង្កើតសមាគម ឬបណ្តាញមន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាស្ត្រី ដើម្បីជួយគាំទ្រគ្នាទៅវិញទៅមក (ឧទាហរណ៍ បណ្តាញសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី) និងជួយអភិវឌ្ឍសមត្ថភាពដល់សមាគម ឬបណ្តាញទាំងនេះក្នុងការតាមដាន និងចូលរួមរៀបចំគោលនយោបាយដែលយកចិត្តទុកដាក់យេនឌ័រ។
- កំណត់អំពីធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីបង្កើតនិងអនុវត្តគោលនយោបាយនានាដែលយកចិត្តទុកដាក់យេនឌ័រ (ឧទាហរណ៍ ការចូលរួមក្នុងវិស័យអប់រំ សុខភាព និងកិច្ចការនយោបាយជាដើម)។

## ២.២. ការកសាងសមត្ថភាព

ដើម្បីសម្រេចបាននូវការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសធាតុកម្មវិធី៥ ដូចបានអធិប្បាយខាងលើ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់ដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងមន្ត្រី បុគ្គលិកទាំងពីរភេទ ជាពិសេសស្ត្រី។ ដូច្នេះផែនការអភិវឌ្ឍន៍សមត្ថភាពដែលនឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងពេលអនុវត្តកម្មវិធីជាតិ ត្រូវកំណត់អំពីតម្រូវការនៃការគាំទ្រចាំបាច់ ដើម្បីធានាឱ្យស្ត្រីមានជំនាញគ្រប់គ្រាន់ ដែលអាចធ្វើឱ្យសំឡេងរបស់ខ្លួន ជ្រាបចូលនៅក្នុងដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

# ឧបសម្ព័ន្ធទី៣

# គណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

# ឧបសម្ព័ន្ធទី៣
# គណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩) នឹងធ្វើឱ្យមានការផ្លាស់ប្តូរពីការគ្រប់គ្រងបែបមជ្ឈការ ទៅកាន់ការគ្រប់គ្រងបែបវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីពង្រឹងអភិបាលកិច្ចនិងស្វ័យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ការផ្លាស់ប្តូរនេះនឹងមានផលប៉ះពាល់ដល់ខ្សែគណនេយ្យភាពនៃស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អាស្រ័យហេតុនេះ កម្មវិធីជាតិបានកំណត់យកការពង្រឹងខ្សែគណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាប្រធានបទអន្តរវិស័យ ដែលទាមទារឱ្យមានការសិក្សាលើមូលដ្ឋានច្បាប់រៀបចំអង្គការនានាជាធរមាន ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត យន្តការ និងសកម្មភាពនានានៅគ្រប់សមាសធាតុកម្មវិធីទាំងប្រាំនៃកម្មវិធីជាតិ។

## ១. មូលដ្ឋានច្បាប់ក្នុងការជំរុញគណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

បទប្បញ្ញត្តិនានាទាក់ទងនឹងគណនេយ្យភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ទោះបីជាយ៉ាងដូច្នេះក្តី ក្នុងការអនុវត្តនូវបទប្បញ្ញត្តិនានានៃច្បាប់ខាងលើនេះ ទាមទារឱ្យមានការបង្កើតឡើងនូវវិធានការ និងបទប្បញ្ញត្តិនានាជាបន្ថែមទៀត ដើម្បីធានាដល់ការពង្រឹងខ្សែគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ។

### ១.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់បានចែងថា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោតដោយផ្ទាល់ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន។ ចំណែកច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌបានចែងថា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោតអសកលដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាអ្នកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទាំងនេះ។ ការបោះឆ្នោតទាំងពីរនេះត្រូវបានធ្វើឡើងតាមប្រព័ន្ធសមាមាត្រ ដែលតម្រូវឱ្យបេក្ខជនចុះឈ្មោះតាមបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ សម្រាប់ចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ បេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេនៅក្នុងក្រុមប្រឹក្សានឹងក្លាយជាប្រធាននៃក្រុមប្រឹក្សានោះ។

ប្រព័ន្ធបោះឆ្នោតតាមសមាមាត្រនៅក្នុងការជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនេះ ផ្តល់អំណាចទៅឱ្យគណបក្សនយោបាយក្នុងការរៀបចំបញ្ជីបេក្ខជនសមាជិកក្រុមប្រឹក្សា ដែលធ្វើឱ្យសមាជិកក្រុមប្រឹក្សាទាំងនោះត្រូវមានគណនេយ្យភាពផងដែរចំពោះគណបក្សរបស់ខ្លួន។ ហេតុនេះ គណបក្សនយោបាយក៏មានការពាក់ព័ន្ធផងដែរដល់

គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ។ ប្រព័ន្ធបោះឆ្នោតស្រដៀងគ្នានេះក៏បានអនុវត្តនៅប្រទេសអឺរ៉ុបមួយចំនួន ហើយប្រទេសទាំងនោះ ក៏អាចកសាងរដ្ឋបាលមូលដ្ឋានរបស់ខ្លួនបានយ៉ាងល្អប្រសើរផងដែរ។

## ១.២. ការតែងតាំងមន្ត្រីសំខាន់ៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ថា មន្ត្រីសំខាន់ៗមួយចំនួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងត្រូវតែងតាំង និងដកហូតពីមុខតំណែងដោយរដ្ឋបាលថ្នាក់ជាតិ។ មន្ត្រីសំខាន់ៗទាំងនោះរួមមានស្មៀនឃុំ សង្កាត់ អភិបាល អភិបាលរង នាយករដ្ឋបាល និងប្រធានហិរញ្ញវត្ថុរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ទោះបីយ៉ាងដូច្នេះក្តី មាត្រា១៧៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាច្បាប់រៀបចំអង្គការ បានកំណត់ថា មន្ត្រីដែលតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា គឺជាបុគ្គលិករបស់ក្រុមប្រឹក្សា។ ហេតុនេះ មន្ត្រីដែលតែងតាំងទាំងនេះត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន។ ទន្ទឹមនេះ ច្បាប់រៀបចំអង្គការក៏តម្រូវឱ្យរៀបចំនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់គណនេយ្យភាពមន្ត្រីដែលបានចាត់បញ្ជូនទៅឱ្យបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិចំពោះក្រុមប្រឹក្សារបស់ខ្លួន។ ផ្អែកតាមគោលការណ៍ខាងលើនេះ និងគោលការណ៍នានាដែលបានបញ្ញត្តិនៅក្នុងច្បាប់រៀបចំអង្គការសម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ទាមទារត្រូវរៀបចំនូវលិខិតបទដ្ឋានគតិយុត្តជាបន្ថែមទៀត ដើម្បីកំណត់អំពីរបៀបរបបការងាររវាងក្រុមប្រឹក្សានិងគណៈអភិបាល និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាក្នុងការគ្រប់គ្រង ចាត់ចែង ត្រួតមើលទៅលើបុគ្គលិករបស់ខ្លួន រួមទាំងបុគ្គលិកដែលតែងតាំងដោយក្រុមប្រឹក្សា បុគ្គលិកដែលតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា និងបុគ្គលិកដែលត្រូវបានរៀបចំឡើងវិញទៅឱ្យក្រុមប្រឹក្សា ដើម្បីធានាឱ្យក្រុមប្រឹក្សានីមួយៗ មានការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

## ១.៣. តួនាទីរបស់ក្រុមប្រឹក្សា និងមន្ត្រីប្រតិបត្តិ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងយ៉ាងច្បាស់អំពីតួនាទីរបស់ក្រុមប្រឹក្សា និងមន្ត្រីប្រតិបត្តិនានា។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចក្នុងការអនុម័តផែនការអភិវឌ្ឍន៍ ថវិកា ការវិនិយោគ ប្រភេទនិងអត្រាពន្ធមូលដ្ឋាន ថ្លៃសេវា ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិ ការគ្រប់គ្រងបុគ្គលិក ព្រមទាំងការដាក់ចេញនូវសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិនានាសម្រាប់មូលដ្ឋានរបស់ខ្លួន។ ក្រុមប្រឹក្សាទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់មន្ត្រីប្រតិបត្តិនានា។ ក្រុមប្រឹក្សាមានសិទ្ធិមិនផ្ទេរនូវអំណាចទាំងនេះទៅឱ្យមន្ត្រីប្រតិបត្តិ។

មន្ត្រីប្រតិបត្តិនានារបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ លើសពីនេះទៀត ការសម្រេច ឬការអនុវត្តកិច្ចការណាមួយរបស់គណៈអភិបាល ឬអភិបាល ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពបានឡើយ។

ការកំណត់យ៉ាងជាក់លាក់ និងច្បាស់លាស់អំពីសិទ្ធិអំណាច តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា និងមន្ត្រីប្រតិបត្តិ បានផ្តល់នូវមូលដ្ឋានគតិយុត្តសម្រាប់រៀបចំលិខិតបទដ្ឋាន និងយន្តការនានា ដើម្បីធានាបាននូវគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋរបស់ខ្លួន។

## ១.៤. តម្លាភាព ការពិគ្រោះយោបល់ និងការទទួលបានព័ត៌មាន

បទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា២៣ មាត្រា២៧ មាត្រា៦៤ និងមាត្រា៧០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមាត្រា៣៨ មាត្រា៤១ មាត្រា៤៣ មាត្រា៦៨ និងមាត្រា១៦៦នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាមូលដ្ឋានគ្រឹះក្នុងការធានាឱ្យមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ការផ្តល់សិទ្ធិដល់សាធារណជនក្នុងការទទួលព័ត៌មាន និងតម្លាភាពជាទូទៅ។ បទប្បញ្ញត្តិទាំងនេះ តម្រូវឱ្យមានការរៀបចំនូវវិធានការមួយចំនួនដូចខាងក្រោម :

- ការប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ដោយរួមទាំងការផ្សព្វផ្សាយជាសាធារណៈអំពីប្រតិទិនប្រជុំក្រុមប្រឹក្សា និងឯកសារសំខាន់ផ្សេងៗទៀត ដូចជារបៀបវារៈ និងកំណត់ហេតុអង្គប្រជុំជាដើម។
- ការពិគ្រោះយោបល់ជាមួយពលរដ្ឋ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងការធ្វើអង្កេតនានា។
- ការបង្កើតគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ដល់ក្រុមប្រឹក្សា រួមមាន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ និងគណៈកម្មាធិការទទួលបន្ទុកការងារណាមួយតាមការចាំបាច់។
- ការជ្រើសរើសប្រធានភូមិតាមភូមិនីមួយៗនៃឃុំ សង្កាត់ ដើម្បីបម្រើការងារជាអ្នកទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយនឹងប្រជាពលរដ្ឋ។
- ការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការអនុញ្ញាតឱ្យប្រជាពលរដ្ឋ អាចពិនិត្យឯកសារសំខាន់ៗរបស់ក្រុមប្រឹក្សានៅការិយាល័យនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចស្នើសុំឯកសារនានារបស់ក្រុមប្រឹក្សាដោយមិនគិតថ្លៃ និងអាចទទួលបានព័ត៌មានតាមមធ្យោបាយនានា ដូចជាតាមរយៈក្តារព័ត៌មានសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិជាដើម។
- ការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរអំពីតួនាទី ភារកិច្ចរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការបង្កើតគណៈកម្មាធិការលទ្ធកម្ម ដើម្បីត្រួតពិនិត្យមើលសុចរិតភាព ភាពបើកចំហ តម្លាភាព និងភាពត្រឹមត្រូវក្នុងកិច្ចការលទ្ធកម្មទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក៏បានផ្តល់សិទ្ធិដល់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនូវលិខិតបទដ្ឋានគតិយុត្ត និងយន្តការ វិធានការបន្ថែមនានា ដើម្បីពង្រឹងការពិគ្រោះយោបល់ជាសារធារណៈ សិទ្ធិទទួលបានព័ត៌មានរបស់សាធារណជន និងតម្លាភាព។ លិខិតបទដ្ឋានគតិយុត្ត និងយន្តការទាំងនោះរួមមាន :

- វេទិកាការពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈ ដោយមានការផ្សព្វផ្សាយជាមុន និងជាចំហនូវរាល់ឯកសារសំខាន់ៗ មុនពេលក្រុមប្រឹក្សាធ្វើសេចក្តីសម្រេច។
- ការពិគ្រោះយោបល់ទាក់ទងនឹងកិច្ចការថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការដាក់បញ្ចូល និងតែងតាំងតំណាងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិល ជាសមាជិកគណៈកម្មាធិការនានា ដោយផ្តល់នូវតួនាទីសមស្រប មិនមែនត្រឹមតែជាទីប្រឹក្សា ឬអ្នកសង្កេតការណ៍។
- សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ ។ល។

## ១.៥. ការតាមដាន និងវាយតម្លៃ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាក្នុងការតាមដាន និងវាយតម្លៃការអនុវត្តផែនការ កម្មវិធី គម្រោង និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ។ របាយការណ៍ស្តីពីការអនុវត្តការងារខាងលើនេះ នឹងរួមបញ្ចូលផងដែរនូវរបាយការណ៍ទាក់ទងនឹងការងារស្ត្រី និងកុមារ។ ក្រុមប្រឹក្សាត្រូវអនុម័តលើរបាយការណ៍នានា និងរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោម (ក្នុងរយៈពេល៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ) ហើយអនុញ្ញាតឱ្យសាធារណជនអាចប្រើប្រាស់ និងពិនិត្យរបាយការណ៍ទាំងនោះដោយឥតគិតថ្លៃ។

វិធានការ និងយន្តការនេះ នឹងផ្តល់ឱកាសដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា មានលទ្ធភាពចូលរួមពិនិត្យ និងតាមដានទៅលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ដើម្បីពង្រឹងនូវការអនុវត្តវិធានការ និងយន្តការសម្រាប់ការតាមដាន និងវាយតម្លៃ ចាំបាច់ត្រូវរៀបចំនូវលិខិតបទដ្ឋានគតិយុត្ត យន្តការ និងវិធានការនានាបន្ថែម ដូចខាងក្រោម :

- ការធ្វើសវនកម្មសង្គម ដើម្បីជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា នៅក្នុងដំណើរការតាមដាន និងវាយតម្លៃ។
- ការធ្វើសវនកម្មដែលតម្រូវដោយច្បាប់ទៅលើហិរញ្ញវត្ថុថ្នាក់មូលដ្ឋាន តាមរយៈសវនករផ្ទៃក្នុង និងឬសវនករផ្ទៃក្រៅ។
- សវនការសាធារណៈដើម្បីពិភាក្សាអំពីលទ្ធផលដែលរកឃើញនៅក្នុងរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ និងសវនកម្មហិរញ្ញវត្ថុ ព្រមទាំងវិធានការដែលរដ្ឋបាលថ្នាក់ក្រោមជាតិនឹងប្រកាន់យក ដើម្បីដោះស្រាយបញ្ហានានា និងកែលម្អការបំពេញការងាររបស់ខ្លួន។

## ១.៦. គណនេយ្យភាពពីក្រោមទៅលើ (ឬការត្រួតពិនិត្យនីត្យានុកូលភាព)

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់សិទ្ធិអំណាចដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចដែលចេញដោយក្រុមប្រឹក្សា ដើម្បីធានាថា ដីកា និងសេចក្តីសម្រេចទាំងនោះស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ឧទាហរណ៍ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចធ្វើមោឃភាពសេចក្តីសម្រេច ឬស្នើឱ្យក្រុមប្រឹក្សាកែ

សម្រួលសេចក្តីសម្រេចនានាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ថ្នាក់ជាតិ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក៏មានសិទ្ធិអំណាចក្នុងការតាមដានការអនុវត្តតួនាទី និងភារកិច្ច ព្រមទាំងរាល់ការរំលោភអំណាចនានាដែលកើតឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

លើសពីនេះទៀត ច្បាប់រៀបចំអង្គការខាងលើ ក៏បានផ្តល់សិទ្ធិដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការរំលាយក្រុមប្រឹក្សាឃុំ សង្កាត់ និងការស្នើទៅរាជរដ្ឋាភិបាលឱ្យធ្វើការរំលាយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះអនុវត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញ គោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏អាចចេញសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ ដើម្បីជំរុញឱ្យក្រុមប្រឹក្សាអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវឡើងវិញ ឬអាចគ្រប់គ្រងជំនួសជាបណ្តោះអាសន្ន រហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចស្នើទៅរាជរដ្ឋាភិបាលក្នុងការដកចេញពីមុខតំណែងនូវអភិបាល អភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ និងអាចដកចេញពីមុខតំណែងនូវអភិបាលរងក្រុង ស្រុក ខណ្ឌ តាមសំណើរបស់ក្រុមប្រឹក្សា។

ទន្ទឹមនឹងនេះ ច្បាប់រៀបចំអង្គការខាងលើ ក៏បានចែងផងដែរថា ប្រជាពលរដ្ឋមានសិទ្ធិតវ៉ា និងស្នើសុំឱ្យក្រុមប្រឹក្សាកែតម្រូវការសម្រេចរបស់ខ្លួន ដែលមិនសមស្រប និងមានប៉ះពាល់ជាអវិជ្ជមានដល់ជីវភាពរបស់ប្រជាពលរដ្ឋ។

ដូច្នេះ ដើម្បីធានាដល់ការអនុវត្តនូវគោលការណ៍ខាងលើនេះដោយរលូន មិនប៉ះពាល់ដល់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ គ.ជ.អ.ប ត្រូវរៀបចំវិធានការ និងយន្តការនានាសម្រាប់ការត្រួតពិនិត្យនីត្យានុកូលភាព និងការធ្វើអន្តរាគមន៍របស់ថ្នាក់ជាតិចំពោះថ្នាក់ក្រោមជាតិដូចខាងក្រោម :

- កំណត់អំពីទំនាក់ទំនងអន្តររដ្ឋបាលឱ្យបានច្បាស់លាស់ ជាពិសេសទាក់ទងនឹងល័ក្ខខ័ណ្ឌ ពេលវេលា និងនីតិវិធីដែលនឹងអនុញ្ញាតឱ្យថ្នាក់ជាតិអាចធ្វើមោឃភាព ឬចោទសួរទៅលើដីកា និងសេចក្តីសម្រេចដែលអនុម័តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។
- កំណត់អំពីវិសាលភាព អត្ថន័យ និងដំណើរការដែលនឹងត្រូវប្រើប្រាស់ដោយក្រសួង ស្ថាប័នក្នុងការតាមដាន និងវាយតម្លៃទៅលើប្រសិទ្ធភាពនៃការបំពេញមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- កំណត់អំពីនីតិវិធីសម្រាប់ឱ្យក្រុមប្រឹក្សាដាក់ពាក្យបណ្តឹងតវ៉ាទៅរាជរដ្ឋាភិបាល ឬតុលាការ ប្រសិនបើខ្លួនមិនយល់ស្របជាមួយនឹងការសម្រេចរបស់ក្រសួង ស្ថាប័ននានា ដែលបានជំទាស់នឹងនីត្យានុកូលភាពនៃបទប្បញ្ញត្តិដែលក្រុមប្រឹក្សាបានអនុម័ត។

## ១.៧. គណនេយ្យភាពពីលើទៅក្រោម

មាត្រា១១ និងមាត្រា១២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមគោលការណ៍ដូចខាងក្រោម :

- ភាពជាតំណាងសាធារណៈ

- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅក្នុងមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច ។

មាត្រា១៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា ក្រុមប្រឹក្សានីមួយៗ ត្រូវធ្វើជាតំណាង និងធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋទាំងអស់ ដែលរស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ មាត្រា៣៤ នៃច្បាប់នេះបានចែងថា ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយ មាត្រា១២១ ក៏កំណត់ឱ្យក្រុមប្រឹក្សាត្រូវទទួលខុសត្រូវរាល់សេចក្តីសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា ដែលខ្លួនបានបង្កើតឡើង និងទទួលខុសត្រូវចំពោះផលវិបាកពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ ។

បទប្បញ្ញត្តិខាងលើនេះ គឺជាគោលការណ៍ និងមូលដ្ឋានគ្រឹះដ៏ជាក់លាក់ ក្នុងការធានាឱ្យមានគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ ។ ដើម្បីពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមចំពោះប្រជាពលរដ្ឋកាន់តែរឹងមាំ ចាំបាច់ត្រូវរៀបចំនូវវិធានការ និងយន្តការមួយចំនួន ដូចខាងក្រោម :

- កំណត់អំពីកាតព្វកិច្ចរបស់ក្រុមប្រឹក្សា ក្នុងការចេញបទប្បញ្ញត្តិទាក់ទងនឹងបញ្ហាជាក់លាក់ណាមួយ ដើម្បីឆ្លើយតបទៅនឹងការចង់បានរបស់ប្រជាពលរដ្ឋក្នុងចំនួនភាគរយណាមួយនៅមូលដ្ឋាន ។
- កំណត់អំពីនីតិវិធីសម្រាប់ការចូលរួមផ្តល់យោបល់របស់ប្រជាពលរដ្ឋទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។
- ផ្តល់ការអនុញ្ញាតពិសេសណាមួយដល់ប្រជាពលរដ្ឋក្នុងការស្នើសុំឱ្យមានការត្រួតពិនិត្យឡើងវិញ ទៅលើសមាជិកក្រុមប្រឹក្សានានា និងមន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- កំណត់អំពីសិទ្ធិរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការតែងតាំងបុគ្គលិករបស់ខ្លួនដោយផ្ទាល់ ។
- ផ្តល់សិទ្ធិ និងលទ្ធភាពដល់សាធារណជនក្នុងការទទួលបានព័ត៌មាននានា ។

## ២. ការលើកកម្ពស់គណនេយ្យភាពនៅក្នុងការអនុវត្តកម្មវិធីជាតិ

ក្នុងការពង្រឹងបញ្ហាគណនេយ្យភាព កម្មវិធីជាតិបានកំណត់ឱ្យមានខ្សែគណនេយ្យភាពសំខាន់ៗចំនួនបួន ដូចខាងក្រោម :

១. **គណនេយ្យភាពផ្ទៃក្នុង** សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ក្នុងបរិបទនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុង សំដៅទៅលើការរៀបចំវិធានការ

យន្តការ និងនីតិវិធីនានាសម្រាប់រដ្ឋបាលនីមួយៗនៃថ្នាក់ក្រោមជាតិ ដើម្បីធានាថា ក្រុមប្រឹក្សា (ជាអង្គជាប់ឆ្នោត) គឺជាអង្គទទួលខុសត្រូវកំពូលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អាចធ្វើសេចក្តីសម្រេចផ្អែកតាមតម្រូវការរបស់ប្រជាពលរដ្ឋ មានលទ្ធភាពត្រួតពិនិត្យ និងណែនាំដល់គណៈអភិបាល និងអង្គភាពនានាដែលអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។

២. **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ ការងារដំបូងក្នុងការពង្រឹងគណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ គឺការលើកស្ទួយការឆ្លើយតបការគាំទ្រ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមមាត្រា៩៧ មាត្រា៩៨ និងមាត្រា១០០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៣. **គណនេយ្យភាពអន្តររដ្ឋបាល** សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត គណនេយ្យភាពអន្តររដ្ឋបាលនឹងស្តែងចេញតាមរយៈការត្រួតពិនិត្យនីត្យានុកូលភាព (គណនេយ្យភាពផ្អែកច្បាប់) ការត្រួតពិនិត្យដើម្បីធានាបាននូវស្តង់ដារបច្ចេកទេសតាមវិស័យ និងការធ្វើសវនកម្មរដ្ឋបាល និងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤. **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ ឬគណនេយ្យភាពពីលើទៅក្រោម** សំដៅទៅលើខ្សែគណនេយ្យភាពផ្អែកនយោបាយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការរៀបចំឱ្យមាននីតិវិធីការ យន្តការ និងនីតិវិធីនានាសម្រាប់ធានាឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ២.១. ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ

ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ ទាមទារឱ្យមានការយកចិត្តទុកដាក់ទៅលើការពង្រឹងដល់ខ្សែគណនេយ្យភាពទាំងបួនប្រភេទ ដូចខាងក្រោម :

- **គណនេយ្យភាពផ្ទៃក្នុង** នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតនូវប្រព័ន្ធរដ្ឋបាលដោយផ្អែកលើវិធាននៃច្បាប់ និងតម្រូវការរបាយការណ៍នានា
- **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** នឹងបង្ហាញឱ្យឃើញតាមរយៈការបង្កើតអង្គភាពគាំទ្រឃុំ សង្កាត់របស់ថ្នាក់ស្រុក និងប្រព័ន្ធរបាយការណ៍រវាងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- **គណនេយ្យភាពអន្តររដ្ឋបាល** នឹងបង្ហាញឱ្យឃើញតាមរយៈការសម្របសម្រួលខ្សែទទឹងរវាងមន្ទីរ ការិយាល័យ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌនៃរដ្ឋបាលឯកភាព

- **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ** នឹងបង្ហាញឱ្យឃើញតាមរយៈ (១) ការអង្កេតពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈនានា (២) ការប្រើប្រាស់ព័ត៌មានវិទ្យាដើម្បីជួយឱ្យប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មាន និងសេវាសាធារណៈនានា (៣) គោលការណ៍ណែនាំ សេចក្ដីណែនាំ និងឧបករណ៍នានាសម្រាប់ការចូលរួម ការទទួលបាននូវព័ត៌មាន និងការពិគ្រោះយោបល់របស់ប្រជាពលរដ្ឋ (៤) ការបង្កើតនូវកម្មវិធី និងយន្តការនានាសម្រាប់លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ។ល។

ជាក់ស្ដែង សមាសធាតុកម្មវិធីនេះចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់ជាចម្បងទៅលើការរៀបចំវិធានការយន្តការ និងនីតិវិធីនានាដើម្បីពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុង ពាក់ព័ន្ធនឹងតួនាទី ភារកិច្ច និងទំនាក់ទំនងរវាងគណៈអភិបាល គណៈកម្មាធិការ និងអង្គភាពនានាដែលអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា ជាមួយនឹងក្រុមប្រឹក្សារបស់ខ្លួន និងខ្សែគណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្ដោតទៅលើទំនាក់ទំនងការងាររវាងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរវាងរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក ។

## ២.២. ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើខ្សែគណនេយ្យភាពរបស់អង្គភាពនានា ប្រធានហិរញ្ញវត្ថុ ជាមួយនាយករដ្ឋបាល និងគណៈអភិបាលរបស់រដ្ឋបាលថ្នាក់នីមួយៗ និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាសាមីទៅលើការគ្រប់គ្រង ចាត់ចែងមន្ត្រីរបស់គណៈអភិបាល នាយករដ្ឋបាល និងការប្រព្រឹត្តិទៅរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ស្របតាមស្មារតីនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាពិសេសបទប្បញ្ញត្តិក្នុងមាត្រា១១៩ មាត្រា១៥៤ មាត្រា១៥៥ មាត្រា១៥៧ មាត្រា១៦២ មាត្រា១៦៣ មាត្រា១៨៤ មាត្រា១៩០ និងមាត្រា១៩១។ កិច្ចការសំខាន់ៗ និងបន្ទាន់ក្នុងការពង្រឹងខ្សែគណនេយ្យភាពក្នុងប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិ រួមមាន :

- ការកំណត់តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់អង្គការចាត់តាំង និងអង្គភាពនានា និងល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្ដោតលើការប្រគល់ការគ្រប់គ្រងមន្ត្រី បុគ្គលិកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅឱ្យក្រុមប្រឹក្សានានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ការបង្កើតឱ្យមានការប្រាស្រ័យទាក់ទងជាទៀងទាត់រវាងមន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយសហគមន៍ដើម្បីបង្កើនការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីតួនាទី និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋក្នុងការចូលរួម និងជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

- ការរៀបចំឱ្យមានកម្មវិធី និងសកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សនានា ដែលផ្តោតការយកចិត្តទុកដាក់លើការពង្រឹងខ្សែគណនេយ្យភាពចំពោះប្រជាពលរដ្ឋ (អ្នកទទួលសេវា)។

## ២.៣. ការផ្ទេរមុខងារ

ក្នុងដំណើរការអនុវត្តសមាសធាតុកម្មវិធីទី៣នៃកម្មវិធីជាតិ ខ្សែគណនេយ្យភាពអន្តររដ្ឋបាលនឹងលេចឡើងកាន់តែច្បាស់លាស់ តាមរយៈការផ្ទេរមុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាចក្នុងការចាត់ចែងធនធានដើម្បីអនុវត្តនូវមុខងារនោះ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ក្នុងការអនុវត្តមុខងារជាជម្រើសដែលបានប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនោះ។ ក្នុងករណីនេះ ក្រុមប្រឹក្សាត្រូវទទួលបាននូវសិទ្ធិអំណាចពេញលេញក្នុងការចាត់ចែងធនធានសម្រាប់អនុវត្តមុខងារនោះ ហើយប្រជាពលរដ្ឋចាំបាច់ត្រូវទទួលបាននូវសិទ្ធិអំណាច និងការលើកទឹកចិត្តក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្ទាល់។

ការផ្ទេរមុខងារជាកាតព្វកិច្ច ចាំបាច់ត្រូវអនុវត្តតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាពិសេសបទប្បញ្ញត្តិក្នុងមាត្រា២២៥។ ការផ្តល់ទៅឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិអំណាចជាអតិបរមាក្នុងការចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ច ព្រមទាំងសិទ្ធិអំណាចក្នុងការអនុវត្តនូវសកម្មភាពលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពកាន់តែច្រើនឡើងចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ក្នុងន័យនេះ ក្រសួង ស្ថាប័នថ្នាក់ជាតិនឹងរក្សាទុកនូវតួនាទីដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយ ការកំណត់ស្តង់ដារបច្ចេកទេសជាអប្បបរមា ការផ្តល់សមត្ថភាព និងការតាមដាននិងត្រួតពិនិត្យទៅលើការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ដើម្បីពង្រឹងគណនេយ្យភាពអន្តររដ្ឋបាល និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ កិច្ចការសំខាន់ៗដែលត្រូវអនុវត្តក្នុងសមាធាតុកម្មវិធីនេះ រួមមាន :

- ការកំណត់អំពីមុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាចក្នុងការចាត់ចែងធនធានសម្រាប់អនុវត្តមុខងារនោះឱ្យបានច្បាស់លាស់តាមប្រភេទរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការកំណត់អំពីតួនាទី ការទទួលខុសត្រូវ និងសិទ្ធិអំណាចដែលត្រូវរក្សាទុកនៅថ្នាក់ជាតិ។
- ការកំណត់អំពីស្តង់ដារបច្ចេកទេសជាអប្បរមា និងតម្រូវការក្នុងការផ្តល់សមត្ថភាពចំពោះមុខងារជាក់លាក់។
- ការកំណត់អំពីនីតិវិធីច្បាស់លាស់ក្នុងការតាមដាន និងត្រួតពិនិត្យរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ។
- ការផ្សព្វផ្សាយជាសាធារណៈអំពីការទទួលខុសត្រូវ និងសិទ្ធិអំណាចក្នុងការចាត់ចែងធនធានសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការទទួលខុសត្រូវ និងសិទ្ធិអំណាចដែលរក្សាទុកនៅថ្នាក់ជាតិ។

- ការធ្វើវេទិកាសាធារណៈ ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋស្តីពីសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ការរៀបចំឱ្យមានសន្លឹកប័ណ្ណរបាយការណ៍របស់ប្រជាពលរដ្ឋអំពីសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- ការរៀបចំឱ្យមានក្រុមគណនេយ្យភាព ឬការិយាល័យប្រជាពលរដ្ឋ ការចូលរួមផ្តល់យោបល់ ឬរិះគន់តាមរយៈប្រអប់សំបុត្រ និងប្រព័ន្ធផ្សេងៗទៀត ។ល ។

## ២.៤. ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ការពង្រឹងខ្សែគណនេយ្យភាពនៅក្នុងដំណើរការអនុវត្តសមាសធាតុកម្មវិធីទី៤នេះ នឹងត្រូវធ្វើឡើងតាមរយៈយន្តការខាងក្រោម :

- **គណនេយ្យភាពផ្ទៃក្នុង** នឹងស្តែងឡើងតាមរយៈការធ្វើសវនកម្មផ្ទៃក្នុង ទំនាក់ទំនង និងរបៀបរបបធ្វើការងាររវាងក្រុមប្រឹក្សា គណៈអភិបាល និងអង្គភាពនានារបស់ក្រុមប្រឹក្សាពាក់ព័ន្ធនឹងការអនុវត្តថវិកា ។
- **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ** នឹងស្តែងឡើងច្បាស់លាស់ តាមរយៈការចែករំលែកចំណូលរវាងស្រុក និងឃុំ សង្កាត់នៅក្នុងស្រុក ។
- **គណនេយ្យភាពអន្តររដ្ឋបាល** នឹងស្តែងឡើងតាមរយៈការធ្វើអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ ទៅលើការអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។
- **គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ** នឹងស្តែងឡើងតាមរយៈការរៀបចំការសម្រេច និងការអនុវត្តថវិកា និងតាមរយៈវេទិកាពិគ្រោះយោបល់ និងផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងកិច្ចការថវិកា ការវិនិយោគ និងការអភិវឌ្ឍនានា ព្រមទាំងតាមរយៈការអនុវត្តសាកល្បងនូវយន្តការនានាដែលពាក់ព័ន្ធនឹងសវនកម្មផ្នែកសង្គមកិច្ច និងការផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋ ឬក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការចូលរួមផ្តល់យោបល់លើគម្រោងថវិកានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រភេទផ្សេងទៀត ។

ដើម្បីធានាឱ្យមានការពង្រឹងគោលការណ៍ប្រជាធិបតេយ្យ តាមរយៈខ្សែគណនេយ្យភាពពីលើទៅក្រោមឱ្យកាន់តែស៊ីជម្រៅក្នុងការរៀបចំវិធានការ និងយន្តការនានា ត្រូវយកចិត្តទុកដាក់ជាពិសេសដល់ការលើកកម្ពស់ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ស្ត្រី ក្រុមជនងាយរងគ្រោះនៅក្នុងសហគមន៍ និងអង្គការសង្គមស៊ីវិលទៅលើការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍ ការផ្តល់សិទ្ធិស្របច្បាប់ និងការបង្កើតនីតិវិធីដើម្បីទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសជាសាធារណៈ និងដេញដោលសួរអំពីហិរញ្ញវត្ថុ និងការប្រើប្រាស់ថវិកា) ។

## ២.៥. ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល។ ដូច្នេះ គ.ជ.អ.ប ចាំបាច់ត្រូវបង្កើតនូវយន្តការ និងនីតិវិធីច្បាស់លាស់ដើម្បីធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំយន្តការ និងនីតិវិធីច្បាស់លាស់ក្នុងការកំហិតការត្រួតពិនិត្យរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិទៅលើការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (គណនេយ្យភាពអន្តររដ្ឋបាល)។ លើសពីនេះទៀត គ.ជ.អ.ប ក៏នឹងត្រូវរៀបចំបង្កើត និងពង្រឹងនូវយន្តការសម្របសម្រួលកិច្ចការ និងដោះស្រាយវិវាទរដ្ឋបាលនានា ដើម្បីពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុង និងខ្សែគណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

អាស្រ័យហេតុនេះ គ.ជ.អ.ប ត្រូវធានាឱ្យមានការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត នីតិវិធី និងយន្តការសំខាន់ៗមួយចំនួនដូចខាងក្រោម :

- កំណត់នីតិវិធី និងយន្តការត្រួតពិនិត្យនីត្យានុកូលភាពទៅលើការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការទាមទារ សាកសួរលើករណីមានការធ្វើមោឃភាពសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ឬក្នុងករណីមានការរំសាយក្រុមប្រឹក្សាណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- រៀបចំគោលនយោបាយដែលបង្កបរិយាកាសអំណោយផល និងជំរុញឱ្យមានការបង្កើតសមាគម និងសម្ព័ន្ធភាពនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ឋានៈ សមត្ថភាព និងជាពិសេសការពារសិទ្ធិ និងផលប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ធានា និងផ្តល់ធនធានសម្រាប់ការរៀបចំនីតិវិធី និងយន្តការសំខាន់ៗក្នុងការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន ការប្រឹក្សាយោបល់ជាសាធារណៈ និងការចូលរួមផ្តល់យោបល់របស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋាន ព្រមទាំងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ល។

គ.ជ.អ.ប នឹងរៀបចំក្របខ័ណ្ឌការងារគណនេយ្យភាពដ៏លម្អិត និងច្បាស់លាស់សម្រាប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់នៅក្នុងអភិបាលកិច្ចថ្នាក់ក្រោមជាតិ។

# សន្ទានុក្រម

# សន្ទានុក្រម

១. **ការកែទម្រង់ស្ថាប័ន ឬកំណែទម្រង់ស្ថាប័ន (Institutional Reform)** សំដៅទៅលើការផ្លាស់ប្តូររចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី និងរបៀបរបបធ្វើការងារ រួមទាំងខ្សែគណនេយ្យភាព ទំនាក់ទំនង និងដំណើរការនៃការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

២. **ការឆ្លើយតប និងគណនេយ្យភាព (Responsiveness and Accountability)** មានន័យថា ក្នុងនាមជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន ក្រុមប្រឹក្សាត្រូវ ឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត ។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា ។

៣. **ការទទួលខុសត្រូវ (Responsibility)** សំដៅទៅលើតួនាទី និងកាតព្វកិច្ចដែលបានប្រគល់ឱ្យដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ទៅឱ្យបុគ្គល អង្គការចាត់តាំងនៃរដ្ឋបាលណាមួយ ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

៤. **ការធ្វើប្រតិភូកម្ម ឬការធ្វើវិសហមជ្ឈការមុខងារ (Delegation of Function)** សំដៅទៅលើការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងឆន្ទានុសិទ្ធិ ទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ ក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្ម នៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម ។

៥. **ការធ្វើស្ថាប័នភាវូបនីយកម្ម (Institutionalization)** សំដៅលើការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី ប្រតិបត្តិការ និងនិយាមការងារ សមស្របនៅក្នុងស្ថាប័នមានសមត្ថកិច្ច ដើម្បីធានាដល់បំពេញការងារប្រកបដោយប្រសិទ្ធភាព និងនិរន្តភាព ។

៦. **ការបង្កើនភាពអង់អាចដល់ស្ត្រី (Empowerment of Women)** សំដៅទៅលើដំណើរការក្នុងការជួយស្ត្រីផ្នែកសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និងច្បាប់ ដើម្បីឱ្យស្ត្រីអាចនឹងធ្វើសកម្មភាពក្នុងការពង្រឹងសិទ្ធិ សមត្ថភាព ការទទួលបាននូវសេវាសាធារណៈ ការគ្រប់គ្រងធនធាន និងការចូលរួមដោយស្មើភាពនៅក្នុងកិច្ចការដែលពីមុនគេហាមឃាត់ ឬកម្រិតស្ត្រីមិនឱ្យចូលរួម ។

៧. **ការបញ្ជ្រាបយេនឌ័រ (Gender Mainstreaming)** សំដៅទៅលើវិធីសាស្ត្រនៃការដាក់បញ្ចូលកង្វល់ពាក់ព័ន្ធនឹងយេនឌ័រទៅក្នុងការវិភាគ ការរៀបចំ និងការតាមដានត្រួតពិនិត្យគោលនយោបាយ កម្មវិធី និងគម្រោងអភិវឌ្ឍន៍នានា ដើម្បីធានាដល់ការកាត់បន្ថយវិសមភាព និងគម្លាតយេនឌ័រ ។

៨. **ការប្រគល់ ឬការធ្វើវិមជ្ឈការមុខងារ (Assignment of Function)** សំដៅទៅលើការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ ។

៩. **ការប្រែប្រួលអាកាសធាតុ ឬបម្រែបម្រួលអាកាសធាតុ (Climate Change)** សំដៅទៅលើការប្រែប្រួលសីតុណ្ហភាពនៃបរិយាកាសនៅជុំវិញភពផែនដី ជាពិសេសការកើនកំដៅ (ដែលអាចបណ្តាលឱ្យប្រែប្រួលដល់របបទឹកភ្លៀង មានទឹកជំនន់ មានព្យុះ និងគ្រោះមហន្តរាយផ្សេងៗទៀត) ដែលបណ្តាលមកពីការកើនឡើងនូវកំហាប់ឧស្ម័នផ្ទះកញ្ចក់។ **ឧស្ម័នផ្ទះកញ្ចក់** គឺជាស្រទាប់បរិយាកាសនៅជុំវិញភពផែនដី ដែលផ្សំឡើងដោយសារចំហាយទឹក ឧស្ម័នកាបូនិច មេតាន ឌីអាសូតម៉ូណូអុកស៊ីត និងអូសូន ហើយបើឧស្ម័នទាំងនេះកើតឡើងដោយធម្មជាតិ នោះឧស្ម័នផ្ទះកញ្ចក់នេះមានតួនាទីថែរក្សាសីតុណ្ហភាពសមស្របសម្រាប់ទ្រទ្រង់ជីវិតសត្វ និងរុក្ខជាតិនៅលើភពផែនដី។

១០. **ការផ្ទេរមុខងារ (Transfer of Function)** សំដៅទៅលើការប្រគល់ ឬការធ្វើប្រតិភូកម្មនូវមុខងារ ទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវធនធាន និងសមត្ថភាព។

១១. **ការពិគ្រោះយោបល់ និងការចូលរួម (Consultation and Participation)** មានន័យថា ជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងលើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ច ដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។

១២. **ការរៀបចំស្ថាប័នឡើងវិញ (Institutional Restructuring)** សំដៅទៅលើការសិក្សាពិនិត្យ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួង ស្ថាប័ន។

១៣. **ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (Promotion of Life Quality of the Local Residents)** សំដៅទៅលើកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាពនិងសុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច និងលើកកម្ពស់ផាសុកភាពនិងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

១៤. **ការលើកស្ទួយសមធម៌ (Promotion of Equity)** មានន័យថា ការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗគ្នារបស់ក្រុមជនងាយរងគ្រោះ រាប់បញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច។

១៥. **ការវិភាគយេនឌ័រ (Gender Analysis)** សំដៅទៅលើដំណើរការនៃការពិនិត្យ និងកំណត់ឱ្យបានច្បាស់អំពីស្ថានភាព តួនាទី តម្រូវការ និងផលប្រយោជន៍ខុសគ្នាៗរវាងស្ត្រី បុរសនៅក្នុងការប្រកបការងារ និងជីវិតរស់នៅ និងនៅក្នុងគោលនយោបាយ ផែនការ គម្រោង និងកម្មវិធីអភិវឌ្ឍន៍នានា ដើម្បីធ្វើឱ្យកិច្ចអន្តរាគមន៍ និងដំណោះស្រាយនានា មានការឆ្លើយតបទៅនឹងស្ថានភាព និងតម្រូវការទាំងនោះ។

១៦. **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (Democratic Development)** សំដៅទៅលើការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈ (១) ភាពជាតំណាងសាធារណៈ (២) ស្វ័យភាពរបស់មូលដ្ឋាន (៣) ការពិគ្រោះយោបល់និងការចូលរួម (៤) ការឆ្លើយតបនិងគណនេយ្យភាព (៥) ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជា

ពលរដ្ឋក្នុងមូលដ្ឋាន (៦) ការលើកស្ទួយសមធម៌ (៧) តម្លាភាពនិងសុចរិតភាព និង (៨) វិធានការប្រឆាំងអំពើពុករលួយនិងការរំលោភអំណាច។

**១៧. ការអភិវឌ្ឍស្ថាប័ន (Institutional Development)** សំដៅទៅលើការបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី ក្រមប្អូនិយាមការងារ និងការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នណាមួយ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**១៨. គណនេយ្យភាព (Accountability)** គឺការកាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ។

**១៩. គណនេយ្យភាពខ្សែទទឹង (Horizontal Accountability)** សំដៅទៅលើខ្សែគណនេយ្យភាពរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខ្លួនប្រតិបត្តិនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ។

**២០. គណនេយ្យភាពខ្សែបណ្តោយ (Vertical Accountability)** សំដៅទៅលើខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ឬរវាងមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័នដែលប្រតិបត្តិនៅថ្នាក់ក្រោមជាតិ ជាមួយក្រសួង ស្ថាប័នសាមី។

**២១. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ឬគណនេយ្យភាពពីលើទៅក្រោម (Accountability to Citizens or Downward Accountability)** សំដៅទៅលើខ្សែគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ឧទាហរណ៍ ៖

- រដ្ឋបាលថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ និងជនជាតិដើមភាគតិច និងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព
- រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានយន្តការសម្រាប់ការចូលរួមប្រជាពលរដ្ឋនៅក្នុងដំណើរការរៀបចំ និងអនុវត្តផែនការនិងថវិកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំឱ្យមានយន្តការសម្រាប់ការពារសិទ្ធិនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ

**២២. គណនេយ្យភាពផ្ទៃក្នុង (Internal Accountability)** សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ ៖

- គណនេយ្យភាពរវាងគណៈអភិបាលនិងទីចាត់ការនានានៃរដ្ឋបាលខេត្ត "ក" ជាមួយនឹងក្រុមប្រឹក្សាខេត្ត "ក"
- គណនេយ្យភាពនៅក្នុងគណៈអភិបាលខេត្ត "ក"
- គណនេយ្យភាពនៅក្នុងទីចាត់ការនីមួយៗនៃរដ្ឋបាលខេត្ត "ក"។

**២៣. គណនេយ្យភាពផ្នែកគោលនយោបាយ (Political Accountability)** សំដៅទៅលើគណនេយ្យភាពរបស់អ្នកជាប់ឆ្នោតចំពោះប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោត តាមរយៈការបំពេញតួនាទីនៅក្នុងអំឡុងអាណត្តិរបស់ខ្លួន។

២៤. **គណនេយ្យភាពផ្នែកច្បាប់ (Legal Accountability)** សំដៅទៅលើគណនេយ្យភាពចំពោះមុខច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

២៥. **គណនេយ្យភាពផ្នែករដ្ឋបាល (Administrative Accountability)** សំដៅទៅលើគណនេយ្យភាព ដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រង នីតិវិធីប្រតិបត្តិស្តង់ដារ និងនិយាមការងាររបស់បុគ្គល និងអង្គការចាត់តាំង ទៅតាមឋានានុក្រម ។

២៦. **គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ (Financial Accountability)** សំដៅទៅលើគណនេយ្យភាពដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ស្របទៅតាមច្បាប់ និងគោលការណ៍ហិរញ្ញវត្ថុសាធារណៈ ។

២៧. **គណនេយ្យភាពផ្នែកសង្គម (Social Accountability)** សំដៅទៅលើសកម្មភាព និងយន្តការនានា ដែលប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីទាមទារឱ្យរដ្ឋមានគណនេយ្យភាពចំពោះខ្លួន ព្រមទាំងសកម្មភាពនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល និងតួអង្គដទៃទៀត ក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាព និងយន្តការទាំងនោះ ។

២៨. **គណនេយ្យភាពអន្តររដ្ឋបាល (Inter-governmental Accountability)** សំដៅទៅលើគណនេយ្យភាពរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ឧទាហរណ៍ ៖

- គណនេយ្យភាពរវាងក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាលឃុំ សង្កាត់
- គណនេយ្យភាពរវាងមន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលរាជធានី ខេត្ត ឬរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬរដ្ឋបាលឃុំ សង្កាត់

២៩. **គណនេយ្យភាពអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ (Intra-SNA Accountability)** សំដៅទៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា ។ ឧទាហរណ៍ ៖

- គណនេយ្យភាពរវាងរដ្ឋបាលខេត្ត"ក" និងរដ្ឋបាលខេត្ត"ខ"
- គណនេយ្យភាពរវាងរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់
- គណនេយ្យភាពរវាងក្រុមប្រឹក្សាខេត្ត"ក"និងក្រុមប្រឹក្សាខេត្ត"ខ"
- គណនេយ្យភាពរវាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់
- គណនេយ្យភាពរវាងគណៈអភិបាលខេត្ត"ក"និងគណៈអភិបាលខេត្ត"ខ"
- គណនេយ្យភាពរវាងគណៈអភិបាលរាជធានី ខេត្ត គណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ។

៣០. **តម្រូវការផ្នែកមូលធន (Capital Requirement)** សំដៅលើតម្រូវការផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់បម្រើឱ្យការបំពេញការងាររបស់ស្ថាប័ននានា ។

៣១. **តម្រូវការយេនឌ័រ (Gender Need)** បែងចែកជាពីរ គឺតម្រូវការយេនឌ័រចំពោះមុខ និងតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ។

- **តម្រូវការយេនឌ័រចំពោះមុខ** សំដៅលើតម្រូវការ ឬសេចក្តីត្រូវការរបស់បុរស និងស្ត្រីសម្រាប់បំពេញនូវជីវភាពរស់នៅប្រចាំថ្ងៃ។
- **តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ** សំដៅដល់ធនធាន សម្ភារៈ ឧបករណ៍ សេវាកម្ម ឬសកម្មភាពនានាដែលអាចជួយពង្រីកឱកាស បង្កើនការចូលរួម ឬគ្រប់គ្រងតួនាទីយេនឌ័ររបស់បុរសនិងស្ត្រី និងការងារ។ នៅពេលដែលតម្រូវការទាំងនោះត្រូវបានបំពេញ អំណាចនៃទំនាក់ទំនងរវាងបុរសនិងស្ត្រី និងការបែងចែកការងារតាមយេនឌ័រពិតជាអាចកែប្រែបានច្រើន ហើយអាចជួយរួមចំណែកលើកកម្ពស់សមភាពយេនឌ័រថែមទៀតផង។ តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ អាចប្រើប្រាស់រយៈពេលយូរជាងធម្មតា ហើយមើលមិនសូវឃើញជារូបរាងច្បាស់លាស់ទេ ដូចជាការផ្តល់នូវឱកាសទទួលបានតំណែងក្នុងឆាកនយោបាយ តំណែងក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ការលុបបំបាត់ឧបសគ្គផ្លូវច្បាប់ ក៏ដូចជាការរើសអើងនៃសិទ្ធិកាន់កាប់ដីធ្លី ឬឥណទានជាដើម។

ដោយសារទំនាក់ទំនង តួនាទី និងសិទ្ធិអំណាច ដែលសង្គម សហគមន៍ និងគ្រួសារបានផ្តល់ដល់ស្ត្រី បុរសមានលក្ខណៈខុសគ្នា ដូចនេះសេចក្តីត្រូវការរបស់ពួកគេក៏មានលក្ខណៈខុសគ្នាទៅតាមនោះដែរ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹង និងវិភាគបែងចែកឱ្យបានច្បាស់ពីតម្រូវការទាំងនោះ ដើម្បីធ្វើឱ្យកម្មវិធី គម្រោង និងផែនការអភិវឌ្ឍន៍នានា បានឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ស្ត្រីនិងបុរសនៅក្នុងសហគមន៍ និងមូលដ្ឋាន។

៣២. **តម្លាភាព និងសុចរិតភាព (Transparency and Integrity)** មានន័យថា ជាការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការ ហិរញ្ញវត្ថុ ដោយអនុលោមតាមបទដ្ឋានខ្ពស់បំផុតនៃសុចរិតភាព និងច្បាប់ ក្នុងលក្ខណៈបើកចំហ ប្រកបដោយតម្លាភាព ការចូលរួម និងការឆ្លើយតប។

៣៣. **តួនាទី (Role)** សំដៅទៅលើសំណុំសកម្មភាពដែលផ្តល់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទៅឱ្យបុគ្គលិក ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣៤. **តួនាទីយេនឌ័រ (Gender Role)** សំដៅលើតួនាទី ឬភារកិច្ចសម្រាប់ក្មេងស្រី ក្មេងប្រុស ស្ត្រី បុរស ដែលកំណត់ឡើងដោយសង្គម។ ដោយសារតួនាទីយេនឌ័រត្រូវបានបង្កើតឡើងដោយសារសង្គម ដូច្នេះតួនាទីនេះអាចកែប្រែ ឬប្រែប្រួលគ្រប់ពេលវេលា ហើយខុសៗគ្នា ទៅតាមទំនៀមទម្លាប់ និងវប្បធម៌នៃប្រទេសនីមួយៗ។ តួនាទីយេនឌ័រមាន ឥទ្ធិពលប៉ះពាល់ដល់ទំនាក់ទំនងរវាងបុរស និងស្ត្រី ហើយឥទ្ធិពលនេះអាចបង្កឱ្យមានវិសមភាពនៃឱកាស និងការរំពឹងទុករបស់បុរស និងស្ត្រីនៅក្នុងសង្គម និងកិច្ចអភិវឌ្ឍ។

៣៥. **ទ្រព្យសម្បត្តិសាធារណៈ (Public Goods)** គឺជាទ្រព្យសម្បត្តិ និងសេវាសាធារណៈទាំងឡាយដែលបុគ្គលគ្រប់រូបអាចប្រើប្រាស់បានក្នុងពេលដំណាលគ្នា ដោយពុំមានការបន្ថយនូវលទ្ធភាព និងតម្លៃក្នុងការប្រើប្រាស់របស់បុគ្គលណាមួយឡើយ។

**៣៦. ទំនាក់ទំនងអន្តររដ្ឋបាល (Inter-governmental Relations)** សំដៅទៅលើទំនាក់ទំនងរវាងក្រសួង ស្ថាប័ន មន្ទីរ ទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ជាមួយនឹងរដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**៣៧. ទំនាក់ទំនងអន្តររដ្ឋបាលថ្នាក់ក្រោមជាតិ (Intra-SNA Relations)** សំដៅទៅលើទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានប្រភេទដូចគ្នាឬប្រភេទផ្សេងគ្នា ។

**៣៨. ធាតុចូល (Input)** សំដៅទៅលើអ្វីៗដែលចូលរួមចំណែកក្នុងការបង្កើតនូវលទ្ធផល (**Output**) ។

**៣៩. នីតិវិធីប្រតិបត្តិស្តង់ដារ (Standard Operating Procedure)** សំដៅទៅលើនីតិវិធីស្តីពីកិច្ចការរដ្ឋបាល (រួមទាំងការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងការិយាល័យ) និងនីតិវិធីស្តីពីកិច្ចការហិរញ្ញវត្ថុ (រួមទាំងកិច្ចលទ្ធកម្ម) ដែលធានាឱ្យមានតម្លាភាព សុចរិតភាព និងប្រសិទ្ធភាពក្នុងការបំពេញការងាររបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**៤០. បញ្ហាយេនឌ័រ (Gender Issue)** សំដៅលើផលប៉ះពាល់ជាអវិជ្ជមានដែលកើតមកពីផ្នត់គំនិត ឬការប្រព្រឹត្តមកលើបុរស ស្ត្រី ឬក្មេងប្រុស ក្មេងស្រីរបស់គ្រួសារ សហគមន៍ និងសង្គម តាមរយៈការចែកការងារ ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទី ។ ដូចជាការកំណត់ថាក្មេងស្រីមិនគួររៀនច្រើនបានបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ស្ត្រី និងក្មេងស្រី ពុំសូវមានចំណេះដឹងខ្ពស់ មានការលំបាកក្នុងការចូលរួមក្នុងការងារសង្គម ទទួលព័ត៌មានជាដើម ។

**៤១. បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (Climate Change Adaptation)** គឺជាលទ្ធភាពកែតម្រូវរបស់មនុស្ស សត្វ រុក្ខជាតិ និងប្រព័ន្ធអេកូឡូស៊ីទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ សំដៅទាញយកកាលានុវត្តភាព ឬដោះស្រាយផលវិបាកនៃការប្រែប្រួលអាកាសធាតុ ។ បន្សាំអាចកើតឡើងដោយឯកឯង ឬដោយការគ្រោងទុកជាមុន ។

**៤២. ភាពជាតំណាងសាធារណៈ (Public Representation)** មានន័យថា ក្រុមប្រឹក្សាត្រូវអនុវត្តការងារក្នុងនាម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋ ទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**៤៣. ភារកិច្ច (Duty)** សំដៅទៅលើកិច្ចការនានាដែលបុគ្គលិក ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានកាតព្វកិច្ច ត្រូវអនុវត្ត ។

**៤៤. មុខងារ (Function)** សំដៅទៅលើសកម្មភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ តាមរយៈទង្វើប្រកបដោយនិរន្តរភាព ហើយផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។ ឧទាហរណ៍ សហគមន៍ត្រូវការទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ។ រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលយកនូវមុខងារក្នុងការផ្តល់នូវទឹកស្អាតដល់សហគមន៍ប្រើប្រាស់ជាប្រចាំ តាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ព្រមទាំងយន្តការសម្រាប់គ្រប់គ្រង ថែទាំ ត្រួតពិនិត្យគុណភាពទឹក ។ល ។

**៤៥. មុខងារជាកាតព្វកិច្ច (Obligatory Functions)** គឺជាមុខងារដែលផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស តាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម

បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល សម្រាប់គោលបំណងជាកាតព្វកិច្ច មួយ ឬច្រើនដែលបានកំណត់ដោយក្រសួង ស្ថាប័នថ្នាក់ជាតិ។

៤៦. **មុខងារជាជម្រើស (Permissive Functions)** គឺមុខងារដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានឆន្ទានុសិទ្ធិ ក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីឆ្លើយតបដោយផ្ទាល់ទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមិនមានការរំលោភ ឬផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ជាតិ។

៤៧. **មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ (Unconditional Fund)** គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ដើម្បី ៖

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសនានា។

៤៨. **មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ (Conditional Fund)** គឺជាមូលនិធិដែលក្រុមប្រឹក្សាត្រូវប្រើប្រាស់ ៖

- ដើម្បីគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចមួយឬច្រើនដែលត្រូវបានផ្ទេរឱ្យក្រុមប្រឹក្សា តាមការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ ឬ
- ដើម្បីបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយឬច្រើនដែលក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ
- សម្រាប់គោលបំណងជាកាតព្វកិច្ចមួយឬច្រើនដែលបានកំណត់។

៤៩. **យេនឌ័រ (Gender)** សំដៅលើផ្នត់គំនិត ឬការប្រព្រឹត្តរបស់គ្រួសារ សហគមន៍ និងសង្គមដែលពាក់ព័ន្ធនឹងការបែងចែកការងារ ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទីដល់កូនស្រី និងកូនប្រុស ឬស្ត្រី និងបុរស។ ដូចជាការកំណត់របស់គ្រួសារលើការសិក្សារបស់កូនស្រី កូនប្រុស ការកំណត់ការងារសម្រាប់ក្មេងស្រី ក្មេងប្រុស រួមទាំងការងារផ្ទះសម្បែងជាដើម។

៥០. **រចនាសម្ព័ន្ធប្រតិបត្តិការ (Operational Structure)** ត្រូវអនុវត្តទៅតាមទស្សនទានពីរ គឺផ្នែកជួរមុខ និងផ្នែកទ្រទ្រង់។

- **ផ្នែកជួរមុខ (Front Office)** គឺជាផ្នែកដែលត្រូវធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់សេវា។ ដើម្បីឱ្យផ្នែកជួរមុខមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាជូនអ្នកប្រើប្រាស់សេវា មន្ត្រីរាជការ ឬភ្នាក់ងារដែលបម្រើការងារនៅផ្នែកនេះ ត្រូវតែយល់ដឹងជារួម និងតាមវិស័យជំនាញនូវសេវាសាធារណៈនោះ និងត្រូវមានអាកប្បកិរិយាល្អ យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការ និងជួយបំភ្លឺចម្ងល់ផ្សេងៗរបស់អ្នកប្រើប្រាស់សេវា។ ផ្នែកជួរមុខ មានភារកិច្ចផ្តល់ព័ត៌មាន ពន្យល់អំពីនីតិវិធីនៃការទទួលសេវា បញ្ជូននិងបែងចែក

សំណុំឯកសារទៅតាមវិស័យជំនាញ ទទួលប្រាក់កម្រៃសេវា ព្រមទាំងផ្តល់លទ្ធផល និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការស្នើសុំសេវា ទៅអ្នកប្រើប្រាស់សេវាវិញ។ ក្នុងករណីចាំបាច់ ត្រូវផ្តល់ការណែនាំបន្ថែម និងជួយសម្រួលដល់ការបំពេញបែបបទ និងការទទួលពាក្យស្នើសុំពីអ្នកប្រើប្រាស់សេវាទាំងឡាយណា ដែលពុំមានការយល់ដឹងច្បាស់លាស់ ដូចជាករណីអ្នកមិនចេះអក្សរជាដើម។

- **ផ្នែកទ្រទ្រង់ (Back Office)** គឺជាផ្នែកដ៏សំខាន់សម្រាប់ធានាឱ្យផ្នែកជួរមុខទទួលបានជោគជ័យ។ ផ្នែកទ្រទ្រង់មានភារកិច្ចពិនិត្យពាក្យស្នើសុំនិងឯកសារនានា លើកយោបល់ និងបញ្ជូនតាមលំដាប់លំដោយទៅសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រេច និងប្រគល់លទ្ធផលទៅផ្នែកជួរមុខវិញ។

៥១. **រចនាសម្ព័ន្ធមុខងារ (Functional Structure)** សំដៅលើរបៀបរបបធ្វើការងារដែលធ្វើទៅតាមនីតិវិធី និងបទប្បញ្ញត្តិដែលបានកំណត់ ដោយមិនគិតពីលទ្ធផល ប្រសិទ្ធភាព និងការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាឡើយ។

៥២. **រដ្ឋបាលថ្នាក់ក្រោមជាតិ (Sub-national Administration)** សំដៅទៅលើរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដែលរដ្ឋបាលនីមួយៗមានក្រុមប្រឹក្សាមួយជាតំណាង។

៥៣. **រដ្ឋបាលឯកភាព (Unified Administration)** គឺការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន រាប់ទាំងហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិរបស់ខ្លួន ហើយក្រុមប្រឹក្សានីមួយៗនោះ មានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍផ្សេងៗទៀត ដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

៥៤. **វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច (Measures to Fight Corruption and Abuse of Power)** មានន័យថា ជាការប្រកាន់យកនូវវិធាននៃច្បាប់ ព្រមទាំងការប្រឆាំង និងរាយការណ៍អំពីអំពើពុករលួយ និងការរំលោភអំណាច។

៥៥. **វិធីសាស្ត្រផ្អែកតាមកម្មវិធី (Program-based Approaches)** សំដៅទៅលើវិធីសាស្ត្រដែលជំរុញឱ្យមានកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍ ដោយផ្អែកលើគោលការណ៍នៃការប្រមូលផ្តុំនូវការគាំទ្រនានា សម្រាប់អនុវត្តកម្មវិធីដែលរដ្ឋាភិបាលធ្វើជាម្ចាស់។ ធាតុសំខាន់ៗទាំងបួននៃវិធីសាស្ត្រផ្អែកតាមកម្មវិធី រួមមាន (១)រដ្ឋាភិបាលជាអ្នកដឹកនាំ (២)ស្ថិតនៅក្រោមក្របខ័ណ្ឌកម្មវិធីនិងថវិកាតែមួយ (៣)សម្របសម្រួល និងធ្វើសុខដុមនីយកម្មនីតិវិធីសម្រាប់ផ្តល់ហិរញ្ញប្បទាន និង(៤)ខិតខំប្រឹងប្រែងក្នុងការប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីរបស់រដ្ឋាភិបាល។

៥៦. **វិធីសាស្ត្រផ្អែកតាមវិស័យ (Sector-wide Approaches)** សំដៅទៅលើវិធីសាស្ត្រផ្អែកតាមកម្មវិធីសម្រាប់ប្រតិបត្តិការនៅក្នុងកម្រិតវិស័យទាំងមូល។ ឧទាហរណ៍ ការប្រើប្រាស់វិធីសាស្ត្រផ្អែកតាមកម្មវិធីសម្រាប់អនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

៥៧. **សនិទានភាព (Rationale)** គឺជាសេចក្តីពន្យល់អំពីមូលហេតុ ឬហេតុផលចម្បងៗដែលនាំឱ្យមានការរៀបចំ និងអនុវត្តកម្មវិធី គម្រោង សកម្មភាព ឬវិធានការណាមួយ។

៥៨. **សមធម៌យេនឌ័រ (Gender Equity)** គឺជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និងបុរស សំដៅឆ្ពោះទៅសមភាពយេនឌ័រ តាមរយៈគោលនយោបាយ ច្បាប់ និងវិធានការនានាដើម្បីកែសម្រួលនូវភាពលំអៀងដែលមាននៅក្នុងសង្គមចំពោះស្ត្រីនិងបុរស។ ក្នុងនោះសំដៅលើវិធានការ ឬសកម្មភាពពិសេសជាក់លាក់ក្នុងការបង្កឱកាស ការលើកទឹកចិត្ត ការជំរុញដើម្បីឈានទៅរកភាពស្មើគ្នារវាងបុរស និងស្ត្រីនៅក្នុងការងារសង្គម និងនៅក្នុងគ្រួសារ(សមភាពយេនឌ័រ)។ ឧទាហរណ៍ ការប្រើប្រាស់គោលការណ៍សមធម៌យេនឌ័រក្នុងការលើកទឹកចិត្តឱ្យស្ត្រីបានចូលរួមជាបុគ្គលិករបស់ក្រុមប្រឹក្សា តាមរយៈការផ្តល់អាទិភាពដល់បេក្ខនារី ឬកំណត់ចំនួនជាក់លាក់ និងការពង្រឹងសមត្ថភាពជាដើម។

៥៩. **សមភាពយេនឌ័រ (Gender Equality)** សំដៅទៅលើភាពគ្មានការរើសអើងដែលប្រកាន់លើភេទណាមួយនៅក្នុងការបែងចែកធនធាន ផលប្រយោជន៍ ឬនៅក្នុងការទទួលបានសេវានានា។ សមភាពយេនឌ័រអាចវាស់វែងបានដោយការពិនិត្យមើលអំពី ការមានកាលានុវត្តភាពស្មើគ្នា ឬការទទួលបាននូវលទ្ធផលដូចគ្នារបស់ស្ត្រីបុរស។ ក្នុងនោះសំដៅលើភាពស្មើគ្នាលើការចូលរួម ការទទួលបាន ការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចរវាងបុរស និងស្ត្រីទៅលើធនធាន ទ្រព្យសម្បត្តិ និងសកម្មភាពផ្សេងៗក្នុងវិស័យសាធារណៈ និងឯកជន។

៦០. **សវនកម្មផ្ទៃក្នុងផ្នែកហិរញ្ញវត្ថុ (Financial Internal Audit)** គឺជាដំណើរការនៃការត្រួតពិនិត្យទៅលើប្រតិបត្តិការ និងកិច្ចបញ្ជីកាហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករផ្ទៃក្នុងដែលជាមន្ត្រី បុគ្គលិកនៅក្នុងអង្គភាព ស្ថាប័នរបស់ខ្លួនផ្ទាល់ ដើម្បីធានាដល់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។

៦១. **សវនកម្មផ្ទៃក្រៅផ្នែកហិរញ្ញវត្ថុ (Financial External Audit)** គឺជាដំណើរការនៃការត្រួតពិនិត្យទៅលើប្រតិបត្តិការ និងកិច្ចបញ្ជីកាហិរញ្ញវត្ថុដែលធ្វើឡើងដោយសវនករឯករាជ្យ ដើម្បីធានាដល់ភាពត្រឹមត្រូវនៃការអនុវត្តថវិកាទៅតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់។

៦២. **សវនកម្មផ្នែកសង្គម (Social Audit)** សំដៅទៅលើដំណើរការដែលប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋាភិបាល ស្ថាប័នឯករាជ្យ ឬអង្គការសង្គមស៊ីវិលក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ទៅលើការអនុវត្តសកម្មភាព ការផ្តល់សេវាសាធារណៈ កម្មវិធី ឬគម្រោងជាក់លាក់ណាមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

៦៣. **សវនកម្មយេនឌ័រ (Gender Audit)** សំដៅទៅលើវិធី និងដំណើរការសម្រាប់ធ្វើការប៉ាន់ប្រមាណ ដើម្បីឱ្យស្ថាប័ននានាមើលឃើញពីទំហំ និងកម្រិតនៃការប្តេជ្ញាចិត្ត ការគាំទ្រ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងបុគ្គលិកលើការដោះស្រាយ និងឆ្លើយតបនឹងបញ្ហាយេនឌ័រក្នុងកម្មវិធី និងដំណើការផ្ទៃក្នុងរបស់ស្ថាប័ន និងដើម្បីកំណត់បាននូវដំណោះស្រាយ ឬកិច្ចអន្តរាគមន៍សមស្រប ឈានឆ្ពោះទៅការលើកកម្ពស់សមភាពយេនឌ័រ។

៦៤. **ស្តង់ដារគណនេយ្យភាព (Accountability Standard)** សំដៅទៅលើគណនេយ្យភាពដែលបានកំណត់សម្រាប់មន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបំពេញការងាររបស់ខ្លួន។

៦៥. **ស្តង់ដារបំពេញការងារ (Performance Standard)** សំដៅទៅលើនិយាមដែលបានកំណត់សម្រាប់ការអនុវត្តការងាររបស់មន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

៦៦. **ស្តង់ដារសមធម៌យេនឌ័រ (Gender Equity Standard)** សំដៅទៅលើស្តង់ដារដែលត្រូវបានប្រើប្រាស់ដើម្បីធានាដល់ការអនុវត្តប្រកបដោយសមធម៌រវាងស្ត្រី និងបុរស ។

៦៧. **ស្តង់ដារសមភាពយេនឌ័រ (Gender Equality Standard)** សំដៅទៅលើស្តង់ដារដែលត្រូវបានប្រើប្រាស់ដើម្បីធានាដល់ការអនុវត្តប្រកបដោយសមភាពរវាងស្ត្រី និងបុរស ។

៦៨. **ស្វ័យភាពរបស់មូលដ្ឋាន (Local Autonomy)** មានន័យថា ស្ថានភាពដែលក្រុមប្រឹក្សាអាចម្ចាស់ការចាត់ចែង គ្រប់គ្រងនូវកិច្ចការ ដែលបានប្រគល់ ឬធ្វើប្រតិភូកម្មដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌប្រកប ដោយប្រសិទ្ធភាព ។

៦៩. **សិទ្ធិអំណាច (Authority)** សំដៅទៅលើលទ្ធភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តនូវការទទួលខុសត្រូវដែលផ្ទេរទៅឱ្យរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ និងដោះស្រាយតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៧០. **សេដ្ឋកិច្ចវិមាត្រ (Economy of Scale)** សំដៅទៅលើការផ្ទេរមុខងារ ការទទួលខុសត្រូវ និងសិទ្ធិអំណាចទៅឱ្យរដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចអនុវត្តមុខងារនោះ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។

៧១. **សេវាសាធារណៈ (Public Service)** : រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ ។ **ស្ថាប័នមានសមត្ថកិច្ច** ក្នុងន័យនេះ សំដៅលើស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន ។ **ស្ថាប័នទទួលសមត្ថកិច្ច** ក្នុងន័យនេះ សំដៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ ។

៧២. **ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure)** សំដៅទៅលើរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី ក្រមឬនិយាម និងបណ្តាញទំនាក់ទំនងការងារ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ។

៧៣. **ហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន (Institutional Infrastructure)** សំដៅទៅលើរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធី ក្រមឬនិយាម និងបណ្តាញទំនាក់ទំនងការងាររបស់អង្គភាពនីមួយៗ ។

៧៤. **អសមប្បមាណ (Asymmetric)** សំដៅទៅលើភាពខុសគ្នាក្នុងការអនុវត្តសមាសធាតុកម្មវិធី និងសកម្មភាពនានានៃកម្មវិធីជាតិ ទៅតាមស្ថានភាព និងសមត្ថភាពជាក់ស្តែងរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

# គំនូសបំប្រួញស្ដីពីកម្មវិធីជាតិ
# សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ




បោះពុម្ពផ្សាយដោយលេខាធិការដ្ឋាន គ.ជ.អ.ប